# អភិធម្មត្ថាធិប្បាយ



## ភាគ ២

## បរិច្ឆេទទី ១-២-៣



# ពាក្យប្រារព្ធ

ខ្ញុំព្រះករុណាខ្ញុំបាទបានឃើញខ្លឹមសារនៃព្រះអភិធម្ម ពិស្តារនេះសំខាន់ ហើយមានន័យទូលំទូលាយ ត្រឹមត្រូវ តាមពុទ្ធដិកា និងថេរដិកាត្រឹមត្រូវល្អ ខ្ញុំព្រះករុណាខ្ញុំបាទ នូ បុណ្ណចន្ទ . ចៅ ឧត្តមរដ្ឋា ក៏បានមូលមតិគ្នាផ្តើមធ្វើសៀវ ភៅនេះ ឱ្យមានទ្រង់ទ្រាយជាប្រយោជន៍សំខាន់ ក្នុងព្រះ ពុទ្ធសាសនា ដើម្បីទុនសំរាប់អ្នកយល់ ចូលចិត្តសិក្សា ព្រះអភិធម្មពិស្តារដោយខ្លួនឯង ។

ខ្ញុំព្រះករុណា ខ្ញុំបាទសូមគោរពដឹងគុណចំពោះ សប្បុរសជនដែលមានឧបការៈ ជួយជ្រោមជ្រែង និង ឧបត្ថម្ភ គាំទ្រគ្រប់បែបយ៉ាង ដើម្បីឱ្យបានសម្រេចនូវសៀវ ភៅអភិធម្មពិស្តារនេះ ចែកជាធម្មទាន ក្នុងឱកាសបុណ្យ ភ្ជុំបិណ្ឌខាងមុខនេះ ។

ដោយសៀវភៅនេះ មានការឃ្លៀងឃ្លាតបាលី

សំរាយមួយចំនួន មកពីការវាយកំព្យូទ័រ នឹងការផ្ទៀងផ្ទាត់ មានការភ្លាំងភ្លាត់ ដូច្នេះទើបមានការខុសខ្លះ សូមអភ័យទោសទុកជាមុន និង រង់ចាំទទួលរិះគន់ កែលំអរអំពីសប្បុរសជនទាំងឡាយ ។

រាជធានីភ្នំពេញ, ថ្ងៃសៅរ៍ បិណ្ឌ ៣
ខែ ភទ្របទ ពុទ្ធសករាជ ២៥៤៤
ខ្ញុំព្រះករុណាខ្ញុំបាទ
**ទុ បុណ្ណចន្ទ , ចៅ ឧត្តមរដ្ឋា**
បោះពុម្ពលើកទី១
សម្រាប់ជាធម្មទានតែម្យ៉ាង



**ទុ បុណ្ណចន្ទ**



**ចៅ ឧត្តមរដ្ឋា**

# បុណ្យកុសលនៃការបោះពុម្ព

សៀវភៅនេះ សូមឧទិសកុសលប្រគេនជូនព្រះតេជគុណព្រះនាម ផង ខាំ នឹង មាតា បិតា របស់លោក ដែលអនិច្ចធម្ម និង ធ្វើមរណកាលទៅហើយ នឹង ជូនដល់បុព្វការីជនទាំងអស់ តែដោយកុសលនៃការព្យាយាមរបស់ព្រះតេជគុណ ទើបសមាគម ធម្មិកសង្គហបានមូលមតិគ្នាដើម្បីបោះពុម្ពសៀវភៅដ៏កម្រនេះឡើង ។

អ្នករៀបរៀង និង កែសំរួល

ឧបាសក ឡៀប ស៊ីម៉ឿន

ឧបាសក ជាំ កុយ

ឧបាសក នូ បុណ្ណចន្ទ

ឧបាសក ចៅ ឧត្តមរដ្ឋា

ឧបាសិកា អ៊ុន សារឿន អ្នកបរិច្ចាក

ប្រាក់ក្នុងការបោះពុម្ព

**ឃានវិញ្ញាណវិថី ជីវ្ហាវិញ្ញាណវិថី កាយវិញ្ញាណវិថី មនោវិញ្ញាណវិថី ចេតិ វិញ្ញាណវសេន ទ្វារប្បវត្តា ចិត្តប្បវត្តិយោ យោ ចេតព្វា ៕**

ក្នុងវិថីសង្គហនេះ មានឆក្ក ៦គឺ :

**វត្ថុឆក្ក ទ្វារឆក្ក អារម្មណឆក្ក វិញ្ញាណឆក្ក វិថីឆក្ក វិសយប្បវត្តិឆក្ក ៕**

រួម ៦ ឆក្ក ។

ចំណែកវិសយប្បវត្តិ របស់វិថីវិមុត្តិចិត្ត ១៩ដួងនោះ មាន៣គឺ កម្ម កម្មនិមិត្ត គតិនិមិត្ត ។

វត្ថុទ្វារ អារម្មណ៍ទាំង ៣នេះ បានសំដែងមុនមក ហើយនៅមានវិញ្ញាណទាំង ៦គឺ :

ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ រួម ៦ វិញ្ញាណ នៅមានវិថី ៦គឺ :

ចក្ខុទ្វារវិថី សោតទ្វារវិថី ឃានទ្វារវិថី ជិវ្ហាទ្វារវិថី កាយទ្វារវិថី មនោទ្វារវិថី រួមវិថី ៦ ។

នៅមានវិញ្ញាណវិថី ៦ទៀត គឺ :

**ចក្ខុវិញ្ញាណវិថី សោតវិញ្ញាណវិថី ឃានវិញ្ញាណវិថី ជីវ្ហាវិញ្ញាណវិថី កាយវិញ្ញាណវិថី មនោវិញ្ញាណវិថី រួមជាវិញ្ញាណវិថី ៦ ។**

## អធិប្បាយឆក្កទាំង ៦

ពាក្យថាឆក្ក បានដល់ធម៌៦យ៉ាង : ១យ៉ាង ៦ពួក ១ពួក ហៅថាឆក្ក ពួកវត្ថុទ្វារ អារម្មណ៍ ទាំង ៣ពួកនេះ បានអធិប្បាយមកហើយក្នុងបកិណ្ណសង្គហ នៅសល់ ៣ ឆក្កទៀតប៉ុណ្ណោះ ដែលចាំបាច់ត្រូវសំដែង និង អធិប្បាយ

ក្នុងសង្គហថ្មីនេះ ។

អារម្មណ៍របស់ចិត្ត ជាវិថីវិមុត្តិ ១៩ដួង មាននិមិត្តទាំង បីជាអារម្មណ៍ ទៅរហូតជីវិត គឺ កម្ម កម្មនិមិត្ត និង គតិនិមិត្ត មានន័យថាក្នុងខណៈដែលមិនទាន់កើតវិថីនេះ ត្រូវមាននិមិត្ត និង គតិនិមិត្ត មានន័យថាក្នុងខណៈដែលមិនទាន់កើតវិថីនេះ ត្រូវមាននិមិត្តទាំង ៣ជាអារម្មណ៍កាលវិថីកើតហើយ ត្រូវបានជាអារម្មណ៍ ដែលវិថីចិត្តទទួលមកពីបញ្ចទ្វារាវជ្ជនៈ រហូតដល់តទាលម្ពណៈ ជវនៈ វោដ្ឋវនៈ ឬ ស្រេចតែវិសយប្បវត្តិ តែយ៉ាងណាក្តីអ្នកដែលយក ក្នុងវិថី ត្រូវចាំឆក្កទាំង៣ដែលពោលមកហើយនោះ គឺ វិញ្ញាណទាំង ៦ ទ្វារទាំង ៦ វិញ្ញាណវិថីទាំង ៦ រួម ៣ឆក្ក ។

ពាក្យអធិប្បាយ វត្ថុទ្វារអារម្មណ៍ បានអធិប្បាយមកតាំងពីបរិច្ឆេទទី ១ រហូតដល់ទី ៣ អ្នកសិក្សា គង់នឹងចូលចិត្តបានខ្លះហើយ ។ ដូច្នេះក្នុងទីនេះ មិនចាំបាច់អធិប្បាយទៀតទេ ។

# សំដែងវិសយប្បវត្តិ "ត" តាមបាលី

អតិមហន្តំ មហន្តំ បរិត្តំ អតិបរិត្តញ្ចេតិ បញ្ចទ្វារេ មនោទ្វារេ វិភូតមវិភូតញ្ចេតិ ឆធា វិសយប្បវត្តិ វេទិតព្វា ។ កថំ ។ ឧប្បាទឋិតិភង្គវសេន ខណត្ត្យំ ឯកចិត្តក្ខណំ នាម ។ តានិ បន សត្តរស ចិត្តក្ខណានិ រូបធម្មានមាយុ ។ ឯកចិត្តក្ខណាតីតានិ វា ពហុចិត្តក្ខណាតីតានិ វា ឋិតប្បត្តានេវ បញ្ចាលម្ពណានិ បញ្ចទ្វារេ អាបាថមាគច្ឆន្តិ ។ តស្មា យទិ ឯក ចិត្តក្ខណាតីតំ រូបារម្មណំ ចក្ខុស្ស អាបាថមាគច្ឆតិ តតោ ទ្វិក្ខត្តុំ ភវង្គេ ចលិតេ ភវង្គសោតំ វោច្ឆិន្ទិត្វា តមេវ រូបារម្មណំ អាវជ្ជន្តំ បញ្ចទ្វារាវជ្ជនចិត្តំ ឧប្បជ្ជិត្វា និរុជ្ឈតិ តតោ តស្សានន្តរំ តមេវ

រូបំ បស្សន្តំ ចក្ខុវិញ្ញាណំ សម្បដិច្ឆន្តំ សម្បដិច្ឆនចិត្តំ សន្តីរយមានំ សន្តីរណចិត្តំ វវដ្ឋបេន្តំ វោដ្ឋព្វនចិត្តញ្ចេតិ យថាក្កមំ ឧប្បជ្ជិត្វា និរុជ្ឈន្តិ ។ តតោ បរំ ឯកូនតឹស កាមាវចរជវនេសុ យំ កិញ្ចិ លទ្ធបច្ចយំ យេភុយ្យេន សត្តក្ខត្តុំ ជវតិ ។ ជវនានុពន្ធានិ ច ទ្វេតទាលម្ពណបាកានិ យថារហំ បវត្តន្តិ ។ តតោ បរំ ភវង្គបាតោ ។

ឯត្តាវតា ចុទ្ទស វិថីចិត្តុប្បាទា ទ្វេ ភវង្គចលនានិ បុព្វេវា តីតកមេកចិត្តក្ខណន្តិ កត្វា សត្តរស ចិត្តក្ខណានិ បរិបូរេន្តិ ។ តតោ បរំ និរុជ្ឈន្តិ ។ អារម្មណមេតំ អតិមហន្តំ នាម គោចរំ ។

ប្រែ អារម្មណ៍ដែលប្រាកដ ក្នុងទ្វារទាំង ៥ មាន ៤ អារម្មណ៍គឺ :

# អតិមហន្តារម្មណ៍ មហន្តារម្មណ៍ បរិត្តារម្មណ៍ និង អតិបរិត្តារម្មណ៍ ៤

ក្នុងមនោទ្វារនោះ មានពីរអារម្មណ៍ គឺ វិភូតារម្មណ៍ អវិភូតារម្មណ៍ រូម គឺ វិសយប្បវត្តិ ជាអារម្មណ៍ដែលប្រាកដក្នុងទ្វារទាំង ៦ មាន ៦ អារម្មណ៍ ។

ការដែលអារម្មណ៍ប្រាកដនោះជាយ៉ាងណាខ្លះ ? ខណៈទាំង ៣ ដោយ ឧប្បាទ ឋិតិ ភង្គ ហៅថាខណចិត្ត១ខណៈ ចិត្តក្ខណ ១៧ខណនេះ ជាអាយុរបស់រូបធម៌ កាលចិត្តក្ខណៈ១ ឬ ច្រើនចិត្តក្ខណៈឆ្លងកើតទៅហើយ អារម្មណ៍ទាំង ៥នេះ ដល់ឋិតិខណៈ ព្រោះហេតុដូច្នេះ រូបារម្មណ៍ដែលចិត្តក្ខណៈ ១ខណៈបានឆ្លងកាត់ទៅហើយ ក៏នឹងប្រាកដនៅចក្ខុបសាទ ខាងក្រោយដែលចិត្តជាភវង្គ២ដួង ញ័រហើយកាត់ក្រសែចិត្តជាភវង្គ បញ្ចទ្វារាវជ្ជនចិត្ត ១ដួងដែលពិចារណារមែងកើតហើយរលត់ចុះមួយរំពេច ។ កាលចិត្តជាបញ្ចទ្វារាវជ្ជនរលត់ហើយ ចក្ខុវិញ្ញាណចិត្តដែលឃើញ ទើប

កើតឡើង សម្បដិច្ឆន្នចិត្ត ដែលទទួលសន្តីរណចិត្ត ពិចារណា វោដ្ឋវនចិត្ត ដែលកាត់អារម្មណ៍ទាំងអស់នោះ រមែងកើត តាមលំដាប់ៗហើយរលត់តាមគ្នាទៅ ពីនេះតទៅចិត្តដួង ណានិមួយក្នុងកាមាវចរជវនចិត្ត ២៩ដួង បច្ច័យកំពុងមាន ល្អមនោះរមែងកើតយ៉ាងច្រើន ៧ដងៗ និង តទាលម្ពណ- វិបាកចិត្ត ២ដួងក៏រមែងតាមក្រោយមកផង ។ ពីនោះមក ចិត្តជាភវង្គ ( ភវង្គចិត្ត ) កកើតតទៅរឿយៗ ដូចដែល បរិយាយមកហើយនេះ ចិត្តក្ខណ ១៧ដួង ក៏ពេញបរិបូណ៌ គឺចិត្តជាវិថី ១៤ដួង ភវង្គៈ ចលនៈ ២ ចិត្តដែលឆ្លងផុតទៅ ហើយមួយដួង ( ១ដួង ) រួម ១៧ដួង ហើយរលត់ទៅ អារម្មណ៍នេះហៅថាអតិមហន្តារម្មណ៍ ។

# អធិប្បាយអតិមហន្តារម្មណ៍

- ពាក្យថា អតិមហន្តាម្មណ៍ ប្រែថា អារម្មណ៍ដែលប្រាកដយូរជាទីបំផុត ។

- ពាក្យថាមហន្តារម្មណ៍ ប្រែថា អារម្មណ៍ដែលប្រាកដយូរល្មមសមគួរ ។

- ពាក្យថាបរិត្តារម្មណ៍ ប្រែថា អារម្មណ៍ដែលប្រាកដ ខ្លីសមគួរ ។

- ពាក្យថាអតិបរិត្តារម្មណ៍ ប្រែថា អារម្មណ៍ដែលប្រាកដ ខ្លីបំផុត ។

✵ រូម៤អារម្មណ៍ នេះ រមែងប្រាកដក្នុងទ្វារទាំង ៥ជានិច្ចក្នុងមនោទ្វារនោះ :

- វិភូតារម្មណ៍ គឺ អារម្មណ៍ដែលឃើញប្រាកដច្បាស់
- អវិភូតារម្មណ៍ គឺ អារម្មណ៍ដែលឃើញមិនប្រាកដ ។

✵ រូម ២យ៉ាង

រូបទាំងអស់មាន ៦ អារម្មណ៍ ដែលអធិប្បាយមកហើយ ។

អារម្មណ៍ទាំង ៦យ៉ាងនេះហៅថា វិសយប្បវត្តិ ។

វិសយប្បវត្តិ ប្រែថា ការប្រាកដនៃអារម្មណ៍តាមទ្វារទាំង ៦ ( មេត្តាមើលឆក្កទាំង ៦ ក្នុងបរិច្ឆេទខាងដើមនេះ ) ។

ការដែលអារម្មណ៍ទាំង ៤ ប្រាកដចម្ងាគនៃសង្ខត គឺរូប និងនាមទាំងពីររមែងមានខណៈទាំង ៣គឺ :

- ឧប្បាទ ការកើត
- ឋិតិ ការតាំងនៅ
- ភង្គ ការរលត់

ខណៈទាំង ៣នេះហៅថា ចិត្តក្ខណ ( ចិត្ត + ខណ) ១៧ចិត្តក្ខណ ឬ ១៧ × ៣ = ៥១ ខណៈនេះប្រហែលនឹងអាយុនៃរូបមួយរូប ។ មានន័យថា រូប ១ មានអាយុយូរប្រហែលចិត្តក្ខណ ១៧ដូងជានិច្ច ។

វិញ្ញត្តិទាំងពីរ និង លក្ខណរូបទាំង ៤ មានអាយុខ្លី ណាស់ ព្រោះហេតុដូច្នោះ ក្នុងទីនេះត្រូវវៀរលែងនៅសល់ តែអាយុរបស់រូប ២២ប៉ុណ្ណោះ ។

ធម្មតាចិត្តតាំងពីបដិសន្ធិ តរហូតដល់ចុតិ ហៅថា ភវង្គចិត្ត ។ ភវង្គចិត្តនេះកាលដឹង ( ឃើញ ) អារម្មណ៍ណា និមួយហើយ វិថីចិត្ត ក៏រមែងកើតឡើងជានិច្ច រាប់តាំងពី ភវង្គចិត្ត ១ដួង ឬជួនកាលច្រើនជាង១ដួង ដែលឆ្លង កាត់ហើយទៅរហូតដល់តទាលម្ពណៈ ២ដួង រួមចិត្តក្ខណ ១៧ដួង នេះហៅថាអតិមហន្តាអារម្មណ៍ គឺអារម្មណ៍ដែល វែង ឬ យូរជាទីបំផុតហើយកើតប្រហែលគ្នា នឹង អាយុរូប ១ ក្នុង ២២រូបដែលពោលមកហើយ ។

ព្រោះហេតុដូច្នេះ រូបរូប មានអាយុប្រហែលនាម ធម៌ ១៧ដួងកើតហើយរលត់ ។ មានន័យថា អាយុរូប ១ យូរប្រហែលចិត្ត១៧ដួង រលត់ក្នុងទីនេះ ដើម្បីឱ្យអ្នកសិក្សា ចូលចិត្ត ងាយយល់ស្រួល ចាំបាច់ត្រូវសំដែងភាពវិថីចិត្ត

អតិមហន្តារម្មណ៍ចំពោះរូបារម្មណ៍បះទង្គិចចក្ខុទ្វារ តាមបាលីអភិធម្មត្ថសង្គហ មុនតារាង ភាពរូបារម្មណ៍ប្រាកដក្នុងចក្ខុទ្វារ គឺ អតិមហន្តារម្មណ៍




-គំនូស ||| គឺ ឧប្បាទ ឋិតិភង្គ ។

-ក្រៅអំពីវង់ក្រចក ហៅថាភវង្គចិត្ត ដែលតមកអំពី បដិសន្ធិ ។

រូមចិត្តជាវិថី ១៤ដួង អតីតភវង្គ ១ដួង ភវង្គចលន ១ដួង ភវង្គុបច្ឆេទ ១ដួង រូមចិត្ត ១៧ដួងនេះ ប្រហែលអាយុរបស់រូបណានិមួយ ១រូប ក្នុងចំនួន ២២រូប ហៅថា អតិមហន្តារម្មណ៍ ។

# សំដែងវិស័យប្បវត្តិ "៦" តាមបាលី

យាវ តទាលម្ពណុប្បាទា បន អប្បហោន្តាតីត-
កមាបាថមា គតំ អារម្មណំ មហន្តំ នាម ។
តត្ថ ជវនវសានេ ភវង្គបាតោវ ហោតិ ។
នត្ថិ តទាលម្ពណុប្បាទោ ។

យាវ ជវនុប្បាទាបិ ( អប្បហោន្តាតីត-
កមាបាថមាគតំ ) អារម្មណំ បរិត្តំ នាម ។ តត្ថ
ជវនំបិ អនុប្បជ្ជិត្វា ទ្វិតិក្ខត្តុំ វោដ្ឋវនមេវ
បវត្តតិ ។ តតោយំ ភវង្គបាតោ វ ហោតិ ។

យាវ វោដ្ឋវនុប្បាទា ច បន
អប្បហោន្តាតីតកមាបាថមាគតំ និរោធា
សន្នមាសម្ពណំ អតិបរិត្តំ នាម ។ តត្ថ
ភវង្គចលនមេវ ហោតិ ។ នត្ថិ វីថិចិត្តុប្បាទោ

**ឥច្ចេវំ ចក្ខុទ្វារេ តថា សោតទ្វារាទីសុ ចេតិ សព្វថាបិ បញ្ចទ្វារេ តទាលម្ពណវារេន-ទោឡ្ហវារមោឃវារសង្ខាតានំ ចតុន្នំ វារានំ យថាក្កមំ អារម្មណភូតា វិសយប្បវត្តិ ចតុធា វេទិតព្វា ៕**

**ប្រែ** អារម្មណ៍ដែលប្រាកដហើយ មិនអាចនឹងតាំងដល់តទាលម្ពណ ហៅថាមហន្តារម្មណ៍ ។

ក្នុងមហន្តារម្មណ៍ កាលដល់ទីបំផុតជវន ៧ដួង ភវង្គកកើត គ្មានតទាលម្ពណកើតទេ ។

អារម្មណ៍ដែលប្រាកដ មិនអាចនឹងតដល់ជវនទាំង ៧ ហៅថាបរិត្តារម្មណ៍ ។ ក្នុងបរិត្តារម្មណ៍ ជវនទាំង ៧ រមែងកើត កើតពីវោដ្ឋវន ២ ឬ ៣ ខណៈហើយ ទើបកើតទៅជាភវង្គ ។

អារម្មណ៍ដែលប្រាកដខ្ចីបំផុត ព្រោះមិនអាចដល់វោដ្ឋវនចិត្តហៅថា អតិបរិត្តារម្មណ៍ ។ ក្នុងអតិបរិត្តារម្មណ៍

មានតែភវង្គចលនៈប៉ុណ្ណោះ មិនអាចមានវិថីចិត្តទេ ។

ក្នុងទ្វារទាំង ៥ ដូចជាក្នុងចក្ខុទ្វារ សោតទ្វារ ជាដើមរមែងដឹងបាន ដែលជាការប្រាកដរបស់អារម្មណ៍ទាំង ៤ ដោយលំដាប់របស់តទាលម្ពណវារៈ ជវនវារៈ វោដ្ឋវនវារៈ និង មោឃវារៈ ។

※※※※※

# អធិប្បាយចំពោះអារម្មណ៍ទាំង ៣

កាលដែលអារម្មណ៍ប្រាកដក្នុងទ្វារទាំង៥ តែអារម្មណ៍នេះមិនអាចនឹងតាំង នៅរហូតដល់ តទាលម្ពណវារៈ អារម្មណ៍នោះហៅថា មហន្តារម្មណ៍ មានជវន ទាំង ៧ ជាទីបំផុត ហើយភវង្គចិត្តកកើតរឿយៗទៅ ។ តែថាអារម្មណ៍នេះ ពីខាងដើមជាអតីត ភវង្គ ២ ឬ ៣ ដួង កន្លងបាត់ទៅហើយ រាប់តែភវង្គចិត្ត ២ ដួងដែលកន្លងទៅ

រហូតដល់ភវង្គដែលកើតខាងក្រោយ ជវន ៧ ដួង រមែង ពេញបរិបូណ៌ ១៧ដួង នៃអារម្មណ៍ ។

( មេត្តាមើលរូបភាព មហន្តារម្មណ៍ តាមអភិធម្មត្ថ សង្គហ ក្នុងបរិច្ឆេទទី ៣ ) ។

ភាពរូបារម្មណ៍ ប្រាកដក្នុងទ្វារទាំង ៥ គឺ មហន្តារម្មណ៍




អារម្មណ៍ដែលប្រាកដក្នុងទ្វារទាំង ៥ តែមិនអាចនឹងតាំង នៅដល់ជវនវារៈ ហៅថា បរិត្តារម្មណ៍ មានវោដ្ឋវនៈជាទី បំផុត ។ ពីខាងដើមវិថីចិត្តនេះជាភវង្គចាស់គឺ អតីតភវង្គ ៤ដួងកន្លងទៅ ហើយរាប់តែចិត្តជាអតីត ៤ ដួងនោះទៅ រហូតដល់ ១៧ដួង គឺ ភវង្គថ្មី ៤ ដួងទៀត ពេញបរិបូណ៌ ១៧ដួង ហៅថាបរិត្តារម្មណវិថី ។

( មេត្តាមើលរូបភាព បរិត្តារម្មណ៍តាមអភិធម្មត្ថសង្គហ )

ភាពរូបារម្មណ៍ ប្រាកដក្នុងទ្វារទាំង ៥ គឺ បរិត្តារម្មណ៍

| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ |
| អតីតភវង្គ | អតីតភវង្គ | អតីតភវង្គ | អតីតភវង្គ | ភវង្គចលន | ភវង្គុបច្ឆេទ | បញ្ចទ្វារាវជ្ជន | ចក្ខុវិញ្ញាណ | សម្បដិច្ឆន្ន | សន្តីរណ | វោដ្ឋព្វន | វោដ្ឋព្វន | វោដ្ឋព្វន | ភវង្គ | ភវង្គ | ភវង្គ | ភវង្គ |

អារម្មណ៍ដែលប្រាកដក្នុងទ្វារទាំង ៥ តែមិនអាចនឹងតាំងនៅដល់វោដ្ឋវនៈ ត្រូវរាប់ពីដើម ភវង្គចាស់ ១០ដួង ហៅថា អតិបរិត្តារម្មណ៍ ។ តែយ៉ាងណាក្តីគ្រប់ៗវិធី និង ត្រូវរាប់យកគ្រប់ ១៧ដួងជានិច្ច ។

( មេត្តាមើលរូបភាព បរិត្តារម្មណ៍ តាមអភិធម្មត្ថសង្គហ )

ភាពអារម្មណ៍ប្រាកដក្នុងទ្វារទាំង ៥ គឺ អតិបរិត្តារម្មណ៍

| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ | ⦀ |
| ភវង្គ | ភវង្គ | ភវង្គ | ភវង្គ | ភវង្គ | ភវង្គ | ភវង្គ | ភវង្គ | ភវង្គ | ភវង្គ | ភវង្គចលនៈ | ភវង្គចលនៈ | ភវង្គ | ភវង្គ | ភវង្គ | ភវង្គ | ភវង្គ |

តាមដែលបានពោលមកហើយនេះ អតិមហន្តារម្មណ៍ វិថីមាន១ន័យ ។ មហន្តារម្មណ៍វិថីមាន ២ន័យ ។ បរិត្តារម្មណ៍ វិថីមាន ៦ន័យ ។ អតិបរិត្តារម្មណ៍ វិថីមាន ៦ ន័យ ។

រួមអារម្មណ៍ទាំង ៤ ជាមួយគ្នាមាន ១៥ន័យ ។

ព្រោះហេតុដូច្នេះ ក្នុងបញ្ចទ្វារនោះ វិថីមាន ៧៥ ន័យ គឺ រូបារម្មណ៍ ១៥ន័យ សទ្ទារម្មណ៍ ១៥ន័យ ជាដើម

## គាថាសង្គហ

**វិថីចិត្តានិ សត្តេវ ចិត្តុប្បាទា ចតុទ្ទស**

**ចតុប្បញ្ញាស វិត្ថារា បញ្ចទ្វារេ យថារហំ ។**

តាមដែលអារម្មណ៍ប្រាកដក្នុងទ្វារទាំង ៥ ថាដោយវិថីចិត្តមាន៧វិថី : ដោយចិត្តុប្បាទនេះ រមែងមាន ១៧ដួង ដោយពិស្តារមាន៥៤ដួង ។

អយមេត្ថ បញ្ចទ្វារេ វិថីចិត្តុប្បាទវត្តិនាយោ នេះឯង ជាការកើតវិថីចិត្តក្នុងបញ្ចទ្វារ ។

# សំដែងវិថីរបស់មនោទ្វារតាមបាលី

**មនោទ្វារេ បន យទិ វិភូតារម្មណំ អាបាថមាគច្ឆតិ ។ តតោ បរំ ភវង្គចលន-មនោទ្វារាវជ្ជនជវនាវសានេ តទាលម្ពណ-បាកានិ បវត្តន្តិ ។ តតោ បរំ ភវង្គបាតោ ។ អវិភូតេ បន្លារម្មណេ ជវនាវសានេ ភវង្គបាតោ វ ហោតិ ។ នត្ថិ តទាលម្ពណុ-ប្បាទោតិ ។**

ក្នុងមនោទ្វារវិថីនោះ កាលបើវិភូតារម្មណ៍ ប្រាកដក្នុងមនោរទ្វារ ភវង្គចលនមនោទ្វារាវជ្ជនៈ ជវនទាំងអស់នេះ រមែងប្រាកដតាមតទាលម្ពណចិត្ត កកើតតមកហើយ ភវង្គចិត្ត កកើតតទៅតាមធម្មជាតិ ។ កាលអវិភូតារម្មណ៍ ប្រាកដនោះ ខាងក្រោយដែលជវនចិត្ត ៧ដួងរលត់ហើយ ភវង្គចិត្តរមែងកើតតទៅ គ្មានតទាលម្ពណទេ

បរិច្ឆេទទី ៤

# អធិប្បាយមនោទ្វារវិថី

អធិប្បាយវិភូតារម្មណ៍ និង អវិភូតារម្មណ៍ ទាំងពីរ នេះបានពន្យល់មកពីខាងដើមបរិច្ឆេទនេះហើយ ។

អារម្មណ៍របស់មនោទ្វារនោះជាធម្មារម្មណ៍ប៉ុណ្ណោះ ធម្មារម្មណ៍មាន ២យ៉ាងគឺ :

១- កាលខណៈដែលប្រាកដ ក្នុងមនោទ្វារ គឺ វិភូតារម្មណ៍ និង អវិភូតារម្មណ៍

២- កាលខណៈដែលប្រាកដ មានវិថីចិត្ត ១០ដួង សំរាប់វិភូតារម្មណ៍ ហើយរលត់ចុះមួយរំពេច ។

( មេត្តាមើលវិថី មនោទ្វារវិភូតារម្មណ៍ផង )

ភាពវិភូតារម្មណ៍ ប្រាកដក្នុងមនោទ្វារ



ភាពអវិភូតារម្មណ៍ ប្រាកដក្នុងមនោទ្វារ




វិថីក្នុងមនោទ្វារនេះ មានវិថី ២គឺ :

១- ហៅថា តទាលម្ពណវារៈ ។

២- ហៅថាជវនវារៈ

- តទាលម្ពណវារៈ មានវិថីចិត្ត ១០ដួង ។

- ជវនវារៈ មានវិថីចិត្ត ៨ដួង

( មេត្តាមើល គាថាសង្គហៈផង )

## គាថាសង្គហៈ

**វិថីចិត្តានិ តីណេវ ចិត្តុប្បាទា ទសេរិតា**

**វិត្ថារេន បនេត្ថេកចត្តាឡីស វិភាវយេ**

ប្រែ អារម្មណ៍ដែលប្រាកដក្នុងមនោទ្វារនេះថា( ពោល ) ដោយវិថីមាន ៣ ថាដោយចិត្តុប្បាទ មានចិត្ត ១០ដួង ថាដោយពិស្ដារនោះមាន៤១ដួង ប៉ុណ្ណោះ ។

**អយមេត្ថ បរិត្តជវនវារោ ប្រែ**

នេះជាវារៈ កាមជវន ( នេះជាកាមជវនវារ )

## ពាក្យសួរ_ឆ្លើយវិថីចិត្តកាមជវន

សួរ៖ ពាក្យថាវិថីប្រែត្រង់ៗបានដល់អ្វី ? ហើយដូចម្ដេចទើបហៅចិត្តជាវិថី ?

ឆ្លើយ ពាក្យថាវិធីប្រែត្រង់ៗ តាមវិគ្គហថា :

**វិយន្តិ គច្ឆន្តិ ឯតេនាតិ វិថី ប្រែ**

មនុស្ស និង សត្វ ដើរបានដោយវិថី ដូច្នេះហៅថា វិថីបានដល់ផ្លូវ ( មេត្តាមើលបទានុក្រម សរសេរថាវិថី តែក្នុងវេយ្យាករណ៍បាលីថា : វិថីមានគោលភស្ដុតាង ឬ ទ្រឹស្ដីថា វិតោថិ គឺ វិ ធាតុ ថិ បច្ចយ )

ដូច្នេះក្នុងទីនេះ ត្រូវសរសេរថាវិថី ។

**សួរ** ពាក្យថាខណៈ និង ពាក្យវិថីផ្សេងគ្នាយ៉ាងណា ? ហើយអធិប្បាយត្រង់ៗ តើអធិប្បាយយ៉ាងណា ?

**ឆ្លើយ** - ខណៈប្រែថា វេលា ឬ គ្រាក៏បានបានដល់ខណៈកើត រលត់តែក្នុងអភិធម្មពោលថា ៈមាន៣ខណៈ គឺ ឧប្បាទៈ សេចក្តីកើត ឬ ការកើត ឋិតិ ការតាំងនៅ ភង្គ សេចក្តី រលត់ ឬ ការរលត់ ។ រួម៣ខណៈ ខណៈទាំង៣នេះ ហៅថា ចិត្តុប្បាទ ១ដួង ។

វិថីបានដល់លំដាប់នៃផ្លូវផ្លូវ ( គន្លងផ្លូវ ) គឺលំដាប់នៃចិត្ត បានដល់វិថីផ្សេងៗ ដូចដែលអធិប្បាយមកពីខាងដើមបរិច្ឆេទនេះហើយ ។ ព្រោះហេតុដូច្នេះ ពាក្យថា ខណៈ ប្រែត្រង់ៗបានដល់ ៣ គ្រារបស់ខណៈតូចៗ គឺ ការកើត ១ ខណៈ ការតាំងនៅ១ខណៈ និង ការរលត់១ខណៈ ។ រួមទាំង៣ខណៈនេះ មានអាយុប្រហែលគ្នា ។

**សួរ** តាមដែល មនុស្សទាំងឡាយគ្រប់ៗគ្នា ដឹងថាមានតែការកើត ការរលត់ ពីរខណៈប៉ុណ្ណោះ ដូចម្តេចលោក

អដ្ឋកថាចារ្យ សំដែងខណៈមានបី ?

**ឆ្លើយ** តាមធម្មតាសង្ខតធម៌ រមែងមានការកើត ការរលត់ ជានិច្ច ព្រោះហេតុដូច្នេះ ទើបហៅថាសង្ខតធម៌ ក្នុងអំគុត្តរ ព្រះបាលីថា : **តីណិ មានិ ភិក្ខវេ សង្ខតស្ស សង្ខតលក្ខណានិ កតមានិ តីណិ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ទ្វេប្រ**

ម្នាលភិក្ខុទាំងឡាយ នៅមានលក្ខណរបស់ សង្ខតធម៌ ៣ ប្រការគឺ :

-ការកើត រមែងប្រាកដ

-ការរលត់ រមែងប្រាកដ

-ការតាំងនៅ រមែងប្រាកដ

មានន័យថា មិនមានតែការកើត និង ការរលត់ ក្នុងរវាងទាំង២ ខណ ក៏រមែងកើតមួយខណៈ ក្នុងរវាងខណៈ គឺការកើត និង រលត់ សំដៅដល់ពេលវេលាមួយដែលធ្វើឱ្យ

ការកើត និង ការរលត់ ញែកចេញពីគ្នាប៉ុណ្ណោះ តែរយៈនេះក៏មានអាយុប្រហែល១គ្នា ក្នុងការកើត ឬ រលត់ ។ ន័យមួយទៀតក៏ចាំបាច់ត្រូវ អធិប្បាយថា ចិត្តមួយដួង១ត្រូវបែងចែកជា៣វេលា (គ្រា )វេលាទីមួយ ហៅថាឧប្បាទៈ ការកើត វេលាទី ២ ហៅថាឋិតិ ( ថិតិ ) ការតាំងនៅវេលាទី ៣ ហៅថាភង្គការរលត់ រួមវេលាទាំង ៣នោះហៅថាចិត្ត១ដួង ។ ព្រោះហេតុដូច្នេះ ព្រះបរមសាស្តាទើបទ្រង់ទេសនាថា : **ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ**

ដូចដែលបានអធិប្បាយមកហើយ ។

**សួរ** តាមដែលអារម្មណ៍ទាំង ៥ មានប្រាកដក្នុងទ្វារទាំង ៥នោះ ប្រាកដតែបញ្ចទ្វារប៉ុណ្ណោះឬ ? ដូចម្តេចទើបមិនប្រាកដក្នុងមនោទ្វារ ?

**ឆ្លើយ** ធម្មតារបស់អារម្មណ៍ ( ធម្មតានៃអារម្មណ៍ )

អារម្មណ៍ដែលប្រាកដក្នុងទ្វារទាំង ៦នោះ តាមដែលព្រះអដ្ឋកថាចារ្យពោលទុកថា :

**ឯកេកំ អារម្មណំ ទ្វិសុ ទ្វិសុ ទ្វារេសុ អាបាថមាគច្ឆតិ**

**ប្រែ** អារម្មណ៍មួយៗ រមែងប្រាកដក្នុងទ្វារទាំងពីរទ្វារ គឺរូបទាំង មនោទ្វារផង ព្រោះហេតុដូច្នេះ កាលអារម្មណ៍ណាមួយ ប្រាកដក្នុងទ្វារណា ១ហើយ ក៏ត្រូវប្រាកដក្នុងមនោទ្វារផងដែរជាធម្មជាតិ ក្នុងអដ្ឋកថាពោលថា ឧបមាដូចសត្វដែលហើរមកពីទីឆ្ងាយ មកទុំមែកឈើ ព្រោះអាស្រ័យមែកឈើ ស្រមោលសត្វក៏ប្រាកដនៅដី និង ទីមែកឈើ ព្រមៗគ្នា មានឧបមាយ៉ាងណា ការប្រាកដក្នុងអារម្មណ៍ក្នុងទ្វារទាំង ៦ ក៏មានឧបមេយ្យដូច្នេះដែរ ។ គឺរូបារម្មណ៍ប្រាកដក្នុងចក្ខុទ្វារ និងមនោទ្វារវេលាជាមួយគ្នា ឬខណៈជាមួយគ្នា ។ ចំណែកសោត ឃាន ជិវ្ហា កាយទាំងអស់នេះក៏ទំនងដូចចក្ខុទ្វារដែរ ។

**សួរ** ពាក្យថាអារម្មណ៍ក្នុងបរិច្ឆេទ ៣ ក្នុងបកិណ្ណកសង្គហៈសំដែងមកហើយថា អារម្មណ៍មាន ៦ អារម្មណ៍ គឺ រូបារម្មណ៍ សទ្ទារម្មណ៍ជាដើម ។ ក្នុងបរិច្ឆេទទី ៤ ក៏ថា អតិមហន្តារម្មណ៍ មហន្តារម្មណ៍ជាដើម រួមជាមួយមាន ៦ អារម្មណ៍ ។

អារម្មណ៍ ២ ដែលពោលមកហើយនេះផ្សេងគ្នាយ៉ាងណា ?

**ឆ្លើយ** - ពាក្យថាអារម្មណ៍ទាំង ៦ គឺ រូបារម្មណ៍ជាដើម ។

- ពាក្យថាអារម្មណ៍ទាំង ៦ គឺ អតិមហន្តារម្មណ៍ជាដើម ។

អារម្មណ៍ទាំងពីរយ៉ាងនេះ សង្គ្រោះចូលជាមួយគ្នាបាន គឺ រូបារម្មណ៍ជាដើម ។ កាលប៉ះទង្គិចទ្វារទាំង ៦នោះ មានវារៈផ្សេងគ្នា គឺ ប៉ះទង្គិចជាវេលាយឺនយូរជាទីបំផុត ហៅថា អតិមហន្តារម្មណ៍ យឺនយូរល្មមសមគួរហៅថា

មហន្តារម្មណ៍ អារម្មណ៍ដែលខ្លីល្មមសំគួរ ហៅថាបរិត្តា-រម្មណ៍ អារម្មណ៍ដែលខ្លីបំផុតហៅថា អតិបរិត្តារម្មណ៍ ។

(អារម្មណ៍ទាំង ៤ នេះហៅ) ហៅអារម្មណ៍ទាំង៤ នេះដោយអាស្រ័យកាល របស់អារម្មណ៍ទាំង ៦នោះឯង ។

ព្រោះហេតុដូច្នេះ ពាក្យថារូបារម្មណ៍នេះ សេចក្ដីពិតគឺ ការប៉ះទង្គិចទ្វារមានខណៈ ខ្លី វែង ផ្សេងៗគ្នា និង អារម្មណ៍ដែលផ្សេងៗគ្នាទើបមានឈ្មោះថា អតិមហន្តា-រម្មណ៍ មហន្តារម្មណ៍ព្រោះហេតុដូច្នេះ រូបារម្មណ៍ សទ្ទារម្ម-ណ៍ ទាំងអស់នេះ ខណៈដែលប៉ះទង្គិចទ្វារទាំង ៥ នោះមានឈ្មោះថា អតិមហន្តារម្មណ៍ ។ល។ ដូចនេះជាដើម ។

**សួរ** កាលដែលប្រកាន់ថា ការកើតរលត់នោះអ្វីដែលកើតរលត់ មានន័យថា រូប និង នាមទាំងពីរនេះមានកើតរលត់ឬ ? កើត រលត់យ៉ាងដូចម្ដេច ?

**ឆ្លើយ** ពាក្យថាការកើត រលត់នោះ គឺការកើត ការរលត់នៃសង្ខារទាំងពីរ គឺរូប និង នាម មានន័យថា ការកើត ការ

រលត់នៃនាមធម៌រហ័សជាងរូបធម៌ ។

ព្រោះការកើត រលត់របស់រូបធម៌១ ប្រហែលការកើត ការរលត់នៃនាមធម៌ ១៧ខណៈ គឺរូបធម៌ ១ អាយុប្រហែលនឹងនាម ១៧ដួងជានិច្ច ។

អធិប្បាយតទៅទៀតថា : កាលភ្នែកឃើញរូប ចិត្តដែលកើត ហើយរលត់ទៅ មាន ១៧ដួងដោយបរិបូណ៌ ហៅថាអតិមហន្តារម្មណ៍ និង មហន្តារម្មណ៍ជាដើម ។

ការកើត ការរលត់នៃនាមធម៌ និង រូបធម៌យ៉ាងនេះ នៅមានជានិច្ច រហូតទាល់តែដល់ជាតិដែលរលត់ខន្ធ ។ ការដែលមានការកើតរលត់ ដូច្នេះក្នុងព្រះអភិធម្ម ហៅថា មានកើត មានរលត់ តាមភាសា សាសនា ហៅថា ឧប្បាទវយធម្ម៍ ជាធម្មជាតិដែលមានកើត រលត់ជានិច្ច ។

( មេត្តាមើលបាលី ឧប្បាទវយធម្មិនោ ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ) ជាធម្មជាតិដែលមានកើត រលត់ កើតហើយរលត់សូន្យបាត់ទៅ ការស្ងប់រម្ងាប់នៃ

សង្ខារនេះជាសេចក្តីសុខពិតប្រាកដ ដូច្នេះឯង ។

**ស្ទួរ** នាមធម៌ គឺចិត្ត មានកើត មានរលត់ទៅ ដូច្នេះតើចិត្តទាំងអស់មានវិថីកើតបានឬទេ ?

**ឆ្លើយ** វិថីចិត្ត មិនបានមានក្នុងចិត្តទាំងអស់ទេ ចិត្តដែលនិងបានជាវិថីនោះមានត្រឹម ៧០ដួងប៉ុណ្ណោះ ។

ចំណែកទ្វារវិមុត្តិចិត្ត ១៩ដួងនេះ ហៅថាវិថីវិមុត្តិចិត្ត មានន័យថា ជាចិត្តដែលមិនកើតជាវិថី ឬ ក្រៅអំពីវិថីចិត្តក៏បាន បានដល់ចិត្តជាឧបេក្ខាសន្តីរណៈ ២ដួង មហាវិបាក ៨ដួង មហគ្គតវិបាក ៩ដួង រួមទាំងអស់ហៅថាវិថីវិមុត្តិចិត្ត ។

**ស្ទួរ** កាលដែលវិថីចិត្តនឹងកើត មាននៅយ៉ាងនេះហើយវិថីវិមុត្តិចិត្តទាំងអស់នេះ ទទួលអារម្មណ៍អ្វីខ្លះ ?

**ឆ្លើយ** តាមដែលព្រះអនុរុទ្ធាចារ្យពោលថា :

វិថីវិមុត្តានំ បន កម្មកម្មនិមិត្តគតិនិមិត្តវសេន តិវិធា វិសយប្បវត្តិ ។ ប្រែ

វិថីវិមុត្តិចិត្ត ១៩ដួងនេះ សូម្បីនឹងហៅថាវិថីវិមុត្តិ-ចិត្តក្តី ក៏នៅមានអារម្មណ៍គឺ កម្ម កម្មនិមិត្ត គតិនិមិត្ត ទាំង ៣ដែលកើតទាក់ទងមកពីចុតិចិត្តជាតិមុនជាអារម្មណ៍បាន ជានិច្ច ។

ដូច្នេះវិថីវិមុត្តិចិត្ត ១៩ដួង មានអារម្មណ៍បានដូចវិថី-ចិត្តនេះផងដែរ ហៅថាវិសយប្បវត្តិនៃវិថីវិមុត្តិចិត្ត ១៩ ដួងដោយពិតប្រាកដ ។

**សួរ** ពាក្យថាភវង្គៈ និង វិថីវិមុត្តិចិត្ត ផ្សេងគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថាភវង្គៈ បានដល់ចិត្ត ន័យម្យ៉ាងដែលទាក់ទងមកពីបដិសន្ធិរហូតដល់ចុតិ ឬ ជាចិត្តដែលជាគ្រឿងសំ-គាល់របស់ជាតិ ហៅថាភវង្គ បានដល់ភវង្គចិត្ត ១៩ដួង គឺៈ

ឧបេក្ខាសន្តីរណៈ ២ដួង មហាវិបាក ៨ដួង មហគ្គត-វិបាក៩ដួង រួម ១៩ដួង ។

ក- ពាក្យថាវិថីវិមុត្តិចិត្ត មានន័យថា ចិត្ត ១៩ដួងនេះ

ឯងរមែងជាវិថីចិត្តមិនបាន ដូច្នេះហៅថាវិថីវិមុត្តិ ទ្វារវិមុត្តិ ក៏ បានតែជាធម្មជាតិជាមួយគ្នា ។

ខ. សំខាន់ដែលថា ភវង្គចិត្ត ១៩ដួងនេះ កាលកើតជាវិថីចិត្តនេះ រមែងមាននាមថាវិថីចិត្ត ។ កាលវិថីចិត្តមិនកើត ក៏រមែងហៅថា ភវង្គចិត្ត តែក៏ជាធម្មជាតិជាមួយគ្នានេះឯង ។

ស្នួរ  តាមដែលព្រះបរមសាស្ដាត្រាស់ទុកថា :

**ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ ប្រែ**

**ចក្ខុបសាទ និង រូបារម្មណ៍** ដែលជាស័ព្ទពហុវចន អាស្រ័យការប៉ះទង្គិចគ្នា ទាំងពីរនេះហើយ ចក្ខុ-វិញ្ញាណក៏រមែងកើតភ្នែកជាស័ព្ទឯកវចននេះ បានឃើញរូបដែលជាស័ព្ទពហុវចន សំដៅដល់ភ្នែកតែ១ឃើញរូបារម្មណ៍ច្រើនអារម្មណ៍បាន ឬ ភ្នែកតែ១ឃើញរូបត្រឹមតែ១ ។ តែបើរូបតែ១ ដូចម្ដេចព្រះបរមសាស្ដាទើបទ្រង់ប្រើ( ពាក្យ

ឬ) ស័ព្ទជារូបញ្ចៈ មិនបានឬ ?

**ឆ្លើយ** និងប្រើស័ព្ទ ដូច្នោះនោះមិនបាន ព្រោះធម្មតាភ្នែក ឃើញរូបនោះ អាចនឹងឃើញបានច្រើនអារម្មណ៍ គឺ ពណ៌ ក្រហម ខ្មៅ ស ជាដើម ។

បើមើលទៅរហូតពេញ ១ថ្ងៃ ក៏ឃើញច្រើនពាន់ អារម្មណ៍ អារម្មណ៍ទាំងអស់នេះ មានឈ្មោះថារូបារម្មណ៍ ទាំងអស់ ។

តែភ្នែក ក៏ គឺភ្នែកតែ១ ដែលមានស័ព្ទថាចក្ខុនោះ ឯង ។ ព្រោះហេតុដូច្នេះ ព្រះបរមសាស្តា ទ្រង់ប្រើពាក្យ ឯកវចន ថា ចក្ខុញ្ច ដូចនេះ ។

ចំណែករូបារម្មណ៍មានច្រើនពណ៌ទើបត្រូវប្រើពាក្យ ថា រូបេ ច ដូច្នេះ ។ មានន័យថា ភ្នែកឃើញរូបតែ១ មិនអាចដែលនឹងឃើញ ១ដង ច្រើនអារម្មណ៍បាន ។

## សំដែងអប្បនាជវន តាមបាលី

អប្បនាជវនវារេ បន វិភត្តាវិភត្តភេទោ
នត្ថិ តថា ផលសម្ភវោ ច ។ តត្ថ ហិ
ញាណសម្បយុត្តកាមាវចរជវនានមដ្ឋន្នំ ។
អញ្ញតរស្មឹ បរិកម្មោបចារានុលោមគោត្រភូនា-
មេន ចតុក្ខត្តុំ តិក្ខត្តុមេវ វា យថាក្កមំ
ឧប្បជ្ជិត្វា និរុទ្ធានន្តរមេវ យថារហំ ចតុត្ថំ វា
បញ្ចមំ វា ឆព្វីសតិ មហគ្គតលោកុត្តរ-
ជវនេសុ យថាភិនីហារវសេន យំ កិញ្ចិ ជវនំ
អប្បនាវិថីមោតរតិ ។ តតោ បរំ អប្បនាវ-
សានេ ភវង្គបាតោ វ ហោតិ ។ តត្ថ
សោមនស្ស សហគតជវនានន្តរំ អប្បនាបិ
សោមនស្ស សហគតាវ បដិកង្ខិតព្វា
(បដិកង្ខិតព្វា ) ។ ឧបេក្ខាសហគតជវនានន្តរំ
ឧបេក្ខាសហគតាវ ។ តត្ថាបិ កុសលជវនាន-
ន្តរំ កុសលជវនញ្ចេវ ហេដ្ឋិមញ្ចផលត្តយមប្បេតិ

## កិរិយាជវនានន្តរំ កិរិយាជវនំ អរហត្តផលញ្ចា តិ ៥

## ប្រែសេចក្តីថា

ក្នុងអប្បនាជវនវារនេះ គ្មានប្រភេទរបស់ វិភូតារម្មណ៍ និង អវិភូតារម្មណ៍ ហើយតទាលម្ពណ ក៏រមែងមានផង ចិត្ត ឯណានិមួយក្នុង ៨ នៃញាណសម្បយុត្តជវនចិត្ត រមែងកើត ៣ដង ឬ ៤ដង តាមលំដាប់នៃ :

១- បរិកម្ម

២- ឧបចារ

៣- អនុលោម

៤- គោត្រភូ និង ក្រោយដែលរលត់ចុះហើយ តាម ឋានៈរបស់សមថៈ ឬ វិបស្សនា ។ ចិត្តដួងឯណានីមួយក្នុង មហគ្គត លោកុត្តរជវន ២៦ដួងនោះគឺ ( មហគ្គតកុសល ៩ + មហគ្គត្តកិរិយា ៩ លោកុត្តរ ៨ ) ក្លាយជាអប្បនាដោយ មនទុបុគ្គល រាប់ជាខណទី ៥ ។

ចំណែកតិក្ខបុគ្គលរាប់ជាខណ ( គ្រា ) ទី ៤ តាំងពីនេះតទៅ ភវង្គចិត្តកកើតឡើង ។

អប្បនាចិត្តដែលបានប្រាកដ ក្រោយពីសោមនស្សជវន ត្រូវជាសោមនស្សអប្បនា និង អប្បនាដែលប្រាកដខាងក្រោយឧបេក្ខត្រូវជាឧបេក្ខាអប្បនា ។

អប្បនាដែលកើតក្រោយពី ជវនកុសលចិត្តនោះត្រូវជាជវនកុសលចិត្ត ហើយចិត្តជាផលទាំង ៣ នៃលោកុត្តរ និង អប្បនាដែលបានកើតក្រោយពីជវន កិរិយាចិត្តត្រូវជាជវនកិរិយាចិត្ត និង អរហត្តផល ដូចនេះឯង ។

---

## សំដែងពាក្យអធិប្បាយ អប្បនាជវន

វារៈដែលវិថីចិត្តកើតនោះមាន ២ គឺ :

- បរិត្តជវនវារៈ
- អប្បនាជវនវារៈ ។

បរិត្តជវនវារបានដល់វារៈ នៃកាមជវនដែលបានសំ

ដែងមកហើយខាងដើមនេះ ។

អប្បនាជវនវារៈ បានដល់វារៈនៃមហគ្គតៈ និង លោកុត្តរជវនទាំងពីរ ដូចនឹងសំដែងតទៅនេះ :

ក្នុងអប្បនាជវនវារៈនេះ គ្មានប្រភេទរបស់អារម្មណ៍ គឺ វិភូតារម្មណ៍ ឬ អវិភូតារម្មណ៍ទេ ហើយការកើតរបស់ តទាលម្ពណៈ រមែងមិនមានផង ។

ព្រះយោគាវចរដែលចំរើនកម្មដ្ឋាន នៅគ្រប់១ខណៈ កាលជិតនឹងបានសំរេចហើយ ក្នុងកាមាវចរញាណសម្ប-យុត្តជវនចិត្ត ៨ដួងនោះ ដួងឯណានីមួយក្តី រមែងកើតជា បរិកម្ម ឧបចារ អនុលោម និង គោត្រភូ ៣គ្រា ឬ ៤គ្រា ហើយរលត់ចុះ១រំពេច ។

ខាងក្រោយដែលអប្បនាវិថី ៤ដួងរលត់ហើយចិត្ត ដួងឯណានីមួយ ក្នុងមហគ្គតចិត្ត លោកុត្តរជវនចិត្ត ២៦ ដួងនេះ ក្លាយជាអប្បនាវិថី នៅដោយន័យ តាំងពីគ្នាទី៤នៃ អ្នកដែលមានកាមាវចរជវនចិត្ត ៣គ្រា ហើយរាប់តាំងពី

គ្រាទី ៥ នៃអ្នកដែលមាន កាមាវចរជវនចិត្ត ៤គ្រា តាំងពីនេះតទៅ ភវង្គចិត្តកកើតឡើង ។

មហគ្គតចិត្តនឹងលោកុត្តរជវនចិត្ត ២៦ដូងគឺ : មហគ្គតកុសល ៩ + មហគ្គតកិរិយា ៩ + លោកុត្តរ ៨

## សំដែងភាពអប្បនាវិថី ២

✵ សំរាប់មន្ទបុគល តាមបាលីថា : **បញ្ចមំ វា**

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| អតីតភវង្គ | ភវង្គចលនៈ | ភវង្គុបច្ឆេទ | មនោទ្វារាវជ្ជនៈ | បរិកម្ម | ឧបចារៈ | អនុលោម | គោត្រភូ | ឈាន | ភវង្គ | ដើមតទៅ |

✵ សំរាប់ តិក្ខបុគល តាមបាលីថា : **ចតុត្ថំ វា**

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| អតីតភវង្គ | ភវង្គចលនៈ | ភវង្គុបច្ឆេទ | មនោទ្វារាវជ្ជនៈ | ឧបចារៈ | អនុលោម | ឈាន | គោត្រភូ | ភវង្គខាង | ដើមតទៅ |

ក្នុងមគ្គវិថីនេះ បរិកម្ម ឧបចារ អនុលោម គោត្រភូ ហើយដល់មគ្គចិត្ត និង ភវង្គចិត្តជាដើម ។

ក្នុងអប្បនា ដែលកើតពីសោមនស្ស ហៅថាសោមនស្សអប្បនា ដែលកើតមកពីឧបេក្ខា ត្រូវហៅថា ឧបេក្ខាអប្បនាផង ។

ក្នុងទីនេះមិនថាជាសោមនស្ស ឬ ឧបេក្ខាក៏ដោយ អប្បនា ដែលទាក់ទងមកពីជវនចិត្ត ជាកាមាវចរកុសលចិត្ត នោះ បានដល់អប្បនាកុសលចិត្ត ២៩ដួង សោតាបត្តិផលចិត្ត៥ដួង សកទាគាមិផលចិត្ត ៥ដួង អនាគាមិផលចិត្ត ៥ ដួង រួម ៤៤ដួង និងអប្បនា ដែលទាក់ទងពីជវនចិត្ត ជាកាមាវចរកិរិយាចិត្តនោះ បានដល់អប្បនាកិរិយាចិត្ត ៩ដួង អរហត្តផលជវនចិត្ត ៥ ដួង រួម ១៤ដួង ។

## គាថាសង្គហនៃអប្បនាវិថី

**ទ្វត្តឹស សុខបុញ្ញម្ហា ទ្វាទសោបេក្ខកា បរំ**

**សុខិតកិរិយាតោ អដ្ឋ ឆ សម្ភោន្តិ ឧបេក្ខកា ។**

## បុថុជ្ជនានំ សេក្ខានំ កាមបុញ្ញតិហេតុតោ តិហេតុកាមកិរិយាតោ វីតរាគានមប្បនា ២

ខាងក្រោយដែលកើត សោមនស្សញាណសម្បយុត្ត កុសលចិត្តជវន ២ដួង បានដល់សោមនស្សអប្បនាចិត្ត ៣២ ដួងក្រោយពីការកើតឧបេក្ខាជវន ២ដួងហើយ បានដល់ ឧបេក្ខាអប្បនាចិត្ត ១២ដួង ក្រោយពីកើតសោមនស្ស ញាណសម្បយុត្តកិរិយាចិត្ត ២ដួង បានដល់សោមនស្ស អប្បនាចិត្ត ៨ដួង និងក្រោយពីដែលបានកើតឧបេក្ខាជវន ចិត្ត ២ដួង បានដល់ឧបេក្ខាអប្បនាចិត្ត ៦ដួង ។

**ប្រែ :** អប្បនាសមាធិចិត្ត កើតដល់បុថុជ្ជន និង សេក្ខបុគ្គល គឺ កើតអំពីកាមាវចរកុសលញាណសម្បយុត្តត្រៃហេតុ អប្បនាសមាធិចិត្ត កើតដល់វីតរាគបុគ្គល គឺ កើតអំពី កាមាវចរកិរិយាញាណសម្បយុត្តត្រៃហេតុ អប្បនាសោម-នស្ស ក្នុងសន្តានបុថុជ្ជន និង សេក្ខបុគ្គល ៣២ អប្បនា ឧបេក្ខា ក្នុងសន្តានបុថុជ្ជន និង សេក្ខបុគ្គល ១២ អប្បនា-

សោមនស្សក្នុងសន្តានអសេក្ខបុគ្គល ៨ អប្បនាឧបេក្ខា ក្នុងសន្តានអសេក្ខបុគ្គលឯពូក រួមជាអប្បនា ៥៨ ។

**អយមេត្ថ មនោទ្វារេ វិថីចិត្តប្បវត្តិនយោ** **ប្រែ**

សេចក្តីដែលពោលមកហើយនេះ ជាន័យនៃការកើតរបស់វិថីចិត្តនៃមនោទ្វារ ។

ំំំំំំ

## ពាក្យសួរ_ឆ្លើយនៃអប្បនាជវន

**សួរ** ពាក្យថាអប្បនាប្រែថាអ្វី ? ហើយបានដល់អ្វី ?

**ឆ្លើយ** ពាក្យថា អប្បនាប្រែថាត្រង់១ បានដល់ការទំលាយ ព្រោះវិគ្គហៈថា និវរណាទិសព្វកិលេសេ អប្បតិ វិនាសេតីតិ អប្បនា

**ប្រែ** ចិត្តដែលទំលាយកិលេសទាំងអស់គឺ : នីវរណទាំង៥

ជាដើមនោះ ហៅថាអប្បនា អប្បនាជវនចិត្ត ២៦ដួង ប៉ុណ្ណោះ ។

**សួរ** តាមពាក្យឆ្លើយ ទី១ថា វិតក្កចេតសិកហៅថា អប្បនា ហើយទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចម ជ្ឈានដែលប្រាសចាកវិតក្កជាអប្បនាអ្វី ? សុំឱ្យឆ្លើយដោយ មានភស្តុតាងដែលគួរជឿបាន ? ។

**ឆ្លើយ** តាមព្រះបាលី ធម្មសង្គណីថា :

**តក្កោ វិតក្កោ សង្កប្បោ អប្បនា ព្យប្បនា**

**ប្រែ តក្ក វិតក្ក អប្បនា** ឈ្មោះទាំងអស់នេះ បាន ដល់ចេតសិកទាំងអស់ ។

អធិប្បាយថា តាំងពីគោត្រភូនៃបឋមជ្ឈានហៅថា អប្បនា ហើយសំរាប់ទុតិយជ្ឈាន តតិយ ចតុត្ថ បញ្ចមទាំង អស់នេះ ហៅថាអប្បនាបាន ព្រោះឈានទាំងអស់នេះសុទ្ធ ចិត្តដែលទាក់ទងមកពីវិតក្កនេះឯង ។

មូលដីកាចារ្យលោកអធិប្បាយថា : វិតក្កស្ស កិច្ចវិ-សេសេន ថិរភាវប្បត្តេ បឋមជ្ឈានសមាធិ មហិបញ្ចនិកថ្ចិរ ភាវ កតេន ថិរភាវេនតំ សទិសេសុ វិតក្ករហិតេសុ ទុតិយជ្ឈានាទិ សមាធិ សុខអប្បនាតិ អដ្ឋកថាវោហារោ ។

**ប្រែ** វិតក្កចេតសិក តាំងមាំនៅក្នុងសមាធិនៃបឋមជ្ឈាន ដោយមានកិច្ចវិសេស ដែលលើកចិត្តឡើង កាន់អារម្មណ៍បាន មានឧបមេយ្យយ៉ាងណា ទុតិយជ្ឈានសមាធិ ជាដើម ក៏មានឧបមាដូច្នេះដែរ គឺបានឆ្ងាយពី កិលេសដូច្នេះក្នុង អត្ថកថាហៅថា អប្បនា ទាំងអស់ ។

**សួរ** តាមបាលីថា : **អប្បនាជវនវារេ បន វិភូតាវិភូតភេទោ នត្ថិ**

ក្នុងអប្បនាជវនវារនោះ គ្មានប្រភេទរបស់វិភូតា-រម្មណ៍ អវិភូតារម្មណ៍ទេ ។ កាលបើដូច្នេះនេះ អប្បនាជវន មិនមានអារម្មណ៍ខ្លះឬ ?

មូលដីកាចារ្យលោកអធិប្បាយថា : វិតក្កស្ស កិច្ចវិ-សេសេន ថិរភាវប្បត្តេ បឋមជ្ឈានសមាធិ មហិបញ្ចកថ៉ិរ ភាវំ កតេន ថិរភាវេនតំ សទិសេសុ វិតក្ករហិតេសុ ទុតិយជ្ឈានាទិ សមាធិ សុខអប្បនាតិ អដ្ឋកថាវោហារោ ។ **ប្រែ** វិតក្កចេតសិក តាំងមាំនៅក្នុងសមាធិនៃបឋមជ្ឈាន ដោយមានកិច្ចវិសេស ដែលលើកចិត្តឡើង កាន់អារម្មណ៍បាន មានឧបមេយ្យយ៉ាងណា ទុតិយជ្ឈានសមាធិ ជាដើម ក៏មានឧបមាដូច្នេះដែរ គឺបានឆ្ងាយពី កិលេសដូច្នេះក្នុង អត្ថកថាហៅថា អប្បនា ទាំងអស់ ។

**សួរ** តាមបាលីថា : **អប្បនាជវនវារេ បន វិភូតាវិភូតភេទោ នត្ថិ**

ក្នុងអប្បនាជវនវារនោះ គ្មានប្រភេទរបស់វិភូតា-រម្មណ៍ អវិភូតារម្មណ៍ទេ ។ កាលបើដូច្នេះនេះ អប្បនាជវន មិនមានអារម្មណ៍ខ្លះឬ ?

Page missing

បានដល់ជវនចិត្តទាំងអស់ ដែលកើតមុនអប្បនា និង ចិត្ត ក្រោយនោះ ដោយត្រង់បានដល់អប្បនាចិត្ត ។

- ពាក្យថាគោត្រភូ ញែកចេញបានពីរបទគឺ

គោត្រ + ភូ

គោត្រ ប្រែថា ជាតិ ឬ ក្រសែ ស្រលាយ

ភូ ប្រែថា ទំលាយ ភាសាបាលីថា : អភិភុយ្យ

ដូច្នេះពាក្យថា គោត្រភូប្រែត្រង់ៗ បានដល់ចិត្ត១ ដូងដែលទំលាយជាតិ ឬ ក្រសែ ស្រលាយរបស់កាម ឬ បុថុជ្ជន ព្រោះគោត្រភូមានពីរយ៉ាង គឺ :

១-មហគ្គតគោត្រភូ

២-លោកុត្តរគោត្រភូ

ក្នុងទីនេះ មហគ្គតគោត្រភូ តាមវិគ្គហៈថា

**បរិត្ត គោត្តំ អភិភុយ្យតីតិ គោត្រភូ**

**ប្រែ** ទំលាយជាតិកាម ហៅថាមហគ្គតគោត្រភូ ចំណែក លោកុត្តរ គោត្រភូនោះ តាមវិគ្គតថា :

**បុថុជ្ជនគោត្តំ អតិក្កមតីតិ គោត្រភូ ប្រែថា**
ទំលាយក្រសែស្រលាយរបស់បុថុជ្ជន ហៅថាលោកុត្តរគោ-
ត្រភូ ។

**សួរ** តាមបាលីថា អប្បនាជវន រមែងកើត៣គ្រា ឬ ៤
គ្រា តើកើតយ៉ាងណា ? និងអប្បនាជវន កើត១ដូង១
រមែងកើតទៀត ៤គ្រា ឬ ៥គ្រា ដូចនេះឬ ? ពាក្យថា ៣
គ្រា ឬ ៤គ្រាហើយនៅមានកើត ៤ ឬ ៥ គ្រាទៀត ដូច្នេះ
មានន័យថាជាអ្វី ?

**ឆ្លើយ** -ដែលពោលដល់ការកើត ៣គ្រា ឬ ៤គ្រានោះសំ
ដៅដល់ព្រះយោគីបុគ្គល ដែលជិតនឹងដល់ឈាន កាលខណ
ដែលអប្បនាវិថីកើតនោះ អ្នកខ្លះកកើត ៣គ្រា អ្នកខ្លះ
កកើត ៤គ្រា ។

-ដែលកើត៣គ្រានោះគឺ តិក្ខបុគ្គល ជាអ្នកមាន
បញ្ញាច្រើន ។

-ដែលកើត៤គ្រានោះគឺ មន្ទបុគ្គលជាអ្នកមានបញ្ញា

ទន់ខ្សោយ ។

( មេត្តាមើលអប្បនាវិថីទាំងពីរ ដែលសំដែងខាងដើមវាររនេះ )

✵ មន្ទបុគ្គលដែលមានវិថីចិត្ត ៤គ្រានោះ គឺ : ១ បរិកម្ម ២ ឧបចារ ៣ អនុលោម ៤ គោត្រភូ ហើយទើបកើតដល់ឈានចិត្ត ឬ មគ្គចិត្ត ១ដួង រួម ៥ គ្រា

✵ តិក្ខបុគ្គលដែលមានវិថីចិត្ត ៣គ្រានោះគឺ : ១ ឧបចារ ២ អនុលោម ៣ គោត្រភូ ហើយទើបដល់ឈានចិត្ត ឬ មគ្គចិត្ត ១ដួង រួម ៤គ្រា តាមបាលីថា : ចតុត្ថំ វា បញ្ចមំ វា បួនគ្រា ឬ ប្រាំគ្រា រមែង កើតក្នុងអប្បនាវិថី របស់ឈានលាភីបុគ្គល ក្នុងខណៈដែលឈាន ឬ អរិយមគ្គដូច្នោះ ។

**សួរ** ក្នុងអប្បនាវិថីនេះ សោមនស្សអប្បនា និង ឧបេក្ខាអប្បនា ផ្សេងគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ធម្មតា អប្បនាវិថីមានពីរយ៉ាងគឺ :

១-កុសលអប្បនា ២-ឧបេក្ខាអប្បនា ។

✵ ក្នុងកិរិយាអប្បនា មានពីរយ៉ាងគឺ :

១-សោមនស្សអប្បនា ២-ឧបេក្ខាអប្បនា ។

✵ ក្នុងកុសលអប្បនា ក៏មានពីរយ៉ាងដូចគ្នាគឺ :

១-សោមនស្សអប្បនា ២-ឧបេក្ខាអប្បនា ។

សំរាប់ព្រះមហាយោគាវចរបុគ្គល ក្រោយពី សោម-នស្សមហាកុសលចិត្ត ជាញាណសម្បយុត្ត ២ដួងកើតហើយ សោមនស្សចិត្តនៃ មហគ្គតកុសលចិត្ត ៤ដួង សោមនស្សនៃមគ្គចិត្ត ១៦ដួង សោមនស្សនៃផលចិត្តទាំង ១២ដួង រួមសោមនស្សចិត្ត ៣២ដួង ហៅថា សោមនស្សអប្បនា ។ មានសេចក្តីថា សោមនស្សអប្បនា ទាក់ទងមកពី សោមនស្សនៃមហាកុសលចិត្ត ។

ក្រោយពីឧបេក្ខា មហាកុសលចិត្តជាញាណសម្បយុត្តកើតហើយ ឧបេក្ខាមហគ្គតកុសលចិត្ត ៥ដួង ឧបេក្ខា

មគ្គចិត្ត ៤ដួង ឧបេក្ខាផលចិត្តទាំង ៣ បាន៣ដួង រួម ១២ ដួងនេះ ហៅថា ឧបេក្ខាអប្បនា ។

ឧបេក្ខាអប្បនានេះទាក់ទង មកពីឧបេក្ខានៃឧបេក្ខា មហាកុសលដួចគ្នា ។ រួមសោមនស្សអប្បនា និង ឧបេក្ខា អប្បនាទាំងពីរនេះ ដែលអធិប្បាយមកហើយនេះ ហៅថា អប្បនាកុសលទាំងអស់ ។

ចំណែកអប្បនាកិរិយា គឺ សោមនស្សកិរិយា ៨ដួង គឺ សោមនស្សនៃមហគ្គត ៤ដួង សោមនស្សនៃអរហត្តផល ៤ដួង រួម ៨ដួង និង ឧបេក្ខាអប្បនាកិរិយា ៦ដួងគឺ ឧបេក្ខា នៃមហគ្គត ៥ដួង ឧបេក្ខានៃអរហត្តផល១ដួង រួម ៦ដួង។

សោមនស្ស និង ឧបេក្ខាទាំងពីរដែលពោលមកនេះ ហៅថាអប្បនាកិរិយាទាំងអស់ ។

**សួរ** ក្នុងអប្បនាវិថីនេះ ទោមនស្សវេទនា ឬ ទោមនស្ស ជវនមានឬទេ ?

**ឆ្លើយ** រីឯធម្មជាតិ របស់អប្បនាវិថី បានដល់មហគ្គត-

កុសលចិត្ត ៩ដួង និង លោកុត្តរចិត្ត ៨ដួង និង មហគ្គត-កិរិយាចិត្ត ៩ដួង ដែលជាសោភណចិត្តទាំងអស់ ។

ពាក្យថាទោមនស្សនេះ ជាអកុសលចិត្ត ដូច្នេះអប្បនាចិត្តនោះ ទើបគ្មានទោមនស្សទេ ។

**សួរ** ក្នុងអប្បនាវិថីនេះ លោកអដ្ឋកថាចារ្យ បានសំដែងអប្បនា ២យ៉ាងគឺ ១- កុសលអប្បនា ២- កិរិយាអប្បនា ចង់ជ្រាបថា កុសលអប្បនាបានដល់បុគ្គលណាខ្លះ ?

**ឆ្លើយ** កុសលអប្បនា រួមទាំងសោមនស្ស និង ឧបេក្ខា ចំនួន ៤៤ដួង ដូចដែលបានសំដែងមកហើយ រមែងកើតដល់តិហេតុកបុគ្គល និង សោតាបត្តិផល សាកទាគាមិផល អនាគាមិផល ។

បុគ្គលទាំង ៣ រួមទាំងបុគ្គលចំពូក កិរិយាអប្បនាទាំងសោមនស្ស ឧបេក្ខា មានចំនួន ១៤ដួង រមែងកើតដល់ព្រះអរហត្តផល បុគ្គល ១ប៉ុណ្ណោះ ( មេត្តាមើលក្នុងគាថាសង្គហអប្បនាជវនវារនេះឯង ) ។

**សួរ** តាមដែលបានអធិប្បាយមកហើយថា អប្បនាជវនទ្វារនេះ រមែងមិនមានអារម្មណ៍ទាំង ៤ គឺ : អតិមហន្តារម្មណ៍ មហន្តារម្មណ៍ បរិត្តារម្មណ៍ អតិបរិត្តារម្មណ៍ នោះ ។

មានសេចក្តីថា លោកឈានលាភីបុគ្គល មិនឃើញអ្វី មិនបានឮអ្វី ? មិនបានខឹងអ្វី ? មិនទទួលទានហើយមិនមានធ្លោដ្ឋព្វដូច្នេះឬ ?

**ឆ្លើយ** មិនមានលោក ឈានលាភីបុគ្គលគឺ អ្នកដល់ឈានមានអារម្មណ៍ ៦ជានិច្ច ។

ពាក្យអប្បនានោះហៅថា អប្បនាវិថី ក្នុងខណដែលដល់ឈាន និង អរិយមគ្គ អរិយផល ក្នុងខណនេះជាតួនា ទីរបស់មនោទ្វារ និង វិភូតារម្មណ៍ប៉ុណ្ណោះ ។ គ្មានតួនាទីរបស់អតិមហន្តារម្មណ៍ មហន្តារម្មណ៍ បរិត្តារម្មណ៍ និង អតិបរិត្តារម្មណ៍ទេ ក្រោយពីអប្បនាវិថីកើតហើយ លោកអ្នកដល់ឈាន និង អរិយបុគ្គលគ្រប់អង្គរមែងមានអារម្មណ៍ទាំងនេះ រហូតដល់រលត់ខន្ធ ។

តែអារម្មណ៍ដែលជវនទាំងនេះ គ្មានជាអប្បនាទេ ត្រូវហៅថា បរិត្តជវន គឺ កាមជវនប៉ុណ្ណោះ ។

សេចក្តីសំខាន់ត្រូវចាំថា ព្រះអរិយនឹងដល់ឈាន មានពីរបែបគឺ : ១- បរិត្តជវន ២ អប្បនាជវន ។

ចំណែកបុថុជ្ជន នោះមានតែ បរិត្តជវន ១យ៉ាង ប៉ុណ្ណោះព្រោះហេតុដូច្នេះ អប្បនាជវនទើបមិនមានក្នុងអារម្មណ៍ទាំង ៤ ។

## សំដែងតទាលម្ពណវារ តាមបាលី

**សព្វត្ថាបិ បនេត្ថ អនិដ្ឋេ អារម្មណេ អកុសលវិបាកានេវ បញ្ចវិញ្ញាណសម្បដិច្ឆន្ន-សន្តីរណតទាលម្ពណានិ ច ឥដ្ឋេ កុសលវិបាកានិ ច**

**អតិឥដ្ឋេ បន សោមនស្ស សហគតានេវ សន្តីរណតទាលម្ពណានិ ច តត្ថាបិ សោមនស្សសហគតកិរិយាជវនាវសានេ**

សោមនស្សសហគតា នេវ តទាលម្ពណានិ ភវន្តិ ។ ឧបេក្ខាសហគតា កិរិយាជវនាវសានេ ច ឧបេក្ខា សហគតា នេវ ហោន្តិ ។ ទោមនស្សសហគតជវនាវសានេ ច បន តទាលម្ពណានិ ចេវ ភវង្គលានិ ច ឧបេក្ខា សហគតានេវ ភវន្តិ ។ តស្មា យទិ សោមនស្ស បដិសន្ធិកស្ស ទោមនស្ស សហគតជវនាវសានេ តទាលម្ពណមារព្ភ ឧបេក្ខាសហគតសន្តីរណំ ឧប្បជ្ជតិ តមនន្តរិត្វា ភវង្គបាតោ វ ហោតីតិ វទន្តិ អាចរិយា ។ តថា ( កាមាវចរជវនា វសានេ ) កាមាវចរសត្តានំ កាមាវចរធម្មេស្វេវ អារម្មណភូតេសុ តទាលម្ពណំ ឥច្ឆន្តីតិ ។

ប្រែ ក្នុងបញ្ចទ្វារ និង មនោទ្វារវិថីទាំងពីរ :

- ក្នុងអនិដ្ឋារម្មណ៍ រមែងកើតអំពីបញ្ចវិញ្ញាណ សម្បដិច្ឆន្ន សន្តីរណ តទាលម្ពណ ដែលជាអកុសលវិបាក ។

- ក្នុងឥដ្ឋារម្មណ៍ រមែងកើតអំពីបញ្ចវិញ្ញាណ សម្បដិច្ឆន្ន សន្តីរណតទាលម្ពណ ដែលជាកុសលវិបាក ។

- ក្នុងអតិឥដ្ឋារម្មណ៍ សន្តីរណ តទាលម្ពណ កើតព្រម ជាមួយ និង សោមនស្សវេទនាទាំងអស់ ។

ខាងក្រោយអំពី មហាកិរិយា សោមនស្សជវន កើតហើយ តទាលម្ពណដែលជាសោមនស្ស ក៏រមែងកើត ។ ក្រោយអំពីឧបេក្ខាកើតហើយ តទាលម្ពណដែលជាឧបេក្ខា ក៏រមែងកើត ក្រោយអំពីទោមនស្សជវនកើត ក៏រមែងកើត តទាលម្ពណ និង ភវង្គដែលជាឧបេក្ខា ។

ដូច្នេះ អ្នកដែលមានបដិសន្ធិ ព្រមជាមួយនិង សោមនស្សវេទនា ប្រសិនបើមិនមានតទាលម្ពណ ( ប្រសិនបើមិនមាន តទាម្ពណ អ្នកដែលមានបដិសន្ធិព្រមជាមួយនឹង សោមនស្ស វេទនា ) អាស្រ័យកាមារម្មណ៍ចាស់

ហើយឧបេក្ខាសន្តីរណ ក៏រមែងកើត ហើយភវង្គចិត្ត ក៏មានដំណើរតទៅដូចដែលអាចារ្យទាំងឡាយ បានពោលទុកដូច្នេះ សត្វដែល ជាកាមាវចរទាំងនេះ រមែងកើតតទាលម្ពណក្នុងកាមារម្មណ៍នោះឯង នេះជាតទាលម្ពណនិយាម ។

## ពាក្យអធិប្បាយតទាលម្ពណវារៈ តាមបាលី

ក្នុងបញ្ចទ្វារវិថី និង មនោទ្វារវិថី ដែលបានអធិប្បាយមកហើយ នៅមានសភាពនៃអារម្មណ៍ទាំង ៣ យ៉ាង :

១-អនិដ្ឋារម្មណ៍

២-ឥដ្ឋារម្មណ៍

៣-អតិឥដ្ឋារម្មណ៍

រូបអារម្មណ៍ទាំង ៣ ។

កាលណាទ្វារប៉ះទង្គិច និង អារម្មណ៍ ដែលមិនពេញចិត្ត ឬ អារម្មណ៍ដែលមិនគាប់ចិត្ត អារម្មណ៍នោះហៅថា អនិដ្ឋារម្មណ៍ ហើយបញ្ចវិញ្ញាណ សម្បដិច្ឆន្ន សន្តីរណ តទាលម្ពណទាំងនេះ រមែងជាផ្នែក អកុសលវិបាកទាំងអស់ ។

មានន័យថា អកុសលវិបាក ៧ដួង ដែលពោលមកហើយក្នុងអហេតុកចិត្ត ១៨ដួង ក្នុងចិត្តបរិច្ឆេទ រមែងកើតកាលណាប៉ះទង្គិចនឹងអនិដ្ឋារម្មណ៍ប៉ុណ្ណោះ ។

កាលណាប៉ះទង្គិច និង ឥដ្ឋារម្មណ៍ គឺអារម្មណ៍ដែលពេញចិត្ត បញ្ចវិញ្ញាណ សម្បដិច្ឆន្ន សន្តីរណ តទាលម្ពណទាំងនេះសុទ្ធតែជាផ្នែកកុសលវិបាកទាំងអស់ ។

តែកាលណាប៉ះទង្គិចនិង ឥដ្ឋារម្មណ៍ គឺអារម្មណ៍ដែលល្អជាទីបំផុតនោះ សន្តីរណ តទាលម្ពណទាំងអស់នេះរមែងកើតកុសលវិបាក ហើយជាសោមនស្សជានិច្ច ។

ខាងក្រោយដែលសោមនស្ស មហាកិរិយាកើត ហើយសោមនស្សតទាលម្ពណរមែងកើតហើយ ក្រោយពីឧបេក្ខាមហាកិរិយាកើត ឧបេក្ខាតទាលម្ពណកកើតតាម ។

មានន័យថា ក្នុងចិត្តរបស់ព្រះអរហន្តកាលតទាលម្ពណកើតក្រោយសោមនស្ស មហាកិរិយាហៅថាសោមនស្សតទាលម្ពណ ក្រោយឧបេក្ខា ត្រូវហៅថាឧបេក្ខាតទាម្ពណ

តែខាងក្រោយដែល ទោមនស្សជវនកើតនោះ តទាលម្ពណ និង ភវង្គត្រូវកើតជាឧបេក្ខា ព្រោះហេតុដូច្នោះ អ្នកដែលបដិសន្ធិមក ដោយសោមនស្ស ប្រសិនបើមិនមានតទាលម្ពណក្នុងកាលទោមនស្សជវនកើតនោះ កាមារម្មណ៍ចាស់ណាមួយ ដែលធ្លាប់មកជាអារម្មណ៍មកពីអតីតកាលនោះឯង ជាឧបេក្ខាសន្តីរណបាន ហើយភវង្គ ក៏រមែងកើតតាមក្រោយមកផងដែរ ។

ដូចដែលពោលមកហើយនេះ តាមវាទៈរបស់លោកអាចារ្យទាំងឡាយប៉ុណ្ណោះ ។

សេចក្ដីពិត សត្វដែលនៅក្នុងកាមភូមិ ខាងក្រោយដែលកាមជវនកើត លោកអាចារ្យទាំងឡាយរមែងពោលថា តទាលម្ពណ កើតជាធម្មតា មានន័យថាកាមបុគ្គលកាលជវនកើតហើយ កាមបុគ្គលតទាលម្ពណ កើតជាធម្មជាតិជានិច្ច ។

---

# គាថាសង្គហ

**កាមេ ជវនសត្តាលម្ពណានំ និយមេ សតិ**
**វិភូតេតិ មហន្តេ ច តទាលម្ពណមីរិតំ ៕**

**ប្រែ** ក្នុងកាមភូមិនេះ កាលសំបូណ៌ដោយជវន កាម-បុគ្គលអារម្មណ៍រូបទាំង បីនេះហើយ ក្នុងអារម្មណ៍គឺ អតិមហន្តារម្មណ៍ និង វិភូតារម្មណ៍ ទាំងពីរនេះ តទាលម្ពណរមែងកើតជានិច្ចទៅ ។

**អយមេត្ថ តទាលម្ពណនិយមោ**

**ប្រែ** នេះឯងគឺ វត្ថុដែលគួរចាំ ទាក់ទងនិងតទាលម្ពណ

ក្នុងវិថីសង្គហនេះ ។

# សំដែងជវនវារៈតាមបាលី

ជវនេសុ ច បរិត្តជវនវីថិយំ កាមាវចរជវនានិ សត្តក្ខត្តុំ មេវ ជវន្តិ ។

មន្ទប្បវត្តិយំ បន មរណកាលាទីសុ បញ្ចវារមេវ ។ ភគវតោ បន យមកបាដិ-ហារិយកាលាទីសុ លហុកប្បវត្តិយំ ចត្តារិ វា បញ្ច វា បច្ចវេក្ខណចិត្តានិ ភវន្តីតិ បិ វទន្តិ ។ អាទិកម្មិកស្ស បន បឋមកប្បនាយំ មហគ្គតជវនានិ អភិញ្ញាជវនានិ ច ។

សព្វទាបិ ឯកវារមេវ ជវន្តិ ។ តតោ បរំ ភវង្គបាតោ ។ ចត្តារោ បន មគ្គុប្បាទា ឯកចិត្តក្ខណិកា ។ តតោ បរំ ទ្វេ តីណិ

ផលចិត្តានិ យថារហំ ឧប្បជ្ជន្តិ ។ តតោ បរំ ភវង្គបាតោ ។

និរោធសមាបត្តិកាលេ ទ្វិក្ខត្តុំ ចតុត្ថារុប្បជវនំ ជវតិ ។ តតោ បរំ និរោធំ ផុសតិ វុដ្ឋានកាលេ ច អនាគាមិផលំ វា អរហត្តផលំ វា យថារហមេកវារំ ឧប្បជ្ជិត្វា និរុទ្ធេ ភវង្គបាតោវ ហោតិ ។

សព្វត្ថាបិ សមាបត្តិវិថិយំ ភវង្គសោតោ វិយ វិថិនិយមោ នត្ថីតិ កត្វា ពហូនិបិ លព្ភន្តីតិ ។

ប្រែ ក្នុងបរិត្តជវនវិថី របស់ជវននិយាមនេះ កាមាវចរជវនរមែងកើត ៦ដង ( គ្រា) ឬ ៧ដង ប៉ុណ្ណោះ ។

មន្ទប្បវត្តិ ក្នុងខណៈដែលជិតនឹងស្លាប់នោះ ជវនចិត្តរមែងកើត ៥គ្រា ប៉ុណ្ណោះ ។ តែថាអាចារ្យទាំងឡាយរមែងពោលថា :

ជវនចិត្តរបស់ព្រះសាស្តា កាលដែលសម័យសំដែងបាដិហារជាដើមនោះ មានបញ្ចវេក្ខណចិត្ត រហ័សជាទីបំផុតត្រឹម ៤ ឬ ៥ គ្រាប៉ុណ្ណោះ ។

អំពីនេះតទៅ ជាភវង្គចិត្ត ជាមគ្គចិត្តទាំង ៤ដួង មានចិត្តក្ខណ ១ដួង តមកផលចិត្ត ២ ឬ ៣ដួង រមែងកើតតាម ហើយភវង្គចិត្តរមែងកើតក្នុង ខណៈដែលចូលនិរោធ-សមាបត្តិ ចតុត្ថអរូបសមាបត្តិ រមែងកើត ២ដួង ហើយដល់និរោធតែម្តង ។

កាលចេញពីនិរោធ អនាគាមិផលចិត្ត ឬ អរហត្ត-ផលចិត្ត រមែងកើត ១ ដួងហើយរលត់ចុះ ចិត្តជាភវង្គតទៅ ។

កាលសមាបត្តិវិថីទាំងអស់នេះ ភវង្គចិត្តតទៅ ដូចក្រសែរបស់ភវង្គចិត្ត មិនមានសេចក្តីបំណាង ចាំរបស់វិថីទេ ព្រោះជវនចិត្ត រមែងកើតជាកម្លាំងដូរច្នេះឯង ។

## អធិប្បាយជវននិយម

ក្នុងជវនវារនេះ ធម្មតាកាមាវចរចិត្ត រមែងកើតយ៉ាងច្រើន ៧ដង ( គ្រា ) និង យ៉ាងតិច ៦ដងជានិច្ច ។ ( មេត្តាមើល ភាពវិថី អតិមហន្តារម្មណ៍ បរិត្តារម្មណ៍ អតិបរិត្តារម្មណ៍ និង មហន្តារម្មណ៍ ) ។

ក្នុងខណៈដែលបុគ្គលជិតនឹងស្លាប់ ព្រោះមានកម្លាំងយ៉ាងតិចបំផុត អាចនឹងកើតជវនចិត្តបាន ៥ ជវនប៉ុណ្ណោះ តែអាចារ្យទាំងឡាយក្នុងលង្កាទ្វីបនិយាយថា កាលព្រះបរមសាស្តានៃយើងសំដែង ឫទ្ធិបាដិហារក្នុងនគរសាវត្ថីនោះ ព្រោះចិត្តរបស់ព្រះសាស្តា លឿនរហ័សទៅ ចិត្តដែលពិចារណាកើត ៤ ឬ ៥ ដង ប៉ុណ្ណោះ ។ អប្បនាវិថីចិត្តគ្រាដំបូង របស់ព្រះកម្មដ្ឋាន ដែលលោកដល់ឈានហើយនោះ មហគ្គតជវនចិត្ត និង អភិញ្ញាជវនចិត្ត រមែងកើតមួយដងជានិច្ច ពីនោះតមកកើតជាភវង្គចិត្ត ។ ព្រះអរិយបុគ្គលមានចិត្តក្ខណៈ ១ដង ជានិច្ច តពីនេះទៅផលចិត្ត ២ ឬ ៣ ដងរមែងកើតតាម ពីនោះតមក កកើតជាភវង្គចិត្ត ។

ព្រះអនាគាមិ ឬ ព្រះអរហន្ត ចូលនិរោធសមាបត្តិ នោះនេវសញ្ញានាសញ្ញាយតន កុសលចិត្ត ឬ កិរិយាចិត្ត រមែងកើត ២ ដង ហើយចិត្ត និង ចេតសិក រមែងរលត់ចុះ មួយរំពេច ។

កាលចេញពីនិរោធ សមាបត្តិនោះ រមែងកើតជា អនាគាមិផលចិត្ត ឬ អរហត្តផលចិត្ត ហើយដល់ភវង្គចិត្ត តែក្នុងខណៈដែលផលសមាបត្តិ វិថីកើតនោះ មិនបានសំដែងថាមានចំនួនវិថីប៉ុន្មាន ព្រោះធម្មតាវិថីក្នុងខណៈនោះ រមែងកើតដូចក្រសែទឹកដូច្នេះ ។

---

## គាថាសង្គហៈ

**សត្តក្ខត្តុំ បរិត្តានិ មគ្គាភិញ្ញា សកិំ មតា អវសេសានិ លព្ភន្តិ ជវនានិ ពហូនិបិ ។**

**ប្រែ** សេចក្តីថា កាមាជវនចិត្ត រមែងកើត ៧ដង មគ្គចិត្ត និង អភិញ្ញាជវន រមែង និង កើតបាន ១ដង សល់ពីនោះ

បានជវ័ន ច្រើនដង ។

**អយមេត្ថ ជវននិយមោ** នេះឯងគឺវត្ថុដែលគួរចាំ ជវ័ននិយាម ( នេះឯងគឺ វត្ថុជវ័ននិយាមដែលគួរចាំ )

## ពាក្យសួរ-ឆ្លើយតទាលម្ពណ និង ជវន

**សួរ** ក្នុងតទាលម្ពណនិយាមនេះ ពាក្យថាឥដ្ឋារម្មណ៍ អនិដ្ឋារម្មណ៍ និង អតិឥដ្ឋារម្មណ៍ ប្រែថាអ្វី ? ហើយបានដល់អ្វី ?

**ឆ្លើយ** ពាក្យ ឥដ្ឋារម្មណ៍ តាមវិគ្គហថា :

**ឥច្ឆិតព្វន្តិ ឥដ្ឋំ ប្រែ**

អារម្មណ៍ដែលល្អ ហៅថាឥដ្ឋារម្មណ៍

**អធិកំ ឥដ្ឋន្តិ អតិឥដ្ឋំ ប្រែ**

អារម្មណ៍ដែលប្រណិត ហៅថា អតិឥដ្ឋារម្មណ៍

**ន + ឥដ្ឋ => អនិដ្ឋ ប្រែ**

មិនមានអារម្មណ៍ដែលត្រូវការ ឬ អារម្មណ៍ដែលមិនត្រូវការ ហៅថាអនិដ្ឋារម្មណ៍ ។ អារម្មណ៍ទាំង ៣នេះ បានដល់អកុសលវិបាក កុសលវិបាកទាំងអស់គឺ :

- អកុសលវិបាក ទាក់ទងមកពីការប៉ះទង្គិច អនិដ្ឋារម្មណ៍ ។
- កុសលវិបាកទាក់ទងមកពីការប៉ះទង្គិច ឥដ្ឋារម្មណ៍ ។

តែបែបទាំងពីរនេះ ជាទុក្ខវេទនា សុខវេទនា ឧបេក្ខាវេទនាទាំងអស់ ។

ចំណែកអតិឥដ្ឋារម្មណ៍នោះ ជាសោមនស្សវេទនាតែម្តង ។

**សួរ** តាមពាក្យឆ្លើយដែលពោលមកហើយ ពាក្យថា អនិដ្ឋារម្មណ៍ កើតព្រោះអកុសលវិបាក ។

- ឥដ្ឋារម្មណ៍ កើតព្រោះកុសលវិបាក ។

- អតិឥដ្ឋារម្មណ៍ ក៏ជាកុសលវិបាកដូចគ្នា នេះប្រពៃហើយ តែវេទនាដែលប្រកបជាមួយនោះ ដូចម្ដេចឥដ្ឋារម្មណ៍ទើបប្រកប និង ឧបេក្ខាវេទនាបាន ព្រោះធម្មតាឥដ្ឋារម្មណ៍កាលណាប៉ះទង្គិច ភ្នែក ត្រចៀក ច្រមុះ អណ្ដាតនោះ រមែងត្រេកអរជានិច្ច កាលត្រេកអរហើយដូច្នេះ នឹងរាប់ថាជាសោមនស្សវេទនាបានឬទេ ?

**ឆ្លើយ** តាមព្រះបាលីផ្សេង១ថា ក្នុងអហេតុកចិត្ត រមែងមានតែអារម្មណ៍បីគឺ :

-ឥដ្ឋារម្មណ៍

-អតិឥដ្ឋារម្មណ៍

-អនិដ្ឋារម្មណ៍ ប៉ុណ្ណោះ ។

ក្នុងទីនេះ កាលអនិដ្ឋារម្មណ៍ ប៉ះទង្គិច ភ្នែក ត្រចៀក ច្រមុះ អណ្ដាត មិនខ្លាំងក្លា ដូចការប៉ះទង្គិចកាយកាលឃើញហើយ ឮហើយ មានក្លិនហើយ ដឹងរសជាតិហើយ មិនចូលចិត្ត មិនពេញចិត្ត ។

កាលមិនចូលចិត្ត មិនពេញចិត្ត ហើយចិត្តក៏ព្រងើយ ១ទៅ វត្ថុនេះហៅថា ឧបេក្ខាវេទនា ។

កាលណាប៉ះទង្គិចរាងកាយ រមែងជាទុក្ខវេទនា ព្រោះការប៉ះទង្គិចខ្លាំង១ និងទ្វារដទៃ១ ។

កាលណាឥដ្ឋារម្មណ៍ប៉ះទង្គិចភ្នែក ច្រមុះ អណ្តាត ក៏ទំនងនេះឯង គឺ មិនខ្លាំងក្លា ដូចប៉ះទង្គិចកាយ ។ មានន័យថា សេចក្តីសុខតិចបំផុត ឬ មិនល្មមនិងចិត្តត្រូវការហៅថា ឥដ្ឋមជ្ឈត្តារម្មណ៍ ព្រោះហេតុដូច្នោះ ឧបេក្ខាវេទនា គឺ មានសេចក្តីព្រងើយ ឬ ត្រេកអរ មិនល្មមនឹង ចិត្តបើប៉ះទង្គិចរាងកាយហើយជាសុខ វេទនាពិត ។

កាលអតិឥដ្ឋារម្មណ៍ គឺ អារម្មណ៍ ដែលប្រណីតប៉ះទង្គិចភ្នែក ច្រមុះ អណ្តាត ព្រោះអារម្មណ៍ដែលទទួលប៉ះ-ទង្គិចជាទីពេញចិត្តច្រើនបំផុត ទើបមានបីតិ ឡើងបាន កាលបើបានទទួលអារម្មណ៍ យ៉ាងនេះហៅថា សោមនស្ស-វេទនា ។ ប៉ុន្តែ សោមនស្សវេទនាគ្មានប្រាកដក្នុងសន្តីរណ-

ចិត្ត ។

( មេត្តាមើលភាពវិថីចិត្តដែលសំដែងមកហើយពីខាងដើម លោកនឹងឃើញមួយរំពេចថា :

កាលមានចិត្តវិញ្ញាណហើយ ក៏មានសម្បដិច្ឆន្នៈ និង សន្តីរណៈផងដែរ ។ សន្តីរណៈនេះប្រក្រតី ជាឧបេក្ខាតែក្នុង អតិឥដ្ឋារម្មណ៍នេះ ក៏ជាសោមនស្សសន្តីរណៈដោយត្រង់ ។

**សួរ** ក្នុងតទាលម្ពណនិយមនេះ ពាក្យថាតទារម្មណ៍ ប្រែថាអ្វី ? ហើយបានដល់អ្វីខ្លះ ?

**ឆ្លើយ** ពាក្យថាតទារម្មណ៍ តាមដីកាលង្កាទីបថា :

**តតំ ជវនគហិតារម្មណស្ស អារម្មណភ-រណំ តទាលម្ពណំ កិច្ចំ**

**ប្រែ** ការកើតនៃអារម្មណ៍ ៧ដួង ( គ្រា ) ដែលជវន ទទួលមកពីលំដាប់វិថីរបស់ចិត្ត ហៅថា តទាលម្ពណកិច្ច ។ មានសេចក្ដីថា អារម្មណ៍ណាដែលជវន ៧ដួងទទួលមកអំពី ក្រសែនៃចិត្ត ជាវិថីនោះឯង ដែលតទាលម្ពណៈទទួលយក

ជាអារម្មណ៍តទៅ តាមវិគ្គហថា :

**តស្ស អារម្មណំ តទាលម្ពណំ**

**ប្រែ** អារម្មណ៍នេះ បានដល់តទាលម្ពណចិត្ត ១១ដួង គឺ សន្តីរណៈ ៣ដួង នៃអហេតុកចិត្ត និង មហាវិបាកចិត្ត ៨ដួង រួម ១១ដួង ។

ក្នុងទីនេះ ពិចារណាស័ព្ទតាមវេយ្យាករណ៍ នោះជាឈ្មោះតទាលម្ពណៈ តែអាលម្ពណស័ព្ទ១ យកចេញតាមសមាសន័យ ។

( មេត្តាមើល បកិណ្ណសង្គហៈ ក្នុងកិច្ចសង្គហនេះផង )

**សួរ** ក្នុងវិថីបរិច្ឆេទថា តទាលម្ពណៈមានចំនួន ១១ដួង គឺ សន្តីរណ ៣ដួង និង មហាវិបាក ៨ដួង ។

ក្នុងទីនេះខាងក្រោយដែលកុសល ឬ កិរិយាជវនរលត់ចុះហើយ សន្តីរណៈទាំង ៣នេះ ជាធម្មជាតិអហេតុទៅហើយ តើជាតទាលម្ពណៈបានយ៉ាងណា ?

**ឆ្លើយ** តាមដែលព្រះអនុរុទ្ធាចារ្យ ពោលទុកក្នុងអារម្មណ៍សង្គហៈថា ឧបេក្ខាសន្តីរណៈ ២ដួង មាន ៥កិច្ច គឺ :

បដិសន្ធិ ភវង្គ ចុតិ តទាលម្ពណៈ និង សន្តីរណៈ ។

ចំណែកសន្តីរណៈ ២ដួង មាន២កិច្ច គឺ សន្តីរណកិច្ច ១ តទាលម្ពណកិច្ច ១ ។ មានន័យថា សន្តីរណពមាន សន្តីរណកិច្ច និងតទាលម្ពណកិច្ច ជាប្រចាំនៅជានិច្ច គឺ ខាងក្រោយដែលចិត្តជាសម្បដិច្ឆន្នៈ ( សម្បដិច្ឆន្នចិត្ត ) រលត់ចុះហើយ ជាតួនាទីរបស់សន្តីរណៈ ៣ដួង តាមឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។

វត្តនេះហៅថា សន្តីរណកិច្ច ខាងក្រោយដែលជវនរលត់ចុះ ហើយជួនកាល សន្តីរណៈក៏រមែងកើតទៀត វត្តនេះសន្តីរណៈធ្វើតួនាទី តទាលម្ពណកិច្ច ព្រោះសន្តីរណៈទាំង ៣ដួង អាចនឹងទទួលធ្វើតួនាទី ក្នុងកាមភូមិ និងរូបភូមិបាន ឬ ជួនកាលធ្វើសន្តីរណកិច្ចបាន ជួនកាលក៏ធ្វើតទាលម្ពណបាន ។

( មេត្តាមើលបុគ្គលភេទ ក្នុងបរិច្ឆេទនេះផង )

ក្នុងតទាលម្ពណចិត្ត ១១ ដួង :

- សន្តីរណៈទាំង ៣ សោយសេចក្តី ( អារម្មណ៍ ) ច្រើនជាង ។

- មហាវិបាក ៨ដួង តាមវិថីវិមុត្តិសង្គហថា :

មហាវិបាកានិ បន អដ្ឋសព្វត្ថាបិ កាមសុគតិយំ បដិសន្ធិ ភវង្គចុតិវសេន បវត្តន្តិ ប្រែ

មហាវិបាក ៨ដួងសាធារណៈបានតែកាមសុគតិភូមិ ដោយបដិសន្ធិ ភវង្គ ចុតិ មានន័យថា មហាវិបាកមានចំនួន ក្នុងកាមសុគតិ ៧ភូមិប៉ុណ្ណោះ ។ ចំណែកអហេតុកវិបាក នេះ លោកពោលថា អហេតុកវិបាកានិ បន អដ្ឋបិ សព្វត្ថាបិ កាមលោកេ ច រូបលោកេ ច យថារហំ វិបច្ចន្តិ

ប្រែ អហេតុកវិបាកចិត្ត មានចំនួនក្នុងកាមភូមិ និង រូបភូមិទាំងពីរកន្លែង ដូច្នេះ សន្តីរណៈ ៣ដួង ប្រើបានច្រើនជាង មហាវិបាកដោយពិតប្រាកដ កាលដែលសន្តីរណៈកើត

ជាតទាលម្ពណ ឬមហាវិបាកកើតជាតទាលម្ពណៈនោះ ហើយ ជាអារម្មណ៍របស់ ជវនគឺ

- បើជវនទទួលអារម្មណ៍ជាអនិដ្ឋារម្មណ៍ ត្រូវកើតជាអកុសលវិបាក សន្តីរណកើតជាតទាលម្ពណ ។

- បើអតិឥដ្ឋារម្មណ៍នោះ សោមនស្សសន្តីរណ ទទួលតួនាទី តទារម្មណ៍ទៅដូច្នេះ ។

**សួរ** តាមដែលលោកអធិប្បាយមកនេះថា : សេចក្តី (អារម្មណ៍) ជាតទាលម្ពណៈ ហើយជាអារម្មណ៍ជវន ។

ក្នុងទីនេះ ជវនមាន៥៥ដួង ។ ក្នុង ៥៥ដួងនេះ អកុសលជវនដូចជា ទោមនស្សក៏នៅមាន កាលបើបុគ្គលណាកើតទោមនស្សហើយនោះ តទាលម្ពណកើតយ៉ាងណា? ព្រោះទោមនស្ស សន្តីរណំ មិនឃើញមានក្នុងបិដក ទាំង៣ឡើយ ?

**ឆ្លើយ** ធម្មតាចិត្តជាតទាលម្ពណៈ រមែងមានតែ ១១ដួង ក្នុង ១១ដួងនេះ ទោមនស្សសន្តីរណចិត្ត មិនមានទេ ប៉ុន្តែ

ទោះបីយ៉ាងនេះក៏ល្អ ព្រោះខាងក្រោយទោមនស្សជវនរលត់ហើយ ។

ក្នុងអតិមហន្តារម្មណ៍ និង វិភូតារម្មណ៍វិថីនោះត្រូវមានតទាលម្ពណៈជានិច្ច ។ តទាលម្ពណៈនោះអាស្រ័យអារម្មណ៍ចាស់ ៗ ហើយឧបេក្ខាសន្តីរណចិត្តទើបកើតឡើងដល់ភវង្គចិត្ត ។

តាមអភិធម្មត្ថសង្គហថា :

តទាយំ កិញ្ចិ បរិចិត្តបុព្វំ បរិត្តារម្មណមារព្ភ ឧបេក្ខាសហគតសន្តីរណំ ឧប្បជ្ជតិ ។

អាស្រ័យកាមារម្មណ៍ចាស់ ដែលធ្លាប់ជាឧបនិស្ស័យមកហើយ និង ជាឧបេក្ខាសន្តីរណចិត្ត ក៏រមែងកើត ព្រោះហេតុដូច្នោះ ខាងក្រោយដែលទោមនស្សជវនកើត ឧបេក្ខាសន្តីរណៈ ត្រូវតទារម្មណ៍ ទៅរហូតដល់ភវង្គចិត្ត ។

**សួរ** លក្ខណកន្លែង អង្គរបស់តទារម្មណ៍នោះបានដល់អ្វីខ្លះ ?

**ឆ្លើយ** លក្ខណៈតទាលម្ពណៈ ឬ អង្គ កន្លែងការកើតរបស់តទាលម្ពណៈនោះមាន ៣យ៉ាងគឺ :

១- កាមបុគ្គល

២- កាមជវន

៣- អារម្មណ៍របស់ អតិមហន្តារម្មណ៍ ឬ វិភូតារម្មណ៍

រួម៣ប្រការ ។

**មានសេចក្ដីថា** ការដែលកើតតទាលម្ពណៈនោះ ព្រោះអង្គទាំង ៣ ដែលបរិយាយមកហើយ ប្រជុំរួមគ្នា ។ ( មេត្តាមើលសង្គហគាថា តទាលម្ពណៈនិយម ក្នុងបរិច្ឆេទនេះផង ) ។

**សួរ** តាមអភិធម្មត្ថសង្គហថា :

**អសីតិ វិថីចិត្តានិ កាមេ រូបេ យថារហំ ចតុសដ្ឋី**

**ប្រែ** កាមភូមិមានវិថីចិត្ត ៨០ដួង រូបភូមិ មានវិថីចិត្ត

៦៤ដួង រមែងកើតហើយ ដូចម្តេចថាសត្វជាព្រហ្មនេះ រមែងមិនកើតតទាលម្ពណៈ ព្រោះព្រហ្មមានសន្ធិរណដែរ ?

**ឆ្លើយ** តាមធម្មតាតទាលម្ពណ ទាក់ទងពីជវន ធម្មតាជវន អាស្រ័យជាតិរបស់ចិត្តជាបដិសន្ធិគឺ បដិសន្ធិចិត្ត កាមជវន ក៏ត្រូវជាកាម បើបដិសន្ធិចិត្តជាជាតិ រូបាវចរជវនក៏ត្រូវជា រូបាវចរៈ ជាចិត្តនិយមជានិច្ចទៅ ។

ក្នុងទីនេះ ជាតិជាតទាលម្ពណៈ ជាជាតិកាមពិតគឺ អកុសលវិបាកសន្តិរណៈ ធ្វើឱ្យកើតនៅអបាយទាំង ៥ ។

កុសលវិបាកសន្តីរណ ធ្វើឱ្យកើតនៅកាមសុគតិ បដិសន្ធិមហាវិបាក ៨ដួង ក៏ដូចគ្នាដែរ រមែងកើតក្នុង កាមបុគ្គល ។

ចំណែករូបព្រហ្មនោះ ជាតួនាទីរបស់រូបវិបាក ដោយ ឡែក ព្រោះហេតុដូច្នោះ រមែងមិនកើតតទាលម្ពណៈ ឡើយ កាលដែលសន្តីរណចិត្ត រមែងមានវិថីចិត្តរបស់រូប ព្រហ្មនោះ ដើម្បីជាសន្តីរណកិច្ច មិនមែនដើម្បីជា

តទាលម្ពណៈទេ មានន័យថា ព្រហ្មមានសន្តីរណៈ ដើម្បីចក្ខុទ្វារវិថី គឺ ទ្វារវិថីដោយត្រង់ មិនមែនកើតដើម្បីតទាលម្ពណៈទេ ។

**សួរ** កាមាវចររមែងកើតជាជវន ដល់កាមជវនវិថីយ៉ាងណាខ្លះ ?

**ឆ្លើយ** តាមធម្មតាកាមាវចរជវនរមែងកើត៧ដង( ៧ត្រា) សន្លប់កើត ៦ដង បើជិតនឹងស្លាប់ក៏៥ដង ។

កាលសន្លប់ ឬ ប្រាសចាកសតិនោះ រមែងកើត ៥ ដងជានិច្ច ។ មេត្តាមើលក្នុងជវននិយាមថា :

**មរណកាលាទិសុ បញ្ចវារមេវ**

តាមដីកាលង្កាបរិយាយថា :

មរណកាលាទិសុតិ អាទិសទ្ទេន មុញ្ឆាកាលំ សង្គណ្ហាតិ ប្រែថា : ជាអាទិនៃ មរណកាលាទិសុ ក្នុងអភិធម្មតាថាសង្គហត្រូវរាប់កាលវេលាសន្លប់ផងដែរ ។

**សួរ** ក្នុងអប្បនាវិថី រមែងកើតជាជវនយ៉ាងណាខ្លះ ?

**ឆ្លើយ** អប្បនាវិថី មានពីរយ៉ាងគឺ :

១- មហគ្គតអប្បនា

២- លោកុត្តរអប្បនា

- មហគ្គតអប្បនានោះ ជវនកើត១គ្រាហើយដល់ភវង្គ ។

- លោកុត្តរអប្បនានោះ ខាងក្រោយដែលមគ្គជវនកើត១គ្រាហើយ ចិត្តទៅជាភវង្គ ។

**សួរ** និរោធសមាបត្តិវិថីនោះ ចូលនិរោធយ៉ាងណា ? ហើយការចេញពីនិរោធនោះ មានវិថីចិត្តយ៉ាងណាខ្លះ ?

**ឆ្លើយ** និរោធសមាបត្តិ តាមស័ព្ទ ថា :

និរុជ្ឈនំ និរោធោ សមាបជ្ជនំ សមាបត្តិ និរោធស្ស សមាបត្តិ និរោធសមាបត្តិ

**ប្រែថា** សេចក្តីរលត់របស់ចិត្ត និង ចេតសិក ហៅថានិរោធ ។ ក្នុងខណៈដែលមាននិរោធយ៉ាងខ្លាំងនេះ ចិត្តជរូបរមែងមិនកើតដែរ ។ ការចូលឬការដែលចុះ ធ្វើសេចក្តី

ព្យាយាមដើម្បីវិថីរលត់ហៅថា សមាបត្តិ ។ ព្រះអនាគាមិ ឬ ព្រះអរហន្ត បុគ្គលណាមួយ និង ចូលនិរោធសមាបត្តិ នោះ គ្រាដំបូងត្រូវពិចារណានេវសញ្ញានាសញ្ញាតតនឈាន ខាងក្រោយដែលនេវសញ្ញានាសញ្ញាយតនជវន រលត់ចុះ ហើយ រមែងដល់និរោធសមាបត្តិមួយរំពេច ។

ការដែលចូលនិរោធសមាបត្តិយ៉ាងនេះ មានសេចក្តីថា ចិត្ត លែងធ្វើការ និង មិនឱ្យមានឱកាសរូបថ្មីនឹងកើតតទៅ ទៀតឡើយ ។ ការធ្វើដូចនេះ ព្រះអរិយបុគ្គលរមែង ប្រកាន់ថា មានសេចក្តីសុខស្រដៀង និង ព្រះនិព្វាន ១គ្រា ប៉ុន្តែជីវិតនេះមានកំណត់ ប្រមាណត្រឹម ៧ថ្ងៃប៉ុណ្ណោះ ។ កាលចេញពីនិរោធសមាបត្តិ អនាគាមិផលចិត្ត ឬ អរហត្ត ផលចិត្ត រមែងកើតមុនហើយ ទើបជាភវង្គចិត្ត (ទើប ភវង្គចិត្តកើត) ។

ក្នុងសម័យពុទ្ធកាល ព្រះមហាកស្សប និង ព្រះសារិ បុត្តព្រះអង្គចូលចិត្ត ចូលនិរោធជានិច្ច ក្នុងខណៈដែលចូល

ចិត្ត ក្នុងខណៈដែលចូលសមាបត្តិនេះ មិនមានវិថីចិត្តកើតទេ ព្រោះចិត្ត និង ចេតសិករលត់ទៅឯង ។

## សំដែងបុគ្គលភេទតាមបាលី

ទុហេតុកានមហេតុកានញ្ច បនេត្ថ កិរិយាជវននានិ ចេវ អប្បនាជវនានិ ច ន លព្ភន្តិ តថា ញាណសម្បយុត្តានិ ច មហាវិបាកានិ ន លព្ភន្តិ ។

តិហេតុកេសុ ច ខីណាសវានំ កុសលាកុសលជវនានិ ច ន លព្ភន្តិ ។ តថា សេក្ខបុថុជ្ជនានំ កិរិយាជវនានិ ។ ទិដ្ឋិគតសម្បយុត្តវិចិកិច្ឆាជវនានិ ច សេក្ខានំ ។ អនាគាមិបុគ្គលានំ បន បដិឃជវនានិ ច ន លព្ភន្តិ ។

## លោកុត្តរជវនានិ ច យថារហំ អរិយានមេវ សមុប្បជ្ជន្តីតិ ។

ក្នុងវិថីសង្គហៈនេះ ក្នុងសន្តានរបស់ទុហេតុកបុគ្គល និង អហេតុកបុគ្គល រមែងមិនបានទទួល កិរិយាជវន និង អប្បនាជវន ។ ក្រៅពីនេះជាញាណសម្បយុត្ត មហាវិបាក-ចិត្តទាំងនេះ ក៏រមែងមិនបានទទួលទុគ្គតិភូមិដែរ ។

ក្នុងតិហេតុកបុគ្គលទាំង ៩នោះ ក្នុងសន្តានរបស់ព្រះអរហន្តបុគ្គល ជវននៃកុសល និង អកុសល រមែងមិនកើតឡើយ ។

ក្នុងសន្តានរបស់សេក្ខបុគ្គល និង បុថុជ្ជន រមែងមិនបានទទួលកិរិយាជវន និង ជវនរបស់ទិដ្ឋិគតសម្បយុត្ត វិចិកិច្ឆារមែងមិនមានក្នុងសន្តានរបស់សេក្ខបុគ្គល ។

ក្នុងសន្តានរបស់អនាមិ និង ព្រះអរហន្ត រមែងមិនបានទទួលទោសជវន ចំពោះលោកុត្តរជវនទាំងអស់នេះ រមែងកើតក្នុងសន្តានរបស់ព្រះអរិយបុគ្គលជានិច្ច ។

# អធិប្បាយក្នុងបុគ្គលភេទ

ក្នុងបុគ្គល១២ចំពូកនេះ អហេតុកបុគ្គល គឺ អ្នកដែលមានបដិសន្ធិ ។ ហេតុទាំងពីរ និង សត្វក្នុងអបាយទាំង៤ បុគ្គល២ចំពូកនេះ មិនបានទទួលកិរិយាជវន និង អប្បនាជវន ព្រោះជវនទាំងពីរយ៉ាងគឺ :

១-ជវនរបស់អ្នកដែលជាព្រះអរហន្ត

២-ជវនរបស់អ្នកដែលដល់ឈានទាំងអស់ ។

ក្នុងសុគតិបុគ្គល គឺបុគ្គលដែលកើតមកមិនគ្រប់អង្គ ដូចជាទេវតាជំពូកខ្លះ និង មនុស្សជំពូកខ្លះ រមែងមិនបានទទួលវិបាករបស់ញាណសម្បយុត្តជវន ព្រោះញាណសម្បយុត្តជវននោះ ជាចិត្តរបស់ត្រៃហេតុកបុគ្គល ដោយធម្មនិយាម ។

ក្នុងទុគ្គតិបុគ្គល គឺ សត្វក្នុងអបាយទាំង ៤ រមែងមិនបានទទួលចិត្តជាញាណវិប្បយុត្ត វិបាកចិត្ត ព្រោះញាណវិប្បយុត្តវិបាកចិត្តនេះជាបដិសន្ធិរបស់ទុហេតុកបុគ្គល

ក្នុងត្រៃហេតុក ៩ ជំពូកនេះ ព្រះអរហន្ត រមែងមិនបានទទួលកុសលជវ័ន និង អកុសលជវ័នទាំងពីរព្រោះ អកុសល និង កុសលនោះជាចិត្តរបស់បុថុជ្ជន ។

សេក្ខបុគ្គល និង បុថុជ្ជន រមែងមិនបានទទួលជវ័ន-កិរិយាព្រោះ ជវ័នកិរិយាជាកិរិយារបស់ព្រះអរហន្ត ដោយត្រង់និង សេក្ខបុគ្គល រមែងមិនបានទទួលទិដ្ឋិគតសម្បយុត្ត និង វិចិកិច្ឆា ព្រោះពីរយ៉ាងនេះជាចិត្តរបស់ បុថុជ្ជនដែលមានអត្តទិដ្ឋិជានិច្ច ។

ព្រះអនាគាមិបុគ្គល ទ្រង់ប្រហារទោសៈ ដាច់ខាតហើយរមែងមិនបានទទួល បដិឃជវ័ន និង អរិយបុគ្គលទាំងអស់ រមែងមានលោកុត្តរជវ័នជានិច្ច ។

## គាថាសង្គហ

**អសេក្ខានំ ចតុចត្តាឡីស សេក្ខានមុទ្ទិសេ
ឆប្បញ្ញាសាវសេសានំ ចតុប្បញ្ញា សម្ភវា ។**

ប្រែ វិថីចិត្តរបស់ ព្រះអរហន្តលោកសំដែងថាមាន ៤៤ ដួង

វិថីចិត្តរបស់សេក្ខបុគ្គល លោកសំដែងថាមាន ៥៦ ដួង

និង វិថីចិត្តរបស់បុថុជ្ជន លោកសំដែងថា មាន ៥៤ដួង

ដូចនេះ អយមេត្ថ បុគ្គលភេទោ

ប្រែថា នេះឯងជាប្រភេទនៃបុគ្គល ។

## សំដែងភូមិវិភាគតាមបាលី

កាមាវចរភូមិយំ បនេតានិ សព្វានិបិ វិថីចិត្តានិ យថារហមុបលព្ភន្តិ រូបាវចរភូមិយំ បដិឃជវនតទាលម្ពណវិជ្ជិតានិ ។ អរូបាវចរភូមិយំ បឋមមគ្គរូបាវចរហសនហេតុដ្ឋិមារូប្បា

**វិថិចិត្តានិ ច លព្ភន្តិ ។**

**សព្វត្ថាបិ ច តំ តំ បសាទរហិតានំ តំ តំ ទ្វារិកវិថីចិត្តានិ ន លព្ភន្តេវ ។**

**អសញ្ញសត្តានំ បន សព្វត្ថាបិ ចិត្តប្បវត្តិ នត្ថេវាតិ ។**

- ក្នុងកាមាវចរភូមិ ១១ដូងនេះ រមែងបានទទួលវិថិចិត្តទាំងអស់ ។

- ក្នុងរូបព្រហ្ម ១៤ភូមិ ( វៀរលែង អសញ្ញិសត្ត) នោះមិនមាន បដិឃជវន ២ ដួង និងតទាលម្ពណ ៨ដួង ។

- ក្នុងអរូបាវចរ ៤ភូមិ វៀរលែងបឋមមគ្គ ១ដួង រូបាវចរជវនចិត្ត ១០ដួង ហសិតុប្បាទ ១ដួង ជាខាងក្រោយរបស់អរូបាវចរចិត្ត ហើយរមែងបានទទួលវិថីចិត្តទាំងអស់ ។

ភូមិទាំងអស់ដែលប្រាកដ បសាទរូបណាមួយហើយ រមែងមិនបានទទួលវិថីចិត្តនោះ ប៉ុន្តែក្នុងអសញ្ញិសត្តភូមិ

រមែងមិនមានចិត្តឡើយ ។

## អធិប្បាយភូមិវិភាគ

ក្នុងចិត្ត ៨៩ដួង វៀរលែងមហគ្គតចិត្ត ៩ដួងចេញ គឺជាវិថីចិត្តទាំងអស់រមែងមាន ៨០ដួង ។ វិថីចិត្តទាំងនេះរមែងកើតក្នុងកាមបុគ្គល ក្នុងកាមភូមិ ១១ភូមិជានិច្ច ។

ក្នុងរូបព្រហ្ម ១៦ភូមិ វៀរលែង អសញ្ញិសត្ត-ព្រហ្មចេញ គឺជាព្រហ្ម ១៥ភូមិ ។ ក្នុងរូបព្រហ្មនេះ រមែងកើតវិថីចិត្ត ៦៤ដួង គឺ វិថីចិត្ត ៨០ដួង វៀរទោសមូល ២ដួង ឃានវិញ្ញាណ ២ដួង ជីវ្ហាវិញ្ញាណ ២ដួង កាយវិញ្ញាណ ២ដួង និង មហាវិបាកចិត្ត ៨ដួង រួម ១៦ដួងគង់សល់ ៦៤(=៨០-១៦)=៦៤ដួង

ក្នុងអរូបព្រហ្ម ៤ភូមិ រមែងកើតវិថីចិត្ត ៤២ដួងគឺក្នុងវិថីចិត្ត ៦៤ដួងរបស់រូបព្រហ្មនោះ វៀរលែងសោតា-បត្តិមគ្គចិត្ត ១ដួង រូបាវចរកុសល និង រូបាវចរកិរិយាចិត្ត

១០ ដួង ហសិតុប្បាទ១ដួង បញ្ចទ្វារាវជ្ជនៈ ១ដួង ចក្ខុវិញ្ញាណ ២ដួង សោតវិញ្ញាណ ២ដួង សម្បដិច្ឆន្នៈ ២ដួង សន្តីរណៈ ៣ ដួង រួម ២២ដួង គង់នៅសល់ ៤២ដួង ។

ខ. សំខាន់ ភូមិណាមួយប្រាសចាក បសាទរូបណាមួយហើយវិថីចិត្តដែលទាក់ទង នឹងបសាទរូបនោះ រមែងមិនកើតវិថីចិត្តឡើយ ។

ក្នុងអសញ្ញិសត្តព្រហ្ម រមែងមិនមានវិថីចិត្តកើត ព្រោះ អសញ្ញិសត្តព្រហ្ម ជាសត្វដែលកើតមកដោយរូបសុទ្ធសឹងតែរកនាមគ្មាន ។

---

## គាថាសង្គហ

**អសីតិ វិថីចិត្តានិ កាមេ រូបេ យថា រហំ**

**ចតុសដ្ឋី តថា រូបេ ទ្វេចត្តាឡីស លព្ភរេ**

**ប្រែសេចក្តីថា**

-ក្នុងកាមភូមិ រមែងមានវិថីចិត្តកើតមាន ៨០ដួង

-ក្នុងរូបភូមិ រមែងមានវិថីចិត្តកើត មាន ៦៤ដួង

-ក្នុងអរូបភូមិ រមែងមានវិថីចិត្ត កើតមាន ៤២ដួង

**អយមេត្ថ ភូមិវិភាគោ**

**ប្រែ** នេះឯងក្នុង វិថីចិត្ត បរិច្ឆេទនេះហៅថា ភូមិវិភាគ គឺ បែងចែកជាវិថីចិត្ត តាមភូមិ ។

**ឥច្ចេវំ ឆទ្វារិកចិត្តប្បវត្តិ យថា សម្ភវំ ភវង្គន្តរិតា យាវ តាយុកមព្ភោច្ឆិន្នា បវត្តន្តិ ។**

សេចក្តីបរិយាយដែលសំដែងមកហើយនោះ គឺ ការប្រាកដរបស់ចិត្ត ក្នុងទ្វារទាំង ៦ រមែងកើតរហូតជីវិត ដោយមិនដាច់ក្រសែ ព្រោះភវង្គចិត្ត រមែងកើតរឿយៗតទៅ ឬកើតបន្តមិនទំនេរឡើយ ។

**ឥតិ អភិធម្មត្ថសង្គហេ វិថីសង្គហេ វិថីសង្គហវិភាគោ នាម ចតុត្ថោ បរិច្ឆេទោ**

នេះឯងក្នុងគម្ពីរអភិធម្មត្ថសង្គហ មាននាមថា វិថី

សង្គហៈ គឺបែងចែកចិត្តជាវិថី ក្នុងបរិច្ឆេទទី ៤ ចប់តែប៉ុណ្ណោះ ។

---

## ពាក្យសួរ-ឆ្លើយបុគ្គលភេទនិងភូមិភាគ

**សួរ** ពាក្យថាបុគ្គលភេទប្រែថាអ្វី ? ហើយមានបុគ្គលប៉ុន្មានជំពូកជាមួយគ្នា ?

**ឆ្លើយ** ពាក្យថាបុគ្គលភេទ មានន័យថា សំដែងប្រភេទនៃបុគ្គលផ្សេងៗគឺ ទុហេតុកបុគ្គល ត្រៃហេតុកបុគ្គលជាដើម បានដល់បុគ្គល ២ចំពូក ឬ ១២បុគ្គល គឺ

១-បុថុជ្ជន

២-អរិយបុគ្គល

រួម ២ចំពូក ។

បុថុជ្ជន នៅមាន ៤ បុគ្គលគឺ.១ ទុគ្គតិហេតុកបុគ្គល ២ សុគតិហេតុកបុគ្គល ៣ ទុហេតុកបុគ្គល ៤ ត្រៃហេតុកបុគ្គល ។

៥ ចំណែកព្រះអរិយ ៨ពួកគឺ :

១ **ព្រះសោតាបត្តិមគ្គបុគ្គល**

២ **ព្រះសកទាគាមិមគ្គបុគ្គល**

៣ **ព្រះអនាគាមិមគ្គបុគ្គល**

៤ **ព្រះអរហត្តមគ្គបុគ្គល**

៥ **ព្រះសោតាបត្តិផលបុគ្គល**

៦ **ព្រះសកទាគាមិផលបុគ្គល**

៧ **ព្រះអនាគាមិផលបុគ្គល**

៨ **ព្រះអរហត្តផលបុគ្គល**

រួម ៨ ពួកនេះហៅថា ព្រះអរិយបុគ្គល

រួមទាំងអស់គឺ បុថុជ្ជន ៤ + ព្រះអរិយ ៨ ហៅថា បុគ្គល ។ ( ១២ពួក )

**សួរ** តាមដែលព្រះអនុរុទ្ធាចារ្យ សំដែងចិត្តបរមត្ថ ៨៩ ដួង ឬ ១២១ដួងបើប្រកបដោយបុគ្គល ១២ និង ចំណែកចូលគ្នាហើយ តើបុគ្គលណាមានចិត្តប៉ុន្មានប្រាកដ ?

**ឆ្លើយ** ចិត្ត ៨៩ដួង ឬ ១២១ដួង មានន័យថាចិត្តរបស់បុគ្គល១២ពួកដែលបានបរិយាយមកហើយ ។ ព្រះបរមសាស្តាទ្រង់រួបរួមចិត្តនៃបុគ្គលទាំងអស់ ក្នុង ៣១ភូមិ ហើយទ្រង់សំដែងកំពូលបញ្ជី ឬ រួមបញ្ជីថា មានចំនួន ៨៩ ដួង ១២១ដួង ប៉ុណ្ណោះ ។

គ្មានច្រើនជាង ឬ តិចជាងចំនួននេះទេ ។ ប៉ុន្តែចំណែកចែកតាមចិត្តនៃបុគ្គលដូចតទៅនេះ គឺ :

- ទុគ្គតិហេតុកបុគ្គល សាធារណដល់ចិត្ត ៣៧ដួង គឺ អកុសលចិត្ត ១២ដួង អហេតុកចិត្ត ១៧ដួង ( វៀរលេងហសិតុប្បាទ ១ដួង ) មហាកុសល ៨ដួង រួម ៣៧ដួង ។

- សុគតិហេតុកបុគ្គល សាធារណៈដល់ចិត្ត៤១ដួង គឺ អកុសលចិត្ត ១២ដួង អហេតុកចិត្ត ១៧ដួង មហាកុសលចិត្ត៨ដួង មហាវិបាកវិប្បយុត្ត ៤ដួង រួម ៤១ដួង ។

- ទុហេតុកបុគ្គល មានប្រហែល សុគតិហេតុកបុគ្គលដែរ ។

- ត្រៃហេតុកបុគ្គល សាធារណៈដល់ចិត្ត ៤៥ដួងគឺ : អកុសលចិត្ត ១២ដួង អហេតុកចិត្ត ១៧ដួង មហាកុសល-ចិត្ត ៨ដួង មហាវិបាក ៨ដួង រួម ៤៥ដួង ។

សំរាប់មនុស្សដល់ឈាន គឺឈានលាភីបុគ្គល រមែងមានមហគ្គតកុសល ៩ដួងទៀត ។ ព្រោះហេតុដូច្នោះ ត្រៃហេតុកបុគ្គល ត្រូវញែកចែកជាពីរយ៉ាងគឺ :

១-អ្នកប្រាសចាកឈាន

២-អ្នកដល់ឈាន

អ្នកប្រាសចាកឈាន សាធារណៈដល់ចិត្ត ៤៥ដួង ដូចដែលពោលមកហើយ ។

សំរាប់អ្នកដល់ឈាន បូកចូល និង មហគ្គតកុសល-ចិត្ត ៩ដួង រួម ៥៤ដួង ។

ក្នុងព្រះអរិយបុគ្គល ៨ពួកនេះ :

- ព្រះសោតាបន្នបុគ្គល កំណត់ចិត្ត ៤១ដួង គឺ

អកុសល ចិត្ត ៧ដួង (វៀរលែង ទិដ្ឋិគតសម្បយុត្ត ៤ដួង វិចិកិច្ឆា១ ដួង ) អហេតុកចិត្ត ១៧ដួង មហាកុសលចិត្ត ៨ដួង មហាវិបាក ៨ដួង សោតាបត្តិផលចិត្ត ១ ដួង រួម ៤១ដួង បើដល់ឈានយកមហគ្គតកុសល ៩ដួង បូកជាចំនួន ៥០ ដួង ។

- ព្រះសកទាគាមិបុគ្គល ក៏ដូចគ្នានិងព្រះសោតាបត្តិបុគ្គលគឺ ៤១ ដួង ឬ ៥០ដួង ។

- ព្រះអនាគាមិបុគ្គល កំណត់ចិត្ត ៣៩ដួង ក្នុងចំនួនចិត្តដែលព្រះសោតា ព្រះសកទាគាមិ បាននោះ ដកចិត្តជាទោសមូល ២ ដួងចេញ បើដល់ឈានក៏កំណត់បាន ៤៨ ដួង ។

- ព្រះអរហន្តបុគ្គលកំណត់ចិត្ត ៣៥ដួងគឺ អហេតុកចិត្ត ១៨ដួង មហាវិបាកចិត្ត ៨ដួង មហាកិរិយាចិត្ត ៨ដួង អរហត្តផលចិត្ត ១ ដួង រួម ៣៥ដួង ។

បើបានដល់ឈានត្រូវរួម មហគ្គតកុសល ៩ដួង ចូលជាមួយត្រូវជា ៤៤ដួង ។

**សួរ** តាមបាលីអភិធម្មត្ថសង្គហ ថា :

ទុហេតុកានមហេតុកានញ្ច បនេត្ថ កិរិយាជវនា ចេវ អប្បនា ជវនានិ ច ន លព្ភន្តិ

ទុហេតុកបុគ្គល និង អហេតុកបុគ្គល ទាំងពីរ រមែង មិនមានកិរិយាជវនចិត្ត និង អប្បនាជវនចិត្ត ។ ក្តីនេះ តើដោយហេតុអ្វី ទើបបុគ្គលទាំងនេះ មិនទទួលជវនចិត្ត ទាំងពីរ ?

**ឆ្លើយ** ក្នុងបុគ្គល ១២ជំពូកនោះ នៅមានបុគ្គល ៣ជំពូក ដែលប្រាសចាកឈាន ឬ លោកុត្តរ ឬ ទុគ្គតិបុគ្គល ១ សុគតិបុគ្គល ១ ទុហេតុកបុគ្គល ១ សូម្បីមានសេចក្តី ព្យាយាមក្នុងសមថ និង វិបស្សនា យ៉ាងណាក៏ដោយ មិន អាចនឹងដល់ឈាន ឬ លោកុត្តរក្នុងជាតិនេះបាន ។

កិរិយាជវនចិត្ត ជាចិត្តរបស់ព្រះអរហន្តដោយត្រង់ ។

អប្បនាជវនចិត្ត ក៏ជាអប្បនាវិថីចិត្ត ក្នុងខណៈដែលឈានលាភីបុគ្គល និង អរិយបុគ្គលដែលដល់ឈាន នឹងដែលដល់អរិយមគ្គ អរិយផល ។

(មេត្តាមើល ភាពអប្បនាវិថីចិត្ត ដែលសំដែងមកហើយពីខាងដើម )

ព្រោះហេតុដូច្នេះ កិរិយាជវនចិត្ត និង អប្បនាជវនចិត្តទាំងពីរ ទើបរមែងមិនកើតក្នុងសន្តាន របស់បុគ្គលទាំង ៣ ឡើយ ។

ក្នុងអន្តរាយិកៈ ទាំង៥នេះ ហៅថាវិបាកអន្តរាយិកៈ គឺ ជាវិបាកម្យ៉ាងដែលជាអន្តរាយចំពោះឈាន ឬ អរិយមគ្គ-ផល មានសេចក្តីថា : អ្នកដែលបដិសន្ធិមកដោយទុគ្គតិបដិសន្ធិ សុគតិបដិសន្ធិ ទុហេតុកបដិសន្ធិហើយ អ្នកនោះរមែងមិនមាន សង្ឃឹមថានឹងដល់ឈាន ឬ ដល់លោកុត្តរ ក្នុងជាតិនេះឡើយ ។

ដូច្នេះ ទើបហៅថាអន្តរាយម្យ៉ាងរបស់ឈាន ឬ

មគ្គ-ផល បាន ។

**សួរថា ញាណសម្បយុត្តវិបាកានិ ច សុគតិយំ**

ក្នុងសុគតិភូមិនោះ ញាណសម្បយុត្តវិបាកចិត្តរមែង មិនកើត និង ទុគ្គតិយំ បន ញាណវិប្បយុត្តានិ ច មហាវិបាកានិ ន លព្ភន្តិ ។

- ទុគ្គតិភូមិ រមែងមិនមានចិត្តជាមហាវិបាក (មហាវិបាកចិត្ត) មានសេចក្តីយ៉ាងណា ?

ឆ្លើយ សុគតិ និង ទុគ្គតិបុគ្គលទាំងពីររមែងមិនបានទទួល មហាវិបាកចិត្ត ៨ ដូចនោះគឺ :

ធម្មជាតិ ទុគ្គតិ បដិសន្ធិ ដោយចិត្តជាអហេតុកៈមាន សេចក្តីថា មិនមានហេតុ គឺ : អលោភ អទោស អមោហ មកពីកំណើត ហើយសុគតិបុគ្គលក៏ដូចគ្នា គឺ ធម្មជាតិដែល ប្រាសចាក អលោភ អទោស អមោហ និង បញ្ញាមកពី បដិសន្ធិ ។

មហាវិបាកចិត្ត ជាបដិសន្ធិ ទុហេតុកបុគ្គល និង ត្រៃហេតុកបុគ្គល ដូច្នេះ ទុគ្គតិបុគ្គល រមែងមិនបានទទួលមហាវិបាកចិត្ត ។ សុគតិបុគ្គលរមែងមិនបានទទួលញាណ-សម្បយុត្តមហាវិបាកឡើយ ។

**សួរ** ពាក្យថា តិហេតុកេសុ ច ខីណាសវានំ ថា : ត្រៃហេតុក ៩នាក់នោះ បានដល់បុគ្គលអ្វីខ្លះ ? ហើយដូចម្ដេចខីណាសវបុគ្គល ទើបមិនបានទទួលកុសល និង អកុសលជវនទាំងពីរទៀត ?

**ឆ្លើយ** តាមពាក្យប្រែ របស់តិហេតុកេសុថា : ត្រៃហេតុក-បុគ្គល ៩នាក់នោះ គឺ ត្រៃហេតុក បុថុជ្ជន ១ និង អ្នកដែលបានសំរេច លោកុត្តរ ៨នាក់ រួម ៩នាក់នេះហៅថា ត្រៃហេតុកបុគ្គល ៩នាក់ ។

ក្នុងការដែលព្រះអរហន្ត មិនបានទទួលជវនកុសល ឬ អកុសលព្រោះអរហត្តផល បានទំលាយកុសល ឬ អកុសលទាំងពីរអស់រលីងហើយ ។ ក្នុងសន្តានរបស់ព្រះ

អរហន្ត ទើបមិនកើតកុសល និង អកុសលទៀត តែជាកិរិយាចិត្ត គង់មាននៅប្រចាំព្រោះកុសលចិត្តបានក្លាយទៅជាកិរិយាចិត្តដោយធម្មជាតិ ។

( មេត្តាមើល បាលីតទា សេក្ខបុថុជ្ជនានំ កិរិយាជវនានិផង )

**សួរ** តាមគាថាសង្គហ : **អសេក្ខានំ ចតុចត្តាឡីស សេក្ខានមុទ្ទិសេ ឆបញ្ញាសាវសេសានំ ចតុបញ្ញាស សម្ភវា**

**ប្រែថា** ព្រះអរហន្ត កំណត់ចិត្ត ៤៤ដួង
សេក្ខបុគ្គល កំណត់ចិត្ត ៥៦ដួង
បុគ្គលដទៃៗ កំណត់ចិត្ត ៥៤ដួង

ចិត្តទាំងនេះ បានដល់ចិត្តអ្វីខ្លះ ? សុំសំដែងសរុបផង ? ។

**ឆ្លើយ** ព្រះអរហន្តកំណត់ចិត្ត ៤៤ដួង គឺ :

អហេតុកចិត្ត ១៨ដួង មហាវិបាកចិត្ត ៨ដួង មហាកិរិយាចិត្ត ៨ដួង មហគ្គតកិរិយាចិត្ត ៩ដួង អរហត្ត-ផលចិត្ត ១ដួង

រួម ៤៤ដួង នេះកំណត់ចិត្តតាមបាលី អសេក្ខានំ ចតុចត្តាឡីស ។

- សេក្ខបុគ្គលកំណត់ចិត្ត ៥៦ដួង គឺ

អកុសលចិត្ត ៧ដួង អហេតុកចិត្ត ១៧ ដួង មហា-កុសលចិត្ត ៨ដួង មហាវិបាកចិត្ត ៨ដួង មហគ្គតកុសលចិត្ត ៩ដួង លោកុត្តរចិត្ត ៧ដួង រួម ៥៦ដួង ។

ពាក្យថា សេក្ខបុគ្គល និង អសេក្ខបុគ្គលនោះ គឺ :

- អសេក្ខបុគ្គល បានដល់ អរហត្តបុគ្គល

- សេក្ខបុគ្គលបានដល់ ព្រះអរិយបុគ្គល ៧ពួក (វៀរលែង ព្រះអរហន្ត ) មានចិត្ត ៥៦ដួង ដែលពោលមកហើយ កំណត់តាមបាលីថា : សេក្ខានមុទ្ទិសេ ឆ បញ្ញាស ចំណែកបុថុជ្ជន ៤នាក់កំណត់បានចិត្ត ៥៤ដួង គឺ : អកុសល

ចិត្ត ១២ដួង អហេតុកចិត្ត ១៧ដួង មហាកុសលចិត្ត ៨ដួង មហាវិបាក ៨ដួង មហគ្គតកុសល ៩ដួង រួម ៥៤ដួងនេះ កំណត់តាមបាលីថា : អវសេសានំ ចតុបញ្ញាស សម្ភវា ។

**ស្នួរ** ក្នុងភូមិវិភាគថា វិថីចិត្ត ៨០ដួង ក្នុងកាមភូមិនោះ បានដល់ចិត្តអ្វីខ្លះ ?

**ឆ្លើយ** ក្នុងចំនួនចិត្ត បរមត្ថ ៨៩ដួងនោះ យកចិត្ត មហគ្គតវិបាកចិត្ត ៩ដួងចេញ នៅសល់ ៨០ដួង ហៅថាវិថីចិត្ត ៨០ ដួងដោយត្រង់គឺ ជាកាមភូមិដោយត្រង់ ។

( មេត្តាមើល គាថាសង្គហថា : អសីតិ វិថីចិត្តានិ កាមេផង ចុះ )

**ស្នួរ** ក្នុងរូបាវចរព្រហ្មមានវិថីចិត្តប៉ុន្មាន ? ហើយក្នុង អរូបព្រហ្មមានវិថីចិត្តប៉ុន្មាន ?

**ឆ្លើយ** ក្នុងរូបាវចរ ព្រហ្ម ១៥ភូមិ ( វៀរលែងអសញ្ញិសត្ត ) មានវិថីចិត្ត ៦៤ដួងគឺ ក្នុងចិត្ត ៨០ដួង ដែលពោល មកហើយយកចិត្ត ១៦ដួងចេញ គឺ ឃានវិញ្ញាណ ២ ជិវ្ហា

វិញ្ញាណ ២ កាយវិញ្ញាណ ២ បដិឃ ២ដួង មហាវិបាកចិត្ត ៨ដួង ។ ចិត្តដែលនៅសល់៦៤ ដួងនោះជាវិថីចិត្តរបស់ រូប-ព្រហ្ម ១៥ភូមិ ( មេត្តាមើលគាថាសង្គហៈថា រូបេ យថារហំ ចតុសដ្ឋី ផង )

ក្នុងអរូបព្រហ្មនេះ មានវិថីចិត្ត ៤២ដួង គឺ :

ក្នុងចំនួនវិថីចិត្តរបស់ព្រហ្ម ៦៤ដួងនោះ យកចិត្ត ២២ដួង ចេញគឺ សោតាបត្តិមគ្គចិត្ត ១ រូបាវចរចិត្ត ១០ដួង ចិត្តហសិតុប្បាទ ១ ចក្ខុវិញ្ញាណ ២ សោតវិញ្ញាណ ២ បញ្ចទ្វារាវជ្ជន ១ សម្បដិច្ឆន្ន ២ សន្តីរណ ៣ រួម ២២ដួង សល់ ៤២ដួង ជាវិថីចិត្តរបស់អរូបព្រហ្ម ( មេត្តាមើលគាថា សង្គហ តថា រូបេ ទ្វេចត្តាឡីស លព្ភរេ ផង )

**ស្នូរ** តាមអភិធម្មត្ថសង្គហថា : វិថីចិត្តរបស់កាមភូមិ និង រូបភូមិ ៨០ដួង នោះចូលចិត្តហើយ ព្រោះកាមបុគ្គល រូបបុគ្គល រមែងមានរូប និង នាម ឬ ក្នុងពាក់កណ្តាល អារម្មណ៍ទាំង ៦ ។

ចំណែកអរូបព្រហ្មនេះ គ្មានអារម្មណ៍ ឬ រូបដែលមកបដិសន្ធិទេ តាមធម្មតាវិថីចិត្តនេះ កើតមកហើយព្រោះវត្ថុ និង អារម្មណ៍ប៉ះទង្គិចគ្នា ។

ដូច្នេះ នៅក្នុងអរូបព្រហ្មនោះ កើតវិថីចិត្តបានយ៉ាងណា ?

**ឆ្លើយ** នៅក្នុងអរូបព្រហ្មនេះមិនមានរូបក៏ពិតមែន តែធម្មតានាមធម៌ ក៏អាចនឹងទទួលអារម្មណ៍បាន អារម្មណ៍នោះគឺ ជាធម្មារម្មណ៍ សូមមើលវិថីមនោទ្វារ ( មនោទ្វារវិថី ) ថា វិភូតារម្មណ៍ និង អវិភូតារម្មណ៍ និង នៅក្នុងចំនួនបុគ្គលដែលអាស្រ័យនៅក្នុង អរូបព្រហ្មនេះមាន ៨ពួក ( ៨នាក់ ) ជាមួយគ្នាគឺ :

ត្រៃហេតុកបុថុជ្ជន ១ ព្រះសកទាគាមិមគ្គបុគ្គល១ ព្រះអនាគាមិមគ្គបុគ្គល ១ ព្រះអរហត្តមគ្គបុគ្គល ១ និង ផលដ្ឋបុគ្គល ៤ ( ព្រះសោតាបត្តិ ព្រះសកទាគាមិ ព្រះអនាគាមិ ព្រះអរហត្តផល ) រួម ៨ ដួង ។

កាលព្រះសោតាបត្តិបុគ្គល និង ឡើងកាន់លោកុត្តរៈតទៅត្រូវមានវិថីចិត្ត កើតធម្មតា វិថីចិត្តដែលកើតនោះដូចនេះឯង ។

វិថីចិត្តរបស់ព្រះសោតាបត្តិបុគ្គល កាលខណៈដែលនឹងឡើងសកទាគាមិ




ចំណែកព្រះសកទាគាមិ និង ព្រះអនាគាមិ និង ព្រះអនាគាមិ ក៏ទំនងជាមួយគ្នា កាលជិតចុតិ ត្រូវមានមរណាសន្នវិថីកើតទៀត ព្រោះហេតុដូច្នេះ អរូបព្រហ្មទោះបីមិនមានរូបក៏ដោយ ត្រូវមានវិថីចិត្តកើត បាលី តថា រូបេ ទ្វេចត្តាឡីស លព្ភរេ ។

**សួរ** ធម្មជាតិ អសញ្ញិសត្តព្រហ្ម ជាសត្វមួយជំពូក ដែលរមែងកើតមកដោយរូប សូម្បីតែនាម១ដួង ក៏គ្មានដែរ

វិថីចិត្តនោះជាលំដាប់ សភាពរបស់ចិត្ត ព្រោះហេតុដូច្នោះ ក្នុងអសញ្ញិសត្តព្រហ្ម ទើបមិនមានវិថីចិត្តកើត តាំងពីបដិសន្ធិរហូតដល់ចុតិ មានតែជីវិត នវកកលាបៈប៉ុណ្ណោះ

មានសេចក្តីថា : កើតមកដោយរូប តាំងនៅដោយរូប ស្លាប់ក៏ដោយរូប មិនមាននាមទេ ហេតុនេះការរាប់វិថីចិត្ត ទើបត្រូវវៀរចេញ អសញ្ញិសត្តព្រហ្មចេញ ។

**ចប់បរិច្ឆេទទី ៤**

# បរិច្ឆេទទី ៥ វិថីមុត្តកសង្គហ

## សំដែងគាថាខាងដើម

**វិថីចិត្តវសេនេវំ បវត្តិយមុទីរិតោ បវត្តិសង្គ-ហោ នាម សន្ធិយំ ទានិ វុច្ចតិ**

ដោយន័យដែលបានបរិយាយមកហើយ យើងបានសំដែងវិថីសង្គហចប់ តទៅនឹងសំដែង វិថីមុត្តសង្គហគឺសំដែងបដិសន្ធិ និង បវត្តិទាំងពីរបន្តទៅទៀត ។

## សំដែងភូមិចតុក្ក តាមបាលី

**ចតស្សោ ភូមិយោ ចតុព្វិធា បដិសន្ធិ ចត្តារិ កម្មានិ ចតុធា មរណុប្បត្តិ ចេតិ វិថិមុត្តសង្គហេ ចត្តារិ ចតុក្កានិ វេទិតព្វានិ ឲ តត្ថ អបាយភូមិ កាមសុគតិភូមិ រូបាវចរភូមិ**

អបាយចតុភូមិ ចេតិ ចតស្សោ ភូមិយោ នាម ។
តាសុ និរយោ តិរច្ឆានយោនិ បេតវិសយោ
នាម ។
តាសុ និរយោ តិរច្ឆានយោនិ បេត្តិវិសយោ
អសុរកាយោ ចេតិ អបាយភូមិ ចតុព្វិធា
ហោតិ ។
មនុស្សា ចតុមហារាជិកា តាវតឹសា យាមា
តុសិតា និម្មានរតី បរនិម្មិតវសវត្តី ចេតិ
កាមសុគតិភូមិ សត្តវិធា ហោតិ ។
សា បនាយមេកាទសវិធាបិ កាមាវចរ
ភូមិច្ចេវ សង្ខយំ គច្ឆតិ ។
ព្រហ្មបារិសជ្ជា ព្រហ្មបុរោហិតា
មហាព្រហ្មា ចេតិ បឋមជ្ឈានភូមិ បរិត្តាភុតា
អប្បមាណាភា អាភស្សរា ចេតិ ទុតិយជ្ឈានភូមិ
បរិត្តាសុភា អប្បមាណាសុភា សុភកិណ្ហាចេតិ

តតិយជ្ឈានវេហប្ផលា អសញ្ញិសត្តា សុទ្ធាវា-
សា ចេតិ ចតុត្ថជ្ឈាន ភូមតិ រូបាវចរភូមិ
សោឡសវិធា ហោតិ ។ អវិហា អតប្បា
សុទស្សា សុទស្សី អកនិដ្ឋា ចេតិ សុទ្ធាវាស-
ភូមិ បញ្ចវិធា ហោតិ ។

អាកាសានញ្ចាយតនភូមិ នេវសញ្ញានា-
សញ្ញាយតនភូមិ ចេតិ អរូបភូមិ ចតុព្វិធា
ហោតិ ។

ប្រែ ក្នុងវិថីមុត្តសង្គហ នៅមានចតុក្ក ៤ ចតុក្ក

១ ភូមិចតុក្ក ២ បដិសន្ធិចតុក្ក ៣ កម្មចតុក្ក

៤ មរណចតុក្ក រួម ៤ចតុក្ក ។

ក្នុង ៤ ចតុក្កនេះ មានអបាយភូមិ ៤ភូមិ គឺ

១ នរក ២ តិរច្ឆាន ៣ ប្រេត

៤ អសុរកាយ រួម ៤ភូមិ ។

មានកាមសុគតិភូមិ ៧ ភូមិ គឺ :

១ មនុស្ស ២ ចាតុមហារាជិកា ៣ តាវតឹសា

៤ យាមា ៥ តុសិតា ៦ និម្មានរតី

៧ បរនិម្មិតវសវត្តី រួម ៧ភូមិ ។

ភូមិទាំង ១១ភូមិ ដែលពោលមកហើយនេះ រមែងរាប់ចូលក្នុងកាមាវចរភូមិទាំងអស់ ។

❋ ១-ព្រហ្មបារិសជ្ជាភូមិ ២-ព្រហ្មបុរោហិតាភូមិ ៣-មហាព្រហ្មាភូមិ ទាំង៣ភូមិនេះជាបឋមឈាន ។

❋ ១-បរិត្តាភាភូមិ ២-អប្បមាណាភាភូមិ ៣-អាភស្សរាភូមិ ទាំង ៣ភូមិនេះជា ទុតិយជ្ឈាន ។

❋ ១-បរិត្តសុភាភូមិ ២-អប្បមាណសុភាភូមិ ៣-សុភកិណ្ហភូមិ ទាំង ៣ភូមិនេះជាតតិយជ្ឈាន

❋ ១-វេហប្ផលាភូមិ ២-អសញ្ញិសត្តាភូមិ និង ៣-សុទ្ធាវាសទាំង ៥ ភូមិ រួម ៧ភូមិ ជាចតុត្ថជ្ឈានភូមិ ។

❋ សុទ្ធាវាសទាំង ៥ ( ឬ បញ្ចសុទ្ធាវាស ) នោះគឺ

១-អវិហា ២-អតប្បា ៣-សុទស្សា ៤-សុទស្សី ៥-អកនិដ្ឋា រួម ៥ភូមិ

❊ អរូបភូមិទាំង ៤ភូមិគឺ :

១-អាកាសានញ្ចាយតនភូមិ ២-វិញ្ញាណញ្ចាយ-តនភូមិ ៣- អាកិញ្ចញ្ញាយតនភូមិ ៤-នេវសញ្ញានា-សញ្ញាយតនភូមិ រួម ៤ ភូមិ ។

## អធិប្បាយ ៣១ ភូមិដោយលំដាប់

- តាមបាលីថា : អបាយភូមិ ពាក្យថាអបាយញែកជា ២បទ

អប + អយ

អប ប្រែថា ប្រាសចាក

អយ ប្រែថា កុសល ឬ សេចក្ដីសុខ

មានសេចក្ដីថា : ប្រាសចាកសេចក្ដីសុខ

- ពាក្យថាភូមិ បានដល់ទីកន្លែងដែលសត្វកើត ឬ ជួនកាលក៏ប្រែថា ជាឋានដែលធម្មជាតិ រមែងប្រាកដហៅថាភូមិ ។ ស័ព្ទបន្ថែមមកអំពី ភវន្តិ ប្រែថាកើត ព្រោះហេតុដូច្នោះ ត្រូវប្រែពាក្យថា អបាយភូមិថា ជាទីកើតនៃសត្វដែលមិនមានសេចក្ដីសុខ បានដល់អបាយទាំង ៤ ភូមិ គឺ : ១- នរក ២-តិរច្ឆាន ៣-ប្រេត ៤-អសុរកាយ រួម ៤ភូមិ ។

- ពាក្យថានរក មកពី និរយ ញែកចេញជា ២បទ គឺ

  និរ: + អយ

  និរ: ប្រែថា មិនមាន

  អយ: ប្រែថា សេចក្ដីសុខ

**មានន័យថា** មិនមានសេចក្ដីសុខ បានដល់នរក ៨ជាន់គឺ ១-សញ្ជីវ: ២-កាឡសុត្ត: ៣-សំឃាត: ៤-រោរុវ: ៥-មហារោរុវ: ៦-តាបន: ៧-មហាតាបន: ៨-អវីចិ រួមរណ្ដៅ នរក ៨ រណ្ដៅ ។

- ពាក្យថាតិរច្ឆាន ញែកចេញបាន ២បទគឺ :

តិរ + អច្ឆាន

តិរៈ ប្រែថា ទទឹង

អច្ឆានៈ ប្រែថា ដើរ

**មានន័យថា** សត្វកាលដែលដើរនោះ គឺ : ដើរទទឹង ឬ ការដើរដោយផ្តោះមុខទៅកាន់ខាងក្រោម បានដល់សត្វតិរច្ឆាន ផ្សេងៗដែលឃើញ សព្វថ្ងៃ តែក្នុងទីនេះតាមបាលី តិរច្ឆានយោនិ

- ពាក្យថា យោនិ ប្រែថា កាយ គឺ កាយរបស់តិរច្ឆាន ហៅថា យោនិ ។ យោនិនោះឯង ហៅថា ភូមិ

- ពាក្យថា បេត ញែកបានជា ២ បទ

បៈ + ឥត

បៈ ប្រែថា ឆ្ងាយ

ឥតៈ ប្រែថារមែងកើត ឬ បានដល់

មានសេចក្តីថា : សត្វរមែងដើរទៅឃ្លាតឆ្ងាយពីសុខក្នុង

បាលីថា :

បេតវិសយ ប្រែថា បេតវិស័យ

វិសយៈ ឬ វិស័យនោះ បានដល់ទីកន្លែងនៅរបស់សត្វ ប្រេត កន្លែងដែលសត្វកើត ឬ ជាទីអាស្រ័យរបស់ពួកប្រេត ហៅថា ភូមិក៏បាន (តែពាក្យថា បេតៈ ជាមួយនិង ពាក្យ បេតិ មេត្តាមើលក្នុងពាក្យ ញែកសួរឆ្លើយផង ។

- ពាក្យថា អសុរកាយ ញែកបាន ៣បទគឺ :

អៈ + សុរៈ + កាយ

អៈ ប្រែថា មិន

សុរៈ ប្រែថា សេចក្តីសប្បាយ ឬ ក្លាហាន

កាយ ប្រែថា ពួក

មានសេចក្តី សត្វមួយជំពូកដែលមិនមាន សេចក្តីសប្បាយ ពួកនេះមិនបានពិចារណាមើលទៅ ប្រហាក់ប្រហែលជាមួយនិងពួកប្រេត ដូច្នេះ រាប់ចូលក្នុងពួក ប្រេតក៏បាន ។

រូមសត្វ ៤ ចំពួកដែល អធិប្បាយមកហើយ នេះហៅថា អបាយ និង ទីអាស្រ័យរបស់ សត្វនេះហៅថា ភូមិ ។

រូមពីរស័ព្ទនេះចូលគ្នាហើយ ហៅតាមស័ព្ទសមាស ថា អបាយភូមិ ឬ ភូមិរបស់សត្វអបាយ ។

**តាមបាលីថា កាមសុគតិភូមិ**

- ពាក្យថាកាម បានដល់សេចក្តីត្រូវការ ឬ សេចក្តីស្រឡាញ់ ស្នេហាក៏បាន ។
- ពាក្យថា សុគតិ ប្រែថា គតិដែលល្អ ឬ ស្អាតស្អំ
- ភូមិប្រែថាទីកើត ទីអាស្រ័យមានសេចក្តីថា ជាទីកន្លែងកើតរបស់សត្វមួយបែប ដែលទាក់ទងជាមួយសេចក្តីត្រូវការជានិច្ច បានដល់កាមសុគតិភូមិ ៧ ភូមិ គឺ ១ មនុស្ស ២ ចាតុម្មហារាជិកា ៣ តាវតឹសា ៤ យាមា ៥ តុសិតា ៦ និម្មានរតី ៧ បរនិម្មិតវសវត្តី រូម ៧ភូមិ ។

ពាក្យថាមនុស្ស ញែកបានជា ២បទ គឺ

មនោ + ឧសន្ន

មនោ ប្រែថា ចិត្ត . គំនិត

ឧសន្នៈ ប្រែថា ក្លាហាន

មានន័យថា សត្វមួយជំពូកដែលមានចិត្តគំនិតក្លាហាន ក្នុងផ្លូវសេចក្ដីល្អ និង សេចក្ដីអាក្រក់ ។

តែគម្ពីរខ្លះអធិប្បាយថា ជាកូនចៅរបស់មនុស្សតាបស ហៅថាមនុស្ស ។

- ពាក្យថា ចតុម្មហារាជិកា បានដល់ទីកន្លែងរបស់ស្ដេចមហារាជ ៤ អង្គ ( ពាក្យអធិប្បាយ និង ពាក្យប្រែនេះងាយហើយ ) ។

ជាថ្នាក់ទី ២ អំពីមនុស្ស តាំងនៅកណ្ដាលគេសីណេរុជាឋាន របស់ទេវតា ១ ជំពូក ដែលស្ដេចមហារាជ ៤ ព្រះអង្គជាអ្នកគ្រប់គ្រងនៅ តែសត្វដែលអាស្រ័យមហានេរុ ក៏មានច្រើនជំពូក សត្វទាំងអស់នេះ គឺ នាគ គ្រុឌ កុម្ភណ្ឌ និងយក្សជាដើម ។ ខ្លះក៏រាប់ចូលក្នុង ទេវតា ឬ តិរច្ឆាន តាម

តែកំណើតរបស់ខ្លួន ។

- ពាក្យថា តាវតឹសា នោះកើតមកអំពី ស័ព្ទថា :

  តេត្តឹស ប្រែថា ៣៣ គឺ តេ ប្រែថា ៣

  តឹស ប្រែថា ៣០

**មានសេចក្តីថា** ជាទីនៅរបស់ពួកទេវរាជា ៣៣ អង្គ ដែលមានព្រះឥន្ទ ជាប្រមុខ ។ ពួកទេវតាដែលកើតទីនេះ ហៅថាតាវត្តឹសទេវបុត្ត ។ តាវត្តឹសទេវលោកនេះ ត្រូវនៅលើភ្នំ សិនេរុ ឆ្ងាយពីមនុស្ស ៨៤០០០យោជន៍

- ពាក្យថាយាមា ជាព្រះនាមរបស់ស្តេចមហារាជ ១អង្គដែលជាអ្នកគ្រប់គ្រងភូមិនោះ គឺភូមិទី ៤អំពីមនុស្ស តាំងនៅលើអាកាស ពួកទេវតាហៅថា យាមាទេវតាមាន ព្រះសុយាមទេវរាជ ជាអ្នកគ្រប់គ្រង ។ ការហៅឈ្មោះ ភូមិនេះ អាស្រ័យព្រះនាមរបស់អ្នកគ្រប់គ្រង ហៅថា យាមាភូមិ ។

- ពាក្យថា តុសិតា ញែកចេញបាន ២ បទគឺ :

តុសៈ + ឥត

តុស ប្រែថា សេចក្តីសប្បាយពេញចិត្ត ឬ ត្រេកអរ

ឥតៈ ប្រែថា បានដល់

មានសេចក្តីថា ជំពូកទេវតា ដែលបានដល់ភាវៈដែលមានសេចក្តីចូលចិត្ត ជាភូមិទី ៥ ពីភូមិ មនុស្ស គឺ តាំងនៅលើអាកាស ដូចគ្នា និងភូមិយាមា ។

- ពាក្យថា និម្មានរតី ញែកចេញបាន ២បទគឺ :

និម្មានៈ + រតិ

និម្មានៈ ប្រែថា និម្មិត្ត

រតី ប្រែថា ភ្លើតភ្លើន

មានសេចក្តីថា ទេវតាមួយជំពូកដែលមានសេចក្តីភ្លើតភ្លើនក្នុងអារម្មណ៍ផ្សេងៗដែលខ្លួននិម្មិតបាន តាមអដ្ឋកថា វិភង្គ និង សង្គីតិសូត្រ អធិប្បាយថា ហ្វូងទេវតាដែលមិនមានកិរិយាប្រចាំ ពួកទេវតាទាំងនេះ ដូចមានសេចក្តីត្រូវការពេលណា និម្មិតតាមចូលចិត្តហើយ សេពកាមតាមចូលចិត្ត

តាមធម្មជាតិ ។

- ពាក្យថាបរនិម្មិតវសវត្តី ញែកចេញជា ៤ បទគឺ

បរៈ + និម្មិតៈ + វសៃ + វត្តី

| | | |
|---|---|---|
| បរៈ | ប្រែថា | អ្នកដទៃ |
| និម្មិតៈ | ប្រែថា | និម្មិត |
| វសៃ | ប្រែថា | សេចក្តីត្រូវការ |
| វត្តី | ប្រែថា | រមែងកើត |

មានសេចក្តីថា ទេវតាមួយជំពូកដែលមានសេចក្តីភ្លើតភ្លើន ក្នុងអារម្មណ៍ផ្សេងៗ ដែលទេវតាដទៃៗ និម្មិតទុកឱ្យ ។

ក្នុងទីនេះមានសេចក្តីថា ខ្លួនមិនបាននិម្មិតទេ ការត្រូវការរម្មណ៍ណាៗក៏ដោយ មានទេវតាចាំនិម្មិតឱ្យមានអ្នករក្សាតួនាទីនៅជិតជានិច្ច ។ កាលណាមានបំណងត្រូវការយ៉ាងណា វត្ថុណា ឬ អារម្មណ៍ណាក៏ដោយ ទេវតាដែលរក្សាតួនាទី ត្រូវនិម្មិតថ្វាយ ។ កាលពេញចិត្តក្នុងអារម្មណ៍នេះហើយ ការនិម្មិតត្រូវឈប់ និង ក៏សូន្យ

អន្តរាយភ្លាមទៅ ។

រួមភូមិ ៧ ភូមិនេះ + ជាមួយអបាយភូមិ ៤ភូមិ ហើយហៅថាកាមភូមិ ១១ ភូមិ ។ សត្វដែលអាស្រ័យនៅក្នុង ១១ភូមិ នេះហៅថា កាមបុគ្គលដូច្នេះ ។

- ក្នុងរូបព្រហ្ម ១៦ ភូមិនោះ ពាក្យថា ព្រហ្មបារិសជ្ជា ញែកចេញព្រហ្ម និង បរិសជ្ជា ប្រែថា សេចក្ដីបរិសុទ្ធរបស់ព្រហ្ម មានន័យថា ពួកបរិវាររបស់មហាព្រហ្ម ដែលជាប្រមុខ ឬ អ្នកគ្រប់គ្រងក៏បាន ។ ទីកន្លែងអាស្រ័យរបស់ព្រហ្ម ជំពូកនេះហៅថា ព្រហ្មបារិសជ្ជាភូមិ ។

- ពាក្យថាព្រហ្មបុរោហិតា ញែកចែកជា ២ បទ គឺ : ព្រហ្ម + បុរោហិត

ប្រែថា បុរោហិតរបស់លោកមហាព្រហ្ម ។ ពាក្យថាបុរោហិត ក៏មានន័យថា ជាអាមាត្យរបស់ព្រះរាជាដូច្នេះ ព្រហ្មបុរោហិត ប្រែថា ព្រហ្មមួយជំពូក ដែលមានតួនាទីជាអាមាត្យរបស់ស្ដេច មហាព្រហ្ម ដែលជាអ្នកគ្រប់-

ត្រង់ បឋមភូមិ ៣ជាន់ នេះ ( ៣ថ្នាក់ ) ។

- ពាក្យថា មហាព្រហ្មប្រែថា ជានាមធម៌ពិសេស របស់លោកព្រហ្មមួយអង្គដែលជាប្រមុខនៃបឋមភូមិ ៣ ក្នុងទីនេះពាក្យថាបឋមភូមិ ៣ បានដល់ស្រុក ៣ របស់ព្រហ្មជំពូកនេះដែលតាំងនៅថ្នាក់ជាមួយគ្នា មិនខ្ពស់ មិនទាបជាងគ្នាទេ គឺ ពួកអ្នកតូចនៅមួយកន្លែង ពួកអ្នកធំនៅមួយកន្លែង និង លោកអ្នកជាប្រមុខនៅកន្លែងមួយ រួម ៣ កន្លែង គឺ ស្រុក៣នោះ ហៅថាបឋមភូមិ ៣ ។

ក្នុងទុតិយភូមិទាំង ៣

- ពាក្យថា បរិត្តាភា ញែកចេញ ២ បទគឺ :

បរិត្ត + អាភា

បរិត្ត ប្រែថា តិច

អាភា ប្រែថា ពន្លឺភ្លឺ គឺ ស្មើ

មានន័យថា ព្រហ្មមួយជំពូកដែលមានពន្លឺភ្លឺ គឺរស្មីតិចជាងព្រហ្មទុតិយភូមិ បានដល់ព្រហ្មជំពូកទុតិយភូមិ ដំបូងដែល

ជាទីកន្លែង អាស្រ័យពួកព្រហ្មនេះ ហៅថា បរិត្តាភាភូមិ ។

- ពាក្យថាអប្បមាណាភា ញែកចេញជា ៣ បទ គឺ :

អៈ + បមាណៈ + អាភា

| | | |
|---|---|---|
| អៈ | ប្រែថា | មិនមាន |
| បមាណៈ | ប្រែថា | ប្រមាណ |
| អាភា | ប្រែថា | សេចក្តីភ្លឺ |

មានន័យថា : មានពន្លឺរស្មី ដោយប្រមាណមិនមានថា ដោយសង្ខេប១ បានសេចក្តីថា មានរស្មីច្រើនជាទីបំផុត ជាឈ្មោះរបស់ព្រហ្មមួយជំពូក ក្នុងទុតិយជ្ឈាន ភូមិទី ២ ជាទីកន្លែងអាស្រ័យព្រហ្មជំពូកនេះ ហៅថា អប្បមាណាភាភូមិ ។

- ពាក្យថា អាភស្សរា ញែកចេញបាន ២បទគឺ :

អាភា + សរា

| | | |
|---|---|---|
| អាភា | ប្រែថា | រស្មី |
| សរា | ប្រែថា | ចេញទៅជានិច្ច |

មានន័យថា- មានរស្មីចេញទៅគ្រប់កាល ជាឈ្មោះរបស់ព្រះរាជាក្នុងភូមិទាំង ៣ នៃទុតិយភូមិនោះឯង

ពាក្យថា ៖

បរិត្តាភា ជាទីនៅរបស់ព្រហ្មអ្នកតូច

អប្បមាណាភា ជាទីនៅរបស់ព្រហ្មថ្នាក់កណ្ដាល

អាភស្សរា ជាទីនៅរបស់មហារាជាព្រហ្ម ។

តែ ៣ ភូមិ ( កន្លែង ) នេះតាំងនៅជាមួយគ្នាជា ៣ កន្លែង ហៅថា ទុតិយភូមិ ។

ក្នុងតតិយជ្ឈានភូមិទាំង ៣

ពាក្យថាបរិត្តាសុភា ញែកចេញបាន ៣បទ គឺ

បរិត្តៈ + សុ + អាភា

| | | |
|---|---|---|
| បរិត្តៈ | ប្រែថា | យ៉ាងតិចជាទីបំផុត |
| សុ | ប្រែថា | ស្អាតស្អំ ល្អស្អាត |
| អាភា | ប្រែថា | រស្មី |

មានន័យថា- មានរស្មីដែលស្អាតល្អតែតិច ជាឈ្មោះ របស់

ព្រហ្មមួយជំពូក ក្នុងភូមិដំបូង របស់តតិយភូមិ ទាំង ៣ ទីកន្លែងអាស្រ័យរបស់ព្រហ្មជំពូកនេះ ហៅថា បរិតាសុភា-ភូមិ ។

- ពាក្យថា អប្បមាណាសុភា ញែកចេញបាន ៤ បទគឺ :

អ: + បមាណ + សុ + អាភា

| | | |
|---|---|---|
| អ: | ប្រែថា | មិនមាន |
| បមាណ: | ប្រែថា | ប្រមាណ |
| សុ | ប្រែថា | ស្អាតល្អ ស្អាតស្អំ |
| អាភា | ប្រែថា | រស្មី |

មានន័យថា- មានរស្មីស្អាតល្អដោយមិនប្រមាណ បានដល់ឈ្មោះព្រហ្មមួយជំពូកក្នុងតតិយជ្ឈានភូមិទាំង ៣ ទីកន្លែងអាស្រ័យព្រហ្មមួយជំពូកនេះ ហៅថា អប្បមាណាសុភាភូមិ ។

ពាក្យថា សុភកិណ្ណា ញែកចេញជាពីរបទគឺ :

សុភៈ + អាកិណ្ណ

សុភៈ ប្រែថា ស្អាត ល្អ

អាកិណ្ណ ប្រែថា លាយឡំគ្នា

ច្របូកច្របល់គ្នា ។

មានន័យថា- មានរស្មីដែលល្អស្អាតចេញលាយឡំគ្នានៅជានិច្ច បានដល់ព្រហ្មអ្នកជាមហាភាជ ក្នុងតតិយជ្ឈានភូមិ ទាំង ៣ ។

បរិត្តសុភា ជាទីនៅរបស់ព្រហ្មអ្នកតូច

អប្បមាណាសុភា ជាទីនៅរបស់ព្រហ្មថ្នាក់កណ្តាល

សុភកិណ្ណា ជាទីនៅរបស់ព្រហ្មអ្នកជាប្រមុខ ទាំង ៣ កន្លែងនេះជាថ្នាក់ជាមួយគ្នា ។

ក្នុងចតុត្ថជ្ឈាន ទាំង ២ គឺ :

- ពាក្យថា វេហប្ផលា ញែកចេញជា ២ បទគឺ :

វិ + ផលៈ

វិ ឬ វិបុល ប្រែថា ទូលំទូលាយ

ផលៈ ប្រែថា ផល

មានន័យថា មានផលទូលំទូលាយបរិបូណ៌ បានដល់ឈ្មោះព្រហ្មមួយជំពូក ដែលតាំងនៅក្នុង ចតុត្ថជ្ឈានភូមិ ទី ២ វេហប្ផលា ផ្លាស់មកពីស័ព្ទ វិបុល ។

- ពាក្យថា អសញ្ញីសត្ត ញែកចេញ ៣បទគឺ :

អៈ + សញ្ញី + សត្ត

អៈ ប្រែថា មិនមាន

សញ្ញី ប្រែថា នាមខន្ធដែលមានសញ្ញាជាប្រធាន

សត្ត ប្រែថា សត្ត

មានន័យថា- បានដល់ឈ្មោះរបស់ព្រហ្មមួយជំពូក ដែលមិនមាននាម ព្រហ្មជំពូកនេះ សូម្បីមិនមាននាមក៏ដោយ តែជាឈ្មោះមានពិត ៗ ។

ព្រហ្មពីរ ភូមិដែលអធិប្បាយមកនេះ តាំងនៅជាន់ជាមួយគ្នា ។

- ពាក្យសុទ្ធាវាស ញែកចេញជា ២បទគឺ :

សុទ្ធ: + អាវាស:

សុទ្ធ: ប្រែថា បរិសុទ្ធ

អាវាស: ប្រែថា ទីនៅ ទីអាស្រ័យ

មានន័យថា- ជាទីលំនៅរបស់អ្នកដែលបរិសុទ្ធ គឺ ព្រះអនាគាមិផល និង ព្រះអរហត្តផលបុគ្គល បានដល់សុទ្ធាវាស៥ ភូមិ ដូចនឹងពោលតទៅនេះ :

១-អវិហា កើតពីស័ព្ទ អវិជ្ជាហា ប្រែថា មិនចោល ឬ មានន័យថា ព្រហ្មមួយជំពូកដែលមិនព្រមចោល ភូមិរបស់ខ្លួនក្នុងកាលតិច១ ។

២-អតប្បា ប្រែថា មានការក្តៅក្រហាយ មានន័យថាព្រហ្មជំពូកនេះ មិនមានសេចក្តីក្តៅក្រហាយទាំងកាយទាំងវាចាចិត្តឡើយ ។

៣-សុទស្សា ប្រែថា ឃើញដោយល្អ ឬ ការឃើញដោយល្អក្រៃលែង មានន័យថា ព្រហ្មពួកនេះ មានសេចក្តីអង់អាចឃើញសភាវធមិបាន ដោយបញ្ញាញាណនៃចក្ខុ

ទាំងពីរ ។

៤-សុទស្សី ប្រែថា ឃើញបានច្រើនជាង សុទស្សា មានសេចក្ដីថា ព្រហ្មមួយជំពូកនេះ អាចឃើញសភាវធម៌ច្រើនៗក្នុងទីនេះ ពាក្យសុទស្សីនេះ អក្ខរ តិ សំដៅយកអតិសយៈ ប្រែថា ដ៏ច្រើនជាង ។

៥-អកនិដ្ឋា ញែកចេញជាពីរបទ គឺ :

អ: កនិដ្ឋា

អ: ប្រែថា ជាពាក្យបដិសេធ

កនិដ្ឋា ប្រែថា អ្នកតូច ឬ អ្នកទាបជាង

មានសេចក្ដីថា- ព្រហ្មជំពូកនេះជាព្រហ្មដែលបរិបូណ៌ដោយសេចក្ដីសុខ និង សេចក្ដីចេះដឹង ព្រោះជាព្រហ្មដែលជាព្រះអរហន្តទាំងអស់ ។

រួម ៥ ភូមិដែលពោលមកហើយនេះ ជាសុទ្ធាវាស-ភូមិសុទ្ធតែជាព្រះអរិយបុគ្គលទាំងអស់ ។

ក្នុងអរូបព្រហ្មទាំង ៤ គឺ :

១-អាកាសានញ្ចាយតនភូមិ ញែកបានពាបទគឺ

អាកាសៈ + អកិញ្ចៈ + អាយតនៈ ,

អាកាស ៤ភូមិនេះ បានសំដែងមកហើយ ក្នុងចិត្ត បរិច្ឆេទទី ១ យ៉ាងល្អិត តទៅនេះ និង សំដែងចំនួនភូមិ ប្រកប និង វិធីញែកស័ព្ទប៉ុណ្ណោះ ។

២-វិញ្ញាណញ្ចាយតនភូមិ ញែកចេញជាវិញ្ញាណ + អាណញ្ចៈ + អាយតន :

វិញ្ញាណៈ ប្រែថា វិញ្ញាណ

អាណញ្ចៈ ប្រែថា មិនញាប់ញ័រ

អាយតនៈ ប្រែថា ជាទីតាំង ឬ អណ្តូង

៣-អាកិញ្ចញ្ញាយតនៈ ញែកចេញជា ÷

អាកិញ្ចៈ + អាណញ្ចៈ + អាយតន

អាកិញ្ចៈ ប្រែថា បន្តិចបន្តួច

អាណញ្ចៈ ប្រែថា មិនញាប់ញ័រ

អាយតនៈ ប្រែថា ជាទីតាំង ឬ អណ្តូង

៤-នេវសញ្ញានាសញ្ញាយតន ញែកចេញ

នេវៈ + សញ្ញា + នៈ + នៈ + សញ្ញា + អាយតនៈ

នា សញ្ញា ប្រែថា សញ្ញាយ៉ាងល្អិតមិនមាន

នេវៈ ប្រែថា យ៉ាងល្អិត

រូបព្រហ្មទាំង ៤ ជំពូកនេះ រមែងកើតទៅតាមធម្ម-ជាតិ តែមិនដូចនិង អរូបាវចរព្រហ្ម ត្រឹមតែឈ្មោះថាភូមិ ពាក្យថាភូមិរបស់រូប ភូមិរបស់អរូប និង អាយតន ឬ មាន សេចក្តីជាមួយគ្នាគឺ អាយតនៈនោះឯង ហៅថា ភូមិបាន ។ ( មេត្តាមើលក្នុងពាក្យសួរ ឆ្លើយផង ) ។

## គាថាសង្គហ

បុថុជ្ជនា ន លព្ភន្តិ សុទ្ធាវាសេសុ

សព្វថា សោតាបន្នា ច សកទាគាមិនោ ចាបិ

**បុគ្គលា អរិយានោបលព្ភន្តិ អសញ្ញាបាយភូមិសុ សេសដ្ឋានេសុ លព្ភន្តិ អរិយានរិយាបិ ច ។**

**បុថុជ្ជនបុគ្គល ១ ព្រះសោតាបន្នបុគ្គល ១ ព្រះសកទាគាមិបុគ្គល ១**

រួម ៣ជំពូកនេះ មិន បានកើតក្នុងសុទ្ធាវាសឡើយ និង អរិយបុគ្គល ៨ ជំពូក ក៏មិនបានកើតក្នុង អសញ្ញីសត្ត និង អបាយភូមិ ដែលសល់ ២១ភូមិនោះ ជាទីកើតរបស់ អរិយបុគ្គល និង បុថុជ្ជនទាំងពីរបាន ។

ឥទមេត្ថ ភូមិចតុក្កំ ប្រែ ក្នុងបរិច្ឆេទទី ៥ នេះដែល ពោលមកហើយ ហៅថា ភូមិចតុក្ក ។

## ពាក្យសួរ-ឆ្លើយ ភូមិចតុក្ក

តាមបាលីក្នុងភូមិ បរិច្ឆេទថា :

ចត្តារិ ចតុក្កានិ ប្រែថានៅមាន ចតុក្កទាំង ៤ ចតុក្កៈ ក្នុងទីនេះ ចតុក្កៈប្រែថា ពួកធម៌ ៤ តាមភាសាបាលីថា :

ចតុក្កៈ បញ្ចកៈ ឆក្កៈ ៤ពួក ៥ ពួក ៦ពួក ដូចនេះជាដើម ។ មានន័យថា ពួកធម៌នេះសំដែង តែធម៌ ៤យ៉ាងគឺ មួយពួកមានធម៌ ៤ប៉ុណ្ណោះ បានដល់ភូមិចតុក្កៈ បដិសន្ធិចតុក្កៈ កម្មចតុក្កៈ និង មរណចតុក្កៈ ។

រួម ៤ ចតុក្កៈ ។

**សួរ** ពាក្យថាអបាយ ប្រែថា មិនមានសេចក្ដីសុខ ។

ពាក្យថា និរយៈ ក៏ ប្រែថាមិនមានសេចក្ដីសុខ ។ ប៉ុន្តែពាក្យថាអបាយៈនេះ ជាស័ព្ទដែលស៊ីជំរៅ នៃ សេចក្ដីច្រើន គឺ អបាយទាំង ៤ នេះ ។ ពួកតិរច្ឆានដែលមានសេចក្ដីសុខ ក៏មានពួកប្រេត ដែលមានសេចក្ដីសុខ ក៏មានដូចជា

- វេមានិកប្រេត ពួកនេះមានសេចក្ដីសុខប្រហាក់ប្រហែលនឹងពួកទេវតា ។

- ពួកអសុរកាយខ្លះ ក៏មានសេចក្ដីសុខ គឺ ពួកនេះមានសេចក្ដីទុក្ខពេលយប់ និង ធរមាណ មានសេចក្ដីសុខ

ពេលថ្ងៃជាដើម ។

ក្នុងទីនេះពាក្យថា អបាយភូមិទាំង ៤ រមែងមានភារៈ ក្តៅបក្តាប់ពួកនេះដែរ ហេតុដូច្នេះ ពាក្យថា អបាយ និង និរយ ប្រែតាមធម្មជាតិ និង តាម វេយ្យាករណ៍ និង ឱ្យចូលគ្នាបានយ៉ាងណាខ្លះ ?

**ឆ្លើយ** តាមបញ្ហាទាំង ២ នេះ

ពាក្យថាអបាយញែកចេញ ២ បទគឺ :

អបៈ + អយៈ

អបៈ ប្រែថា ប្រាស

អយៈ ប្រែថា សេចក្តីសុខ

មានសេចក្តីថា-ប្រាសចាកសេចក្តីសុខ តាមដីកាអភិធម្មត្ថ-សង្គហៈថា **បុញ្ញសម្មតា អយា យេតុយ្យេន អបគ្គោតិ អបាយោ**

ពួកដែលប្រាសចាក អយៈ ដែលជាបុណ្យដ៏ច្រើន ព្រោះហេតុដូច្នេះ ហៅថាអបាយ ។

តែពាក្យថាអបាយប្រែថា ជាសេចក្ដីវិនាសក៏បាន គឺ ក្នុងសិង្គាលសូត្រ ព្រះបាលី ព្រះបរមសាស្ដា សំដែងថា អបាយមុខ ប្រែថា ផ្លូវនៃសេចក្ដីវិនាស ។ តាមដែល លោកដីកាចារ្យ សំដែងទុកនេះរមែងមានពាក្យ អធិ-ប្បាយថា អ្នកដែលមិនមានបុណ្យ គឺ អ្នកធ្វើបាប គឺរមែង កើតទីនេះដ៏ច្រើន ដូច្នេះ ហៅថា អបាយ ។ តាមវាទៈរបស់ លោកដីកាចារ្យនោះ អាស្រ័យស័ព្ទជាមួយគ្នាថា

ះយេភុះយ្យេន ប្រែថាដោយច្រើន ឬ មានសេចក្ដីបំណងថា ពួកខ្លះក៏នៅមានសេចក្ដីសុខ ដូចដែលតាំងបញ្ហាមក វិធី ឆ្លើយបែបនេះ ក្នុងវេយ្យាករណ៍នៃបាលីថា យេភុយ្យ ន័យ និង អប្បកន័យ គឺសេចក្ដីសុខដែលមិនមានច្រើនថា យេភុយ្យន័យ សត្វដែលមានសេចក្ដីសុខ តែមាន សេចក្ដី សុខតិចថា អប្បកន័យ ប៉ុន្តែពាក្យ អបះ និង និរះ របស់ពាក្យ និរយនោះ ។

របស់ពាក្យនិរយៈនោះ មានន័យដូចគ្នា ព្រោះអបះ ឬ

អបគតៈ ប្រែថា ប្រាសចាក និង និរ នត្ថិ ក៏ប្រែថា គ្មាន មិនមាន ។

ពាក្យថាមិនមាន ឬ ប្រាសចាក ក៏មានន័យដូចគ្នា គឺ មិនមាននោះឯង។ ប៉ុន្តែទោះជាយ៉ាងណាក្តី ពាក្យថា អយៈ ដែលប្រែថា សេចក្តីសុខនោះ សេចក្តីសុខ មាន ៣ យ៉ាង គឺ :

១-សេចក្តីសុខរបស់កាម

២-សេចក្តីសុខរបស់មហគ្គតៈ

៣-សេចក្តីសុខរបស់លោកុត្តរៈ ។

ពួកដែលរមែងកើត ក្នុងអាបាយទាំង ៤នេះ សេចក្តី សុខក្នុងកាមនេះ ត្រូវមានតាម ធម្មជាតិ ប៉ុន្តែសេចក្តីជា មហគ្គតៈ និង លោកុត្តរៈ នេះ មិនមានជាដាច់ខាតឡើយ ។

**បុញ្ញសម្មតា អយា យេតុយ្យេន អបគ្គោតិ អឃោយោ នត្ថិ អយោ ឯត្ថាតិ និរយោ**

តាមវិគ្គហៈទាំងពីរ ត្រឹមត្រូវតាមសកម្មភាព ដោយមិនចាំបាច់ត្រូវអាស្រ័យផ្លូវវេយ្យាករណ៍ ឱ្យច្រើនដូច្នេះទេ

**សួរ** ពាក្យថាភូមិ ប្រែថាអ្វី បានដល់អ្វី ?

**ឆ្លើយ** ពាក្យថាភូមិ នោះតាមវិគ្គហៈថា ភវន្តិ ឯត្ថាតិ ភូមិ ប្រែថា សត្វរមែងកើតបាន ក្នុងទីនេះ ហៅថា ភូមិ មានន័យថា កន្លែងណាដែលមានសត្វកើតបានទីនោះ ហៅថាភូមិ ជួនកាលភូមិ មិនប្រែថា ជាទីកើតរបស់សត្វក៏មានដូចជា អវត្ថាភូមិ ជាទីកើតនៃលោកុត្តរៈ ជួនកាលក៏ថាពុទ្ធភូមិក៏មានដូច្នេះដែរ ។ ព្រោះហេតុដូច្នេះ ពាក្យថាភូមិ ប្រែត្រង់ៗក៏ថាទីកើត ។

**សួរ** តាមដែលព្រះអនុរុទ្ធាចារ្យ សំដែងកាមសុគតិ ៧ ភូមិ និង ព្រហ្ម ២០ភូមិ ។ ក្នុងសម័យនេះមានមនុស្សសង្ស័យច្រើនគ្រា គឺទេវតា និង ព្រហ្មនោះ អាចារ្យខ្លះក៏ថាមាន អាចារ្យខ្លះក៏ថាមិនមាន គឺការប្រកែកជជែកគ្នានៅជានិច្ច ពួកដែលថាមាននោះអាស្រ័យគម្ពីរ ក្នុងអភិធម្មត្ថ

សង្គហៈ ជាដើមថា មានទេវតា មានព្រហ្មដោយឡែក អ្នកខ្លះក៏ថាទេវតា ព្រហ្មនេះ គ្មានដោយឡែកទេ ។

មនុស្សដែលមានសេចក្ដីសុខ ហៅថាទេវតា មនុស្សដែលមានធម៌ ហៅព្រហ្ម ដូចនេះជាដើម ។ ដូចនេះ ចង់ជ្រាបថាទេវតា ព្រហ្មនេះជាជំពូកជាមួយគ្នា និង មនុស្ស ឬយ៉ាងណា ?

**ឆ្លើយ** ការដែលពោលសេចក្ដីយ៉ាងនេះ ក៏រមែងមានជាធម្មតា ព្រោះលោករបស់យើងនេះ លាយឡំដោយអ្នកមានបញ្ញា និង អ្នកអប្បបញ្ញា តែទោះបីយ៉ាងណាក្ដី យើងនៅមានធម៌ ល្មមប្រកាន់ជឿបានជាភស្តុតាង គឺ ព្រះធម្មក្ខន្ធ ៨៤០០០ របស់ព្រះសាស្ដានៃយើង ប្រាកដមាននៅព្រះបាលី ព្រះនិព្វានសូត្រ យោ ខោ មយា អានន្ទ ទេសិតោ ច បញ្ញត្តោ សោវោ មមច្ចយេន សត្ថា ប្រែ ម្នាលអានន្ទយើងបានទេសនាព្រះធម៌ បានបញ្ញត្តិព្រះវិន័យទុកហើយ ។ ព្រះធម៌ ព្រះវិន័យទាំងអស់នេះ កាលយើង

ផុតអំពីលោកនេះទៅហើយរមែងប្រកាន់យកជាគ្រូ បាន ។

ក្នុងបញ្ហាដែលថាមានទេវតា ឬ មិនមាននោះ តាមពុទ្ធភាសិតថា មនុស្សយើងកាលស្លាប់ពីភព ( ជាតិ ) នេះទៅហើយ រមែងកើតជាទេវតា ឬ ព្រហ្ម ឬជាសត្វដទៃដែលជាឧប្បត្តិកៈក៏មាន តាមចុតិទាំង ៥ របស់សត្វ ក្នុងពុទ្ធភាសិតថា :

**តេ កាយស្ស ភេទា បរម្មរណា សុគតឹ ទេវលោកំ ឧប្បន្នា**

មនុស្សទាំងអម្បាលនេះ ខាងក្រោយដែលមរណៈ រមែងកើតក្នុងទេវលោក ដោយឧប្បត្តិកបដិសន្ធិ ។ ក្នុងទេវតាសំយុត្ត និង អំគុត្តរព្រះបាលីថា លោកអនាថបណ្ឌិកសេដ្ឋី និង នាងវិសាខាជាដើម កាលចុតិពីលោកនេះហើយទៅកើតក្នុងទេវលោក ហើយក្នុងអនាគតវង្សបាលីថា ព្រះពោធិសត្វ ព្រះអរិយមេត្តេយ្យ វេលានេះកើតនៅជាទេវបុត្តក្នុងទេវលោក ដូចនេះជាដើម ។ ទោះបី

យ៉ាងនេះក៏ដោយ តាមព្រះអភិធម្មសំដែងថា មានត្រៃភព

ពាក្យថាត្រៃភពនោះ បានដល់ភូមិ ១១ភូមិ រូបភូមិ ១៦ភូមិ អរូបភូមិ ៤ ភូមិ រួម ៣១ភូមិ ។ គ្មានជាភូមិដែលទំនេរទទេប្រាសចាកសត្វ ដែលអាស្រ័យទេ ។ សេចក្ដីពិតពាក្យថាភូមិនេះ ភវន្តិ ឯត្ថាតិ ភូមិប្រែថា ព្រោះសត្វអាស្រ័យនៅ ដូច្នេះហៅថាភូមិ ។

មានភូមិហើយកើត១ ហើយនឹងត្រូវមានសត្វនៅប្រចាំជានិច្ច ។ ភូមិទាំងអស់នេះ ភូមិខ្លះសំរាប់ទេវតា ខ្លះសំរាប់ព្រហ្ម ព្រោះហេតុដូច្នេះ អាស្រ័យពុទ្ធភាសិតជាភស្តុតាងស្រាប់ ។ ទេវតា និង ព្រហ្មក៏ត្រូវមានទៀតដោយឡែកតាមអភិធម្មត្ថសង្គហៈ អធិប្បាយយ៉ាងពិតប្រាកដ ។

**ស្នូរ** ក្នុងភូមិភេទ តាមបាលីថា អបាយភូមិ កាមសុគតិ-ភូមិ រូបាវចរភូមិ អរូបាវចរភូមិ រួមសំដែងភូមិទាំង ៤ ដែលពោលមកហើយ ។ តពីនេះទៅសំដែង អវយវៈនៃ

ភូមិថា និរយៈ តិរច្ឆាន យោនិ បេតវិសយ អសុរកាយទៀត ក្នុងទីនេះអ្នករៀន អាចយល់បានថា និរយៈជាភូមិមួយ កន្លែងរបស់សត្វនរក តែថា យោនិក្នុងតិរច្ឆាន យោនិក្នុង បេតវិស័យ និង កាយ ។ ក្នុងអសុរកាយ រួមយោនិ ១បទ វិសយ ១បទ កាយ ១បទ យ៉ាងនេះមានន័យថាដូចម្ដេច និង អធិប្បាយយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថា យោនិនៃតិរច្ឆាន យោនិនោះបានដល់ ជាតិរបស់ពួក តិរច្ឆាននេះឯង ហៅថាភូមិ ប៉ុន្តែថា មិនមានភូមិដោយឡែកទេ នៅលាយឡំ ជាមួយមនុស្ស នេះឯង ។

ពាក្យថាវិសយ របស់បេតវិស័យនោះ វិសយៈបាន ដល់ទីនៅរបស់ប្រេត ជាទីអាស្រ័យរបស់ពួកប្រេត គឺ ក្នុង ព្រៃឈើ ឬ លើភ្នំ កោះកណ្ដាលទន្លេជាដើម ទីអាស្រ័យ របស់ពួកប្រេតនេះហៅថាភូមិ ។

ពាក្យថាកាយនៃអសុរកាយនោះ កាយបានដល់ ពួក

**មានន័យថា** ពួករបស់សត្វអសុរកាយ ១ ជំពូកដែល ដែលអាស្រ័យដូចគ្នា និង ពួកប្រេតដែលជាទីអាស្រ័យ ពួកប្រេតហៅថាភូមិ តែពាក្យអសុរកាយនោះប្រែបានច្រើនយ៉ាងទៀតគឺ កន្លែងខ្លះប្រែថា ទេវតាមួយជំពូកដែលបានគិតច្បាំងគ្នា និង ពួកទេវតាធំ ១ ។ ពាក្យថាអសុរ កន្លែងខ្លះបានដល់ពាក់កណ្តាលប្រេត ពាក់កណ្តាលទេវតា ដែលបានសោយសុខទុក្ខ គឺ ពេលថ្ងៃសោយទុក្ខវេទនា និង ពេលយប់សោយសុខវេទនា ។ ពាក្យថាអសុរ កន្លែងខ្លះបានដល់ប្រេតម្យ៉ាងដែលមានឈ្មោះថា កិញ្ជិកអសុរា ហេតុនេះពាក្យថា អសុកាយ គឺ អសុរា ៣ ទៅ ៤ ជំពូក ដូចដែលអធិប្បាយមកហើយ ចំពោះពាក្យ អសុរកាយទាំងនេះ ។

**ស្នូរ** ក្នុងពាក្យអធិប្បាយ កាមាវចរទេវតា ៦ ជំពូក

ពាក្យថា បរនិម្មិតវសវត្តី គឺ ទេវតាមួយជំពូកដែលអាស្រ័យកាមគុណ ដែលពួកទេវតាដទៃៗបាននិម្មិតទុកឱ្យទេវតាដែលអាស្រ័យរបស់ទេវតា ( អង្គ ) ដទៃនោះមិនជា

កាមេសុមិច្ឆាចារឬ ?

**ឆ្លើយ** មិនមែនដូច្នេះទេ ពួកទេវតាទាំងនេះអាស្រ័យនៅក្រោមអំណាចអ្នកគ្រប់គ្រងជានិច្ច ព្រោះក្នុងលោក ទេវតាក៏ដូចមនុស្ស ត្រូវប្រើសេចក្ដីយុត្តិធម៌ បើថាទេវតាអង្គណាមួយ ប្រព្រឹត្តខុសធម៌ហើយ ត្រូវទទួលពាក្យពិភាក្សាពីអ្នកគ្រប់គ្រងតាមការប្រព្រឹត្តិខុសនោះ ។

ពាក្យថា បរនិម្មិតវសវត្តី ប្រែថាទេវតាមួយជំពូកដែល សោយសេចក្ដីសុខ ដែលទេវតាដទៃៗនិម្មិតនេះមានន័យថា ពួកទេវតាទាំងនេះ មានរិទ្ធីច្រើនកាលត្រូវការវត្ថុណាក៏ល្អនៅមានទេវតាមួយចំពួកជាបរិវារបស់លោកចាំនិម្មិត ទុកដើម្បីទេវតាដែលជានាយរបស់ខ្លួន ដូចអ្នកមើលថែទាំ ជំនួសនៃព្រះរាជា ត្រូវចាត់ការងារទុកសំរាប់ព្រះរាជាជា និច្ច ។

ព្រោះហេតុដូច្នោះ តាមរិទ្ធីអំណាចទេវតាជំពូកនេះបានមកពីវាសនាពីជាតិមុន គឺ ធម្មជាតិរបស់គេមានយ៉ាង

នេះ មិនមែនជាការតំរាមគំហែង ទេវតាដទៃ១ ដូច្នេះមិនមានចំណុចថាជាបាប ក៏មិនមែនដែរ មានន័យថា មិនបានកើតអកុសលទេ ។

**សួរ** តាមដែលពួកអាចារ្យខ្លះពោលថា ក្នុងបរនិម្មិតវស-វត្តីនេះមានព្រះយាមា ដែលចាំទំលាយព្រះបរមសាស្តាជានិច្ច ។ ពាក្យនិយាយនេះមិនពិតឬទេ ?

**ឆ្លើយ** តាមពុទ្ធភាសិតផ្សេង១ ព្រមជាមួយគ្នានិង អដ្ឋកថាអះអាងថា ពាក្យថាមារនេះ បានដល់មារទាំង ៥ គឺ ទេវបុត្តមារ កិលេសមារ ខន្ធមារ មច្ចុមារ អភិសង្ខារមារ រួម ៥ មារ ។ ទេវបុត្តមារប្រែថា ទេវបុត្តមារមានន័យថា នៅមានទេវតាដែលមានចិត្តគំនិតនៅផ្លូវអកុសល ហើយស្វែងរករឿងអ្នកដទៃ ដូចជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងព្រះអរហន្តផ្សេង១ ដែលធ្វើល្អជាដើម ។

មារនេះតាមបាលីថា ៖ មារោវសវត្តី គឺ មារដែលអាស្រ័យនៅក្នុងវសវត្តីទេវលោក ។ រឿងមារនៅក្នុងព្រះ

វិន័យ មហាវារព្រះបាលី និង បណ្ណាលព្រះបាលី មារតដ្ឋ-និយសូត្រ អំគុត្តរព្រះបាលីគម្ពីរទាំងអស់នេះ សុទ្ធតែព្រះបាលីបានពោលអះអាងថា : ទេវបុត្តដែលជាព្រះយាមាមាននៅក្នុងអដ្ឋកថាផ្សេងៗ ដូចជា ធម្មបទ អដ្ឋកថាសុត្តនិបាត អដ្ឋកថាជាដើម ក៏មានន័យដូចគ្នា ។

ព្រោះហេតុដូច្នេះ តាមគម្ពីររបស់ព្រះពុទ្ធសាសនាទាំងអស់នេះថា យាមា មានពិត យើងដែលជាពុទ្ធសាស-និកជន ត្រូវកាន់តាមគម្ពីរដែលធានាអះអាងថា មានព្រះ-យាមាពិត ។

**សួរ** ពាក្យថាភូមិ និង ពាក្យថាលោក ផ្សេងគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថាភូមិ តាមវិគ្គហថា ភវន្តិ ឯត្ថាតិ ភូមិ ប្រែថាជាទីកន្លែងកើតរបស់សត្វ ឬ ជាអណ្តូង ជាទីកើតនៃធម៌ដូចពុទ្ធភូមិ សាវកភូមិ ជាដើម ។

ពាក្យថាលោក តាមវិគ្គហថា : លុជ្ជតិ បលុជ្ជតីតិ

លោកា គឺ វិនាស ព្រោះហេតុដូច្នេះ ហៅថា លោក បានដល់សត្វក្នុងលោក សង្ខារលោក ឱកាសលោក ។ សត្វទាំងឡាយហៅថា សង្ខារលោក ទីនៅរបស់សត្វទាំងឡាយ នៃលោក ៣១ភូមិ ហៅឱកាសលោក ។ ក្រៅអំពីនេះលោកនៅប្រែបានច្រើនយ៉ាងទៀត គឺ បរមត្ថ សភាពទាំងអស់ហៅថា លោក គឺ ចក្ខុលោក សោតលោក ជាដើម ។

ទាំងអស់នេះហៅថាលោកដូចគ្នា ជាពាក្យដែលស៊ីជំរៅនៃសេចក្តីច្រើនជាងពាក្យថាភូមិ ។ ព្រោះការពិចារណាមើលក៏ប្រាកដជាចំណែកមួយនៃលោក ។ ភូមិប្រែបានតែឱកាសលោកបានតែម្យ៉ាងប៉ុណ្ណោះ ជួនកាលឱកាសលោក ឬ ភូមិហៅថា លោកធាតុក៏បាន មានន័យថា ភូមិ និង លោកទាំងពីរនេះត្រូវរួមក្នុងធាតុភូមិ ។

ពាក្យថាធាតុនេះស៊ីជំរៅនៃសេចក្តីច្រើនជាងលោក ព្រោះធមិទាំងអស់ ទាំងកន្លែងមានជីវិត និង មិនមានជីវិតនៅ ក៏ជាធាតុទាំងអស់ ។

ព្រោះដូច្នេះ ពាក្យថា ភូមិ លោក ធាតុ មានន័យដូចគ្នា គឺ ភូមិនៅក្នុងលោក លោកនៅក្នុងធាតុ ធាតុនេះស៊ីជំរៅជ្រាលជ្រៅនៃសេចក្ដីរហូតដល់និព្វានផង ។

**សួរ** ក្នុងអរូបភូមិ ៤នេះ តាមដែលស្គាល់ទូទៅថាជានាមធម៌ កាលកើតនាមធម៌សុទ្ធយ៉ាងនេះ តើធ្វើដូចម្ដេចហៅតគ្នាជាមួយនិងភូមិឯទៀត ? ព្រោះពាក្យថាភូមិ ប្រែថា ជាទីកន្លែងនៅរបស់សត្វ ។

**ឆ្លើយ** អរូបប្រែថា មិនមានរូប គឺនាមធម៌ មានន័យថាព្រហ្មអរូបទាំងអស់នេះ កើតមកដោយនាមធម៌សុទ្ធ មិន-មានរូបសូម្បីតែរូបមួយមិនមាន ជាទីកន្លែងកើតរបស់ឈានលាភីបុគ្គលជំពូកខ្លះ ដែលដល់បញ្ចមជ្ឈាន ។ កាលដែលប្រកបជាមួយនិងស័ព្ទថា ភូមិនោះ ព្រោះភូមិប្រែថាជាទីកន្លែងកើតរបស់សត្វ មិនមានន័យដល់ផែនដី ទឹកដូចសត្វក្នុងកាមភូមិទេ ។ សូម្បីក្នុងកាមសុគតិដូច្នេះក៏ដោយជំពូកខ្លះកកើតក្នុងអាកាសក៏មាន ដូចជា អាកាសទេវតា

ជាដើម រមែងកើតក្នុងអាកាសនៅអាកាស បានដល់ពួក ទេវតា យាមា តុសិតា និម្មានរតី បរនិម្មិតវសវត្តី និង ព្រហ្មរូបាវចរទាំងអស់ អាស្រ័យនៅលើអាកាសទាំងអស់ ជាទីនៅនៃទេវតា និង ព្រហ្មទាំងនេះ មិនមានផែនដីដូច ទេវតា តាវត្តី ចាតុម្មហារាជិកា និង មនុស្សទេ ។ ដោយ ហេតុនេះ ព្រហ្មអរូបទាំង ៤ ក៏អាចនឹងកើតនៅលើអា កាស និង អាចនៅក្នុងអាកាសបាន ដូចទេវតាជាន់ទាប១ និង ពាក្យថាភូមិក៏ប្រកបបានព្រោះ ភូមិមានន័យថា : សត្វកើតនៅទីណា ភូមិក៏ប្រកបនៅទីនោះបាន ។

ប្រកប ≈ ប្រាកដ ។

**សួរ** តាមពាក្យសង្គហថា **បុថុជ្ជនា ន លព្ភន្តិ** ប្រែថាក្នុងសុទ្ធាវាសទាំង ៥ភូមិ បុថុជ្ជន និង ព្រះសោតា កាលដែលកើត តាមដែលដឹងទូទៅថា កាលដែលសត្វ កើតក្នុងព្រហ្ម នេះក៏ព្រោះអំណាចរបស់ឈាន មិនមែន អំណាចរបស់លោកុត្តរទេ ។ កាលបើដូច្នេះ ព្រះសោតាបត្តិ

ព្រះសកទាគាមិបុគ្គល ដែលដល់ឈាន ទើបមិនអាចកើតក្នុងសុទ្ធាវាសបាន ?

**ឆ្លើយ** ពាក្យថា សុទ្ធាវាស តាមវិគ្គហ ថា :

សុទ្ធានំ អាវាសោ សុទ្ធាវាសោ ប្រែថាទីកើតរបស់សត្វលោកអនាគាមិបុគ្គល ដែលជាអ្នកមានគុណវិសេសរបស់ព្រះអរិយៈ ដែលអាចនឹងរំលត់ខន្ធបាន បើជាព្រះអរហន្ត ក៏មិនចាំបាច់ត្រូវអធិប្បាយ ព្រោះរលត់ខន្ធពិតប្រាកដ ។ ចំណែកព្រះអនាគាមិបុគ្គលនោះមិនមានកាមរាគ ឬ ព្យាបាទ ព្រោះហេតុដូច្នោះ លោកមិនត្រូវការភ្លឹតភ្លើន វង្វេងក្នុងកាមរាគ ឬ មិនចង់នៅជាពួក ដូចគ្នានិងពួកកាមរាគឡើយ ។

តាមសេចក្តីបំណងរបស់អ្នកមានសីលគុណ ឬ គុណវិសេស ចាំបាច់ត្រូវមានសុទ្ធាវាសទាំង ៥ ភូមិប្រាកដ ជាទីអាស្រ័យដោយឡែក មិនបានកើតលាយឡំគ្នា ជាមួយ និងកាមរាគឡើយ ។ ព្រោះហេតុដូច្នេះ ព្រះបរមសាស្តានៃ

យើង ទ្រង់ទេសនាទុកក្នុងអំគុត្តរនិកាយថា ៖

ឥជ្ឈតិ ភិក្ខវេ សីលវតោ ចេតោ បណិធិ វិសុទ្ធត្តា

**ប្រែថា**- សេចក្តីឧស្សាហ៍ ឬ សេចក្តីប្រាថ្នារបស់អ្នកដែលមានសីលគុណ គុណធម៌សំរេចបានគ្រប់យ៉ាង ព្រោះលោកមានចិត្តបរិសុទ្ធបាន អស់មន្ទិលផ្សេងៗ ។

កាលព្រះសោតា សកទាគាមិ មិនកើតក្នុងសុទ្ធាវាសព្រោះកាមរាគ និង ព្យាបាទ នៅមានគ្រប់សង្កត់ ។ ព្រោះហេតុដូច្នោះ ព្រះសោតា សកទាគាមិ និង បានដល់ឈានក៏ដោយ មិនមានធម្មនិយាម ដែលនឹងបានកើតក្នុងសុទ្ធាវាសបានឡើយ ។ ប៉ុន្តែ ការវៀរចាកអសញ្ញិសត្តភូមិ និង អបាយភូមិហើយ

## សំដែងបដិសន្ធិចតុក្កតាមបាលី

**អបាយបដិសន្ធិ កាមសុគតិបដិសន្ធិ រូបាវចរបដិសន្ធិ អរូបាវចរបដិសន្ធិ ចេតិ ចតុព្វិធា បដិសន្ធិ នាម ។**

**តត្ថ អកុសលវិបាកោបេក្ខា សហគតសន្តីរណំ អបាយភូមិយំ ឱក្កន្តិក្ខណេ បដិសន្ធិ ហុត្វា តតោ យំ តវង្គំ បរិយោសានេ ចវនំ ហុត្វា វោច្ឆិជ្ជតិ ។**

## អយមេកាបាយ បដិសន្ធិ នាម ។

កុសលវិបាកោបេក្ខាសហគតសន្តីរណំ បន កាមសុគតិយំ មនុស្សានញ្ចេវ ជច្ចន្ធាទីនំ ភុម្មនិស្សិតានញ្ច វិនិបាតិកា សុរានំ បដិសន្ធិភវង្គចុតិវសេន បវត្តតិ ។ មហាវិបាកានិ បន អដ្ឋ សព្វត្ថាបិ កាមសុគតិយំ បដិសន្ធិភវង្គចុតិវសេន បវត្តន្តិ ។

ឥមា នវ កាមសុគតិ បដិសន្ធិយោ នាម ។

សាបនាយំ ទសវិធាបិ កាមាវចរបដិសន្ធិច្ចេវ សង្គហំ គច្ឆន្តិ

ប្រែ នៅមានបដិសន្ធិ ៤ ប្រការគឺ ៖

១-អបាយបដិសន្ធិ

២-កាមសុគតិបដិសន្ធិ

៣-រូបាវចរបដិសន្ធិ

៤-អរូបាវចរបដិសន្ធិ

រួមបដិសន្ធិ ៤ ប្រការ

ចិត្តជាអកុសលវិបាកឧបេក្ខាសន្តីរណ ១ដួង រមែងកើតក្នុងអបាយភូមិទាំង ៤ ដោយបដិសន្ធិកិច្ច ភវង្គកិច្ច ហើយដល់វារៈទីបំផុតក៏ចុតិកិច្ច ហើយរលត់ចុះទៅនេះឯងហៅថាអបាយបដិសន្ធិ ១ដួង ។ កុសលវិបាក ចិត្តឧបេក្ខាសន្តីរណ១ដួង រមែងកើតក្នុងកាមសុគតិភូមិទាំង ពីរ គឺក្នុងភូមិមនុស្សនោះ កើតជាមនុស្សពិការផ្សេងៗហើយចាតុមហារាជិកាភូមិនោះ កើតជាវិនិបាតិកៈ អសុរដែលដូចទេវតា ភូមិរាជាដោយបដិសិន្ធិកិច្ច ភវង្គកិច្ច និងដល់វារៈទីបំផុត ជាចុតិកិច្ចហើយរលត់ចុះទៅ ។

មហាវិបាកចិត្ត ៨ដួង រមែងកើតក្នុងកាមសុគតិ ៧ភូមិដោយបដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ច ហើយរលត់ចុះទៅ បដិសន្ធិទាំង ៩ ដែលអធិប្បាយគ្រាក្រោយនេះមាន

ឈ្មោះថា កាមសុគតិបដិសន្ធិ ។ កាមសុគតិបដិសន្ធិទាំង ៨នេះរាប់ចូលក្នុង កាមាវចរបដិសន្ធិទាំង ១០ប្រការ ។

---

## សំដែងតាមបាលីតទៅ

តេសុ ចតុន្នំ អបាយានំ មនុស្សានំ វិនិបាតិកាសុរានញ្ច អាយុប្បមាណគណនាយ និយមោ នត្ថិ ។

ចាតុមហារាជិកានំ បន ទេវានំ ទិព្វានិ បញ្ចវស្សសតានិ អាយុប្បមាណំ មនុស្សគណនាយ នវុតិវស្សសតសហស្សប្បមាណំ ហោតិ តតោ ចតុគ្គុណំ តុសិតានំ តតោ ចតុគ្គុណំ និម្មានរតីនំ តតោ ចតុគ្គុណំ បរនិម្មិតវសវត្តីនំ ។

នវសតញ្ចេកវិស្សវស្សានំ កោដិយោ

តថា វស្សសតសហស្សានិ សដ្ឋី ច វសវត្តីសុ ។ បឋមជ្ឈានភូមិយំ បដិសន្ធិភវង្គចុតិវសេន បវត្តតិ ។ តថា ទុតិយជ្ឈានវិបាកំ តតិយជ្ឈានវិបាកញ្ច ទុតិយជ្ឈានភូមិយំ ។ ចតុត្ថជ្ឈានវិបាកំ តតិយជ្ឈានភូមិយំ ។ បញ្ចមជ្ឈានវិបាកំ ចតុត្ថជ្ឈានភូមិយំ អសញ្ញិសត្តានំ បវត្តិយំ ចវនកាលេ ច រូបមេវ បវត្តិត្វា និរុជ្ឈតិ ។ ឥមា ឆ រូបាវចរបដិសន្ធិយោ នាម ។

តេសុ ព្រហ្មបារិសជ្ជានំ ទេវានំ កប្បស្ស តតិយោ ភាគោ អាយុប្បមាណំ ព្រហ្មបុរោហិតានំ ឧបឌ្ឍកប្បោ មហាព្រហ្មានំ ឯកោ កប្បោ ។ បរិត្តាភានំ ទ្វេ កប្បានិ អប្បមាណាភានំ ចត្តារិ កប្បានិ អាភស្សរានំ អដ្ឋ កប្បានិ បរិត្តសុភានំ សោឡស កប្បានិ អប្បមាណ-

សុភានំ-ទុត្តិស កប្បានិ សុភកណ្ហានំ ចតុ សដ្ឋី កប្បានិ ។

វេហប្ផលានំ អសញ្ញិសត្តានញ្ច បញ្ច កប្បសត្តានិ សុទស្សានំ ចត្តារិ កប្បសហស្សានិ សុទស្សីនំ អដ្ឋ កប្បសហស្សានិ អកនិដ្ឋានំ សោឡស កប្បសហស្សានិ ។

ប្រែ កំណត់អាយុរបស់សត្វក្នុងអបាយទាំង៤ និងមនុស្ស វិនិបាតិកអសុរនោះរមែងមិនមាន ។

អាយុរបស់ទេវតា ចាតុម្មហារាជិកា បើរាប់ដោយឆ្នាំទិព្វមានចំនួន ៥០០ឆ្នាំ បើរាប់ដោយឆ្នាំមនុស្ស ត្រូវជា ៩លានឆ្នាំ ។

អាយុរបស់ទេវតា តាវត្តិំសា ៤ដងឡើងទៅទៀត ។

អាយុរបស់ទេវតា យាមារាប់ឡើងទៅទៀត ៤ដង

អាយុរបស់ទេវតា តុសិតារាប់ឡើងទៅទៀត ៤ដង

អាយុរបស់ទេវតានិម្មានរតីរាប់ឡើងទៅទៀត៤ដង

អាយុរបស់ទេវតា បរនិម្មិតវសវត្តីក៏បន្ថែមឡើងទៅ ៤ដងទៀត ។ អាយុរបស់ទេវតាបរនិម្មិតវសវត្តី បើរាប់ដោយឆ្នាំមនុស្ស ត្រូវជា ៩វស្ស ២១កោដិ ៦លានឆ្នាំគត់ ។

- បឋមជ្ឈានវិបាកចិត្ត រមែងកើតក្នុងបឋមជ្ឈានភូមិដោយបដិសន្ធិភវង្គចុតិ ។

- ទុតិយជ្ឈានវិបាកចិត្ត និង តតិយជ្ឈានវិបាកចិត្ត ទាំងពីរនេះរមែងកើតក្នុងទុតិយភូមិ ដោយបដិសន្ធិភវង្គចុ-តិ ។

- ចតុត្ថជ្ឈានវិបាកចិត្ត រមែងកើតក្នុងចតុត្ថជ្ឈានភូមិដោយបដិសន្ធិ ភង្គចុតិ ។

-បញ្ចមជ្ឈានវិបាកចិត្ត រមែងកើតក្នុងចតុត្ថជ្ឈាន-ភូមិ ដោយបដិសន្ធិ ភវង្គចុតិ ។

✵ អសញ្ញិសត្តព្រហ្ម ជារូបបដិសន្ធិប៉ុណ្ណោះ កាលចុតិរូបនោះក៏រលត់ចុះបដិសន្ធិរូម ៦ដង ដែលបានពោលមក

ហើយនេះជារូបាវចរបដិសន្ធិ ។

ក្នុងទីនេះអាយុរបស់ ព្រហ្មបារិសជ្ជា មានមួយចំ-ណែក ក្នុង ៣ចំណែករបស់មហាកប្ប ។

- អាយុរបស់ព្រហ្ម បុរោហិតា ពាក់កណ្ដាលមហាកប្ប
- អាយុរបស់មហាព្រហ្ម ១ មហាកប្ប
- អាយុរបស់ព្រហ្មបរិត្តាភា ២ មហាកប្ប
- អាយុរបស់ព្រហ្មអប្បមាណាភា ៤ មហាកប្ប
- អាយុរបស់ព្រហ្មអាភស្សរា ៦ មហាកប្ប
- អាយុរបស់ព្រហ្មបរិត្តសុភា ៨ មហាកប្ប
- អាយុរបស់ព្រហ្មអប្បមាណាសុភា ៣២មហាកប្ប
- អាយុរបស់ព្រហ្មសុភកិណ្ហា ៦៤មហាកប្ប
- អាយុរបស់ព្រហ្មវេហប្ផលា ៥០០មហាកប្ប
- អាយុរបស់ព្រហ្មអសញ្ញិសត្តា ៥០០មហាកប្ប

✵ ក្នុងសុទ្ធាវាសទាំង ៥ ភូមិ

- អាយុរបស់ព្រហ្មអវិហា ១០០ មហាកប្ប
- អាយុរបស់ព្រហ្មអតប្បា ២០០០ មហាកប្ប
- អាយុរបស់ព្រហ្មសុទស្សា ៤០០០ មហាកប្ប
- អាយុរបស់ព្រហ្មសុទស្សី ៨០០០ មហាកប្ប
- អាយុរបស់ព្រហ្មអកនិដ្ឋកា ១៦០០០ មហាកប្ប

## សំដែងបាលី "គ"

បឋមារូបាទិវិបាកានិ បឋមារូបាទិភូមិសុ យថា-ក្កមំ បដិសន្ធិ ភវង្គចុតិវសេន បវត្តន្តិ ។

តេសុ អាកាសានញ្ចាយតនូបគានំ ទេវានំ វីសតិ កប្បសហស្សានិ អាយុប្បមាណំ វិញ្ញាណញ្ចាយតនូបគានំ ទេវានំ ចត្តាឡីស កប្បសហស្សានិ អាយុប្បមាណំ នេវសញ្ញាយ-តនូបគានំ ទេវានំ ចតុរាសីតិ កប្បសហស្សា-និ ។

ព្រៃ បបមអរូបវិបាកចិត្ត ទាំងអស់នេះ កើតក្នុង អរូបភូមិដោយបដិសន្ធិ ភវង្គចុតិ ។ អរូបវិបាកចិត្តទាំង ៤ ហៅថា អរូបបដិសន្ធិរបស់ព្រហ្ម ។

- អាយុរបស់ព្រហ្មអាកាសសានញ្ចាយតន ២០០០ មហាកប្ប

-អាយុរបស់ព្រហ្ម វិញ្ញាណញ្ចាយតន ៤០០០ មហាកប្ប

-អាយុរបស់ព្រហ្ម អកនិដ្ឋ ៦០០០ មហាកប្ប

អាយុរបស់ ព្រហ្មនេវសញ្ញានាសញ្ញាយតន ៨៤០០០ មហាកប្ប ។

---

## គាថាសង្គហ

បដិសន្ធិ ភវង្គញ្ច តថា ចវនមានសំ

ឯកមេវ តថេវេកវិសយញ្ចេកជាតិយំ ។

ក្នុងជាតិតែមួយនេះ បដិសន្ធិចិត្ត ភវង្គចិត្ត និង ចុតិចិត្តទាំង ៣យ៉ាងនេះ ជាមួយគ្នា ហើយនិងមានអារម្មណ៍ជាមួយគ្នា ។

## អធិប្បាយបដិសន្ធិទាំង ៤

- ពាក្យថា អបាយបដិសន្ធិ មានន័យថា :

ចិត្តមួយដួង ដែលធ្វើឱ្យសត្វកើតក្នុងអបាយ ទាំង ៤ ភូមិបានដល់ អកុសលវិបាកចិត្តឧបេក្ខាសន្តីរណ ១ ដួង ។

- ពាក្យថា កាមសុគតិបដិសន្ធិ មានន័យថា :

ចិត្តមួយដួង ដែលធ្វើឱ្យសត្វពី ទេវតា មនុស្ស កើតក្នុងកាមភូមិ ១១ជាន់ ដោយបដិសន្ធិ ភវង្គចុតិ បានដល់កុសលវិបាកចិត្ត ឧបេក្ខាសន្តីរណ១ដួង និង មហាវិបាកចិត្ត ៨ដួង រួម ៩ដួង ។

- ពាក្យថា រូបាវចរបដិសន្ធិ មានន័យថា :

ចិត្តមួយដួង ដែលធ្វើឱ្យសត្វកើតក្នុងព្រហ្មលោក ១៦ភូមិបានដល់ រូបាវចរវិបាកចិត្ត ៥ដួង ។

- ពាក្យថាអរូបាវចរបដិសន្ធិ មានន័យថា

ចិត្តមួយដួង ដែលធ្វើឱ្យសត្វកើតក្នុងអរូបាវចរ ព្រហ្មលោក ៤ ភូមិ បានដល់អរូបាវចរវិបាកចិត្ត ៤ដួង ។

អធិប្បាយសរុបនៃបដិសន្ធិទាំង ៤ មាននៅក្នុងបាលី និង ពាក្យប្រពៃហើយ ។ ( មេត្តាមើលពាក្យប្រែផង )

រួមបដិសន្ធិចិត្ត ១៩ ដួង គឺ កាមបដិសន្ធិ ១០ដួង រូបាវចរបដិសន្ធិ ៥ដួង អរូបាវចរបដិសន្ធិ ៤ដួង រួម ១៩ដួង

ក្នុងទីនេះកំណត់អាយុរបស់សត្វក្នុងអបាយទាំង ៤ មនុស្ស និង វិនិបាតិកអសុរគ្មានទេ ព្រោះសត្វក្នុងអបាយទាំង ៤ ជួនកាលមានអាយុ ៧ថ្ងៃក៏មាន ( ៧ ថ្ងៃអាយុមនុស្ស) ដូចជានាង មុល្លិកាទេវី ដែលជាមហេសីរបស់ព្រះរាជា បសេនទិកោសល្យ ។ ព្រះមហេសីអង្គនេះបានកើតក្នុងនរក ត្រឹម៧ថ្ងៃ មនុស្ស ហើយត្រឡប់មកកើតក្នុង

ទេវលោក ជាន់តុសិតដោយឧប្បត្តិកបដិសន្ធិ ។ ខ្លះក៏ត្រូវនៅក្នុងនរក ដ៏យូរ រាប់ជាថ្ងៃ ជាឆ្នាំមិនបាន ។ ព្រោះហេតុដូច្នោះ កាលដែលកើតនៅក្នុងអបាយភូមិយូរប៉ុណ្ណានោះស្រេចហើយតែ អកុសល គ្មានកំណត់ទេ ។

មនុស្សក៏ដូចគ្នាដែរ ជួនកាលមនុស្សមានអាយុដល់អសង្ខេយ្យក៏មានដូចជា ស្តេចមុនធាតុរាជជាដើម ព្រះអង្គមានអាយុច្រើនជាងទេវតា គឺសម័យមួយនៅឋានតាវត្តឹសទេវតា ទីនោះព្រះឥន្ទ ៣៦ព្រះអង្គសុគត ហើយព្រះអង្គ ក៏នៅមិនស្លាប់ ។ ក្នុងទីបំផុតព្រះអង្គត្រឡប់មកកាន់ឋានមនុស្សស្លាប់ហើយក៏បានទៅកើត តាវត្តិទេវលោកទៀត ។ ព្រោះហេតុដូច្នេះ អាយុរបស់មនុស្សទើបគ្មានកំណត់ទេ ។

ក្នុងឋានទេវតា ៦ជាន់ អាយុរបស់ទេវតាចាតុម្មហារាជិកា មានកំណត់របស់លោក ៥០០ឆ្នាំទិព្វថាដោយឆ្នាំ ដូចនេះ ៥០ឆ្នាំមនុស្សប្រហែល ១ថ្ងៃទេវតាចាតុម្មហារាជិកា ។ ៣០ថ្ងៃជាមួយខែ កាលរាប់ជាឆ្នាំ

មនុស្ស មានចំនួន ៩លានឆ្នាំ ដោយបរិបូណ៌ ។

- អាយុរបស់ទេវតាតាវត្តឹស ៤ដងនៃអាយុរបស់ទេវតាចាតុម្មហារាជិកា គឺ ៩.000.000 × ៤ = ៣៦000.000 ឆ្នាំ ។

- អាយុរបស់ទេវតាយាមា ៤ដង របស់តាវត្តឹសគឺ ៣៦ 000 000 × ៤ = ១៤៤ 000 000ឆ្នាំ

- អាយុរបស់ទេវតា តុសិតា ៤ ដង របស់អាយុយាមាគឺ ១៤៤ 000 000 × ៤ = ៥៧៦ 000 000ឆ្នាំ

- អាយុរបស់ទេវតានិម្មានរតី ៤ដង អាយុតុសិតា គឺ ៥៧៦ 000 000 × ៤ = ២ ៣0៤ 000 000ឆ្នាំ

- អាយុរបស់ទេវតាបរនិម្មិតវសវត្តី ៤ដងអាយុនិម្មានរតីគឺ

២ ៣0៤ 000 000 × ៤ = ៩ ២១៦ 000 000ឆ្នាំ

ព្រោះហេតុដូច្នេះ អាយុរបស់ទេវតាបរនិម្មិតវសវត្តី គឺមានចំនួនតាមបាលីថា

**នវសតញ្ចេកវស្សានំ គោដិយោ តថា វស្សសតសហស្សានិ សដ្ឋី ច វសវត្តីសុ** ដូចដែលបានពោលមកហើយ ។ ( មេត្តាមើលពាក្យប្រែ ក្នុងបដិសន្ធិចតុក្កនេះផង ) ។

- រូបាវចរឈានភូមិ ទាំង ៣គឺ ១-ព្រហ្មបារិសជ្ជា ២-ព្រហ្មបុរោហិតា ៣-មហាព្រហ្មា រួម ៣ភូមិ ។

- រូបាវចរទុតិយ តតិយជ្ឈានវិបាក ដែលកើតមកពីទុតិយ និង តតិយជ្ឈានកុសល ២ដួង រមែងធ្វើឱ្យដល់ទុតិយ និង តតិយកើតក្នុងទុតុត្ថជ្ឈានភូមិទាំង ៣ គឺ : ១-បរិត្តាភា ២-អប្បមាណាភា ៣-អាភស្សរា រួម ៣ភូមិ ។

- រូបាវចរបញ្ចមជ្ឈានវិបាក ដែលកើតមកពីរូបាវចរបញ្ចមជ្ឈានកុសល ១ដួង ធ្វើឱ្យអ្នកដល់ឈានកើតក្នុងចតុត្ថជ្ឈានភូមិ ២ ភូមិគឺ : វេហប្ផលា និង អសញ្ញីសត្តតែព្រហ្មពីរនេះផ្សេងគ្នា ដោយបដិសន្ធិ គឺ :

-វេហប្ផលាព្រហ្ម មានរូប និង នាម ចំណែក

-អសញ្ញីសត្តព្រហ្ម រមែងកើតដោយរូប មិនមាននាមឡើយដែលបានអធិប្បាយមកហើយ រូបាវចរបដិសន្ធិទាំង ៦ ។

-បដិសន្ធិក្នុងរូបាវចរព្រហ្ម ១៦ ភូមិនោះ មានកំណត់អាយុដូចនេះ

| | | |
|---|---|---|
| បឋមជ្ឈានភូមិ | ព្រហ្មបារិសជ្ជា | ១/៣ មហាកប្ប |
| | ព្រហ្មបុរោហិតា | ១/២ មហាកប្ប |
| | មហាព្រហ្ម | ១ មហាកប្ប |
| ទុតិយជ្ឈាន | ព្រហ្មបរិត្តាភា | ២ មហាកប្ប |
| | ព្រហ្មអប្បមាណាភា | ៤ មហាកប្ប |
| | ព្រហ្មអាភស្សរា | ៨ មហាកប្ប |
| តតិយជ្ឈាន | ព្រហ្មបរិត្តាសុភា | ១៦ មហាកប្ប |
| | ព្រហ្មអប្បមាណសុភា | ៣២ មហាកប្ប |
| | ព្រហ្មសុភកិណ្ហា | ៦៤ មហាកប្ប |

| | | | |
|---|---|---|---|
| ចតុត្ថជ្ឈាន | ព្រហ្មវេហប្ផលា<br>ព្រហ្មអសញ្ញីសត្ត | } | ៥០០មហាកប្ប |

❋ ក្នុងសុទ្ធាវាស ៥ ភូមិនោះគឺ

១-អវិហា ១០០០ មហាកប្ប

២-អតប្បា ២០០០ មហាកប្ប

៣-សុទស្សា ៤០០០ មហាកប្ប

៤-សុទស្សី ៨០០០ មហាកប្ប

៥-អកនិដ្ឋា ១៦០០០ មហាកប្ប

រួម រូបាវចរភូមិ ១៦ភូមិ ។

❋ ក្នុងអរូបាវចរ បដិសន្ធិ ៤ នោះគឺ :

១-អាកាសានញ្ចាយតនវិបាក ធ្វើឱ្យអ្នកដល់បញ្ចមជ្ឈាន កើតក្នុងអាកាសានញ្ចាយតនភូមិ ដោយបដិសន្ធិភវង្គចុតិ ។

២-វិញ្ញាណញ្ចាយតនវិបាក ធ្វើឱ្យកើតក្នុងវិញ្ញាណ-ញ្ចាយតនភូមិ ។

៣-អាកិញ្ចញ្ញាយតនវិបាក ធ្វើឱ្យកើតក្នុងអាកិញ្ច-ញ្ញាយតនភូមិ

៤-នេវសញ្ញានាសញ្ញាយតនវិបាក ធ្វើឱ្យកើតក្នុងនេវសញ្ញានាសញ្ញាយតនភូមិ ។

ក្នុងក្រុម ៤ ជំពូកនេះ ក៏ ដូចគ្នា និងរូបាវចរព្រហ្មគឺមានកំណត់អាយុ ផ្សេង១គ្នាដូចនេះ

-អាយុរបស់ព្រហ្ម អាកាសានញ្ចាយតនៈ ២០០០ មហាកប្ប

-អាយុរបស់ព្រហ្ម វិញ្ញាណញ្ចាយតនៈ ៤០០០ មហាកប្ប

-អាយុរបស់ព្រហ្ម អកិញ្ចញ្ញាយតនៈ ៦០០០ មហាកប្ប

-អាយុរបស់ព្រហ្ម នេវសញ្ញានាសញ្ញាយតន

៨៤000 មហាកប្ប

(មេត្តាមើលភាពត្រៃភូមិ ក្នុងបែបរៀនព្រះបរមត្ថធម៌ផង)

ពាក្យអធិប្បាយនៃគាថាសង្គហនេះថា ក្នុង១ជាតិ១ នេះជាតិជាបដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្ត ៣ យ៉ាងនេះ ជាភូមិជាមួយគ្នា ជាតិជាមួយគ្នា សម្បយុត្តធម៌ ប្រហែល-គ្នា សំខារជាមួយគ្នា ហើយដែលជាមួយគ្នាគឺ

-បើបដិសន្ធិចិត្ត ជាកាមាវចរ ភវង្គ និង ចុតិក៏ត្រូវជាកាមាវចរ ។

-បើបដិសន្ធិចិត្តជាញាណសម្បយុត្ត ភវង្គ និង ចុតិជាញាណសម្បយុត្ត

-បើបដិសន្ធិចិត្តជាអសង្ខារិក ភវង្គ និង ចុតិ ជាអសង្ខារិក

-បើបដិសន្ធិចិត្តមានអារម្មណ៍ កម្ម កម្មនិមិត្ត គតិ-និមិត្ត ភវង្គចិត្ត ចុតិចិត្ត ក៏ត្រូវជាអារម្មណ៍នោះ ព្រោះហេតុ

ដូច្នេះ បដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្ត ៣យ៉ាងនេះ ត្រូវជានិច្ចកាលជាមួយភូមិ ជាសម្បយុត្ត សង្ខារ អារម្មណ៍រហូតទៅ ។

## ពាក្យសួរ-ឆ្លើយ

**សួរ** ពាក្យថាបដិសន្ធិ ញែកចេញជា ២ បទ គឺ

| | | |
|---|---|---|
| បដិ | + | សន្ធិ |
| បដិ | ប្រែថា | ទៀត |
| សន្ធិ | ប្រែថា | ត១គ្នា |

មានន័យថា ត១គ្នាទៀត ការតជាតិ ឬ ភពថ្មី ហៅថាបដិសន្ធិ បដិសន្ធានំ បដិសន្ធិ ប្រែថា ចិត្តដែលតទៅជាតិថ្មី ហៅថាបដិសន្ធិចិត្ត បានដល់ កាមបដិសន្ធិ ១០ រូបបដិសន្ធិ ៥ អរូបបដិសន្ធិ ៤ រួម ១៩រូប

- ពាក្យថាភវង្គៈ ញែកចេញ ២បទគឺ :

| | | |
|---|---|---|
| ភវៈ | + | អង្គៈ |
| ភវៈ | ប្រែថា | ភព ឬ ជាតិ |

អង្គះ ប្រែថា ប្រដាប់.គ្រឿង

តាមវិគ្គហថា ភវស្ស អង្គំ ភវង្គំ ប្រែថា ចិត្តជាគ្រឿងរបស់ភព បានដល់ចិត្តជាភវង្គចិត្ត ១៩ដួង ។

- ពាក្យថាចុតិ តាមវិគ្គហថា : ចវនំ ចុតិ

ប្រែ ការផ្លាស់ប្តូរ ហៅថា ចុតិ ។ ក្នុងព្រះបាលីវិភង្គ ព្រះបរមសាស្តាទ្រង់សំដែងទេសនា ឈ្មោះនៃចុតិមាន ១០ ប្រការគឺ :

ចុតិ ចវនតា ភេទោ អន្តធាន មច្ចុ មរណៈ កាលកិរិយា ខន្ធភេទ កឡេវរស្សនិក្ខេប ជីវិតិន្ទ្រិយស្ស ឧបច្ឆេទ រួម ១០ បានដល់ចុតិចិត្ត ១៩ដួង ។

មានសេចក្តីថា ចិត្ត ១៩ដួងនេះ មានកិច្ច ៣យ៉ាងគឺ

១-មានតួនាទីតមកអំពីជាតិមុន ។

២-ធ្វើតួនាទីជាសន្តតិ តចិត្ត ១ដួង ទៅនិងចិត្តមួយដួងទៀត ។

៣-ធ្វើតួនាទី ផ្លាស់ប្តូរទៅភពថ្មី ។

រូមមានកិច្ច ៣យ៉ាង ព្រោះហេតុដូច្នោះ ចិត្ត ១៩ ដួងនេះ កាលខណៈដែលចុតិ ហៅថាចុតិចិត្ត សេចក្តីពិតមានតែ ១៩ដួងប៉ុណ្ណោះ ។ អាស្រ័យខណៈដែលធ្វើកិច្ចនោះ ហៅថា បដិសន្ធិ ភវង្គចុតិ ជាឈ្មោះតាមអភិធម្ម ដូច្នេះ ។

**សួរ** ក្នុងកាមបដិសន្ធិ ១០ កុសលវិបាក អកុសលវិបាក សន្តីរណ ២ដួង ធ្វើឱ្យកើតក្នុងអបាយភូមិ និង កាមសុគតិ-ភូមិបដិសន្ធិក្នុងមនុស្ស និង ចាតុម្មហារាជិកាទេវតា តាមដែលបានពោលមកហើយ ក្នុងបរិច្ឆេទទី ១ ថា សន្តីរណៈប្រែថា ការពិចារណាក្នុងបញ្ចទ្វារវិថី ដែលសំដែងមកហើយថា សន្តីរណៈរមែងកើតខាងក្រោយ សម្បដិច្ឆន្ន ប៉ុន្តែអធិប្បាយក្នុងបរិច្ឆេទនេះ សន្តីរណមកជាបដិសន្ធិទៀត ។

ការបដិសន្ធិនេះ មានការពិចារណាទៀត ឬយ៉ាងណា ?

**ឆ្លើយ** ពាក្យថាសន្តីរណ តាមអភិធម្មត្ថវិភាវនីយដីកាថា : សម្មា តីរេតិ យថាសម្បិច្ឆិតំ រូបាទិអារម្មណំ វិមំសតីតិ

សន្តីរណំ

**ប្រែ** សន្តីរណចិត្តដូចនេះ ពិចារណាអារម្មណ៍ មានរូបារម្មណ៍ជាដើម ដែលសម្បដិច្ឆន្នចិត្ត ទទួលមក ដូច្នោះហៅថាសន្តីរណៈ បានសេចក្តីសង្ខេប១ថា " ការពិចារណាត្រិះរិះអារម្មណ៍នោះឯង " ។

ត្រិះរិះពិចារណានោះគឺ កាលបញ្ចទ្វារវិថីកើតខាងក្រោយសម្បដិច្ឆន្នៈទទួលអារម្មណ៍ចូល ហើយសន្តីរណៈក៏រមែងកើតហើយ ពិចារណាអារម្មណ៍តទៅ ដែលថាសន្តីរណៈមានមុខតួនាទី ២ ឬ ៥ យ៉ាងគឺ :

កាលខណៈដែលបដិសន្ធិ សន្តីរណៈត្រូវប្រកបដោយឧបេក្ខាវេទនាក៏មានមុខតួនាទី ជាប់តមកពីភពមុន ( ជាតិមុន ) ។

កាលខណៈដែលជាភវង្គ ក៏មានមុខតួនាទីជាសន្តតិ ។ កាលខណៈដែលស្លាប់ ក៏មានមុខតួនាទីផ្លាស់ប្តូរ អំពីភពចាស់ ។

Page ൧൭൫ missing

Page ១៧៦ missing

កាមសុគតិភូមិជាមនុស្សពិការជាដើម ។ ពាក្យថា ជច្ចន្ធៈ ប្រែថាអ្វី ហើយមានប៉ុន្មានជំពូក ដែលហៅថាជច្ចន្ធៈបាន ?

**ឆ្លើយ** ពាក្យថាជច្ចន្ធៈ តាមវិគ្គហថា ជាតិយា អន្ធា ជច្ចន្ធោ ប្រែថា ភ្នែកខ្វាក់មកពីកំណើត ហៅថា ជច្ចន្ធៈ តែតាមបាលីថាជច្ចន្ធាទិ ។ ជច្ចន្ធាទិ ញែកបានពីរបទគឺ ជច្ចន្ធ + អាទិជច្ចន្ធ ប្រែថា អ្នកដែលខ្វាក់មកពីកំណើត អាទិ ប្រែថាជាដើមអាស្រ័យពាក្យ អាទិ ហើយបានដល់ជច្ចន្ធៈ ពធិរៈ មនុស្សត្រចៀកថ្លង់ ជច្ចឃានៈ = មនុស្សខូច ( មានកំហត ) ច្រមុះ ។ ជច្ចគូត = មនុស្ស ( គ ) មនុស្សពិបាកនិយាយ ជច្ចជឡ = មនុស្សមិនទាបមិនខ្ពស់ ជច្ចមមត្តក = មនុស្ស គ មម្ម = មនុស្សនិយាយមិនបានការ មិនបានសេចក្តី ។ ទាំងអស់នេះរួមគ្នាបានជាពួកមនុស្សកើតដោយ ឧបេក្ខាអកុសលវិបាកសន្តីរណៈទាំងអស់ ដូចដែលបានពោលមកហើយ ។

**សួរ** វិធីរាប់អាយុរបស់ទេវតា តាមក្បួនតម្រាចាស់ៗ ចាតុម្មហារាជិកា អាយុ ៥០០ឆ្នាំទិព្វ តាវត្តិសា ១០០០ឆ្នាំទិព្វ យាមា ២០០០ឆ្នាំទិព្វ ដូច្នេះជាដើមថា ៖ ពីរដង របស់ទេវតាជាន់ទាប បានដល់អាយុទេវតាជាន់លើ ។

ក្នុងអភិធម្មត្ថសង្គហៈពោលថា តតោ ចតុគ្គុណំ ប្រែថា មាន ៤ដូងប៉ុណ្ណោះ តើមានសេចក្តីយ៉ាងណា ព្រោះ ៥០០ឆ្នាំ ទិព្វ ក្នុងចាតុម្មហារាជិកា គុណដោយ ៤ ត្រូវបាន ២០០០ឆ្នាំទិព្វមែនឬទេ ?

**ឆ្លើយ** វិធីរាប់អាយុរបស់ទេវតា ទាក់ទងមកពីពេលវេលា គឺ ក្នុងចាតុម្មហារាជិកាភូមិ មួយថ្ងៃមួយយប់ ក្នុងមនុស្ស ដល់ទៅ ៥០ឆ្នាំពេញបរិបូណ៌ យកតាមទំនងនេះជាទ្រឹស្តី ១០០ឆ្នាំមនុស្ស ត្រូវជាមួយថ្ងៃ មួយយប់ក្នុងតាវត្តិសក្នុង យាមាភូមិ ក៏ដូច្នោះជាដើម ។

ដូច្នេះ បានសេចក្តីថា វិធីរាប់ពីឆ្នាំ មនុស្សនេះមួយ យ៉ាង និងវិធីរាប់ពីទេវតាម្យ៉ាង ជាវិធីរាប់ពីរយ៉ាង ។ វិធី

Page ១៧៩ missing

Page ១៧៦ missing

# វិធីរាប់តាមកាលមនុស្ស

| | | |
|---|---|---|
| ចាតុម្មហារាជិកា | អាយុ | ៩លានឆ្នាំ |
| តាវត្តឹសា | ៩លាន × ៤ | អាយុ ៣៦ លានឆ្នាំ |
| យាមា | ៣៦លាន × ៤ | អាយុ ១៤៤លានឆ្នាំ |
| តុសិតា | ១៤៤លាន × ៤ | អាយុ ៥៧៦លានឆ្នាំ |
| និម្មានរតី | ៥៧៦លាន × ៤ | អាយុ ២៣០៤លានឆ្នាំ |
| បរនិម្មិតវសវត្តី | ២៣០៤លាន × ៤ | អាយុ ៩២១៦លានឆ្នាំ |
| | | = ៩២១កោដិ ៦លានឆ្នាំ |

ប៉ុន្តែវិធីដែលធៀបឆ្នាំមនុស្ស និង ទេវតាចាតុម្មហា-រាជិកានេះ ប្រៀបធៀប ៥០ឆ្នាំ មនុស្ស ≈ ស្មើនឹង ១ថ្ងៃ ១យប់របស់ទេវតាចាតុមហារាជិកា ក៏បានសេចក្ដីល្អហើយ (មេត្តាមើលសេចក្ដីបរិយាយខាងដើមបរិច្ឆេទផង) ។

**សួរ** តាមដែលព្រះអនុរុទ្ធាចារ្យ សំដែងរូបាវចរ ១៥ដួង គឺ រូបាវចរកុសល ៥ដួង រូបាវចរវិបាក ៥ដួង រូបាវចរកិរិយា

៥ដួង ដូច្នេះនេះជាដើម ។ រូបាវចរកុសល និង រូបាវចរ វិបាក ១០ដួងនេះ ។

កាលប្រកបដោយភូមិ ហើយដែលកើតកុសល-វិបាកទាំងនេះ ( ទាំងអស់ ) រមែងមានត្រឹមតែ ៤ ភូមិគឺ លោកអធិប្បាយថា បឋមជ្ឈានវិបាក រមែងកើតក្នុងបឋម-ជ្ឈានភូមិទាំង ៣ ។ ទុតិយ តតិយជ្ឈានវិបាក រមែងកើត ក្នុងភូមិទាំង ៣ ។ ចតុត្ថជ្ឈាន រមែងកើតក្នុងតិតយជ្ឈាន ។ បញ្ចមជ្ឈាន រមែងកើតក្នុងចតុត្ថជ្ឈាន ដូច្នេះឯង ។

រឿងនេះ ពិចារណាក៏ឃើញ មិនត្រង់ឬ មិនចុះសំរុង គ្នា និងព្រះយោគីបុគ្គល គឺ ទុតិយ តតិយជ្ឈាន ឈានទាំង ពីរកើតក្នុងតតិយជ្ឈានភូមិ ។ ព្រះយោគីចាញ់ប្រៀបច្រើន ព្រោះអ្វី ? ទើបបានកើតដូច្នេះ សុំឱ្យឆ្លើយផង ។

**ឆ្លើយ** កាលដែលបញ្ហានេះកើតឡើងបាន ក៏ព្រោះព្រះ អនុ-រុទ្ធាចារ្យទេតើ ! គឺព្រះបរមសាស្តាទ្រង់សំដែងឈានទុក ៤ គឺ បឋម ទុតិយ តតិយ ចតុត្ថជ្ឈានប៉ុណ្ណោះទ្រង់ទេសនា

Page ១៣៩ missing

Page ୧୮୦ missing

** សួរ** តាមបកិណ្ណកបរិច្ឆេទ ថា បដិសន្ធិចិត្ត ១៩ ដួង ក្នុងវិថីមុត្តកសង្គហថា បដិសន្ធិចិត្ត ២០ដួង គឺ កាមបដិសន្ធិ ១០ដួង រូបបដិសន្ធិ ៦ដួង អរូបបដិសន្ធិ ៤ដួង រួម ២០ដួង ផ្សេងៗគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** តាមធម្មតា បដិសន្ធិចិត្ត រមែងមាន ១៩ដួង ព្រោះជាការបរមត្ថទៅហើយ ។ ក្នុងការដែលលោកសំដែងថាមាន ២០ដួងនោះ គ្មានជានាមបដិសន្ធិទាំងអស់ទេ គឺ អនាម បដិសន្ធិ ១៩ដួង រូបបដិសន្ធិ ១ដួង ដូចជាអសញ្ញីសត្តព្រហ្ម មេត្តាមើលបាលី អសញ្ញិសត្តានំ បន រូបមេវ បដិសន្ធិ ហោតិ ។ ប្រែថា អសញ្ញិសត្តព្រហ្ម ជារូបបដិសន្ធិ ឥមា ឆ រូបាវចរបដិសន្ធិយោ នាម ។ ប្រែថា - បដិសន្ធិ ៦ដួងនេះ ហៅថា រូបាវចរបដិសន្ធិ ព្រោះហេតុដូច្នោះ បដិសន្ធិចិត្ត ១៩ដួង រូបបដិសន្ធិ ១ដួង រួម ២០ដួង ក៏ ត្រឹមត្រូវ ។

**សួរ** អាយុបរិច្ឆេទរបស់ព្រហ្មរាប់ដោយស័ព្ទថាកប្បនោះល្មមដែលនឹងចូលចិត្តហើយ កប្បមាន ៤ គឺ ១-អាយុកប្ប ២- អន្តរកប្ប ៣- អសង្ខេយ្យកប្ប ៤- មហាកប្ប ។ រួម ៤ កប្បនេះបានដល់កប្បអ្វី ?

**ឆ្លើយ** តាមដែលព្រះគន្ថរចនាចារ្យ ពោលទុកផ្សេង១ថា សំរាប់បឋមជ្ឈានភូមិទាំង ៣ រាប់ដោយអសង្ខេយ្យកប្ប ព្រោះភូមិ ៣ នេះគ្រាដែលលោកវិនាសគ្រប់១គ្រា ត្រូវវិនាសជានិច្ច ដូច្នេះ ត្រូវរាប់ជា អសង្ខេយ្យកប្ប ។ តាំងពីទុតិយជ្ឈានភូមិឡើងទៅ ត្រូវរាប់ដោយមហាកប្ប ព្រោះទុតិយជ្ឈានទាំងអស់នេះ ផុតពីលោកវិនាសបាន ១គ្រា ។ មានសេចក្តីថា ពេលដែលលោកវិនាស ១គ្រារួចផុតទៅបាន ព្រោះអាយុតាំង ២មហាកប្បឡើងទៅ ដូច្នេះលោកវិនាសគ្រាទី១ ទើបលោកយើងនេះតាំងនៅបាន ។ កាលគ្រាដែលត្រូវវិនាសដោយភ្លើង ហៅថា តេជោសំវដ្ដកប្បកាលត្រូវវិនាសដោយទឹក ទំលាយវិនាសដល់ ទុតិយជ្ឈានភូមិ

ហៅថា អបោសំវដ្តកប្ប ដែលត្រូវទំលាយវិនាសដោយខ្យល់ ទំលាយវិនាសដល់ តតិយជ្ឈានភូមិទាំង ៣ ហៅថា វាយោសំវដ្តកប្ប ព្រោះហេតុដូច្នេះ បដិសន្ធិទាំង ៣ នេះ ត្រូវវិនាសរាល់១គ្រា មិនអាចនឹងឈរនៅ ( តាំងនៅ ) រហូតកប្បបាន ទើបចាំបាច់កំណត់អាយុដោយ អសង្ខេយ្យកប្ប ។

**សួរ** អរូបភូមិ ៤ ជានាមធម៌ ហើយមានជាជាន់១ ដូចរូបព្រហ្មបានទេ ?

**ឆ្លើយ** តាមអភិធម្មថា ទោះបីជានាមធម៌ ក៏ជាសត្វ ១ ជំពូកដែលប្លែកអស្ចារ្យជាងសត្វទាំងពួង ដែលត្រូវនៅម្នាក់១មួយជាន់ដើម្បីមិនឱ្យលាយឡំតាមបុណ្យវាសនារបស់គេ ។

តាមអដ្ឋកថាអធិប្បាយថា អរូបភូមិ ត្រូវមាន ៤ ជាន់ ជាប់តាមលំដាប់ ក្នុងធម្មហទយវិភង្គ ព្រះបាលីថា កតមេ ធម្មា អរូបាវចរហេដ្ឋតោ អាកាសានញ្ចាយតនូបគេ

ទេវេ បរិយន្តំ ករិត្វា ឧបរិមតោ នេវសញ្ញានាសញ្ញាយត-នូបគេ ទេវេ អន្តោ ករិត្វា យំ ឯតស្មិំ អន្តរេ ឯត្ថាវចរា ឯត្ថ បរិយាបន្នា សមាបន្នស្ស វា អប្បន្នស្ស វា ទិដ្ឋធម្មសុខ-វិហារិស្ស វា ចិត្ត ចេតសិកា ធម្មា ឥមេ ធម្មា អរូបាវចរា ។

**ប្រែ** ក្នុងទីនេះ អរូបាវចរបានដល់ធមិអ្វីខ្លះ ? រាប់តាំងពីខាងក្រោមអាកាសានញ្ចាយតនភូមិ រហូតដល់ខាងលើ នេវសញ្ញានាសញ្ញាយតនភូមិ ក្នុងភូមិទាំង ៤ នេះអ្នកដល់សមាបត្តិ ឬ អ្នកដែលបានទៅកើត ឬ អ្នកដែលបានចូលនិរោធសមាបត្តិក្តី ចិត្តនិង ចេតសិកទាំងអស់រមែងមាននៅ នាមធមិទាំងនេះ ហៅថា អរូបាវចរ ។ ពិចារណាតាមព្រះបាលីសំដែងថា អរូបភូមិ ៤ នេះ មានជាន់ទាបជាន់ខ្ពស់គឺ ហេដ្ឋតោ និង ឧបរិមតោ មានន័យថា រាប់តាំងពីក្រោមដល់ខាងលើ អរូបភូមិ ៤ ត្រូវប្រាកដនៅជាជាន់ ។ តាមអដ្ឋកថាអធិប្បាយថា ព្រោះហេតុដូច្នោះ ត្រូវវិនិច្ឆ័យថា តាមលំដាប់ភូមិនោះត្រឹមត្រូវល្អហើយ ។

**សួរ** តាមដែលមនុស្សយើងចូលចិត្តគ្នាហើយថា អរូបធម៌ ឬ នាមធម៌ រមែងអាស្រ័យវត្ថុជានិច្ច ហើយអាស្រ័យអារម្មណ៍ជានិច្ច ក្នុងអរូបព្រហ្មនោះ មានវត្ថុជាទីអាស្រ័យខ្លះទេ ?

**ឆ្លើយ** តាមដែលមនុស្សយើងទាំងឡាយចូលចិត្តថា នាមធម៌មានវត្ថុជាទីអាស្រ័យនោះ ត្រឹមត្រូវហើយ តែត្រូវមានឋានៈគឺ អរូបធម៌ត្រូវអាស្រ័យ ក្នុងកាមភូមិ និង រូបភូមិ ។ ក្នុងអរូបភូមិនោះមិនជាទីអាស្រ័យ ព្រោះក្នុងទីនេះមិនមានរូប ដូច្នេះ ក្នុងអភិធម្មត្ថសង្គហៈ បកិណ្ណកបរិច្ឆេទ ព្រះអនុរុទ្ធាចារ្យ រាប់រងអះអាងក្នុងគាថាសង្គហៈថា តេចត្តាឡីស និស្សាយ ទ្វេ ចត្តាឡីស ជាយរេ និស្សាយ ច អនិស្សាយ បាការុប្បា អនិស្សិតា ។

ចិត្ត ៤៣ដួង រមែងកើតដោយអាស្រ័យវត្ថុរូប ។ ចិត្ត៤២ដួង ជួនកាលអាស្រ័យវត្ថុរូប ជួនកាលមិនអាស្រ័យវត្ថុរូប ប៉ុន្តែអរូបវិបាក ៤ដួង មិនបានអាស្រ័យវត្ថុឡើយ ។

ចិត្ត ៤២ដួងកាលបានកើតក្នុង បញ្ចវោការភូមិនោះ អាស្រ័យ ហទយវត្ថុ កាលកើតក្នុងចតុវោការភូមិ មិនបាន អាស្រ័យ តែអរូបវិបាក រមែងកើតបាន ដោយមិនត្រូវ អាស្រ័យ ដូច្នេះ ត្រូវវិនិច្ឆ័យថា ធម្មតានាមធម៌ កាលកើត ឡើងនោះ អាស្រ័យក៏បាន មិនអាស្រ័យក៏បាន តាមឋានៈ របស់សភាវៈ ។

**សួរ** តាមវិធីរបស់បុគ្គលភេទ ក្នុងអរូបភូមិព្រះសោតា ព្រះសកទា ព្រះអនាគា ជាដើម អរិយៈ និង បុថុជ្ជនមាន ៨ ពួក ពួកអរិយបុគ្គលទាំងអស់ កាលនឹងឡើង អរិយមគ្គ-ផល ជាន់ខ្ពស់ៗនោះ ការឡើងវិបស្សនា និង វិថីកើត យ៉ាងណាខ្លះ ?

**ឆ្លើយ** កាលឡើងវិបស្សនា និង អរិយមគ្គ នោះហើយតែ បុព្វធិកា គឺ អាស្រ័យបុណ្យចាស់ ទើបឡើង អរិយមគ្គ-ផល បានងាយ ។ ការឡើងវិថី ក៏ជាធម្មតា តាមធម្មជាតិ របស់ចិត្ត ព្រោះធម្មតាចិត្តនៅឯណា ឬ កើតឯណាក៏ដោយ

ត្រូវមានការកើត ការរលត់ជានិច្ច មានន័យថា មានសន្តិតិកើតរលត់ជាធម្មតា ។ ព្រះអនុរុទ្ធាចារ្យ បានពោលទុកថា មហគ្គតវិបាកានិ នវ បដិសន្ធិភវង្គចុតិវសេន បវត្តន្តិ ។

**ប្រែ**- ចិត្តជាមហគ្គតចិត្ត ៩ ដួង រមែងកើតដោយ បដិសន្ធិភវង្គចុតិ ។ ក្នុងទីនេះមានសេចក្ដីថា អរូបចិត្តកាលទៅកើតនៅអរូបព្រហ្មនោះ មានបដិសន្ធិតមក ភវង្គចិត្តតមក ចុតិចិត្ត ។ ធម្មជាតិ ៣យ៉ាងនេះ ត្រូវមានសន្តតិទាក់ទងគ្នាដោយ ឧប្បាទៈ ឋិតិ ភង្គៈ ។ បដិសន្ធិ មិនដូច្នោះទេក៏មិនទៀងនៅតភវង្គ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យត១គ្នាមក តាមក្រសែ សន្តតិជានិច្ច ។

កាលដែលមានក្រសែត១គ្នាមក តាមធម្មជាតិ ដូច្នេះហើយ ព្រះសោតាកាលឡើងជាព្រះសកទា ព្រះសកទាក៏ឡើងជាព្រះអនាគា ដោយងាយហើយត្រូវឡើងតាមវិថីរបស់មគ្គវិថី ដល់ផលវិថី ។

## មគ្គវិថីនេះគឺ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ‖‖ | ‖‖ | ‖‖ | ‖‖ | ‖‖ | ‖‖ | ‖‖ | ‖‖ | ‖‖ | ‖‖ |
| ភវង្គ | មនោទ្វារ | បរិកម្ម | ឧបចារ | អនុលោម | គោត្រភូ | សកទាគាមិមគ្គ | សកទាគាមិផល ១ | សកទាគាមិផល ២ | ភវង្គ |

កាលព្រះសោតាឡើងកាន់ព្រះសកទា ឡើងវិថីតាមបែបនេះកាលនឹងឡើងកាន់ អនាគា ក៏ទំនងដូចគ្នាដែរ

## សំដែង កម្មចតុក្កតាមបាលី

ជនកំ ឧបត្ថម្ភកំ ឧបបីឡកំ ឧបឃាតកញ្ចេតិ កិច្ចវសេន គរុកំ អាសន្នកំ អាចិណ្ណកំ កដត្តាកម្មញ្ចេតិ បាកទាន បរិយាយេន ។

ទិដ្ឋធម្មវេទនីយំ ឧបបជ្ជវេទនីយំ អបរាបរវេទនីយំ អហោសិកម្មញ្ចេតិ បាកកាលវសេន ចត្តារិ កម្មានិ នាម ។

តថា អកុសលំ កាមាវចរកុសលំ រូបាវចរកុសលំ អរូបាវចរកុសលញ្ចេតិ

បាកដ្ឋានវសេន ។

តត្ថ អកុសលំ កាយកម្មំ វចីកម្មំ មនោកម្មញ្ចេតិ កម្មទ្វារវសេន តិវិធំ ហោតិ ។

កថំ បាណាតិបាតោ អទិន្នាទានំ កាមេសុ មិច្ឆាចារោចេតិ កាយវិញ្ញត្តិសង្ខាតេ កាយទ្វារេ ពាហុល្លវុត្តិតោ កាយកម្មំ នាម ។

មុសាវាទោ បិសុណាវាចា ផរុសវាចា សម្ផប្បលាបោ ចេតិ វចី វិញ្ញត្តិ សង្ខាតេ វចីទ្វារេ ពាហុល្លវុត្តិតោ វចីកម្មំ នាម ។

អភិជ្ឈាព្យាបាទោ មិច្ឆាទិដ្ឋិចេតិ អញ្ញត្រាបិ វិញ្ញត្តិយា មនស្មីំចេវ ពាហុល្លវត្តិតោ មនោកម្មំ នាម ។

តេសុ បាណាតិបាតោ ផរុសវាចា ព្យាបាទោ ច ទោសមូលេន ជាយន្តិ ។ កាមេសុ មិច្ឆាទិដ្ឋិ ច លោភមូលេន ។ សេសានិ ចត្តា-

**វិបិ ទ្វីហិ មូលេហិ សង្គហន្តិ ។**

**ចិត្តុប្បាទវសេន បនេតំ អកុសលំ សព្វថាបិ ទ្វាទសវិធំ ហោតិ ។**

**ប្រែសេចក្ដីថា** កម្មដែលថាដោយកិច្ចនោះមាន ៤កម្មគឺៈ ជនកកម្ម ឧបត្ថម្ភ ឧបបីឡិកកម្ម ឧបឃាតកកម្ម រួម ៤កម្ម

- ថាដោយបាកទាន មាន ៤កម្មគឺ គរុកម្ម អាសន្នកម្ម អាចិណ្ណកម្ម កដត្តាកម្ម រួម ៤ កម្ម ។

- ថាដោយ បាកកាល មាន ៤ កម្មគឺ ទិដ្ឋធម្មវេទ-និយកម្ម ឧបបជ្ជវេទនិយកម្ម អបរាបរវេទនីយកម្ម អហោសិកម្ម រួម ៤ កម្ម ។

- ថាដោយ បាកដ្ឋាន មាន ៤ កម្មគឺ ៈ អកុសល កាមាវចរកុសល រូបាវចរកុសល អរូបាវចរកុសល រួម ៤ កម្ម ។

ក្នុងទីនេះ អកុសលកម្ម ថាដោយទ្វារនោះមាន កាយកម្ម វចីកម្ម មនោកម្ម រួមកម្ម ៣ ទ្វារ ។

*  កម្មទ្វារយ៉ាងណា ? បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ រួម ៣យ៉ាងនេះ ដោយច្រើនរមែង កើតក្នុងកាយទ្វារ ដែលជាកាយវិញ្ញត្តិ ដូច្នេះ ហៅថា កាយកម្ម

*  មុសាវាទ បិសុណវាចា ផរុសវាចា សម្ផប្បលាវាចា រួម ៤យ៉ាងនេះដោយច្រើនរមែងកើតក្នុងមនោទ្វារ ដែលហៅវចីវិញ្ញត្តិដូច្នេះ ហៅថាវចីកម្ម ។

*  អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ រួម៣យ៉ាងនេះដោយច្រើន ក្រៅអំពីវិញ្ញត្តិទាំងពីរ ដូច្នេះ ហៅថាមនោកម្ម ។

-ក្នុងកម្មទ្វារ ទាំង ៣នេះ បាណាតិបាត ផរុសវាចា ព្យាបាទ រួម ៣ យ៉ាង កើតព្រោះទោសមូលចិត្ត ។

-កាមេសុមិច្ឆាចារ អភិជ្ឈា មិច្ឆាទិដ្ឋិ រួម ៣យ៉ាងនេះ កើត ព្រោះលោភមូលចិត្ត ។

-នៅសល់ទុច្ចរិត ៤ ទៀតនោះកើតមកព្រោះ មូលទាំងពីរ គឺលោភមូល និង ទោសមូល ។

ការពិតគឺអកុសលចិត្ត ១២នេះឯង ។

## សំដែងបាលី "ត"

កាមាវចរកុសលំ បិ កាយទ្វារេ បវត្តំ កាយកម្មំ វចីទ្វារេ បវត្តំ វចីកម្មំ មនោទ្វារេ បវត្តំ មនោកម្មញ្ចេតិ កម្មទ្វារវសេន តិវិធំ ហោតិ ។ តថា ទានសីលភាវនាវសេន ។ ចិត្តុប្បាទវសេន បនេតំ អដ្ឋវិធំ ហោតិ ។ ទានសីលភាវនាអបចាយនវេយ្យាវច្ចបត្តិទាន-បត្តានុមោទនា ធម្មស្សវនធម្មទេសនា ទិដ្ឋុជុកម្មវសេន ទសវិធំ ហោតិ ។

តំ បនេតំ វីសតិធម្បិ កាមាវចរកម្ម-មិច្ចេវ សង្ខយំ គច្ឆតិ រូបាវចរកុសលំ បន មនោកម្មមេវ ។ តំបិ ភាវនាមយំ អប្បនា-បត្តំ-ឈានង្គភេទេន បញ្ចវិធំ ហោតិ ។

តថា អរូបាវចរកុសលញ្ច មនោកម្មំ តំ បិ ភាវនាមយំ អប្បនាបត្តំ អារម្មណាទិវសេន ចតុព្វិធំ ហោតិ ។

ឯត្ថាកុសលកម្មមុទ្ធច្ចរហិតំ អបាយភូមិយំ បដិសន្ធឹ ជនេតិ ។ បវត្តិយំ បន សព្វំបិ ទ្វាទសវិធំ សត្តាកុសលបាកានិ សព្វត្ថាបិ កាមលោកេ ច រូបលោកេ ច យថារហំ វិបច្ចតិ កាមាវចរកុសលំបិ កាមសុគតិមេវ បដិសន្ធឹ ជនេតិ ។ តថា បវត្តិយញ្ច មហាវិបាកានិ អហេតុកវិបាកានិ បន អដ្ឋបិ សព្វត្ថាបិ កាមលោកេ ច រូបលោកេ ច យថារហំ វិបច្ចតិ ។

តត្ថាបិ តិហេតុកមុក្កដ្ឋំ កុសលំ តិហេតុកំ បដិសន្ធឹ ទត្វា បវត្តេ សោឡស វិបាកានិ វិបច្ចតិ ។

តិហេតុកមោមកំ ទ្វិហេតុកមុក្កដ្ឋញ្ច
កុសលំ ទ្វិហេតុកំ បដិសន្ធឹ ទត្វា បវត្តេ
តិហេតុក្កដ្ឋរហិតានិ ទ្វាទស វិបាកានិ
វិបច្ចតិ ។

ទ្វិហេតុកមោមកំ បន ' កុសលំ អហេតុក~
មេវ បដិសន្ធឹ ទេតិ បវត្តេ ច អហេតុកវិ~
បាកានេវ វិបច្ចតិ ។

អសង្ខារំ សសង្ខារវិបាកានិ ន បច្ចតិ
សសង្ខារមសង្ខារវិបាកានីតិ ~កេ ចិ~ន
តេសំ ទ្វាទស បាកានិ ទសដ្ឋ ច យថាក្កមំ
យថាវុត្តានុសារេន យថា សម្ភវមុទ្ទិ
សេ ។

ប្រែ កាមាវចរកុសល មាន ៣ ប្រការ ដោយកម្មទ្វារគឺ

១-កាយកម្ម កើតក្នុងកាយទ្វារ

២-វចីកម្ម កើតក្នុងវចីទ្វារ

៣-មនោកម្ម កើតក្នុងមនោទ្វារ

មាន៣ប្រការដូច្នេះឯង ប្រកបដោយ ទាន សីល ភាវនា អបចាយនៈ វេយ្យាវច្ចៈ បត្តិទាន បត្តានុមោទនៈ ធម្មស្សវនៈ ធម្មទេសនា ទិដ្ឋុជុកម្ម រួម ១០ ប្រការ ។

កុសលកម្ម អកុសលកម្ម ២០ដួង ដែលពោលមកហើយនេះ រាប់ចូលក្នុងកាមាវចរកម្ម ។

រូបាវចរកុសលកម្ម រមែងកើតក្នុងមនោកម្ម ។ មនោកម្មនេះឯង សំរេចដោយភាវនា ហើយមានប្រាំប្រការ

អរូបាវចរកុសលកម្ម ជាមនោកម្ម ។ មនោកម្មនេះ សំរេចដោយភាវនា និង ដល់អប្បនាបានដូចគ្នា ។

ចាំដោយអារម្មណ៍ ៤ ប្រការ ។

ក្នុងកម្មទាំង ៤ ប្រការនេះ អកុសលកម្មដែលប្រាសចាកឧទ្ធច្ចធ្វើឱ្យកើតក្នុងអបាយទាំង ៤ ភូមិ ដោយបដិសន្ធិ ប៉ុន្តែក្នុងបវត្តិកាលនោះ ក្នុងរូបលោក ឬ

កាមលោកក៏ ដោយចិត្តជាអកុសល ១២ដួង ( អកុសលចិត្ត ១២ដួង ) រមែងធ្វើឱ្យផល គឺ អកុសលវិបាកចិត្ត ៧ ដួង ។

កាមាវចរកុសល រមែងឱ្យកើតក្នុងកាមភូមិ ១១ ជាន់ ជាបដិសន្ធិ ។ ក្នុងបវត្តិកាលនោះ កាមសុគតិ ១១ ភូមិ ធ្វើឱ្យកើតមហាវិបាក ៨ដួង ។

ក្នុងកាមលោកឬ រូបលោក រមែងឱ្យកើតជាផលគឺ កុសលវិបាក ៨ ដួង ។

ក្នុងទីនេះអកុសល ដែលជាបែបតិហេតុកឧក្រិដ្ឋ រមែងកើតជាតិហេតុក បដិសន្ធិ និង ក្នុងបវត្តិកាលនោះ ធ្វើឱ្យកើតវិបាក ១៦ដួង ។

តិហេតុកកុសល ដែលជាបែបឱមក្ក ឬ កុសលដែលជាទ្វេហេតុកឧក្រិដ្ឋ ធ្វើឱ្យកើតជាទ្វិហេតុកបដិសន្ធិ ហើយ និងក្នុងបវត្តិកាលនោះ រមែងធ្វើឱ្យកើតវិបាក ១២ដួង ដែលប្រាសចាកញាណសម្បយុត្ត កើតជាផល ។ ចំណែកទ្វិហេតុកកុសលដែលជាបែប ឱមក្កៈនេះធ្វើឱ្យកើតជា

អហេតុកបដិសន្ធិ ក្នុងបវត្តិកាល រមែងជាអហេតុកនេះឯង កើតជាផល ។

កេចិអាចារ្យថា កុសលរបស់អសង្ខារិក មិនកើត ផលសសង្ខារិក ហើយកុសលរបស់សសង្ខារិកមិនកើតផល របស់អសង្ខារិកដូច្នេះឯង ។

ក្នុងវាទៈរបស់អាចារ្យទាំងនេះ សំដែងតាមន័យ ដែលពោលមកហើយថា វិបាកចិត្ត ១២ដួង ១០ដួង និង ៨ដួង តាមលំដាប់ ។

## សំដែងបាលី "ត"

រូបាវចរកុសលំ បន បឋមជ្ឈានំ បរិត្តំ ភាវេត្វា ព្រហ្មបារិសជ្ជេសុ ឧប្បជ្ជតិ តថេវ មជ្ឈិមំ ភាវេត្វា ព្រហ្មបុរោហិតេសុ បណីតំ ភាវេត្វា មហាព្រហ្មេសុ ។

តថា ទុតិយជ្ឈានំ តតិយជ្ឈានញ្ច បរិត្តំ ភាវេត្វា បរិត្តាសុភេសុ មជ្ឈិមំ ភាវេត្វា អប្បមាណាភេសុ បណីតំ ភាវេត្វា អាភស្សរេសុ ។

ចតុត្ថជ្ឈានំ បរិត្តំ ភាវេត្វា បរិត្តាសុភេសុ

មជ្ឈិមំ ភាវេត្វា អប្បមាណសុភេសុ បណីតំ ភាវេត្វា សុភកិណ្ហេសុ

បញ្ចមជ្ឈានំ ភាវេត្វា វេហប្ផលេសុ ។ តទេវសញ្ញាវិរាគំ ភាវេត្វា អសញ្ញិសត្តេសុ ។ អនាគាមិនោ បន សុទ្ធាវាសេសុ ឧប្បជ្ជន្តិ ។ អរូបាវចរកុសលញ្ច យថាក្កមំ ភាវេត្វា អារុប្បេសុ ឧប្បជ្ជតិ ។

ប្រែ រូបាវចរកុសលនេះ កាលសម្លឹងពិនិត្យបឋមជ្ឈាន យ៉ាងតូចទាបរមែងកើតក្នុងព្រហ្មបារិសជ្ជាភូមិ ។

កាលសំម្លឹងពិនិត្យយ៉ាងកណ្តាល រមែងកើតក្នុងព្រហ្មបុរោហិតាភូមិ

កាលសំម្លឹងពិនិត្យយ៉ាងប្រណីត រមែងកើតក្នុងមហាព្រហ្មាភូមិ ។

កាលសំម្លឹងពិនិត្យ ទុតិយ តតិយជ្ឈានខ្សោយ រមែងកើតក្នុងបរិត្តាភាព្រហ្មភូមិ ។ កាលសំម្លឹងពិនិត្យយ៉ាងកណ្តាល រមែងកើតអប្បមាណព្រហ្មភូមិ ។ កាលសំលឹងពិនិត្យយ៉ាងប្រណីតហើយ រមែងកើតក្នុងអភស្សរាព្រហ្មភូមិ ។ កាលសំម្លឹងពិនិត្យចតុត្ថជ្ឈាន យ៉ាងទាប រមែងកើតក្នុងបរិត្តាសុភាព្រហ្មភូមិ ។

កាលសំម្លឹងពិនិត្យ ចតុត្ថជ្ឈានយ៉ាងកណ្តាល រមែងកើតក្នុងព្រហ្ម អប្បមាណាភាភូមិ ។ ការសំលឹងពិនិត្យចតុត្ថជ្ឈានយ៉ាងប្រណីត រមែងកើតក្នុងព្រហ្មសុភកិណ្ហភូមិ ការសំម្លឹងពិនិត្យបញ្ចមជ្ឈាន រមែងកើតព្រហ្មវេហប្ផលាភូមិ ។ ការសំម្លឹងពិនិត្យដោយសញ្ញាវិរាគ គឺ ប្រាសចាក

បញ្ញាហើយ រមែងកើតក្នុងអសញ្ញីសត្តភូមិ ។

ខ.សំខាន់នោះគឺ ព្រះអនាគាមិបុគ្គល រមែងកើតក្នុងសុទ្ធាវាស ៥ភូមិ ។

កាលសំម្លឹងពិនិត្យ អរូបកុសល រមែងកើតក្នុងអរូបភូមិទាំង ៤ តាមលំដាប់ ។

## គាថាសង្គហ

**ឥត្ថំ មហគ្គតំ បុញ្ញំ យថាភូមិ ១ វត្ថិតំ ជនេតិ សទិសំ បាកំ បដិសន្ធិប្បវត្តិយំ ២**

**ប្រែសេចក្តីថា**

ដូចដែលបានពោលមកហើយ ដោយប្រការទាំងពួងមហគ្គតកុសលចិត្ត ធ្វើឱ្យកើតផលក្នុងភូមិដែលកំណត់ទុក

កាលខណៈដែលបដិសន្ធិ និង បវត្តិកាលខាងមុខដែលសម និង កុសលចិត្ត ។

**អយមេត្ថ កម្មចតុក្កំ** **ប្រែថា** ដូចដែលពោលមកហើយជាកម្ម ចតុក្កៈ ក្នុងបរិច្ឆេទទី ៥ គឺ

# អធិប្បាយកម្មចតុក្កៈ

ពាក្យថាកម្ម បានដល់ចេតនារបស់កុសល ឬ របស់អកុសលដែលបានធ្វើហើយហៅថាកម្ម ។ កម្មនេះ មានច្រើនយ៉ាង ដូចនិងពោលតទៅនេះ គឺ

ជនកកម្ម ជាកម្មមួយបែប ដែលធ្វើឱ្យវិបាក និងកម្មជរូបកើតក្នុងវេលា បដិសន្ធិ បវត្តិកាល ។

ឧបត្ថម្ភកកម្ម ជាកម្មមួយបែបដែលជួយឧបត្ថម្ភឱ្យជនកកម្មកើត ឬ កាលជនកកម្មកើតហើយក៏ល្អ ជួយឧបត្ថម្ភចំពោះផលរបស់ជនកកម្មក៏បាន ។

ឧបបីឡកកម្ម ជាកម្មមួយបែប ដែលធ្វើឱ្យកើតសេចក្តី ឬ ជិទាស់កម្មចាស់ដើម្បីមិនឱ្យកើតផល ឬ កាលកើតផលហើយក៏ដោយ ធ្វើមិនឱ្យបានផលច្រើន ។

ឧបឃាតកកម្ម ជាកម្មមួយបែបដែលកាត់កម្មដទៃ-ៗផលរបស់កម្មដទៃៗក៏បាន ។

រួម ៤ កម្មដែលបានអធិប្បាយមកនេះ ។

អធិប្បាយតាមតួនាទីរបស់កម្ម ជាតិរបស់កម្ម ឬតាមកិច្ចរបស់កម្ម រមែងឱ្យផលទាំងពីរចំណែក ទាំងកុសល និង អកុសលគឺ ជនកៈមានកុសលជនកៈ អកុសលជនកៈ ឧបត្ថម្ភកៈ ក៏មានកុសល ឧបត្ថម្ភកៈ អកុសល ឧបត្ថម្ភកៈ ឧបបីឡិកកម្ម ក៏មានកុសល ឧបបីឡិកកម្មអកុសល ឧបបីឡិកៈ ។

ឧបឃាតកកម្មក៏មានកុសល ឧបឃាកៈអកុសល ឧបឃាដកជាគូ១គ្នា ។

ចំាដោយលំដាប់នោះគឺ : គរុកម្ម អាសន្នកម្ម អាចិណ្ណកម្ម កដត្តាកម្ម រួម ៤ កម្ម ។ ក្នុងទីនេះពាក្យថា គរុកម្មនេះ បានដល់កម្មមួយបែប ដែលមានផល្លានិសង្ស-ច្រើនជាទី បំផុត គឺ កម្មដែលមានកម្លាំងក្រៃលែង ។ ជាមួយកម្មផ្សេង១ មិនអាចនិងកាត់ ឬ ជំទាស់បានសូម្បីតែបន្តិចឡើយ ។

អាសន្នកម្ម បានដល់កុសល ឬ អកុសលកម្មដែល

បានធ្វើជិតនិង ស្លាប់ កុសល ឬ អកុសលកម្មដែលបាននឹក ( ឬ នឹកបាន ) កាលវេលាជិតនឹងស្លាប់ក៏មាន ។

អាចិណ្ណកម្ម កុសល ឬ អកុសលដែលបានធ្វើច្រើនខណៈកុសល ឬ អកុសល សូម្បីនឹងបានធ្វើមកហើយតែមួយខណៈតែធ្វើឱ្យកើត អាចិណ្ណ នៅជានិច្ច ( គឺ កម្មដែលសន្សំមករឿយៗជាប់ជានិច្ច ) ។

កដត្តាកម្ម បានដល់កុសល អកុលចាស់ដែលបានធ្វើមកហើយក្នុងអតីតកាល ឬ កុសល អកុសល ដែលបានធ្វើដោយសេចក្ដីមិនដឹង ឬ មិនមានសេចក្ដីប្រយ័ត្នប្រយែង ។

រួម ៤ កម្មកើតហើយនេះ ឱ្យផលតាមលំដាប់គឺគរុកម្មឱ្យផលមុន ។ កាលមិនមានគរុកម្ម ក៏មិនមានគរុកម្មជាតួនាទីរបស់អាសន្នកម្ម កាលមិនមានអាសន្នកម្មជាតួនាទីរបស់អាចិណ្ណកម្ម កាលមិនមានអាចិណ្ណកម្មហើយ ទើបដល់កដត្តាកម្ម ដោយលំដាប់ដូចនេះ ។

ថាដោយកម្មនោះ គឺ ទិដ្ឋធម្មវេទនីយកម្ម ឧបបជ្ជ -

វេទនីយកម្ម អបរាបរវេទនីយកម្ម អហោសិកម្ម ។ រួម ៤ កម្ម ។

ទិដ្ឋធម្មវេទនីយកម្ម បានដល់កុសល អកុសលកម្ម ដែលឱ្យផលក្នុងជាតិបច្ចុប្បន្ន ឬ ឱ្យផលទាន់ភ្នែកក៏ថាបាន (តាមវោហារ) ។

ឧបបជ្ជវេទនីយកម្ម បានដល់កុសល អកុសលកម្ម ដែលឱ្យផល ក្នុងជាតិជាលំដាប់ គឺជាតិទី២ ។

អបរាបរវេទនីយកម្ម បានដល់កុសល អកុសល-កម្មដែលឱ្យផលតាំងពីជាតិទី ៣ រហូតដល់បរិនិព្វានធាតុ ។

អហោសិកម្ម បានដល់កុសល អកុសលកម្មដែលមិន ឱ្យផល ឬ ដល់កាលវេលាដ៏ល្អជាកុសល អកុសលកម្មដែល រមែងចូលជាមួយកម្មដទៃៗបាន ឬ ជាកម្មដែលរមែងដោះ ស្រាយ កម្មដទៃៗ រួម ៤ កម្ម នេះឱ្យផលតាមរបស់ពេល វេលា ហៅថា បាកកាល ។

ថាដោយឋានរបស់កម្មនោះ អកុសលកម្មកាមាវចរ-

កុសល រូបាវចរកុសល និង អរូបាវចរកុសល រួម ៤ កម្ម ។

ក្នុងទីនេះ អកុសលកម្ម រមែងមាន ៣ ប្រការ គឺ :

កាយកម្ម វចីកម្ម មនោកម្ម ដោយអាស្រ័យទ្វារទាំង ៣ ។

❋ កាយកម្មអកុសលបានដល់កាយទុច្ចរិត ៣យ៉ាងគឺ :

បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ រួម ៣ ប្រការ ។

❋ វចីកម្មអកុសល បានដល់វចីទុច្ចរិត ៤ យ៉ាងគឺ :

មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាបវាចា រួម ៤ ប្រការ ។

❋ មនោកម្មអកុសល បានដល់មនោទុច្ចរិត ៣ យ៉ាងគឺ

អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ រួម ៣ ប្រការ ។

រួមអកុសលកម្ម ១០យ៉ាងនេះ បានដល់ កាយកម្ម វចីកម្ម មនោកម្ម អាស្រ័យកើតក្នុងកាយទ្វារ វចីទ្វារ និង មនោទ្វារ ។

កាមេសុមិច្ឆាចារ អភិជ្ឈា មិច្ឆាទិដ្ឋិ រួម ៣ ប្រការនេះកើតមកដោយ លោភមូល ៨ដួង ។

បាណាតិបាត ផរុវាចា ព្យាបាទ រួម៣ប្រការនេះកើតមកដោយ ទោសមូល ២ដួង ។

ទៅសល់ អទិន្នាទាន មុសាវាទ បិសុណាវាចា សម្ផប្បលាប ៤ប្រការនេះ កើតមកដោយ លោភមូល និង ទោសមូល ។

ព្រោះហេតុដូច្នោះ អកុសលដែលពោលមកហើយនេះ ថាដោយចិត្តុប្បាទ ហើយអកុសលចិត្ត រមែងមាន អកុសលចិត្ត ១២ដួង ដែលសំដែងមកហើយក្នុងបរិច្ឆេទទី១ ប៉ុណ្ណោះឯង ។

កាមាវចរ រមែងមាន ៣ កម្មទៀតគឺ :

កាយកម្មកុសល វចីកម្មកុសល មនោកម្មកុសល ដោយអាស្រ័យការកើតក្នុងទ្វារទាំង ៣ ដូចគ្នា ។

បើថាដោយ ទាន សីល ភាវនាក៏បាន ។

ចិត្តប្បាទនេះ រមែងមាន ៨ ដួង គឺ មហាកុសលចិត្ត ៨ដួងនោះឯង ។ ទាន សីល ភាវនា អបចាយន វេយ្យាវច្ចៈ បត្តិទាន បត្តានុមោទនៈ ធម្មស្សវនៈ ធម្មទេសនា ទិដ្ឋុជុកម្ម រួមជាបុញ្ញកិរិយា ១០ ។ វត្ថុ ១០ប្រការនេះ រមែងកើតក្នុង មហាកុសលចិត្តជានិច្ច ។

រួមកាមាវចរកម្ម ២០ដួង គឺ ទាំងកុសល និង អកុសល ។

រូបាវចរកុសល ឬ កុសលដែលទាក់ទងរូបាវចរគឺ មនោកម្មនោះឯង មនោកម្មនេះ ចាត់ជាភាវនាកុសលដែល ដល់អប្បនាបាន ។

ថាដោយអង្គ ឬ គ្រឿងប្រដាប់ប្រដាររបស់ឈាន មាន ៥ ប្រការគឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ( ដូចដែលបានអធិប្បាយមកហើយ ក្នុងបរិច្ឆេទទី ១ ) ។

អរូបាវចរកុសល ក៏ជាមនោកម្មដូចគ្នា ថាដោយ បុញ្ញកិរិយាវត្ថុជាភាវនា និង ថាដោយអារម្មណ៍ រួមមាន

អារម្មណ៍ គឺ អាកាសានញ្ចាយតនៈ ជាដើម ។

ក្នុងកុសលកម្ម និង អកុសលកម្ម ទាំងពីរយ៉ាងនេះ សំរាប់អកុសលកម្មឱ្យផលដូចនេះគឺ អកុសលចិត្ត ១១ ដួង ( វៀរលែង ឧទ្ធច្ច ) រមែងមានបដិសន្ធិក្នុងអបាយទាំង ៤ ជានិច្ច តែក្នុងបវត្តិកាលនេះអកុសលចិត្ត ១២ដួង និង អហេតុកអកុសលចិត្ត ៧ ដួង រួម ១៩ ដួងនេះកើតផលក្នុង កាមលោក និង រូបលោកជានិច្ច ។

ក្នុងកាមាវចរកុសល ត្រូវចែកជា ៤ យ៉ាងគឺ : តិហេតុកឧក្កដ្ឋៈ តិហេតុកឱមក្ក ទ្វិហេតុកឧក្កដ្ឋៈ ទ្វិហេតុកឱមក្ក រួម ៤ យ៉ាង ។

១-កុសលដែលធ្វើឱ្យ សោមនស្សចិត្ត ញាណសម្បយុត្ត ២ ដួង ហៅថាតិហេតុក ឱក្កដ្ឋ កុសលនេះឯង កាលឱ្យ ផលរមែងឱ្យផល តិហេតុកបដិសន្ធិ ។ ក្នុងបវត្តិនេះ រមែងឱ្យ ផលជាវិបាកចិត្ត ១៦ដួង គឺ មហាវិបាកចិត្ត ៨ ដួង អហេតុកកុសលវិបាកចិត្ត ៨ដួង រួម ១៦ ដួង ។

ខ. ២-៣ អកុសលដែលធ្វើឱ្យសោមនស្សចិត្ត ញាណវិប្ប យុត្ត ២ ដួង និង ឧបេក្ខាញាណសម្បយុត្ត ២ ដួងហៅថា តិហេតុក ឱមក្កៈ និង ទ្វិហេតុកឧក្កដ្ឋៈ ជាកុសលដែលធ្វើឱ្យកើតទ្វិហេតុកបដិសន្ធិ និង ក្នុងបវត្តិកាលនោះ រមែងបានផលជា វិបាកចិត្ត ១២ ដួង គឺ កុសលវិបាកចិត្ត ៨ ដួង និង មហា វិបាកចិត្ត ៤ ដួង រួម ១២ ដួង ។

២-៤ កុសលដែលធ្វើឱ្យចិត្តជាឧបេក្ខាញាណវិប្បយុត្ត ២ ដួងនេះ ហៅថា ទ្វិហេតុកឱមក្កៈ ដែលជាកុសលធ្វើឱ្យកើតសុគតិហេតុកបដិសន្ធិ និង ប្របវត្តិកាល រមែងបានផលជាអហេតុក ។

ក្នុងការសំដែងផលរបស់កុសល ៤យ៉ាងនោះ អាចារ្យ មួយអង្គ មានឈ្មោះថា មហាធម្មរក្ខិតថេរក្នុងលង្កាទ្វីបថា កុសលដែលបានធ្វើដោយអសង្ខារិក រមែងមិនកើតជាផលសសង្ខារិកឡើយ និង កុសលដែលបានធ្វើដោយសសង្ខារិក ក៏ដូចគ្នា រមែងមិនកើតផលជាអសង្ខារិក ។

អាស្រ័យវាទៈ របស់លោកអាចារ្យនេះ ហើយយើងត្រូវចាត់ចែងកុសល ទាំងអស់នេះ ដូចតទៅគឺ :

តិហេតុកឧក្កដ្ឋកុសល រមែងបានផល ១២ដួង គឺកុសលវិបាក ៨ដួង មហាវិបាកញាណសម្បយុត្ត ៤ ដួង រួម ១២ដួង ។

តិហេតុកឱមក្កៈ និង ទ្វិហេតុកឧក្កដ្ឋៈ រមែងបានផល ១០ដួងគឺ : កុសលវិបាកចិត្ត ៨ដួង មហាវិបាកចិត្តញាណវិប្បយុត្ត ផ្នែកសោមនស្ស ២ ដួង រួម ១០ ដួង ។

ទ្វិហេតុកឱមក្កកុសល រមែងបានផលដោយកុសលវិបាកចិត្ត ៨ ដួងប៉ុណ្ណោះឯង ។

រូបាវចរកុសលចិត្ត មាន ៣ ប្រភេទគឺ ប្រភេទទាប ប្រភេទកណ្តាល ប្រភេទខ្ពស់ ។ ក្នុងទីនេះ បឋមឈានជាប្រភេទទាប រមែងកើតក្នុងព្រហ្មបារិសជ្ជាភូមិ ។ ប្រភេទកណ្តាលរមែងកើតក្នុងព្រហ្មបុរោហិតាភូមិ ។ ប្រភេទខ្ពស់រមែងកើតក្នុងព្រហ្ម មហាព្រហ្មាភូមិ ដោយលំដាប់ ។

ទុតិយ និង តតិយជ្ឈាន ក៏ដូចគ្នា ប្រភេទទាបរមែង កើតបរិត្តាភាភូមិ ប្រភេទកណ្តាលរមែងកើតក្នុងអប្បមាណាភាភូមិ និង ប្រភេទខ្ពស់រមែងកើតក្នុង អាភស្សរាភូមិ ។

ចតុត្ថជ្ឈាន ប្រភេទទាបរមែងកើតក្នុងបរិត្តាសុភាភូមិ ប្រភេទកណ្តាល រមែងកើតក្នុងអប្បមាណាសុភាភូមិ ប្រភេទខ្ពស់ រមែងកើតក្នុង សុភកិណ្ហាភូមិ ។

បញ្ចមជ្ឈាន មានពីរយ៉ាងគឺ :

១-អ្នកដែលកើតក្នុង វេហប្ផលាភូមិ និង អសញ្ញិសត្តភូមិ ដោយសេចក្តីប្រាថ្នារបស់ឈានលាភីបុគ្គល ។ ព្រះអនាគាមិបុគ្គលគ្រប់១ព្រះអង្គ កាលចុតិហើយត្រូវទៅកើតក្នុងសុទ្ធាវាសភូមិទាំង ៥ ជានិច្ច ។

២-អរូបាវចរកុសលទាំង ៤ រមែងកើតក្នុង អរូបភូមិដោយលំដាប់ ។

អធិប្បាយគាថាសង្គហៈថា កាលមហគ្គតកុសលចិត្ត ៩ ដួង ឱ្យផលក្នុងបដិសន្ធិ ឬ ក្នុងបវត្តិកាលក៏ដោយ

រមែងកើតផលសមនឹងចិត្ត មានសេចក្ដីថា កុសលមាន យ៉ាងណា វិបាកក៏មានយ៉ាងនោះដែរ ។

**ចប់កម្មចតុក្ក**

❄❄❄❄❄❄❄
❄❄❄❄
❄

## ពាក្យសួរ-ឆ្លើយក្នុងកម្មចតុក្ក

**សួរ** ពាក្យថាកម្ម ក្នុងព្រះបរមត្ថនោះ ទ្រង់ទេសនាថា បានដល់អ្វីខ្លះ ? និង មានសេចក្ដីយ៉ាងណា ?

**ឆ្លើយ** ពាក្យថាកម្ម តាមពុទ្ធភាសិតថា ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ប្រែថា ម្នាលភិក្ខុទាំងឡាយ ចេតនាចេតសិក ពោលថាកម្ម ព្រោះហេតុដូច្នោះ ពាក្យថាកម្មមានន័យដល់

ចេតនាចេតសិក ១ ដួង ក្នុង អញ្ញសមានាចេតសិក ១៣ដួង នោះឯង ហៅថាកម្ម ប៉ុន្តែកម្មនេះប្រើបានពីរយ៉ាងគឺ កុសលចេតនា និង អកុសលចេតនា ។

**សួរ** តាមពាក្យអធិប្បាយ ចេតនាដំបូង ពាក្យថាជនក-កម្ម បានដល់កម្ម១បែប ដែលធ្វើឱ្យកើតវិបាក និង កម្មជ្ជ-រូប ។ ឧបត្ថម្ភកកម្ម ដែលជួយឧបត្ថម្ភ ជនកកម្ម ធ្វើឱ្យកើតផលតែម្នាក់ឯងមិនបាន ត្រូវមានកម្មដទៃៗទៀតមកជួយសិន ទើបបានឬយ៉ាងណា សុំអធិប្បាយផង ?

**ឆ្លើយ** មិនបានទេ តាមធម្មតាជនកកម្ម អាចនឹងកើតតែឯង និង ឱ្យផលបានដោយមិនចាំបាច់ ត្រូវអាស្រ័យកម្មដ៏ទៃៗ ។

ពាក្យថា ឧបត្ថម្ភកៈ តាមវិគ្គហថា ៈ កម្មន្តរំ វា កម្មនិប្បត្តខន្ធសន្តានំ វា ឧបត្ថម្ភេតីតិៈ ឧបត្ថម្ភកំ កម្មដទៃៗ ឬ ខន្ធដែលកើតមកព្រោះកម្មដែលល្អជួយឧបត្ថម្ភឱ្យ ដូច្នេះ ហៅថា ឧបត្ថម្ភកៈ មានន័យថា កម្មដទៃៗដែលនៅមិនដល់

វេលាក្តី និង កាលកម្មដទៃឱ្យផលក្តី ជួយឧបត្ថម្ភឱ្យកើតផលលើ ឬ ផលដែលនាំឱ្យកើតដទៃៗក្តី ជួយរក្សាដើម្បីឱ្យរៀបរយល្អ ឬ ដើម្បីឱ្យនៅបាន ជាវេលាយូរ ដូច , កាលអ្នកមានបុណ្យម្នាក់កើតមកនោះ កុសលកម្មដទៃៗមកជួយគ្រប់បែបយ៉ាង ហើយត្រូវជាអ្នកមានបុណ្យបារមីយ៉ាងខ្ពស់បំផុត មិនមានអ្នកណាស្មើដូចនេះទេ ។ (មេត្តាមើលជាតកផ្សេងៗផង កម្មដែលជួយឧបត្ថម្ភ ឬ រួមគ្នាយ៉ាងណានោះ ហៅថា ឧបត្ថម្ភកកម្ម ) ។

**សួរ** ឧបបីឡកកម្ម និង ឧបឃាតកកម្ម ផ្សេងគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថា ឧបបីឡកកម្ម តាមវិគ្គហថា កម្មន្តំ វា កម្មនិព្វត្តខន្ធសន្តានំ វា ឧបបីឡេតីតិ ឧបបីឡកំ ។ ប្រែថា កម្មដទៃៗក្តី ឬ ខន្ធដែលកើតអំពីកម្មក្តី រមែងឱ្យលំបាក ឬ ជិទាស់នោះ ហៅថា ឧបបីឡកកម្ម ។

ពាក្យថា ឧបឃាតកកម្មនោះ តាមវិគ្គហថា កម្មន្តំ

វា កម្មនិប្បត្តខន្ធសន្តានំ វា ឧបឃាដេតីតិ ឧបឃាដកំ ។

ប្រែថា កម្មដទៃៗក្តីឬ ខន្ធដែលកើតមកពីកម្មដទៃៗ ក្តី រមែងកាត់ផ្តាច់ពីគ្នាទៅ ដូច្នេះហៅថា ឧបឃាដកកម្ម ។ ក្នុងទីនេះឧបបីឡកកម្ម ដែលធ្វើមិនឱ្យស្រួល ឬ ជំទាស នោះតែប៉ុណ្ណោះ ។

ចំណែកឧបឃាដកកម្មនេះ កាត់ផ្តាច់ ឬ ទំលាយបាន ដូចជាការកើតមកជាមនុស្សនេះ ព្រោះជាជនកកម្ម ។ មានមាស មានប្រាក់ព្រោះ ឧបបីឡកកម្ម ជួនកាលមាន មនុស្សមកបំផ្លាញជីវិត (សម្លាប់ ) អ្នកនោះព្រោះ ឧបឃាដកកម្មដូច្នេះជាដើម ។

**សួរ** តាមពាក្យអធិប្បាយដែលពោលមកហើយ ការពិចារណាត្រិះរិះជនកៈ និង ឧបត្ថម្ភកៈ ក៏ ជាកុសលកម្ម ។ ឧបបីឡក និង ឧបឃាដកក៏ជាអកុសលកម្ម កាលបើដូច្នេះ តាមដែលលោកអធិប្បាយទុកខាងដើមថា កម្មទាំង ៤ នេះ មានទាំងកុសល និង អកុសល មិនផ្ទុយគ្នាហើយឬ ?

**ឆ្លើយ** តាមគម្ពីរវិសុទ្ធិមគ្គ និង អំគុត្តរ អដ្ឋកថាពោលថា កម្មទាំង ៤ រមែងមានជាកុសល និង អកុសលទាំងពីរយ៉ាង គឺ ជនកកុសល ជនកអកុសល ឧបត្ថម្ភកកុសល ឧបត្ថម្ភកអកុសល ឧបបីឡកកុសល ឧបបីឡកអកុសល ឧបឃាដកកុសល ឧបឃាដកអកុសល រួម ៨ ប្រការនេះ ។ អ្នកដែលកើតក្នុងអបាយទាំង ៤ ភូមិហៅថា ជនកអកុសល ធ្វើឱ្យកើតទីនេះ ។ ដូចជាសត្វដែលកើតក្នុងនរក ប្រេតជាដើម ។

សត្វទាំងអស់នេះ កាលបើជួបនឹង ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ឬ ព្រះអរហន្ត អង្គណាមួយក្តី ក៏មានចិត្ត ចេតនាសទ្ធាហើយបានស្តាប់ធម៌ រក្សាសីលជាដើម ។ ចិត្តនោះជាមហាកុសលចិត្តទាំងអស់កើតឡើង ។ ខណៈនោះ កាលចុតិពីនរក និង ប្រេត ហើយកើតជាមនុស្ស ឬ ទេវតា ក៏មាន ។ ជួនកាលអ្នកដែលប្រេតនៅទីនោះ អាស្រ័យការអនុមោទ-នា ក្នុងការធ្វើបុណ្យទានរបស់កូនចៅ និង អ្នកមានឧបការ

ខ្លះ ហើយបានផុតពីជាតិកំណើតប្រេតក៏មាន ។ ការដែលបានផុតពីទុគ្គតិ ទាំងនេះ ជាឧបបីឡកកុសល ឧបឃាដកៈកាត់អកុសលជនកៈ ( ជនកអកុសល ) និង ឧបត្ថម្ភក្នុងជាតិមនុស្សខ្លះ ជាមនុស្សអនាថាក្តី ក្រលំបាកក្តី ត្រូវចោទថាផ្លូវច្បាប់ ស្រុកប្រទេស ត្រូវចាប់ខ្លួនទៅ ខណៈនោះបានជួបអ្នកជួយសង្គ្រោះ និង ឧបត្ថម្ភគ្រប់បែបយ៉ាងហើយ បានផុតពីសេចក្តីទុក្ខ ដល់ទីបំផុតក្លាយទៅជាមនុស្សស្តុកស្តម្ភទៅក៏មានដូច្នេះដែរ ។ ក្នុងទីនេះជនកកម្មធ្វើកើតជាមនុស្សអនាថា ឧបត្ថម្ភកកម្ម ធ្វើឱ្យមានទោស ឧបបីឡកកម្ម ធ្វើឱ្យបានជួប នឹង អ្នកជួយសង្គ្រោះ ឧបឃាដកកម្មធ្វើឱ្យផុតពីសេចក្តីទុក្ខ ហើយតាំងខ្លួន ឡើងបានព្រោះហេតុដូច្នោះ ឧបបីឡកកម្មកុសល និង ឧបឃាដកកុសល ក៏អាចនឹងកាត់អកុសលបាន ដូច្នោះកម្មទាំង ៤ ទើបត្រូវមានទាំងពីរ គឺ កុសល និង អកុសល ដូចដែលលោកអដ្ឋកថាចារ្យសំដែងទុកក្នុងគម្ពីរវិសុទ្ធិមគ្គ និង អំគត្តរ យ៉ាងពិតប្រាកដ

**សួរ** ក្នុងកម្មចតុក្កៈ ទាំងពីរ មានអាសន្នកកម្ម និង អាចិណ្ណកកម្ម ក្នុងកម្មទាំងពីរនេះ អាសន្នកកម្ម ឬ កម្មដែលបានធ្វើកាលជិតនឹងចុតិ ប៉ុន្តែអាចិណ្ណកកម្មបានធ្វើមករហូតមួយជីវិត រមែងមានកម្លាំងជាងអាសន្នកកម្មច្រើនដង ។ ឥឡូវនេះ តាមគម្ពីរអភិធម្មសង្គហៈថា អាសន្នកកម្ម ត្រូវឱ្យផលមុនអាចិណ្ណកកម្ម មើលទៅមិនសម និង ឋានៈរបស់កម្ម ព្រោះអាចិណ្ណកកម្ម បានធ្វើមកជាច្រើនឆ្នាំ តែត្រឡប់សូវ អាសន្នកកម្មដែលបានធ្វើ រយៈវេលាតែបន្តិច មិនបាន នោះដោយហេតុណា ? សុំឱ្យឆ្លើយតាមគោលធម៌ផង ។

**ឆ្លើយ** ពាក្យថា អាសន្នកកម្ម តាមវិគ្គហថា : អសន្នេ អនុស្សរិតំ អាសន្នំ អសន្នេ វា កតំ អាសន្នំ ប្រែថា កម្មណាមួយ ដែលបានរឭក កាលជិតនឹងស្លាប់ ឬ កម្មណាមួយដែលបានធ្វើ កាលជិតនឹងមរណៈ ដឹងហើយថាកម្មនេះទោះធ្វើបាន មួយគ្រាក្តី ឬ វេលាដែលបានធ្វើកម្មនេះតិចជាទីបំផុតក្តី ព្រោះហេតុដូច្នេះ កម្លាំងតិចជាទីបំផុត ។

ពាក្យថាអាចិណ្ណកម្ម តាមវិគ្គហថា អាចីយតេ វឌ្ឍាបីយតេតិ អាចិណ្ណំ ប្រែថា កម្មដែលបានធ្វើ ឬ ធ្វើឱ្យចំរើនឡើង ឬ បានធ្វើច្រើនគ្រា ច្រើនដង មានន័យថា មានកម្លាំងច្រើនជាង អាសន្នកម្ម កាលបើដូច្នេះ កម្មណាមានកម្លាំងច្រើន កម្មនោះរមែងឱ្យផលមុនជាធម្មតាទៅហើយ ។ ហេតុពីរយ៉ាងនេះលោក អនុរុទ្ធាចារ្យក៏ដឹងល្អថា កាលដែលលោកត្រូវសំដែង អាសន្នកម្មមុនអាចិណ្ណកម្មនោះ ព្រោះធម្មតាសត្វម្នាក់ៗ កាលជិតនឹងចុតិនោះឃើញ ឬ រឭកបានដល់កម្មណា កម្មនោះត្រូវឱ្យផលមុន ព្រោះជាកម្មដែលជិតនឹងមរណាសន្នវិថី ឧបមាដូចជា ក្រោលគោមួយកន្លែងមានគោប្រមាណ ១០០ ក្បាល មានគោចាស់មួយក្បាលនៅជិតទ្វារ គោនោះសូម្បីមានកម្លាំងខ្សោយជាង គោដ៏ទៃៗក៏ដោយ ប៉ុន្តែកាលបើកទ្វារក្រោល គោចាស់នោះត្រូវបានចេញមុន ព្រោះនៅជិតទ្វារ មានឧបមាយ៉ាងណា អាសន្នកម្មក៏មានឧបមេយ្យយ៉ាងនេះដែរ ។

សូម្បីមានកម្មដទៃៗ ដែលមានកម្លាំងច្រើនក៏ដោយ តែអាសន្នកម្មនៅជិតជិត និង មរណាសន្នវិថី ដូច្នោះ ព្រះអនុរុទ្ធាចារ្យ ទើបត្រូវសំដែងអាសន្នកម្មមុន ក្នុងកម្មចតុក្កនេះហៅថា បាកទាន មានន័យដល់លំដាប់ការឱ្យផលមិនមានន័យថា មានកម្លាំងច្រើន ឬ តិចឡើយ ។

**សួរ** ពាក្យថា កដត្តាកម្ម បានដល់កម្មអ្វី ? ហើយប្រែថាអ្វី ?

**ឆ្លើយ** ពាក្យថាកដត្តាកម្ម បានដល់កម្មចាស់ៗពីជាតិមុន ឬកម្មដែលធ្វើដោយខ្វះសេចក្ដីប្រុងប្រយ័ត្ន ហៅថា កដត្តាកម្ម មានន័យថា ក្រៅអំពីកម្មធំ ៣ យ៉ាងគឺ គរុកម្ម អាសន្នកម្ម អាចិណ្ណកម្ម នៅមានកម្ម បន្តិចបន្តួច និង កម្មកំទេចកំទី ទំលាយកម្មតូចៗតាំងនេះហៅថា កដត្តាកម្ម ។ ម្យ៉ាងទៀត មានន័យថា ៖ កម្មចាស់ៗដែលបានធ្វើមកហើយ អំពីអតីតកាល កម្មចាស់ទាំងនេះ ហៅថា កដត្តាកម្មក៏បាន ព្រោះហេតុដូច្នេះ ពាក្យថា កដត្តាកម្មក្នុងជាតិនេះ

បានដល់កម្មស្រាល១ កម្មកំទេចកំទី កម្មតូច១ដែលបាន កើតឡើងដោយមិនបានតាំងចិត្ត ឬ ដែលបានធ្លាប់ធ្វើមក ហើយ អំពីជាតិមុន១កម្ម ទាំងពីរនេះហៅថាកដត្តាកម្ម បាន ។

**សួរ** ក្នុងកម្មចតុក្កៈទី ៣ ទិដ្ឋធម្មវេទនិយកម្មនេះ ប្រែថា ម៉េច ? មានន័យយ៉ាងណា ? ហេតុអ្វីបានជា ទិដ្ឋធម្មវេទ-នីយកម្មបាន ? ។

**ឆ្លើយ** ពាក្យថាទិដ្ឋកម្មវេទនិយមកម្ម មានសេចក្ដីថា ជាកម្មមួយបែបដែលបានឃើញផល ក្នុងជាតិបច្ចុប្បន្ន តែកម្មទាំងនេះ មានតួយ៉ាងជាច្រើន កុសល និង អកុសល ។ ដូចជាផ្លូវកុសល នាយបុណ្ណជាអ្នកធ្វើស្រែ ធ្វើបុណ្យចំពោះព្រះសារីបុត្ត បានជាមហាសេដ្ឋីក្នុងរវាង ៧ ថ្ងៃ ។ ផ្លូវអកុសល នន្ទមាណព អ្នកទំលាយសីលរបស់នាង ព្រះឧប្បល-វណ្ណាថេរី ដល់ថ្នាក់ធ្លាក់អវីចិនរកជាដើម ។

ក្នុងព្រះពុទ្ធសាសនា សំដែងថា អ្នកដែលធ្វើបុណ្យនឹង បានទទួលផលលឿនទាន់ចិត្តជាទីបំផុត ត្រូវបានជួបហេតុ ៤ ប្រការ គឺ :

១-អ្នកដែលទទួលទាន ត្រូវជាអ្នកអស់អាសវៈ គឺ ព្រះអរហន្ត ។

២-អ្នកនោះជាអ្នក ចេញពីនិរោធ សមាបត្តិផង ។

៣-អ្នកបរិច្ចាគ ត្រូវមានចេតនាសទ្ធាច្រើន ។

៤-របស់ជាទេយ្យទាននោះ ត្រូវបានមកដោយបរិសុទ្ធ គឺបានមកដោយសម្មាអាជីវោ ។

រួម ៤ ប្រការនេះ ធ្វើឱ្យអ្នកបរិច្ចាគបានទទួលផលក្នុងជាតិបច្ចុប្បន្ននេះ ។

**សួរ** ក្នុងកម្មចតុក្កៈនេះ ពាក្យថា អហោសិកម្ម អហោសិកម្មមួយណាខ្លះ ? កុសល និង អកុសលដែលធ្វើទុកហើយកម្មនេះមានបាត់សូន្យទៅខ្លះៗ បានទេ ?

**ឆ្លើយ** ពាក្យថា អហោសិ ជាស័ព្ទដែលគួរ នឹង នហោសិ

ប្រែថា កើតហើយក៏មាន មិនកើតក៏មាន បានដល់ឧបបជ្ជ-វេទនីយកម្ម តែឧបបជ្ជវេទនិយកម្មទាំងពីរយ៉ាងគឺ កុសលឧបបជ្ជវេទនីយកម្ម អកុសលឧបបជ្ជវេទនីយកម្ម រួម ២ យ៉ាង ។

ថាដោយឧទាហរណ៍ អ្នកដែលដល់សមាបត្តិ ៨ ប្រការ ហៅថា កុសលឧបបជ្ជវេទនិយកម្ម អ្នកនេះសូម្បីនិង បានសមាបត្តិ ៨ ប្រការក្តី កាលបានដល់នោះសមាបត្តិដែលមានកម្លាំងជាទីបំផុតណាមួយឱ្យផល សល់សមាបត្តិ ៧ អង្គទៀតនោះរមែងជាអហោសិកម្មទៅ ។

ក្នុងផ្លូវអកុសលនោះ បញ្ចានន្តរិយកម្ម ទាំង ៥ ហៅថាអកុសល ។ ឧបបជ្ជវេទនីយកម្ម ក្នុងកម្មទាំង ៥ នេះកម្មណាធ្ងន់ កម្មនោះឱ្យផលតែ ១ សល់កម្ម ៤ ទៀតជាអហោសិកម្មទៅ ។ គោលភស្តុតាងក្នុងវិភង្គអដ្ឋកថា ថា :

**តត្ថ សមាបត្តិលាភី ឯកាយសមាបត្តិយា ព្រហ្មលោកេ និព្វត្តតិ បញ្ចន្នំបិ អនន្តរិយានំ**

**កដត្តា ឯកេន កម្មេន និរយំ និព្វត្តតិ សេសសមាបត្តិយោ ច កម្មានិ ច អហោសិកម្មភាវំយេវ អាបជ្ជន្តិ អវិបាកានិ ហោន្តិ** ប្រែ អ្នកដល់សមាបត្តិ ៨ ប្រការ ព្រោះសមាបត្តិអង្គណា ១ ហើយដែលរមែងកើត ក្នុងព្រហ្មលោក ។ អ្នកបានធ្វើអនន្តរិយកម្មទាំង ៥ ព្រោះ កម្មណាមួយដែលមានកម្លាំង រមែងកើតក្នុងនរក ចំណែក សមាបត្តិ ៧ អង្គ និង អនន្តរិយកម្ម ៤ ដែលសល់ ក្លាយជា អហោសិកម្ម មានសេចក្តីថា មិនបានផលឡើយ ។ បានសេចក្តីថា កម្មដែលបានធ្វើទុកហើយនោះ នឹងបាត់សូន្យទៅទទេគ្មានទេ ។ ធម្មតាកុសល និង អកុសល កាលបានធ្វើដោយចេតនាហើយរមែងមានផលជានិច្ច តែថា ការសោយផលនោះប្រណីតទៅតាមកាល និង ឋានៈ គឺ កម្មខ្លះបាន ផលលឿន កម្មខ្លះបានផលយឺត កម្មខ្លះអាចបានផលមួយ ជាតិ ពីរជាតិ ឬ ច្រើនជាតិក៏បាន ។

ក្នុងទីនេះ ពាក្យថាអហោសិ ជាកិរិយាស័ព្ទប្រែថា កើតហើយ កម្មនោះមានច្រើនកម្មដូចគ្នា កម្មដែលប្រណាំងនឹង កម្មធំៗ ហើយរមែងចាញ់កម្មធំៗ កម្មនេះហៅថា ហោសិកម្ម គឺ មិនបានផល ឧបមាអ្នកខូចម្នាក់ ត្រូវចាប់ដោយចោទថាធ្វើខុសច្បាប់ច្រើនប្រការគឺ :

១-ចោទលួចទ្រព្យ

២-បោកប្រាក់

៣-ធ្វើអាក្រក់រាងកាយ វាយតប់

៤-ចោទក្នុងក្តីនយោបាយ

ក្តីទី ៤ ទាក់ទងក្នុងនយោបាយនេះមានកម្លាំងជាទីបំផុតព្រោះធ្ងន់ជាងគេ ។ កាលអ្នកកាត់សេចក្តីពិចារណាហើយ កាត់សេចក្តីប្រហារជីវិត ។ អ្នកត្រូវចោទនេះត្រូវប្រហារជីវិត ព្រោះក្តីផ្លូវនយោបាយ ។ ក្តីដទៃៗត្រូវជាអហោសិកម្មអស់ទៅ មានន័យថា ក្តីដទៃៗរមែងរួមក្នុងក្តី

ផ្លូវនៃយោបាយទាំងអស់ គ្មានបាត់សូន្យទៅទទេៗទេ ព្រោះហេតុដូច្នេះ ពាក្យថាអហោសិកម្មដែលប្រែថាកម្មដែលកើតហើយ ប៉ុណ្ណោះ ក៏ត្រឹមត្រូវហើយ ក្នុងអំគុត្តរដីកាថា អហោសិ កម្មន្តិ អហោសិ ឯវកម្មំ ប្រែថា អហោសិកម្មបានដល់ចេតនាដែលកើតហើយនេះរមែងជាកម្ម កាលធ្វើវិគ្គហថា **អហោសិ ឯវ កម្មំ** ប៉ុណ្ណោះ ។ តាមវេយ្យាករណ៍ថា អហោសិ កិរិយា ធ្វើសមាស និង កម្មមិនបាន ត្រូវធ្វើ និង ឯវ ព្រោះក្នុងនិទ្ទេសបាលីវេយ្យាករណ៍ថា អខ្យាតេន សមាសោ ន ទិស្សតិ ដូច្នេះតែថាកម្មនេះឯងមានផល និង មិនមានផល រួម ១២កម្ម ក្នុងបដិសម្ភិទាមគ្គបាលីក៏មាន ក្នុងទីនេះមិនបានអធិប្បាយទេ ។

**សួរ** ព្រះបាលីរបស់លោកអនុរុទ្ធាចារ្យថា ឯត្ថា កុសល-កម្មុទ្ធច្ចរហិតំ អបាយភូមិយំ បដិសន្ធឹ ជនេតិ ប្រែថា ក្នុងអកុសលចិត្ត ១២ដួង វៀរលែងឧទ្ធច្ចៈ សល់ ១១ដួង នេះរមែងបដិសន្ធិក្នុងអបាយភូមិ ដូច្នេះក្នុងទីនេះ ឧទ្ធច្ចៈ និង

វិចិកិច្ឆា ប្រកបជាមួយមោហៈ ហេតុនោះ វិចិកិច្ឆាទើបកើតក្នុងអបាយទាំង ៤ ហើយឧទ្ធច្ចៈ មិនអាចដែលនឹងធ្វើឱ្យទៅកើតក្នុងអបាយភូមិបានទេ ? ។

**ឆ្លើយ** លោកអដ្ឋកថាចារ្យ អធិប្បាយថា កាលដែលឧទ្ធច្ចៈដែលមិនបានកើតក្នុងអបាយភូមិទាំង ៤ នេះ ព្រោះកម្លាំងរបស់ឧទ្ធច្ចៈ មិនគ្រប់គ្រាន់ដែលនឹងឱ្យបដិសន្ធិបាន ព្រោះហេតុដូច្នេះ ព្រះបរមសាស្ដាទ្រង់ហៅថា យេវាបនក ប្រែថា - ធម៌ណាមួយដែលមិនប្រាកដ មិនច្បាស់ ក្នុងធម្មសង្គណី ព្រះបាលីនេះ បញ្ជាក់ទុកហើយថា មិនសំដែងត្រង់ឧទ្ធច្ច ព្រះអង្គសំដែងតែ យេវាបន តស្មឹសមយេ អញ្ញេបិ អត្ថិ ដូច្នេះ ។ ព្រោះកម្លាំងរបស់ ឧទ្ធច្ចៈ មិនគ្រប់គ្រាន់ មានន័យថា ជាអកុសល សាមញ្ញនោះឯង ។

ប្រការម្យ៉ាងទៀត ក្នុងសម្បយោគន័យ ១៦ ន័យ ព្រះអនុរុទ្ធាចារ្យ មិនបានសំដែង ឧទ្ធច្ចចេតសិក ប្រកបជាមួយនឹងអកុសលចិត្តប្រាកដ ។ កាលដែលលោកមិន

សំដែង ព្រោះឧទ្ធច្ចៈជាអកុសលសាមញ្ញប៉ុណ្ណោះ ទើបមិនអាចនឹងនាំទៅកើតក្នុងអបាយបាន ។

**សួរ** អ្នកដែលដល់ បញ្ចមជ្ឈាន ដែលកើតក្នុងអញ្ញិសត្តភូមិនោះ ព្រោះហេតុអ្វីទើបបានទៅកើតទីនេះ ?

**ឆ្លើយ** កាលដែល លោកឈានលាភីបុគ្គល បានទៅបដិសន្ធិនោះមិនមែនព្រោះកម្លាំងឈានទេ សេចក្តីពិតនោះព្រោះកម្លាំងប្រាថ្នា គឺ អ្នកដល់ឈានលាភីបុគ្គលនោះយល់ថា នាមធម៌ធ្វើឱ្យមានទុក្ខ បើប្រាសចាកនាមធម៌ហើយ ជាព្រះនិព្វានតែម្យ៉ាង ដូច្នេះ ទើបលោកមិនប្រាថ្នានាម ប្រាថ្នាតែមានរូប ។ សេចក្តីប្រាថ្នារបស់លោកសំរេចដោយចិត្តបណិធិរបស់លោក ដូច្នេះព្រះបរមសាស្តា ទើបទ្រង់ត្រាស់ថា ឥជ្ឈតិ ភិក្ខវេ សីលវតោ ចេតោ បណិធិ វិសុទ្ធត្តា ប្រែថា ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តបណិធិជាចិត្តបរិសុទ្ធ អ្នកមានសីលរមែងសំរេចសេចក្តីប្រាថ្នាបាន ព្រោះហេតុដូច្នេះ កាលដែលលោកឈានលាភីបុគ្គល រមែងកើតក្នុង

អសញ្ញិសត្តភូមិនោះ គ្មានព្រោះឈានទេ ព្រោះសេចក្តីប្រាថ្នានោះឯង ។

**ចប់កម្មចតុក្កតែប៉ុណ្ណោះ**

## សំដែងមរណចតុក្ក តាមបាលី

អាយុក្ខយេន កម្មក្ខយេន ឧភយក្ខយេន ឧបច្ឆេទកកម្មុនា ចេតិ ចតុធា មរណុប្បត្តិ នាម តថា ច មរន្តានំ បន មរណកាលេ យថារហំ អភិមុខីភូតំ ភវន្តរេ បដិសន្ធិជនកំ កម្មំ វា តំ កម្មករណកាលេ រូបាទិកមុបលទ្ធបុព្វមុបករណភូតញ្ច កម្មនិមិត្តំ វា អនន្តរមុប្បជ្ជមានភវេ ឧបលភិតព្វំ ឧបភោគភូតញ្ច គតិនិមិត្តំ វា កម្មពលេន ឆន្នំ ទ្វារានំ អញ្ញតរស្មិំ ទ្វារេ បច្ចុបដ្ឋាតិ ។ តតោ បរំ តមេវ តថោ បដ្ឋិតំ

អារម្មណំ អារម្ភ វិបច្ចមានកកម្មានុរូបំ បរិសុទ្ធំ វា ឧបកិលិដ្ឋំ វា ឧបលភិតព្វភវានុរូបំ តត្ថោណតំវា ចិត្តសន្តានំ អភិណ្ហំ បវត្តតិ ពាហុល្លេន ។ តមេវ វា បន ជនកភូតំ កម្មាភិនវករណវសេន ទ្វារបត្តំ ហោតិ ។

បច្ចាសន្នមរណស្ស តស្ស វីថិចិត្តាវសានេ ភវង្គក្ខយេ វា ចវនវសេន បច្ចុប្បន្នាភវបរិយោសានភូតំ ចុតិចិត្តមុប្បជ្ជិត្វា និរុជ្ឈតិ តស្មឹ និរុទ្ធាវសានេ តស្សានន្តរមេវ តថាគហិតំ អារម្មណំ អារម្ភ សវត្ថុកំ អវត្ថុកមេវ វា អវិជ្ជានុសយបរិក្ខិត្តេន តណ្ហានុសយមូលកេន សង្ខារេន ជនិយមានំ សម្បយុត្តេហិ បរិគ្គយ្ហមានំ សហជាតានមធិដ្ឋានភាវេន បុព្វង្គមភូតំ ភវន្តរបដិសន្ធិវសេន បដិសន្ធិ-

## សន្ធាតំ មានសំ ឧប្បជ្ជមានភេទ បតិដ្ឋាតិ តទនន្តរេ ៗ

នៅមានមរណុប្បត្តិ ៤ ប្រការគឺ ១-អាយុក្ខយ ២-កម្មក្ខយ ៣-ឧភយក្ខយ ៤-ឧបច្ឆេទក រួម មរណុប្បត្តិ ៤ ប្រការ ។

សត្វចាំបាច់ត្រូវស្លាប់ព្រោះ មរណុប្បត្តិ ៤ ប្រការ ដែលបានពេលមកហើយ ។ កាលខណៈដែលនឹងស្លាប់នោះ អារម្មណ៍ទាំងពីររមែងប្រាកដឡើង ក្នុងទ្វារណាមួយ នៃទ្វារ ទាំង ៦ ដោយអំណាចរបស់កម្ម អារម្មណ៍ទាំង ៣ នេះ គឺ កម្មដែលធ្វើឱ្យបដិសន្ធិ កម្មនិមិត្តដែលជា រូបារម្មណ៍ជាដើម ដែលធ្លាប់ជាប់ជាបរិវាររបស់កម្មក្នុង ខណៈដែលធ្វើកម្ម និង គតិនិមិត្តដែលធ្វើអារម្មណ៍ ( គតិ និមិត្តដែលជាអារម្មណ៍ ) ដែលនឹងបានទទួល ហើយនឹងបាន សោយខាងមុខ រួម ៣ អារម្មណ៍ ។ តាំងពីនោះមក ក៏អា ស្រ័យអារម្មណ៍ដែលប្រាកដតាមកម្មផល រមែងកើតក្នុង

ចិត្តដោយមិនដាច់ក្រសែឡើយ ។ កម្មដែលធ្វើឱ្យកើតបដិសន្ធិនោះ ដោយធ្វើឱ្យចិត្តតាក់តែងឡើង ។

ចិត្តរបស់សត្វកាលជិតនឹងស្លាប់ ក្នុងខណៈដែលអវសានរបស់វិថីចិត្តជាភវង្គចិត្តក្ដី ជាចុតិចិត្ត ១ ដួងរលត់ចុះមួយរំពេច ខាងក្រោយដែល ចុតិចិត្តរលត់នោះ អាស្រ័យអារម្មណ៍ដែលមរណាសន្នជវនទទួលមកហើយ មានវត្ថុ ឬមិនមាន ដែលនឹងបានអាស្រ័យជាបដិសន្ធិចិត្តថ្មី ដែលមានអវិជ្ជាជាបរិវារ និង ដែលកើតមកទាក់ទង នឹងសង្ខារទាំងបីនេះឯង ជាអ្នកនាំ ជាអ្នកទៅមុនរមែងកើតនៅ ( ភពថ្មី ) ជាតិថ្មី ដោយធ្វើឱ្យជាតិថ្មី និង ជាតិចាស់ជាប់គ្នា ។

# សំដែងបាលីថា

មរណាសន្នវិថិយំ បនេត្ថ មន្ទប្បវត្តានិ បញ្ចេវ ជវនានិ បាដិកង្ខិតព្វានិ តស្មា យទិ បច្ចុប្បន្នាលម្ពណេសុ អាបាថគតេសុ ធរន្តេស្វេវ មរណំ ហោតិ ។ តទា បដិសន្ធិភវង្គានំបិ បច្ចុប្បន្នាលម្ពណតា លព្ភតីតិ កត្វា កាមាវចរបដិសន្ធិយា ឆទ្វារគហិតំ កម្មនិមិត្តំ គតិនិមិត្តញ្ច បច្ចុប្បន្នមតីតាលម្ពណំ ឧបលព្ភតិ កម្មំ បន អតីតមេវ ។ តញ្ច មនោទ្វារគហិតំ តានិ បន សព្វានិបិ បរិត្តធម្មភូតានេវា-លម្ពណានិ ។

រូបាវចរបដិសន្ធិយា បន បញ្ញត្តិភូតំ កម្មនិមិត្តមេវាលម្ពណំ ហោតិ ។

តថា អរូបបដិសន្ធិយា ច មហគ្គតតត្តំ បញ្ញត្តិភូតញ្ច កម្មនិមិត្តមេវ យថារហំ អាលម្ពណំ ហោតិ ។

អសញ្ញសត្តានំ បន ជីវិតនវកមេវ បដិសន្ធិភាវេន បតិដ្ឋាតិ តស្មា តេ រូបបដិសន្ធិកា នាម ។ អរូបាអរូបបដិសន្ធិកា សេសា រូបារូបបដិសន្ធិកា ។

ក្នុងមរណាសន្នវិថីនេះ ត្រូវការជវនត្រឹម ៥ ដែលជាវិថីទន់ទាប ដូច្នេះ កាលបើស្លាប់មានអារម្មណ៍ ជាបច្ចុប្បន្នប្រាកដមែននោះ បដិសន្ធិចិត្ត ភវង្គចិត្ត ត្រូវទទួលជាអារម្មណ៍បច្ចុប្បន្ន ដូច្នេះ កម្មនិមិត្ត ឬ គតិនិមិត្ត កន្លែងទ្វារទាំង ៦ របស់កាមាវចរទទួលមកនោះ ត្រូវជាអារម្មណ៍អតីត និង បច្ចុប្បន្នពិតប្រាកដ ។ ប៉ុន្តែកម្មណាជាអតីតនោះ ត្រូវទទួលរាប់ដោយ មនោទ្វារ ។ អារម្មណ៍ដែលពោលមកនេះជាកាមារម្មណ៍សុទ្ធ ។

ចំណែករូបាវចរបដិសន្ធិ មានកម្មនិមិត្ត ដែលមានបញ្ញត្តិជាអារម្មណ៍ ។ អរូបាវចរបដិសន្ធិក៏ដូចគ្នា មានមហគ្គតជានិមិត្ត ឬ មានបញ្ញត្តិ ជាអារម្មណ៍ តាមតែគួរ ។

ព្រហ្មដែលកើតក្នុងអសញ្ញីសត្ត ជីវិតនវករូបនោះឯងជាបដិសន្ធិ ដូច្នេះព្រហ្មអសញ្ញីសត្ត ជាព្រហ្មដែលបដិសន្ធិ ដោយរូប ។ អរូបាវចរព្រហ្ម ជាព្រហ្មដែលបដិសន្ធិ ដោយ នាម ។ បុគ្គលដែលសល់ទាំងអស់បដិសន្ធិដោយនាម និង រូប ។

## គាថាសង្គហៈ

**អរូបចុតិយា ហោន្តិ ហេដ្ឋិមារូប្បវជ្ជិតា**
**បរមារូប្បសន្ធិ ច តថា កាមតិហេតុកា ៥**

**រូបាវចរចុតិយា អហេតុរហិតា សិយុំ សព្វា**
**កាមតិហេតុម្ហា កាមេស្វេវ បនេតរា ៗ**

ខាងក្រោយដែលអរូបាវចរចិត្ត ចុតិកើត បដិសន្ធិចិត្ត ៨ដួង រមែងកើតបានគឺ អរូបដិសន្ធិចិត្ត ៤ដួង ដែលបានវៀរចាកអរូបចិត្តខាងចុង និង កាមតិហេតុក បដិសន្ធិចិត្ត ៤ ដួង រួម ៨ដួង ។

ខាងក្រោយដែលរូបាវចរចិត្ត ចុតិកើត បដិសន្ធិចិត្ត ១៧ដួង ដែលវៀរ អហេតុកចិត្ត ២ ដួងរមែងកើតបាន ។ ក្រោយពីចុតិអហេតុក កាមាវចរបដិសន្ធិទាំងអស់រមែងកើតបាន ។

ខាងក្រោយដែលរូបាវចរចិត្ត ចុតិកើត បដិសន្ធិចិត្ត ១៧ដួង ដែលវៀរអហេតុកចិត្ត បដិសន្ធិ ២ដួង រមែងកើតបាន ។ ក្រោយពីចុតិអហេតុកបដិសន្ធិចិត្ត និង ទ្វិហេតុកកាមបដិសន្ធិ រមែងកើតបាន ។

**អយមេត្ថ ចុតិ បដិសន្ធិក្កមោ**

ប្រែថា ដែលបានសំដែងមកហើយគឺ សំដែងលំដាប់ ចុតិ និង បដិសន្ធិ ។

## សំដែងបាលី (ត)

ឥច្ចេវំ គហិតបដិសន្ធិកានំ បន បដិសន្ធិនិរោធានន្តរតោ បភុតិ តមេវារម្មណមារព្ភ តទេវ ចិត្តំ យាវ ចុតិចិត្តុប្បាទា អសតិ វីថិចិត្តុប្បាទេ ភវស្ស អង្គភាវេន ភវង្គសន្តតិ សង្ខាតំ មានសំ អព្វោច្ឆិន្នំ នទីសោតោ វិយ បវត្តតិ ។ បរិយោសានេ ច ចវនវសេន ចុតិចិត្តំ ហុត្វា និរុជ្ឈតិ ។ តតោ បរញ្ច បដិសន្ធាទយោ រថចក្កមិវ យថាក្កមំ ឯវ បរិវត្តន្តា បវត្តន្តិ ។

បដិសន្ធិភវង្គវីថិយោ ចុតិចេហ តថា ភវន្តរេ បុន សន្ធិ ភវង្គមិច្ចយំ បរិវត្តតិ

**ចិត្តសន្តតិ ២**

**បដិសន្ធាយ បវត្តមន្ទុទំ អចិកន្តា បទមច្ចុតំ ពុធា សុសមុច្ចូនិន្លសិនេហពន្ធនា សម្មេស្សន្តិ ចិរាយ សុព្វតា**

បុគ្គលដែលបដិសន្ធិ តាំងពីបដិសន្ធិចិត្ត រលត់ចុះ មានបដិសន្ធិចិត្ត ធ្វើជាអារម្មណ៍រហូតដល់ចុតិ កាលប្រាសចាកវិថីចិត្ត ភវង្គចិត្តរមែងកើត ដូចខ្សែទឹកហូរទៅ ដល់វារៈទីបំផុត ចុតិចិត្ត ហើយរលត់ចុះមួយរំពេច ។

ក្រោយពីចុតិចិត្ត ជាបដិសន្ធិចិត្ត ជាដើម ដូចកង់រថវិលទៅតាមលំដាប់ ។ ក្នុងជាតិបច្ចុប្បន្ននេះ បដិសន្ធិចិត្ត ភវង្គចិត្ត និង វិថីចិត្ត រមែងកើតមិនដាច់ក្រសែ មានឧបមាយ៉ាងណា ក្នុងជាតិបដិសន្ធិចិត្ត ភវង្គចិត្ត និង វិថីចិត្ត រមែងកើតបន្តទៅរឿយ ៗ មានឧបមេយ្យយ៉ាងនោះឯង ។

បណ្ឌិតអ្នកបានប្រតិបត្តិ នៅពេលវេលាដ៏យូរ ពិចារណាឃើញចិត្ត និង ចេតសិក ទាំងនេះថា មិនទៀង

ហើយនឹង ឃើញព្រះនិព្វាន ដោយអរិយមគ្គ-ផល រមែងដកសេចក្តី ស្រឡាញ់ គឺ តណ្ហាបានហើយ និង ទម្លុះសំរេចដល់ព្រះ និព្វានធាតុ ។

**ឥតិ អភិធម្មត្ថសង្គហេ វិថីមុត្ត សង្គហវិភាគោ នាម បញ្ចមោ បរិច្ឆេទោ ។**

**ប្រែថា** នេះឯងមាននាមថា វិថីមុត្តសង្គហវិភាគ គឺវិភាគ ចិត្តជាវិថិមុត្ត ដែលជាបរិច្ឆេទទី ៥ ក្នុងគម្ពីរ អភិធម្មត្ថ សង្គហៈចប់តែប៉ុណ្ណោះ ។

# អធិប្បាយ មរណុប្បត្តិ ៤

ពាក្យថា មរណុប្បត្តិ ញែកបាន ២ បទគឺ មរណ + ឧប្បត្តិ

- មរណៈ ប្រែថា ស្លាប់
- ឧប្បត្តិ ប្រែថា កើតឡើង

មានសេចក្តីថា កើតឡើង បានដល់មរណុប្បត្តិ ៤ ប្រការ ។

មរណុប្បត្តិ ៤ ប្រការ ដូចដែលបានសំដែងមកហើយ

ពាក្យថា អាយុក្ខយ បានសេចក្តីថា ស្លាប់ ដោយអស់អាយុ ។

ពាក្យថា កម្មក្ខយ ស្លាប់ដោយអស់កម្ម

ពាក្យថា ឧភយក្ខយ ស្លាប់ព្រោះអស់ទាំងពីរ អាយុ និង កម្ម

ពាក្យថា ឧបច្ឆេទកៈ ស្លាប់ដោយកម្មដទៃកាត់ តែ កម្ម និង អាយុ ប្រាកដមាននៅឡើយ ។ បុគ្គលណាមួយ ដែលស្លាប់ព្រោះសេចក្តីស្លាប់ ទាំង ៤ ដែលបានពោលមក ហើយនេះ កាលជិតនឹងស្លាប់ កម្មនិង កម្មនិមិត្ត និង គតិនិមិត្ត រមែងប្រាកដក្នុងទ្វារណាមួយ ក្នុងទ្វារទាំង ៦ ជាធម្មតា ។

ក្នុងទីនេះកម្មបានដល់កុសលកម្ម ឬ អកុសលកម្ម ដែលខ្លួនបានធ្វើមកហើយ កម្មនិមិត្តបានដល់ គ្រឿង ឧបករណ៍ផ្សេងៗ ដែលទាក់ទងនិង លក្ខណៈដែលធ្វើកុសល ឬ អកុសល ។ គតិនិមិត្តបានដល់អារម្មណ៍ផ្សេងៗដែលនិង

បានទទួល ឬ បានសោយក្នុងអនាគត ។ កាលនិមិត្តទាំង៣ ប្រាកដហើយ និង ជាផ្នែកកុសល ឬ អកុសលក៏ដោយ រមែង អាស្រ័យអារម្មណ៍ដែលប្រាកដ តាមលំដាប់អ្នកកំពុង ស្លាប់ រមែងកើតរលត់នៅក្នុងវិថីចិត្ត ឬ កម្មដែលនឹងនាំ កាន់បដិសន្ធិនោះឯង រមែងប្រាកដក្នុងមនោទ្វារមួយរំពេច ការដល់អវសាន របស់វិថីចិត្ត ជាភវង្គចិត្ត ជាចុតិចិត្ត ដែលជាចិត្តដួងទីបំផុតនៃជាតិនេះ រមែងកើតហើយរលត់ ចុះមួយរំពេច ចិត្តទីបំផុតរលត់ហើយ មានវត្ថុអាស្រ័យឬទេ ព្រោះបដិសន្ធិចិត្ត រមែងកើតក្នុងភព ឬ ជាតិថ្មីតាមភាព ខាងក្រោយនេះ ។



ដែលពោលថាមានវត្ថុអាស្រ័យ ឬទេនោះ បើកើតក្នុងអរូបភូមិ មិនមានវត្ថុអាស្រ័យទេ បើរូបភូមិដទៃៗ រមែងមានវត្ថុអាស្រ័យ ។

ខ. សំខាន់មានសេចក្តីថា កាលអ្នកស្លាប់ មុនដែលនឹងស្លាប់មានអារម្មណ៍បច្ចុប្បន្នជាពិតប្រាកដ ។ មានន័យថា បដិសន្ធិចិត្ត ទទួលយកអារម្មណ៍ចាស់របស់ចុតិ ប៉ុន្តែអ្នកស្លាប់ដែលឃើញកម្មនោះ ត្រូវមានអារម្មណ៍អតីត ហើយជាមនោកម្ម ។

អារម្មណ៍ទាំង ៣ ដែលអធិប្បាយមកហើយនេះ ជាអារម្មណ៍កាមាវចរសុទ្ធ គ្មានជារូប អរូប ឬ លោកុត្តរៈទេ ។ ( មើលភាពវិថីផង )

ចំណែករូបាវចរបដិសន្ធិនោះ មានបញ្ញត្តិជាអារម្មណ៍ និង កម្មនិមិត្ត អរូបាវចរបដិសន្ធិ ក៏ត្រូវជាប់ជាមហគ្គតៈ និង មានបញ្ញត្តិជាអារម្មណ៍ដែលជាកម្មនិមិត្ត ដូចគ្នា ។ ព្រហ្មអសញ្ញីសត្តនោះ មានជីវិត នវករូប ៩ ជាបដិសន្ធិគឺ

បឋវី អាបោ វាយោ តេជោ វណ្ណៈ គន្ធៈ រសៈ ឱជា និង ជីវិតរូប រួម ៩ រូប ។ ដូច្នេះបដិសន្ធិទើបមាន ៣ យ៉ាងគឺ : រូបបដិសន្ធិ អរូបបដិសន្ធិ និង រូបារូបបដិសន្ធិ រួម ៣ យ៉ាង

- រូបបដិសន្ធិ បានដល់ អសញ្ញីសត្តភូមិ ។
- អរូបបដិសន្ធិ បានដល់ អរូបទាំង ៤ ភូមិ
-សល់ ២៦ភូមិនោះ ហៅថា រូបារូបបដិសន្ធិ ( ឬនាមរូបបដិសន្ធិ )

ខាងក្រោយដែលចុតិរបស់អរូបព្រហ្ម បដិសន្ធិចិត្ត១ដួងក្នុង ៨ដួង ដែលពោលតទៅនេះ រមែងកើតបាន គឺ អរូបវិបាក ៤ ដួង និង មហាវិបាកញាណសម្បយុត្ត ៤ ដួង រួម ៨ ដួង ។

ខាងក្រោយដែលចុតិរបស់រូបព្រហ្ម បដិសន្ធិចិត្ត ១៧ ដួងគឺវៀរលែង អហេតុកបដិសន្ធិចិត្ត ២ ដួង ក្នុងបដិសន្ធិចិត្ត ១៧ដួង រមែងកើតបាន ។

ខាងក្រោយដែលចុតិចិត្ត របស់កាមតិហេតុកបុគ្គល បដិសន្ធិចិត្ត ១៩ ដួង ឬ ២០ដួង ដែលរួមទាំងរូបបដិសន្ធិ រមែងកើតបាន ។

ខាងក្រោយដែលចុតិរបស់កាមទ្វិហេតុកបុគ្គល និង អហេតុកបុគ្គល ។ កាមបដិសន្ធិ ១០ ដួង រមែងកើតបាន ។

អ្នកដែលបដិសន្ធិគ្រប់ៗគ្នា តាំងពីបដិសន្ធិចិត្តដល់ ភវង្គចិត្តចាកពីភវង្គចិត្ត ដល់ចុតិចិត្ត ចាកពីចុតិចិត្ត បន្តទៅ ភវង្គចិត្តភពថ្មី ដូច្នេះឯង ។ ហើយចិត្ត ៣ យ៉ាងកើតតៗគ្នា ទៅក្នុង វដ្តសំសារ ដូចកង់រថដែលវិលទៅជានិច្ច ព្រោះ ដូច្នេះអ្នកមានសតិបញ្ញា រមែងឃើញថា នាមធម៌ទាំងអស់ នេះគ្មានទៀងទេ ជាអនិច្ចំទាំងអស់ ហើយដកសេចក្តី ស្រឡាញ់ គឺ តណ្ហាដោយ ខ. ប្រតិបត្តិផ្សេងៗ ដើម្បីនឹងបាន សំរេចដល់ អសង្ខត គឺ ព្រះនិព្វានធាតុ ។

## ពាក្យសួរ-ឆ្លើយ មរណុប្បត្តិចតុក្ក ៤

**សួរ** ក្នុងមរណុប្បត្តិ ៤ ប្រការ ដែលពោលមកហើយនោះ អធិប្បាយថា មនុស្សដែលមិនទាន់អស់បុញ្ញកម្ម អាច ស្លាប់ដោយឧបច្ឆេទកកម្មក៏មាន ខ.នេះគឺផ្ទុយ និង សេចក្តី ចូលចិត្តរបស់មនុស្សទាំងឡាយទូទៅ ព្រោះមនុស្សទូទៅ ប្រកាន់ថា ការដែលមនុស្សស្លាប់ក៏ព្រោះអស់អាយុ ឬ អស់កម្ម ក្នុងរឿងនេះសុំឱ្យឆ្លើយ ព្រមជាមួយភស្តុតាង ផ្សេងៗ ដែលនឹងសំដែងបាន ?

**ឆ្លើយ** សេចក្តីស្លាប់គឺ មរណៈ តាមពុទ្ធភាសិតថាមាន ២ យ៉ាងគឺ ១-កាលមរណៈ ២-អកាលមរណៈ ។ អ្នកដែល ស្លាប់ដោយ អាយុក្ខយ កម្មក្ខយ ឧបភយក្ខយ រួមទាំង ៣ នេះហៅថាកាលមរណៈ មានន័យថា អ្នកដែលបានស្លាប់ ដោយដល់គ្រា និង វេលាស្លាប់ អ្នកដែលស្លាប់ទៅមិនដល់ គ្រា និង វេលាហៅថាឧបច្ឆេទកមរណៈ មានន័យថា ឧបច្ឆេទកកម្ម មកកាត់ឱ្យស្លាប់ដូចដែលអធិប្បាយក្នុងកម្ម-ចតុក្កៈនោះហើយ ។

ក្នុងទីនេះព្រះអនុរុទ្ធាចារ្យ សំដែងបានដោយឧបមាថា ធម្មតាសត្វរមែងមានជីវិតនៅ ប្រៀបដូចប្រទីប រីឯប្រទីបនោះរមែងអាស្រ័យប្រេង ប្រឆេះនោះឯង ។ ដូចកាលអស់ប្រេង ឬ ប្រឆេះ ហើយគ្មានភ្លើង និង ពន្លឺភ្លឺទេក្នុងកាលដែលភ្លើងប្រទីប និង រលត់នោះ ព្រោះហេតុ ៤ ប្រការគឺ

១-ព្រោះអស់ប្រឆេះ

២-ព្រោះអស់ប្រេង

៣-ព្រោះអស់ប្រេង និង ប្រឆេះ

៤-ព្រោះឧបសគ្គណាមួយមកប៉ះទង្គិច ។

មានឧបមាយ៉ាងណា សេចក្តីស្លាប់របស់មនុស្សក៏មានឧបមេយ្យ យ៉ាងដូច្នេះដែរ ព្រោះអាយុក្ខយ កម្មក្ខយព្រោះអស់កម្ម ឧភយក្ខយ ព្រោះអស់ទាំងអាយុ និង កម្ម និង ឧបច្ឆេទកៈ ព្រោះមានកម្មដទៃមកកាត់ រួមសេចក្តីស្លាប់ព្រោះ ៤ ប្រការនេះ ដូចប្រទីបដែលសំដែងមកហើយ

ក្នុងព្រះបាលីមិលិន្ទបញ្ហា លោកនាគសែនថេរថា **អត្ថិ មហារាជ កាលេបិ មរណំ អត្ថិ អកាលេ មរណំ ប្រែថា** លោកមហារាជ ដល់គ្រាដែលស្លាប់ក៏មានមិនដល់គ្រាដែលស្លាប់ក៏មាន ប៉ុន្តែក្នុងពាក្យអធិប្បាយរបស់លោកនាគសេនថេរ ថា សេចក្តីស្លាប់នោះ ព្រោះបច្ច័យ ៨ ប្រការតាមបាលីថា ជិឃច្ឆាយ បិបាសាយ អហិទដ្ឋា វិសេន ច អគ្គិឧទកសត្តីហិ អកាលេ តត្ថ មីយតិ វាតបិត្តេហិ សេម្ហេណសន្និបាតឧទូហិ ច វិសមោ បក្កមកម្មេហិ អកាលេ តត្ថ មីយតិ ។

មហារាជ កាលដែលសត្វទាំងឡាយស្លាប់នោះព្រោះហេតុ ១៥ ប្រការ គឺ ១- ព្រោះអត់អាហារ ២- ព្រោះអត់ទឹក ៣- ព្រោះពស់ចឹក ៤- ព្រោះថ្នាំពិស ៥- ព្រោះភ្លើង ៦- ព្រោះទឹក ៧- ព្រោះអាវុធផ្សេងៗ ៨- ព្រោះខ្យល់ ៩- ព្រោះប្រមាត់ខូច ១០- ព្រោះសេម្ហ ១១- សន្និបាត គឺខ្យល់ ប្រមាត់ស្លេស្ម រួម ៣

យ៉ាង ១២- ឧតុ ១៣- អាហារមិនសមគួរ ១៤- ព្រោះសេចក្ដី ព្យាយាម ១៥- ព្រោះកម្ម ។ រួម ១៥ ប្រការ

ហេតុ១៥ប្រការនេះ លោកអធិប្បាយថា ជាហេតុរបស់អកាលមរណៈ គឺ សេចក្ដីស្លាប់មិនទាន់ដល់ពេលស្លាប់ទាំងអស់នេះ ប៉ុន្តែទោះជាយ៉ាងណាក្ដី កាលដែលមិនទាន់ដល់វេលា ត្រូវមានជាប្រាកដ ព្រោះឧបច្ឆេទកកម្មនោះ ។

ព្រះបរមសាស្ដា ទ្រង់ទេសនាទុកក្នុងព្រះបាលីសំយុត្តមានច្រើនហើយ ដូច្នេះសត្វដែលមិនទាន់ដល់ពេលស្លាប់ក៏មាន សូម្បីក្នុងទេវលោក និង អបាយទាំង ៤ ក៏ដូចគ្នាដែរ ។

**សួរ** ធម្មតាការស្លាប់របស់បុគ្គលនោះ កម្ម កម្មនិមិត្ត គតិនិមិត្ត រមែងប្រាកដជាមានកាល ព្រះអរហន្តរលត់ខន្ធនោះមាននិមិត្តអ្វីខ្លះ ? សុំឆ្លើយឱ្យមានភស្តុតាង ព្រមដោយហេតុផល ។

**ឆ្លើយ** ធម្មតាការស្លាប់របស់បុគ្គលនោះ តាមព្រះបរមត្ថទេសនាថា បដិសន្ធិ ភវង្គញ្ច តថា ចវនមានសំ ឯកមេវតទេវេកវិសយញ្ចេកជាតិយំ ប្រែថា - បដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្ត រួម ៣ ប្រការនេះជាមួយគ្នាដោយ ភូមិ ជាតិ សម្បយុត្ត សង្ខារ និង ជាអារម្មណ៍ជាមួយគ្នា ។ ចំណែកបុគ្គលជាព្រះអរហន្តនោះ មានវាទៈដែលពោលច្រើនយ៉ាង ច្រើនន័យគឺ ខ្លះក៏ត្រូវថា ជាអារម្មណ៍នៃបដិសន្ធិ ភវង្គ ចុតិ អាស្រ័យបាលីដែលពោលមកហើយ ពីខាងលើនេះជាភស្តុតាង ខ្លះថាកាលព្រះបរមសាស្តា រំលត់ខន្ធក្នុងនគរ កុសិនារា ព្រះអនុរុទ្ធថេរ ពោលគាថា ថា អនេ-ជោសន្តិ មារព្ភ យំ កាលមកីរ មុនី ប្រែថា ព្រះបរមសាស្តា មិនមានតណ្ហា មាននិព្វានជាអារម្មណ៍ ហើយធ្វើកាលកិរិ-យា ដូច្នេះ ។ ព្រះអរហន្តមាននិព្វានជា អារម្មណ៍ ដូចគ្នា ។

វាទៈទាំងពីរន័យនេះ កាលយើងលើកឡើងពិចារណាឃើញថា វាទៈទាំងពីរន័យនេះ ជាវាទដែលត្រឹមត្រូវតាម

ព្រះបាលីព្រមទាំងអដ្ឋកថាគឺមុនដែលចុតិចិត្តរបស់ព្រះបរម សាស្ដា និង មានអារម្មណ៍ជាព្រះនិព្វាន ប្រាកដ ។

ក្រោយដែលមានព្រះនិព្វាន ជាអារម្មណ៍ ប្រាកដ ហើយ ព្រះបរមសាស្ដា ត្រង់យាងចូលនិរោធសមាបត្តិទៅ ( វិធីចូលនិរោធសមាបត្តិសុំមើលកម្មដ្ឋានបរិច្ឆេទ ) ក្នុង ខណៈដែលចូលនិរោធសមាបត្តិនោះ មិនមានអារម្មណ៍ជា ព្រះនិព្វានបានទេ ព្រោះធម្មតាសមាបត្តិ ត្រូវមានបញ្ញត្តា-រម្មណ៍ ឬ មហគ្គតារម្មណ៍ ឬ ទាំង ២ អារម្មណ៍ ។( មេត្តា មើលអារម្មណ៍សង្គហៈ ក្នុងបរិច្ឆេទទី ៣ ) ។

ព្រោះហេតុដូច្នេះ តាមវាទៈទាំង២ន័យនេះ សង្គ្រោះ ចូលគ្នាត្រឹមត្រូវតាមបាលី គឺមុននឹងចូលសមាបត្តិ ត្រូវមាន អារម្មណ៍ព្រះនិព្វាន ក្នុងការចូលសមាបត្តិត្រូវមានបញ្ញត្តា-រម្មណ៍ គឺ ឈាន ដែលរំលត់ខន្ធទៅ ដោយប្រាសចាក កម្ម កម្មនិមិត្ត គតិនិមិត្ត ។

**សួរ** អ្នកមានបដិសន្ធិចិត្តគ្រប់១គ្នា កាលជិតនិងចុតិ កម្ម

កម្មនិមិត្ត គតិនិមិត្ត រមែងមានប្រាកដជាធម្មតា ប៉ុន្តែ អសញ្ញិសត្តបុគ្គលចុតិនោះ មាននិមិត្តទាំង ៣ បានយ៉ាងណាព្រោះមិនមាននាម ។ តាមអភិធម្មត្ថសង្គហៈ កាលបដិសន្ធិ ក៏មានរូបបដិសន្ធិ កាលរលត់ ក៏មានរូបចុតិ ដូច្នេះកាលសំដែងថា អសញ្ញិសត្តព្រហ្មមិនចាំបាច់ឃើញនិមិត្ត ឬ ?

**ឆ្លើយ** អសញ្ញិសត្តព្រហ្ម ជាជំពូកព្រហ្មបុថុជ្ជន ត្រូវតែឃើញនិមិត្តប្រាកដ តាមបាលីថា សញ្ញុប្បាទា ច តេ ទេវា តម្ហាកាយា ចវន្តិ ប្រែថា - អសញ្ញិសត្តព្រហ្មបានចុតិព្រោះមានសញ្ញាកើត ដូច្នេះសូម្បី អសញ្ញិសត្តព្រហ្មចុតិដោយរូបក៏ដោយកាលមានសញ្ញាកើត ត្រូវត្រង់ហើយ ព្រោះអាស្រ័យបុណ្យចាស់ជាតិមុនៗ ។ កម្ម កម្មនិមិត្ត គតិនិមិត្ត ត្រូវមកប្រាកដតាមសភាពនៃបុថុជ្ជន ទាំងឡាយជាប្រាកដ ។

**សួរ** បុគ្គលម្នាក់ ក្នុងខណៈដែលឃើញគតិនិមិត្ត គឺប្រាសាទមាស ទេពអប្សរ បរិវារ និង និមិត្តដទៃៗទៀត

រមែងកើតជាសោមនស្ស គឺ សេចក្តីត្រេកអរ នេះជាសោភណចិត្ត ។ តណ្ហានេះក្លាយជាឧបាទានបាន ( តណ្ហានេះបានក្លាយជាឧបាទាន ) ។ តាមបដិច្ចសមុប្បាទន័យតពីនោះក៏ចុតិ កាលចុតិចិត្តរលត់ហើយ ព្រោះអាស្រ័យតណ្ហាឧបាទានទាំងអស់នេះ អ្នកនោះនឹងត្រូវទៅកើតក្នុង អបាយ ឬ ទេវលោកតាម គតិនិមិត្តខាងដើម ។

**ឆ្លើយ** ត្រូវទៅកើតក្នុងទេវលោកតាមគតិនិមិត្តនោះ ព្រោះការដែលបានឃើញប្រាសាទមាស ជាដើមនោះជាអានិសង្សរបស់កុសល អ្នកដែលបានឃើញយ៉ាងនេះ មានន័យថាជាមនុស្សមានបុណ្យ បុណ្យនោះរមែងមិននាំទៅកាន់អបាយទាំង ៤ ។ តាមធម្មតាបុណ្យនេះត្រូវនាំទៅកាន់សុគតិភូមិជានិច្ច ព្រោះហេតុដូច្នេះ ទើបព្រះបរមសាស្តាទ្រង់ទេសនាទុកថា **អដ្ឋានមេតំ ភិក្ខវេ អនវកាសោយំ កាយសុចរិតសមង្គី តន្និទានា តប្បច្ចយា កាយស្ស ភេទា បរម្មរណា**

**អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧប្បជ្ជេយ្យ នេតំ ឋានំ វិជ្ជតិ** ក្នុងឯកំគុត្តរៈព្រះបាលី ប្រែថា - ម្នាល សាវ័កទាំង ឡាយ អ្នកដែលបរិបូណ៌ដោយកាយសុចរិត ព្រោះកាយសុចរិតកាលដែលស្លាប់ទៅ តាមធម្មតាកាល ដែលនឹងទៅកើតក្នុងអបាយនោះ រមែងមិនមានឡើយ ឬ មិនមែន ឱកាសរបស់កុសល ដែលជូនទៅកើតក្នុងទីនោះ ។

ការពិចារណាមើលទៅក៏បានសេចក្ដីថា កាលដែល អ្នកស្លាប់នឹង បានទៅកើតក្នុងជាតិខាងមុខនោះ ព្រោះកម្ម ចាស់ គឺ កម្មដែលបានធ្វើមកពីមុនឱ្យជាគតិនិមិត្ត ។ ( មេត្តា មើលបាលីរបស់ព្រះ អនុរុទ្ធាចារ្យ ) ថា កម្មំ បន អតីតមេវ តញ្ច មនោទ្វារតហិតំ ប្រែថា កម្មនោះ ជាអតីត ទទួលមក ដោយមនោទ្វារត្រូវអាស្រ័យកម្មចាស់ ហើយ គតិនិមិត្តរមែងកើត ។ គតិនិមិត្តនេះឯងជាអានិសង្សរបស់ កម្ម ដែលមិនអាចនឹងនាំទៅកាន់ទុគ្គតិភូមិបាន តែយ៉ាងណា ក្ដី ការឃើញនិមិត្តរបស់មរណាសន្នវិថី មានត្រឹមជវន ៥គ្រា

ប៉ុណ្ណោះ ។

ក្នុងវេលានេះឯង កម្មជទៃ១ មិនមានឱកាសចូលមកលាយឡំបានឡើយ ព្រោះជវន ៥ គ្រាដែលពោលមកហើយជាពួករបស់កុសល ហើយនាំទៅកាន់ចុតិ និង បដិសន្ធិ ដូចផ្លែកបន្ទោរមួយគ្រាហើយរលត់ចុះ មួយរំពេច ព្រោះហេតុដូច្នេះក៏ឃើញនិមិត្តហើយកើត ភវនិកន្តិកលោភជវន មិនអាចនាំទៅកើតអបាយបាន ដោយន័យដែលពោលរួចមកហើយ ។

**សួរ** អ្នកដែលដល់ឈាន រូបាវចរៈ និង អរូបាវចរៈ រមែងឃើញកម្មនិមិត្តដែលជាបញ្ញត្តិនោះ ។ ពាក្យថាបញ្ញត្តារម្មណ៍ តាមដែលមនុស្សទូទៅចូលចិត្តថា បញ្ញត្តិជាឈ្មោះ ឬ ជាវោហារ និង ឈ្មោះជាកម្មនិមិត្តយ៉ាងណា ? ដល់អ្នកដែលបានដល់ឈាន ។

**ឆ្លើយ** តាមសភាពរបស់ព្រះបរមត្ថ អារម្មណ៍ អារម្មណិកៈមានព្រមគ្នាជានិច្ច ។ ចិត្តនិង ចេតសិកទាំងពីរនេះទទួល

យកអារម្មណ៍ជាប្រចាំ ឬ រហូតគ្រប់ពេលវេលា ។

ពាក្យថាអារម្មណ៍ បានដល់អារម្មណ៍ទាំង ៦ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និង កម្ម ។ អារម្មណ៍ទាំងនេះបើថាដោយបញ្ញត្តិ គឺ មាន កាមារម្មណ៍ មហគ្គតារម្មណ៍ បញ្ញត្តារម្មណ៍ និង លោកុត្តរារម្មណ៍ រួម ៤ អារម្មណ៍ ។

កាមារម្មណ៍ បានដល់រូប ២៨ កាមាវចរចិត្ត ៥៤ដួង ចេតសិក ៥២ដួង ហៅថាកាមារម្មណ៍ ។

មហគ្គតចិត្ត បានដល់ចិត្ត ២៧ដួង ចេតសិក ៣៥ដួង ហៅថា មហគ្គតារម្មណ៍ ។

លោកុត្តរចិត្ត បានដល់ចិត្ត ៤០ដួង ចេតសិក ៣៦ ដួង ហៅថា លោកុត្តរារម្មណ៍ ។

វោហារនេះរមែងមានផ្សេងៗ ដូចជាមនុស្ស ប្រុស ស្រី ដី មេឃ អាកាស បឋវី កសិណ អបោកសិណជាដើម ហៅថា បញ្ញត្តារម្មណ៍ អ្នកដល់ឈានខណៈដែលនឹងចុតិចុះ បានឃើញកម្មនិមិត្តនោះ ដូចជាបឋវីកសិណំ អបោកសិណំ

ជាដើម ជាគ្រឿងឧបករណ៍របស់កម្មដ្ឋាន ៤០ ដែលធ្លាប់បរិកម្មមកហើយ រមែងប្រាកដដល់អ្នកដែលស្លាប់ ពេលនោះហៅថា បញ្ញត្តារម្មណ៍របស់កម្មនិមិត្ត ។

បញ្ញត្តិនេះ ក្នុងបរមត្ថសាសនា ហៅថាវិជ្ជមានបញ្ញត្តិ (មេត្តាមើលប្រភេទ បញ្ញត្តិ ៦ ប្រការក្នុងបរិច្ឆេទទី ៨)

**សួរ** ពាក្យថាអាយុ និង ពាក្យថាជីវិត ទាំងពីរស័ព្ទនេះផ្សេងគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថាអាយុ ក្នុងបាលីប្រើដើម្បីទាក់ទងគ្នាច្រើនស័ព្ទដូចជា អាយុក្ខយ អាយុបរិច្ឆេទ អាយុបមាណ ដូច្នេះជាដើម ។ ប៉ុន្តែពាក្យខ្លះក៏មានន័យដូចគ្នា ដូចជាអាយុសង្ខារ និង អាយុ ។

ក្នុងមូលបណ្ណាសអដ្ឋកថា ថា អាយុសង្ខារាតិ អាយុមេវ ប្រែថា អាយុសង្ខារ គឺ អាយុនោះឯង ។

ពាក្យថា អាយុក្ខយ អាយុបរិច្ឆេទ អាយុបមាណ ទាំងអស់នេះបានដល់កំណត់វេលា ហៅថាអាយុ ។ ពាក្យ

ថាអាយុកន្លែងខ្លះ ប្រែបានថា ជីវិតិន្ទ្រិយំ តែក្នុងជីវិតិន្ទ្រិយ៍នេះ ចែកចេញជាចំណែក គឺ រូបជីវិត និង នាមជីវិត បានដល់សភាពម្យ៉ាងដែលរក្សារូប និង នាម ។

ក្នុងមូលបណ្ណាសអដ្ឋកថា ថា អាយុំ បដិច្ចាតិ ជីវិតិន្ទ្រិយំ បដិច្ច តិដ្ឋន្តិ ប្រែថា អាស្រ័យអាយុនោះ គឺ អាស្រ័យជីវិតិន្ទ្រិយ៍ ហើយរមែងប្រាកដនៅបានដូច្នេះ ពាក្យថាអាយុ កន្លែងខ្លះ ក៏កំណត់វេលាដែលតាំងនៅដូចជា អាយុបមាណេ គឺ ប្រមាណអាយុ ដូច្នេះជាដើម ។ កំណត់នេះ តាមវោហារដើម្បីឱ្យចាំទុកដោយថ្ងៃ ខែ ឆ្នាំ តែវេលានោះ មានមិនស្មើគ្នាក៏មាន ទោះជាយ៉ាងណាក៏ដោយ ពាក្យថា អាយុអាស្រ័យបញ្ញត្តិ គឺ វោហារ ។

ពាក្យថាជីវិតអាស្រ័យបរមត្ថ សេចក្ដីពីរស័ព្ទនេះ ជាមួយគ្នាក្នុងបរមត្ថធម៌ តែក្នុងបញ្ញត្តិនោះផ្សេងគ្នា គឺ អាយុប្រែបានពីរន័យ គឺ ជីវិតក៏បាន កំណត់វេលាក៏បាន ។

**សួរ** អ្នកស្លាប់អំពីជាតិនេះទៅកាន់ភពថ្មីនោះ អ្វីដែលទៅ

កើតមុន រូបកើត ឬ នាមកើតមុន ?

**ឆ្លើយ** តាមបដិច្ចសមុប្បាទសំដែងថា សង្ខារបច្ចយា វិញ្ញាណំ ប្រែថា - វិញ្ញាណកើតមុន វិញ្ញាណនេះហៅថា នាមធម៌ ។ តាមដែលទ្រង់ទេសនាថា វិញ្ញាណកើតមុន នោះមានន័យថា ចេតសិកទាំងអស់អាស្រ័យវិញ្ញាណ ឬ ចិត្តកើត ។ កាលវិញ្ញាណ ឬ ចិត្តមិនមាន ចេតសិកនឹងកើតខ្លួនឯងមិនបាន តាមសេចក្តីពិតព្រមជាមួយនឹងនាមធម៌កើត រូបធម៌កកើត រូបនេះហៅថាកម្មជរូប ដូច្នេះរូប និង និង នាម កើតព្រមគ្នា តែមានចិត្តជាប្រធាន ។ កាលមិន-មានចិត្តកើតមុន រូប- ចេតសិកកើតខ្លួនឯងមិនបាន ព្រោះហេតុដូច្នោះ ទើបព្រះបរមសាស្តាទ្រង់ទេសនាថា មនោ បុព្វង្គមា ធម្មា ប្រែថា មនោ គឺ ចិត្តនោះទៅកើត មុន ។

មហាបដ្ឋានព្រះបាលី ព្រះបរមសាស្តាទ្រង់ទេសនាសហជាតបច្ច័យ ថា ឱក្កន្តិក្ខណេ នាមរូបំ អញ្ញមញ្ញំ សហជាតបច្ចយេន បច្ចយោ ។ ប្រែថា : ក្នុងខណបដិសន្ធិ

នាម និង រូប រមែងកើតព្រមគ្នា ដោយអាស្រ័យនូវគ្នានឹងគ្នា ដូច្នោះ រូបនិង នាមរមែងកើតព្រមគ្នា ប៉ុន្តែនាមធម៌មានពីរយ៉ាង គឺ ចិត្ត និង ចេតសិក ។

ទាំងពីរពាក្យនេះ ពាក្យថាចេតសិក អាស្រ័យចិត្តទើបកើត ឬ កើតតែឯងមិនបាន ដូច្នេះ ការកើតរបស់ចេតសិកនោះ ទាក់ទងមកពីចិត្ត ដូចពន្លឺ និង ភ្លើង គឺ ពន្លឺភ្លឺអាស្រ័យភ្លើង កើត តែថាពន្លឺមានរមែងនៅរួមនឹងភ្លើងជាមួយគ្នាមានន័យថា ពន្លឺ និង ភ្លើង កើតព្រមគ្នាក៏ថាបានមានឧបមាយ៉ាងណា រូប និង នាមក៏មាន ឧបមេយ្យយ៉ាងនោះដែរ គឺ កើតព្រមគ្នា តាមពុទ្ធភាសិតដែលបានអធិប្បាយមកហើយ ។

**សួរ** អ្នកដែលស្លាប់ទៅកាន់បរលោកនោះ មានអ្វីជាប់តាមរូប និង នាម ព្រោះបុណ្យដែលធ្វើទុក រមែងប្រាកដមានហើយបើមិនមានអ្វីដែលនឹងទៅទទួលផលនោះ និងជាការខូចបុណ្យ ឬ បាប ដែលបានធ្វើទុកហើយ ឬ ដូចម្តេច ?

**ឆ្លើយ** បញ្ហាដែលសួរនេះ ក៏មិនប្លែកអ្វីណាស់ណាទេ សូម្បីមនុស្ស សម័យនេះ យល់ថាជាបញ្ហាដែលសមរម្យនិងមហាជនក៏ដោយព្រោះសម័យបុព្វកាល បានមានមកមួយគ្រាហើយ ។

ក្នុងបណ្ណាសូបាលីថា តេនខោ បន សមយេន សាតិស្ស នាម ភិក្ខុនោ កេវដ្ដបុត្តស្ស ឯវរូបំ បាបកំ ទិដ្ឋិឧប្បន្នោ ហោតិ ។ ប្រែថា សម័យនោះមានមិច្ឆាទិដ្ឋិរមែងកើតដល់ភិក្ខុសាតិ ដែលជាបុត្ររបស់អ្នកនេសាទត្រីមានសេចក្ដីថា ភិក្ខុសាតិ នៅប្រកាន់ខុសជាមិច្ឆាទិដ្ឋិ បែបដែលជឿថា កាលមនុស្សស្លាប់ពីមនុស្សទៅហើយ វិញ្ញាណចាស់ទៅទទួលសោយបុណ្យ បាប ដែលបានធ្វើទុកពីមុនគឺកាលមុននឹងស្លាប់នោះឯង ។

តាមទ្រឹស្ដីភស្តុតាងរបស់ព្រះពុទ្ធសាសនា សំដែងថា វិញ្ញាណចាស់ក្នុងជាតិនេះ មិនបានជាប់ទៅតាមមនុស្សស្លាប់ទៅទេ បើវិញ្ញាណជាប់ទៅតាម ជាមួយមនុស្សស្លាប់ទៅ

បាននោះ មានសេចក្តីថា វិញ្ញាណជារបស់ទៀងនៅមិនបាន រលត់ដែលផ្ទុយគ្នានិង សព្វេ សង្ខារា អនិច្ចាទៅហើយ ព្រោះ វិញ្ញាណជាសង្ខារ ធម្មតាសង្ខារទាំងអស់ត្រូវបែក-ធ្លាយ រលត់ដល់ទីបំផុត ព្រោះហេតុដូច្នោះតាមគោលទ្រឹស្តីព្រះពុទ្ធសាសនា អ្នកដែលប្រកាន់ថាវិញ្ញាណចាស់ ជាប់តាមអ្នកស្លាប់ និង សោយបុណ្យបាប នោះ ជាមិច្ឆាទិដ្ឋិតែម្យ៉ាង

តាមវាទៈរបស់ព្រះបរមសាស្តារបស់យើងប្រកាន់ថា ធម្មតាវិញ្ញាណរមែងកើត ព្រោះដោយបច្ច័យ មានសេចក្តីថា មិនមានទុកមុនទេ កាលខណៈដែលមានបច្ច័យនោះឯង វិញ្ញាណរមែងកើតក្នុងខណៈនោះ វិញ្ញាណនោះមិនមែនជាអ្នកទទួលសោយសុខ ឬ ទុក្ខទេ ។ អ្នកដែលសោយទុក្ខសុខ នោះជាវេទនាដោយឡែក ឧទាហរណ៍ តាមការសំដែង របស់ព្រះបរមសាស្តាថា ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្ស បច្ចយា វេទនា ប្រែថា អាស្រ័យចក្ខុបសាទរូប និង

រូបារម្មណ៍ប៉ះទង្គិចគ្នា ចក្ខុវិញ្ញាណរមែងកើត ។ អាស្រ័យ ចក្ខុ រូបារម្មណ៍ និង វិញ្ញាណរួម ៣ យ៉ាងនេះ ផស្សចេតសិក រមែងកើតបន្ត ព្រោះ ផស្សៈនេះ វេទនាក៏រមែងកើតតាម មកទៀត ។

អធិប្បាយចក្ខុ គឺ ភ្នែក និង រូបារម្មណ៍ គឺពណ៌ ប្រជុំ គ្នាចូលផ្លូវភ្នែក វិញ្ញាណក៏រមែងកើតឡើង វិញ្ញាណនេះដឹង តែឃើញ ប៉ុណ្ណោះ នៅមិនទាន់សោយអារម្មណ៍ អាស្រ័យ វិញ្ញាណភ្នែកជារូបារម្មណ៍ ។

ទាំង ៣ នេះ ចក្ខុសម្ផស្ស ក៏កើតតាមក្រោតមក ព្រោះសម្ផស្សនេះ វេទនាដែលជាអ្នកសោយ សុខ និង ទុក្ខ រមែងប្រាកដថា យើងជាអ្នកសោយសេចក្ដីសុខ សប្បាយ រីករាយចិត្ត យើងជាអ្នកសោយសេចក្ដីទុក្ខលំបាកចិត្ត ព្រោះ ហេតុដូច្នេះ បុណ្យ និង បាបរបស់អ្នកស្លាប់ កាលបានទៅ កើតក្នុងជាតិថ្មីនោះ អាស្រ័យបច្ច័យក្នុងជាតិថ្មី និង វិញ្ញាណ ថ្មីកើត អាស្រ័យការប្រជុំគ្នាថ្មី ផស្សៈ វេទនាកើត វេទនាថ្មី

ក្នុងជាតិថ្មីនេះឯង ជាអ្នកសោយសេចក្ដីសុខ ទុក្ខក្នុងវេលានោះ មិនមានវិញ្ញាណចាស់ ជាប់តាមមកសោយសុខ ឬ ទុក្ខទេ ។

ព្រោះហេតុដូច្នេះ តាមគោលទ្រឹស្ដីនៃធម៌ ជាភស្ដុតាងថា អ្នកដែលប្រកាន់សោយសុខ និង ទុក្ខជាមិច្ឆាទិដ្ឋិ ។

ក្នុងខណៈដែលសាកសួរ ភិក្ខុសាតិ ព្រះបរមសាស្ដាទ្រង់ត្រាស់ថា អត្តនាទុត្តហិតេន អមេហាចេវ អព្ភាចិក្ខតិ អត្តានញ្ចេវ ខណតិ ពហុំ អបុញ្ញំ បវសតិ ប្រែថា ភិក្ខុសាតិវាទៈរបស់អ្នកដែលជាទុត្តហិតៈ គឺ ការប្រកាន់ខុសនេះ រមែង និន្ទាយើងផង ធ្វើអាក្រក់ខ្លួនឯងផង និង ធ្វើឱ្យអកុសលច្រើនដូចនេះ។ រឿងវិញ្ញាណកើតយ៉ាងណា វេទនាក៏សោយ យ៉ាងនោះ ។ ( មេត្តាមើលក្នុងបរិច្ឆេទទី ៨ ផង )

**សួរ** បុណ្យ និង បាបចាស់ តាមអ្នកស្លាប់ទៅនោះ តាមទៅយ៉ាងណាខ្លះ តាមបរមត្ថសំដែងថា បុណ្យ និង បាប

រលត់មួយរំពេចទៅហើយ ។

**ឆ្លើយ** ធម្មតាបុណ្យ និង បាប កាលអ្នកដែលធ្វើទៅហើយ រមែងរលត់ទៅក៏ពិតមែន តែអំណាចរបស់អ្នកធ្វើ សេចក្តីអង់អាចនេះគ្មានរលត់ទៅទេ ។ អំណាចនៃសេចក្តីអង់អាចនេះហៅថាផល ឬ វិបាកក៏បាន ក្នុងទីនេះកាលអ្នកស្លាប់ៗចាកពីជាតិនេះទៅកាន់ បរលោកនោះ សន្តតិរបស់ចិត្តគំនិតនៅមានតំណើរការទៅដូច្នោះដែរ ។

ក្នុងចិត្តគំនិតដែលបន្តទៅនោះ អំណាចរបស់សេចក្តីអង់អាចដែលខ្លួនបានធ្វើជាប់ទៅតាម ដូចស្រមោលជាប់តាមមនុស្សជានិច្ច ។ តាមពុទ្ធភាសិត ក្នុងធម្មបទថា ឆាយាវ អនុបាយិនី ប្រែថា បុណ្យដែលខ្លួនបានធ្វើទុក នោះដូចស្រមោលទៅជាប់តាមជានិច្ច អំណាចរបស់សេចក្តីអង់អាចដែលបានជាប់ចិត្តគំនិត ហៅថា និស្ស័យ ឬ ដែលហៅថាវាសនាក៏បាន ។ វាសនានេះទាក់ទងមកពីបុណ្យចាស់ ។

វិធីជាប់តាមដូច្នេះគឺ ចេតនាសមង្គី កម្មសមង្គី ឧបដ្ឋានសមង្គី វិបាកសមង្គី រួមលំដាប់ផ្លូវបុណ្យ បាបរហូតដល់ផល ។

អធិប្បាយថា កាលខណៈដែលធ្វើបុណ្យ ឬ បាបក៏ដោយ ត្រូវបរិបូរណ៌ ដោយចេតនាមុន ចេតនាខណៈនោះហៅថាចេតនា សមង្គី កាលអាស្រ័យចេតនាបានហើយ អ្នកធ្វើបុណ្យ ឬ បាប កម្មដែលល្អ ឬ អាក្រក់ ក៏រមែង ប្រាកដឡើង ក្នុងខណៈនោះហៅថា កម្មសមង្គី ។ អាស្រ័យកម្ម ល្អ ឬ កម្មអាក្រក់ទាំងអស់នេះ អ្នកធ្វើកាលមរណៈរមែងឃើញ និមិត្ត គឺ កម្ម កម្មនិមិត្ត និង គតិនិមិត្ត ខណៈនេះហៅថា ឧបដ្ឋានសមង្គី ។

ខាងក្រោយដែលឧបដ្ឋានសមង្គីរលត់ហើយ កុសល និង អកុសលដែលខ្លួនបានធ្វើទុកនោះ ឱ្យផលក្នុងជាតិថ្មី ឬ ភពថ្មី មួយរំពេចខ្លះនោះ ហៅថាវិបាកសមង្គី និង វិញ្ញាណ ផស្សវេទនាទាំងអស់នេះអាស្រ័យបច្ច័យ ហើយក៏រមែង

កើតតាម១គ្នា និង សោយសេចក្ដីសុខ ទុក្ខ ដូចគ្នា ព្រោះហេតុដូច្នេះ បាបចាស់ តាមទៅឱ្យផលក្នុងជាតិថ្មី ឬ ភពថ្មី អាស្រ័យលំដាប់ធម្មជាតិ ដែលបានសំដែងមកហើយនេះ ។

**សួរ** អ្នកដែលស្លាប់ ស្លាប់ហើយកើតទៀតឬទេ បើកើតអ្វីជាអ្នកកើត ?

**ឆ្លើយ** តាមវោហារថា កើត ឬ ស្លាប់នោះត្រឹមតែ សម្មតិស្លាប់និង កើតថាដោយសង្ខេប១ គឺ បញ្ញត្តិធម៌ប៉ុណ្ណោះ ។ ការដែលត្រូវស្លាប់ និង កើត ឬ មិនកើតទេនោះ ត្រូវអធិប្បាយពីរន័យ គឺ ១-បញ្ញត្តិ ២-បរមត្ថ

១-ពាក្យថាបញ្ញត្តិ គឺ វោហារ ឬ សម្មតិ

២-ពាក្យថាបរមត្ថ គឺ សេចក្ដីពិតរបស់សភាវធម៌ ។

ក្នុងទីនេះ បញ្ញត្តិថា កើត ស្លាប់ នោះជាបញ្ញត្តិ ព្រោះហេតុដូច្នេះ អ្នកឆ្លើយក៏ឆ្លើយដោយបញ្ញត្តិ អាស្រ័យព្រះសូត្រផ្សេង១ជាគោលទ្រស្ដី ។

បើឆ្លើយដោយបរមត្ថ ឆ្លើយដោយរូប នាម ខន្ធធាតុ

ដោយអាស្រ័យ ព្រះអភិធម្ម ជាគោលភស្តុតាង ឆ្លើយ ដោយន័យទី ១ គឺ វោហារ

ក្នុងបញ្ហាថា អ្នកស្លាប់ និង កើត ឬ មិនកើតទេនោះ អ្នកស្លាប់រមែងមាន អ្នកនេះជាអ្នកមានឧបាទាន ហើយ ត្រូវកើតពិតប្រាកដ តាមទ្រឹស្តីគាថាព្រះសូត្រ កាយស្ស ភេទា បរម្មរណា សុគតី សគ្គំ លោកំ ឧប្បន្នា ឬ កាយស្ស ភេទា រម្មណា ទុគ្គតី អបាយំ វិនិបាតំ ឧប្បន្ន ដូច្នេះ ។

ប្រែបទទី ១ សត្វដែលធ្វើបុណ្យទុក កាលរាងកាយ បែកធ្លាយ ខាងក្រោយដែលរាងកាយបែកធ្លាយ រមែងកើត ក្នុងសុគតិ ភូមិក្នុងទេវលោក ។

ប្រែបទទី ២ សត្វដែលធ្វើបាប កាលរាងកាយបែក ធ្លាយ ខាងក្រោយដែលមានរាងកាយ បែកធ្លាយ រមែង កើតក្នុងអបាយទាំង ៤ ភូមិ ដែលជាទីកន្លែងសោយសេចក្តី ទុក្ខលំបាកផ្សេងៗ តាមព្រះសូត្រដែលសំដែងទុកហើយ នោះ កាលមានមនុស្សស្លាប់ មនុស្សដែលកើតនៅសុគតិ

ទុគ្គតិភូមិ រមែងមានដូចគ្នា ព្រោះហេតុដូច្នេះ តាមវោហារសំដែង មនុស្សស្លាប់ហើយរមែងកើត តែជាវោហារ ។ ពាក្យថាវោហារនេះ ជាបញ្ញត្តិធម៌ សេចក្តីពិតមិនមែនជា សភាវៈពិតទេ ។

កាលឆ្លើយតាមគោលទ្រឹស្តីបរមត្ថនោះ បុគ្គល ឬសត្វ មិនមានទេ តាមវោហារថា បុគ្គល ឬ សត្វនេះត្រឹមជាសម្មតិ ដើម្បីឱ្យងាយយល់ ពិតប្រាកដមានតែរូប នាម ខន្ធ អាយតនៈ ធាតុប៉ុណ្ណោះ ។

ពាក្យថាស្លាប់ ។ នោះតាមបាលីមាន ១០ យ៉ាងគឺ : ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំភេទោ កលេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ រួម ១០ យ៉ាងគឺ អសមញ្ញា ដែលលាយឡំគ្នាទាំងបញ្ញត្តិ ទាំងបរមត្ថ ។

ក្នុងទីនេះ តាមអភិធម្មថា ចុតិ ចវនតា ខន្ធានំភេទោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ រួម ៤ ពាក្យនេះប្រើ

ស័ព្ទតាមព្រះបរមត្ថ ដែលសល់ ៦ ពាក្យទៀត ប្រើតាមវោហារ ។

ក្នុង ៤ ពាក្យដែលប្រើតាមព្រះបរមត្ថ ពាក្យថា ខន្ធានំភេទោ ប្រែថា ខន្ធបែកធ្លាយ គឺ ខន្ធទាំង ៥ កើតមកហើយ ត្រូវរលត់ជានិច្ចទៅ ។ ពាក្យថាខន្ធទាំង ៥ មានសេចក្ដីដល់ រូប និង នាម ទាំងពីរ ប៉ុណ្ណោះ ។ រូប និង នាមទាំងពីរនេះ រមែងរលត់ជានិច្ច មិនដាច់ក្រសែទេ ។ រូប និងនាមទាំងពីរនេះអាស្រ័យអនន្តរបច្ច័យ សមនន្តរបច្ច័យ កើតហើយរលត់ រលត់ហើយកើត ទៅតាមសន្តតិ ដូចគ្នា និងក្រសែទឹកហូរមកជានិច្ច ដូច្នេះបើអ្នកណាម្នាក់ ប្រើដោយបញ្ញត្តិ ថាបុគ្គល ឬ សត្វស្លាប់នោះ ជាឧច្ឆេទទិដ្ឋិតែម្យ៉ាង ព្រោះ រូប និង នាម កើតរលត់ត១គ្នា និង ចោទស្លាប់មិនបាន ព្រោះមិនមានបុគ្គលទេ បើយល់ថាបុគ្គល ឬ សត្វមិនស្លាប់ក៏ត្រូវជា សស្សតទិដ្ឋិ មានសេចក្ដីថា ឃើញទៀងនៅដូចព្រះនិព្វានបាន តែយ៉ាងណាក៏ដោយ រូបនាមនោះដំណើរ

ទៅតាម សភាវៈប៉ុណ្ណោះឯង និងថាស្លាប់ . មិនបានស្លាប់ នោះជា បញ្ញត្តិ ។

ក្នុងទីនេះតាមព្រះបរមត្ថ មិនមានបុគ្គល ឬ សត្វទេ ព្រោះហេតុដូច្នេះ ធមិទាំងពីរយ៉ាងនេះចូលគ្នាមិនបានទេ ។ តាមគាថាវត្ថុព្រះបាលីថា :

**ខន្ធេសុ ភិជ្ជមានេសុ សោ ច ភិជ្ជតិ បុគ្គលោ ឧច្ឆេទោ គទតិ ទិដ្ឋិយា ពុទ្ធេន វិវជ្ជិតា ។**

ខន្ធេសុ ភិជ្ជមានេសុ នោ ចេ ភិជ្ជតិ បុគ្គលោ

**បុគ្គលោ សស្សតោ ហោតិ និព្វានេន សមសមោ ។**

**ប្រែថា៖** តាមវោហារ កាលខន្ធបែកធ្លាយ បុគ្គលស្លាប់នោះ ជាឧច្ឆេទទិដ្ឋិ ដែលព្រះបរមសាស្ដាឱ្យវៀរចេញ ។

- កាលខន្ធបែកធ្លាយ បុគ្គលមិនស្លាប់នោះ បុគ្គលទៀងនៅ រហូតដល់ព្រះនិព្វាន ជាសស្សតទិដ្ឋិ ។

ក្នុងទីនេះកាលខន្ធមិនទៀង ត្រូវប្រែថា មិនទៀង (អនិច្ចំ) ត្រឹមត្រូវ តែថាបុគ្គលស្លាប់នោះខុស ។

កាលខន្ធមិនទៀងជាអនិច្ច ប្រើវោហារថា បុគ្គលមិនស្លាប់នោះ តាមធម្មតាបុគ្គលមិនមានទេ មានសេចក្តីថា ពាក្យថាបុគ្គល ទៀងដូចព្រះនិព្វាន ។

ព្រោះហេតុដូច្នោះ ក្នុងបរមត្ថធម៌ នឹងយក ឬ ប្រើពាក្យវោហារ គឺ បញ្ញត្តិមកជ្រៀតជ្រែកមិនបាន ត្រូវនិយាយតាមសភាវៈរបស់គេ គឺ រូប និង នាម រមែងកើតរលត់ដោយអាស្រ័យ សន្តតិ ត១គ្នាទៅ រហូតដល់អសង្ខតៈព្រះនិព្វាន ។

ប៉ុន្តែបើនិយាយជាលោកិយវិញ ត្រូវថា មនុស្សស្លាប់ ឆ្កែស្លាប់ និង សត្វស្លាប់ហើយ ត្រូវកើតទៀតពិត១ (វៀរលែងព្រះអរហន្ត) ។

ព្រោះហេតុដូច្នោះ ត្រូវវិនិច្ឆ័យថា តាមព្រះបរមត្ថ ថាមនុស្សមិនស្លាប់ មិនកើត មានតែរូប និង នាមដែលកើត

វលត់ ។ តាមបញ្ញត្តិត្រូវថា មនុស្សកើតត្រូវស្លាប់ៗ ហើយកើតតាមកម្មដែលបានធ្វើមកហើយប៉ុណ្ណោះ ។

**ចប់មរណចតុក្ក**

**ចប់បរិច្ឆេទទី ៥**

បរិច្ឆេទទី ៦

# អភិធម្មនិទានគាថា

សុតន្តំ អភិធម្មញ្ច វិនយញ្ចាបិ កេវលំ
នវង្គំ ពុទ្ធវចនំ ឯសា ធម្មសភា តវ

ព្រះបាលីអបទានរបស់ថៃទំព័រ ៦៣ បន្ទាត់ទី ១១ ឧបាលិ ថេរវត្ថុ

បពិត្រព្រះពុទ្ធអង្គកំពូលអ្នកប្រាជ្ញ ព្រះសុតន្តបិដក ព្រះអភិធម្មបិដក និង ព្រះពុទ្ធវចនមានអង្គ៩ ទាំងអស់ជាធម្មសភារបស់ព្រះអង្គ ។

ក្នុងព្រះបាលីមានសេចក្តីថា ព្រះបរមសាស្តាជាម្ចាស់របស់សភា ជាព្រះរាជារបស់នគរធមិ និង ជាប្រមុខនៃធមិធម្មសភា ធម្មសភារបស់ព្រះអង្គមាន ៣ ផ្នែកគឺ

១-ផ្នែកព្រះសូត្រ ហៅថា សុតន្តសភា

២-ផ្នែកព្រះអភិធម្ម ហៅថា អភិធម្មសភា

៣-ផ្នែកព្រះវិន័យ ហៅថា វិនយសភា

រួម ៣ សភានេះ ជាពុទ្ធវចនៈទាំងអស់ដោយបរិបូណ៌ អង្គ ៩គឺ

**សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ៗ**

១-ព្រះសូត្រទាំងឡាយ ដូចជា រតនសូត្រ មង្គលសូត្រជាដើម ហៅថា សុត្តៈ ។

២-ព្រះសូត្រដែលលាយឡំដោយគាថា និង បាលីធម្មតា ដូចជាព្រះបាលីសុត្តនិបាត ព្រះបាលីឧភតោវិភង្គជាដើម ហៅថា គេយ្យៈ ។

៣-ព្រះពុទ្ធវចនៈដែលសំដែង ប្រាសចាកគាថា គឺបាលីធម្មតា ដូចជាព្រះអភិធម្មបិដកទាំងអស់ និង ព្រះសូត្រសុទ្ធ មិនមានគាថាឡើយ ហៅថា វេយ្យាករណ៍ ។

៤-ព្រះពុទ្ធវចនៈដែលទាក់ទងមកពី បីតិ សោមនស្សដូចជាព្រះបាលីឧទាន ជាដើមហៅថា ឧទានៈ ។

៥-ព្រះពុទ្ធវចនៈដែលសំដែងគាថាសុទ្ធ ដូចជាព្រះបាលី ធម្មបទ អបទាន ជាដើម ហៅថា គាថា ។

៦-ព្រះពុទ្ធវចនៈដែលប្រកបដោយ ព្រះបាលីថា វុត្តញ្ហេតំ ភគវតា ជាដើម ហៅថា ឥតិវុត្តកៈ ។

៧-ព្រះជាតកផ្សេង១ ដូចជាឯកនិបាត ទុកនិបាត ជាដើម ហៅថាជាតក ។

៨-ព្រះពុទ្ធវចនៈដែលសំដែងអស្ចារ្យផ្សេង១ របស់ព្រះសាវ័ក ឬ អស្ចារ្យផ្សេង១ ហៅថា អព្ភូតធម្មៈ ។

៩-ព្រះពុទ្ធវចនៈដែលសំដែងវិសជ្ជនា-បុច្ឆា ដូចជា មហាភាជ ទល្លសូត្រ ចូឡវេទល្លសូត្រ ជាដើមហៅថា វេទល្លៈ ។

រួមអង្គទាំង ៩ ជាព្រះពុទ្ធវចនៈទាំងអស់ ។

ក្នុងធម្មសភារបស់ព្រះពុទ្ធនេះ ព្រះមហាសាវ័ក ២ រូបព្រះអង្គតាំងទុកជាអធិបតី គឺ ផ្នែកព្រះសូត្រ ព្រះអភិធម្ម ទ្រង់តាំងព្រះឧបាលី ជាធម្មសេនាបតី វិន័យ ។

ព្រះអានន្ទ ជាពហូសូត្រ ជាអ្នករក្សាព្រះធម៌ ( សេនាបតីព្រះឃ្លាំងធម៌ ) ។

សមាជិកសភាមាន ៣ ជំពូក គឺ ព្រះសុត្តន្តិកបុគ្គល ( ផ្នែកព្រះសូត្រ ) អភិធម្មិកបុគ្គល ( ផ្នែកព្រះអភិធម្ម ) និងវិន័យធម្មិបុគ្គល ( ផ្នែកវិន័យ ) ។

ក្រៅអំពីនេះ ពេញទៅដោយសាវ័ក ដែលជាភ្នាក់ងាររក្សាតួនាទីផ្សេងៗដូចជា :

ព្រះមោគ្គល្លាន មានតួនាទីសំដែងរិទ្ធិ ។

ព្រះមហាកស្សប មានតួនាទី ប្រតិបត្តិ ធុតង្គ ១៣ ដូច្នេះជាដើម ។

អាយុបរិច្ឆេទរបស់ធម្មសភានេះ ព្រះពុទ្ធអង្គទ្រង់តាំងទុកមានកំណត់ត្រឹម ៥.០០០ វស្សា ។

**មានសេចក្តីថា** ក្នុង ៥.០០០ វស្សានេះ មាន ការស្តាប់ មានការសិក្សា មានការរៀនសូត្រ ព្រះសូត្រ ព្រះអភិធម្ម និង ព្រះវិន័យ ជានិច្ចមិនដាច់ក្រសែ ។

ក្នុងធម្មសភាររបស់ព្រះ បរមសាស្តា ព្រះសូត្រ ព្រះវិន័យ យើងទាំងអស់គ្នា រមែងដឹងថា កំពុងដំណើរការសិក្សានៅរាល់ថ្ងៃ តែចំណែកព្រះអភិធម្ម មានអ្នកសិក្សាតិចតួច និង អ្នកស្តាប់ក៏មិនសូវច្រើន ដូច្នោះ ខ្ញុំព្រះអង្គសូមសំដែង ព្រះអភិធម្មមុន ។

កាលខ្ញុំព្រះអង្គបានបោះពុម្ព គម្ពីរសៀវភៅ ភាគ ១ ចំណាយវេលាមិនយូរ ខ្ញុំព្រះអង្គសុំសួរ ដោយបញ្ហា ៣ ខ គឺ

១-ព្រះអភិធម្មនោះគឺអ្វី ? ។

២-អ្នកណាដែលជាអ្នកសំដែង ព្រះអភិធម្ម គឺ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែង ឬ សាវ័ក

៣-ក្នុងពុទ្ធកាល តើមានអ្នកសិក្សា ព្រះអភិធម្មដែរឬទេ ?

**បញ្ហាទី ១** ព្រះអភិធម្មគឺជាអ្វី ? សុំវិសជ្ជនាថា : ព្រះ អភិធម្ម គឺ ជាធម៌ ៧ គម្ពីរ គឺ :

១-ធម្មសង្គណី ២ វិភង្គ ៣ ធាតុកថា ៤ បុគ្គលប្បញ្ញត្តិ ៥ កថាវត្ថុ ៦ យមកៈ ៧ មហាបដ្ឋាន រួម ៧ គម្ពីរ ។ ដែលពោលមកហើយនេះ ហៅថា ព្រះអភិធម្ម ៧ គម្ពីរ ។

ក្នុងគម្ពីរអដ្ឋសាលិនីរបស់ថៃ ទំព័រលេខ ៤ បន្ទាត់ទី ១៩ ថា **បករណំ បរិច្ឆេទតោ បនេស ធម្មសង្គណី វិភង្គ ធាតុកថា បុគ្គលប្បញ្ញត្តិ កថាវត្ថុ យមក បដ្ឋានានំ សត្តន្នំ បករណានំ វសេនចិតោបិ**

**ប្រែសេចក្ដីថា**

ព្រះអភិធម្មកំណត់ដោយគម្ពីរនោះគឺ :

**ធម្មសង្គណី វិភង្គ ធាតុកថា បុគ្គលប្បញ្ញត្តិ កថាវត្ថុ យមក បដ្ឋានំ** រួម ៧ គម្ពីរ ។

ក្នុងវិភាវិនីដីកា ផានាថា : **ធម្មសង្គណី អាទិ សត្តប្បករណំ អភិធម្មបិដកំ**

ប្រែសេចក្ដីថា

ក្នុងគម្ពីរ មិលិន្ទបញ្ហារបស់ថៃ ទំព័រលេខ ១៨ បន្ទាត់ទី ១០ ថា :

**អាយស្មា មន្តិ នាគសេនំ បឋមេនេវ អភិធម្មំ អនោសិកុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មាតិ តិកទុកព្យ ធម្មសង្គណី វិភង្គធាតុកថាបុគ្គលប្បញ្ញត្តិ កថាវត្ថុ យមក- មហាបករណំ សព្វន្តំ ភះថសិ ខ**

ប្រែសេចក្ដីថា

ព្រះមហារោហនថេរ បង្រៀនព្រះអភិធម្មដល់លោក **នាគ សេន** គ្រាដំបូង :

**កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា ដែលចាត់ជា តិកៈ ទុកៈ និង ធម្មសង្គណី វិភង្គ ធាតុកថា បុគ្គលប្បញ្ញត្តិ**

**កថាវត្ថុ យមកៈ មហាដ្ឋាន** រួមព្រះអភិធម្មទាំងអស់ ៧ គម្ពីរ ។

អាស្រ័យកុស្តុតាងទាំងអស់ ពាក្យថាអភិធម្ម មិនមែនដទៃទេ បានដល់ព្រះអភិធម្ម ៧ គម្ពីរ ដែលបានពោលមកហើយនេះឯង ។

ពាក្យថា អភិធម្មត្ថៈនេះ ញែកជា ២ បទគឺ អភិធម្មៈ និង អត្ថៈ

**ប្រែថា** អភិធម្មៈ បានដល់ អភិធម្ម ៧ គម្ពីរ ។

អត្ថៈ បានដល់ ន័យសេចក្តី ។

**មានសេចក្តីថា** : ន័យសេចក្តីក្នុង ៧ គម្ពីរបានដល់ចិត្តំ ចេតសិកំ រូបំ និព្វានំ រួម ៤ ប្រការ ។

**អធិប្បាយថា** ក្នុងគម្ពីរទាំង ៧នេះ ពេញទៅដោយន័យ ៤ ប្រការ ។ ន័យ ៤ ប្រការនេះ ហៅថា អភិធម្មត្ថៈ ឬ អាស្រ័យពិគ្រោះស័ព្ទថា **បរមស្ស ឧត្តមស្ស ញាណស្ស អត្ថោ គោចរោតិ បរមត្ថោ**

**ទើបហៅថា បរមត្ថៈ** ។ ប្រែតាមពិគ្រោះស័ព្ទថា ព្រះបរមត្ថ ៤ ប្រការនេះ ជាអារម្មណ៍របស់ព្រះសព្វញ្ញុត-ញ្ញាណ ហៅថាបរមត្ថ ( មេត្តាមើល អភិធម្មត្ថ វិភាវិនីរបស់ ថៃទំព័រលេខ ៦៦ បន្ទាត់ទី ១៤ផង )

ដោយអាស្រ័យទីកន្លែងដែលពោលមកហើយ ផ្សេងៗ ពាក្យថាអភិធម្ម ៧ គម្ពីរ ដែលបានពោលមកហើយ និង ពាក្យបរមត្ថបានដល់ន័យក្នុងព្រះអភិធម្ម ៧ គម្ពីរ ។

**បញ្ហាទី ២** អ្នកណាជាអ្នកសំដែងអភិធម្ម ស៊ីវិជ្ជនា ដូចតទៅ អ្នកទាំងឡាយជ្រាបហើយថា ព្រះអភិធម្ម ៧ គម្ពីរនេះ ជាអារម្មណ៍របស់សព្វញ្ញុតញ្ញាណ ដោយអាស្រ័យ គម្ពីរអភិធម្មវិភាវិនី ទំព័រលេខ ៦៦ បន្ទាត់ទី ១៤ ដែលខ្ញុំ ព្រះអង្គបានអធិប្បាយមកហើយក្នុងវិជ្ជនាទី ១ មិនត្រូវ សង្ស័យថា ព្រះអភិធម្ម ព្រះសាវ័ក អាចនឹងសំដែង បាន ព្រោះមិនមែនសេចក្តីចេះដឹងរបស់សាវ័ក និង សាវ័ក ចេះដឹងដោយខ្លួនឯងទេ ដូច្នោះ ព្រះបរមលោកនាថ

ទើបទ្រង់សំដែងព្រះអភិធម្ម ( ទ្រង់សំដែងទីណា និង កាលណានោះ មេត្តាមើលព្រះអភិធម្មពិស្តារភាគ ១ ផង ) ។

ក្នុងគម្ពីរ អដ្ឋសាលនីរបស់ថៃ ទំព័រលេខ ៤០ បន្ទាត់ទី ៥ ថា **អភិធម្មោ នាមេស សព្វញ្ញុតពុទ្ធា-នំយេវ វិសយោ ន អញ្ញេសំ វិសយោ ។**

**ប្រែសេចក្តីថា**

ក្នុងព្រះអភិធម្ម ជាវិស័យរបស់ព្រះសព្វញ្ញុតពុទ្ធ ជាម្ចាស់ដោយចំពោះ មិនជាវិស័យរបស់សាវ័កទេ ។

ក្នុងអដ្ឋកថា កណ្ខាវណ្ណនា របស់ថៃទំព័រ ៥៧៦ បន្ទាត់ ទី ១១ ថា : **អភិធម្មោ នាម ន សាវកវិសយោ ន សាវកគោចរោ ពុទ្ធវិសយោ ឯស ពុទ្ធគោចរោ ។**

**ប្រែសេចក្តីថា**

ព្រះអភិធម្មនេះ មិនមែនជាវិស័យរបស់សាវ័កទេ

មិនមែនជាអារម្មណ៍ សាវ័កទេ អភិធម្មនេះ ជាពុទ្ធវិស័យ និង ជាអារម្មណ៍ របស់ព្រះពុទ្ធជាម្ចាស់ ។

ដោយហេតុនៃ ព្រះអភិធម្ម ព្រោះសាវ័កមិនអាចសំដែងបាន ព្រោះជាពុទ្ធវិស័យ ចំពោះព្រះអង្គតែ ១ ព្រះអង្គ គឺ ព្រះសព្វញ្ញូពុទ្ធជាម្ចាស់ ប៉ុណ្ណោះ ។ ក្នុងបរិវារៈ ព្រះបាលីវិន័យបិដក របស់ថៃ ទំព័រ ២២៤ បន្ទាត់ទី ៨ ទើបមានសំដែងថា :

អង្គីរសោ សក្យមុនី សព្វត្តានុកម្បកោ សព្វសត្តុត្តមោ សីហោ បិដកេ តីណិ ទេសយិ សុត្តន្តំ អភិធម្មញ្ច វិនយញ្ចបិ មហាគុណំ

**ប្រែសេចក្តីថា**

ព្រះអង្គីរ សក្យមុនី លោកមានសេចក្តីករុណាដល់សត្វទាំងពួងជាអ្នកប្រសើរបំផុត ជាងសត្វទាំងឡាយទ្រង់សំដែង ព្រះត្រៃបីដកទុកគឺ : ព្រះសុត្តន្តបិដក ព្រះអភិធម្ម-

បិដក ព្រះវិន័យបិដក ដែលមានគុណប្រយោជន៍ដ៏ធំទូលំទូលាយ ។

ដោយអាស្រ័យទីកន្លែងផ្សេងៗ ដែលបានពោលមកហើយ ពាក្យវិសជ្ជនា បញ្ហាទី ២ សុំឆ្លើយថា ព្រះពុទ្ធជាម្ចាស់ ព្រះអង្គសំដែង ព្រះអភិធម្មដោយពិតប្រាកដ ។

**បញ្ហាទី ៣** សួរថា ក្នុងសម័យពុទ្ធកាល មានអ្នកសិក្សាខ្លះឬទេ ?

កាលលោកអ្នកទាំងឡាយ ចេះចាំហើយថា ព្រះអភិធម្មជាអារម្មណ៍របស់ព្រះពុទ្ធជាម្ចាស់ ។ ព្រះពុទ្ធអង្គជាអ្នកសំដែង ដូចច្នេះ មិនត្រូវសង្ស័យថា ព្រះអភិធម្មនេះប្រសើរជាងធម៌ទាំងពួងអ្នកដែលត្រូវការរៀនសូត្រ មិនថាឃរាវាស ឬ បព្វជិត ក៏ដោយគង់នឹងមានជាពិតប្រាកដក្នុងសម័យពុទ្ធកាល ។ លោកដែលជាអ្នកតែងហ៊ានអះអាងព្រោះអ្នកតែងធ្លាប់ជួបព្រះសុត្តន្តបិដកនានាថា នាងខុជ្ជុត្តរា ជាប្រមុខរបស់នាង សមាវតី ឆត្តបាណិឧបាសក វិសាខ-

Page ២៨៩ missing

Page ២៩០ missing

ព្រះអភិធម្ម ។

ក្នុងព្រះវិន័យបិដកបាលី សំដែងថា ព្រះសង្ឃដែលរៀនសូត្រ ព្រះអភិធម្មបិដក រមែងមានដ៏ច្រើន ។

ក្នុងសុត្តន្តបិដក ព្រះថេរីអបទានបាលីរបស់ថៃ ទំព័រ ៣០៩ បន្ទាត់ទី ១៨ ថា :

**កុសលាហំ វិសុទ្ធីសុ កថាវត្ថុ វិសារទា អភិធម្មនយញ្ញូ ច វសីបត្តាម្ហិ សាសនេ ។**

**ប្រែសេចក្តីថា**

ក្នុងព្រះពុទ្ធសាសនានេះ នាងខ្ញុំ ( ខេមាថេរី ) ឈ្លាសវៃក្នុងវិសុទ្ធិ ៧ ប្រការ មានសេចក្តីអង់អាចក្នុង កថាវត្ថុ ហើយជាអ្នកដឹងនូវន័យនៃព្រះអភិធម្មបិដក ដែលដល់វសីទាំង ៥ របស់អភិញ្ញា ។

ក្នុងព្រះបាលីសំដែងថា អ្នកសិក្សាព្រះអភិធម្ម មិនចំពោះតែព្រះភិក្ខុ សូម្បីតែភិក្ខុនី ដូចជានាង ខេមាថេរីជាដើមរមែងសិក្សា ព្រះអភិធម្មបានដូចគ្នា ។

ក្នុងវិន័យបិដក ភិក្ខុនីវិភង្គព្រះបាលីរបស់ថៃទំព័រ ២៩៥ បន្ទាត់ទី ៨ ថា៖

**បណ្ណំ បុច្ឆេយ្យាតិ សុត្តន្តេ ឱកាសំ ការាបេត្វា វិនយំ វា អភិធម្មំ វា បុច្ឆតិ អាបត្តិ បាចិត្តិយស្ស វិនយេ ឱកាសំ ការាបេត្វា សុត្តន្តំ វា អភិធម្មំ វា បុច្ឆតិ អាបត្តិ បាចិត្តិយស្ស អភិធម្មេ ឱកាសំ ការាបេត្វា សុត្តន្តំ វា វិនយំ វា បុច្ឆតិ អាបត្តិ បាចិត្តិយស្ស ។បេ។**

**ប្រែសេចក្តីថា**

ក្នុងរឿងព្រះភិក្ខុនី ធ្វើប្រស្នា ដល់ព្រះភិក្ខុនោះ សុំឱកាសណាក៏ត្រូវសួរ ឱកាសនោះ បើភិក្ខុនី អង្គណាសុំឱកាសព្រះសូត្រហើយ សួរព្រះវិន័យ ឬ ព្រះអភិធម្មក្តី សុំឱកាសព្រះវិន័យហើយ សួរព្រះសូត្រ ឬ អភិធម្មក្តី ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយៈ ។ ក្នុងព្រះបាលីសំដែងថា

ព្រះបរមសាស្ដាទ្រង់អនុញ្ញាត ឱ្យភិក្ខុនី សួរព្រះភិក្ខុ សួរព្រះសូត្រ ព្រះវិន័យ និង ព្រះអភិធម្មបិដកណាមួយ ក្នុងបិដកទាំង ៣ ដូចគ្នា ។ នេះសឱ្យឃើញ ភិក្ខុនី ក៏មានសិក្សាជាច្រើន ។

អាគតស្ថាន ទីកន្លែងព្រះសូត្រ ព្រះវិនយបិដកដែលខ្ញុំម្ចាស់លើកមកសំដែង ឱ្យលោកអ្នកសិក្សាឃើញច្បាស់ថា ព្រះអភិធម្ម ឬ ព្រះបរមត្ថបិដក ដែលខ្ញុំម្ចាស់ ឬ លោកយកចិត្តទុកដាក់សព្វថ្ងៃនេះ គ្មានជាធម៌ដែលសាវ័កតែងទុកខាងក្រោយដែលព្រះពុទ្ធអង្គរំលត់ខន្ធនិព្វានហើយនោះទេ

សេចក្ដីពិតជាធម៌ ដែលព្រះបរមសាស្ដា ទ្រង់សំដែងទុកក្នុងពេលដែលព្រះអង្គ មានព្រះជន្មាយុនៅឡើយ មានអ្នកសិក្សារៀនសូត្រដ៏ច្រើន ។ ព្រោះហេតុដូច្នេះ អ្នកកាន់សាសនាគ្រប់ប្រទេស ភូមា លង្កា ឥណ្ឌា ចិន ជប៉ុន ជាដើម យល់ដឹងត្រូវគ្នាល្អហើយថា ព្រះអភិធម្មជាបិដកមួយ នៅ

ក្នុងបិដកទាំង ៣ ។ បើដូច្នេះ ពាក្យថាត្រៃបិដក ក៏ត្រូវដូចគ្នា ពាក្យថា ទុបិដក ឬ ពាក្យទ្វិបិដក ទៅប៉ុណ្ណោះ ។

ក្រៅអំពីភស្តុតាង ដែលខ្ញុំម្ចាស់លើកមកសំដែង នៅមាន អាគតស្ថានជាច្រើនទៀត ដូចជា វិន័យបិដកមហាវគ្គ ព្រះបាលីទំព័រលេខ ១៣៥ និង ១៤១ សុត្តន្តបិដកបាជិកៈវគ្គទំព័រលេខ ២៨២ វិនយបិដក មហាវគ្គបាលីទំព័រលេខ ៤៥៤ សុត្តន្តបិដកដកមូលបណ្ណាសកៈព្រះបាលីទំព័រលេខ ៤០៧ ។ អាគតស្ថានទាំងអម្បាលនេះ សំដែងថា ព្រះអភិធម្មបិដក ជាពុទ្ធវិស័យ ជាពុទ្ធភាសិត ហើយមានអ្នកសិក្សារៀនសូត្រ ដោយមិនមានកំណត់ប្រមាណ ដូចគ្នា ។ ព្រោះហេតុដូច្នោះ អ្នកណាប្រកាន់ ឬ ពោលថា

ព្រះអភិធម្ម មិនមែនពុទ្ធភាសិត អ្នកនោះ ក៏ត្រូវផ្ទុយ និង អាគតស្ថានផ្សេងៗ ដែលខ្ញុំម្ចាស់លើកមក សំដែងហើយជាពាក្យសំដី ដែលមិនមានផល មិនមានគោលភស្តុតាង និយាយតាមតែអំពើចិត្ត ប៉ុណ្ណោះ ។

ក្នុងគម្ពីរអដ្ឋសាលិនី របស់ថៃ ទំព័រលេខ ៣៩ បន្ទាត់ទី ១៥ ថា ៖

**អភិធម្មំ បដិពាហេន្តោ ឥមស្មឹ ជិនចក្កេ បហារំ ទេតិ សព្វញ្ញុតញ្ញាណំ បដិពាហតិ សត្ថុ វេសារជ្ជញ្ញាណំ បដិនិវត្តេសិ សោតុកាមំ បរិសំ វិសំវាទេតិ អរិយមគ្គេ អាវរណំ ពន្ធតិ អដ្ឋារសសុ ភេទករវត្ថូសុ ឯកេកស្មឹ សន្ទិស្សតិ ឧក្ខេបនិយកម្មនិយសកម្មតជ្ជនិយកម្មារហោ ហោតិ ។ល។**

**ប្រែសេចក្តីថា**

ភិក្ខុណាហាម ឬ បដិសេធព្រះអភិធម្ម ភិក្ខុនោះជាអ្នកសម្លាប់ព្រះពុទ្ធសាសនា ហាមព្រះសព្វញ្ញុតញ្ញាណ ហាមព្រះវេសារជ្ជញ្ញាណនៃព្រះពុទ្ធជាម្ចាស់ ធ្វើឱ្យថូលចិត្តដល់បរិស័ទ ទាំង ៤ ដែលមានបំណង និង ស្តាប់ជាអ្នកមានគ្រឿងចងការពារ ក្នុងព្រះអរិយមគ្គមិនឱ្យកើត និង

ក្នុងវត្ថុ ធ្វើសេចក្ដីប្រេះឆា ( ភេទករវត្ថុ ) ១៨ យ៉ាង ភិក្ខុនោះរមែងប្រាកដក្នុងវត្ថុណាមួយ ។ ទើបជាអ្នកគួរដល់ឧក្ខេបនិយកម្ម និស្សយកម្ម និង តជ្ជនិយកម្ម ។

សេចក្ដីនេះ ព្រះអដ្ឋកថាចារ្យ លោកសំដែងទុក ខ្ញុំម្ចាស់គ្រាន់តែជាអ្នកនាំមក និង ប្រែប៉ុណ្ណោះ ។បើសង្ស័យមេត្តាមើល អដ្ឋសាលិនី ក្នុងវារៈទីបំផុតនេះ ។

ព្រះអភិធម្មពិស្ដារ ភាគ II ក៏សំរេចចុះដោយកុសល-ចេតនា បរិសុទ្ធរបស់ខ្ញុំម្ចាស់ ដើម្បីផ្សាយព្រះពុទ្ធសាសនាឱ្យបានទូលំទូលាយ រហូតបរិច្ឆេទ ៥០០០ វស្សា ដោយបរិបូណ៌គ្រប់ប្រការ ។

បើលោកអ្នកអានទាំងឡាយ ឃើញអត្ថៈព្យញ្ជនៈណាមួយខ្វះខាត ខ្ញុំម្ចាស់មានសេចក្ដីត្រេកអរ នឹង ទទួលពាក្យនែនាំ ដាស់តឿនទូទៅដោយសេចក្ដីគោរព ។

# ព្រះអភិធម្មពិស្តារ

## បរិច្ឆេទទី ៦ រូបបរិច្ឆេទ

### គាថាខាងដើម

សម្បយុត្តា យថាយោគំ តេបញ្ញាស
សភាវតោ ចិត្តចេតសិកា ធម្មា រូបំទានិ បវុច្ចតិ

ប្រែសេចក្តីថា

ចិត្ត និង ចេតសិក ទាំងពីរនេះព្រមដោយប្រភេទ និង ប្រវត្តិបានសំដែងមកហើយ ក្នុងបរិច្ឆេទទាំង ៥ ដែលបានពោលមកហើយ ឥឡូវនេះនឹងសំដែងរូបតទៅ

### គាថាខាងដើម " ត "

សមុទ្ទេសា វិភាគា ច សមុដ្ឋានា កលាបតោ
បវត្តិក្កមតោ ចេតិ បញ្ចធា តត្ថ សង្គហោ

**ប្រែសេចក្តីថា**

ក្នុងរូបបរិច្ឆេទនេះ នៅមានសង្គហៈ ៥ ន័យ គឺ ១-រូបសមុទ្ទេសន័យ ២-រូបវិភាគន័យ ៣-រូបសមុដ្ឋានន័យ ៤-រូបកលាបន័យ ៥-រូបបវត្តិកមន័យ រួម ៥ ន័យដូចនេះ។

## សំដែងបាលីរូបសមុទ្ទេសន័យ

✵ ✵ ✵ ✵ ✵

ចត្តារោ ច មហាភូតា ចតុន្នំ មហាភូតានំ ឧបាទាយរូបន្តិ ទុវិធម្បេតំ រូបំ ឯកាទសវិធេន សង្គហំ គច្ឆតិ ។ កថំ

បថវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ភូតរូបំ នាម

ចក្ខុ សោតំ ឃានំ ជីវ្ហា កាយោ បសាទរូបំ នាម

រូបំ សទ្ទោ គន្ធោ រសោ អាបោធាតុ

វជ្ជិតំ ភូតត្តយសង្ខាតំ ផោដ្ឋព្វំ គោចររូបំ នាម

ឥត្ថត្តំ បុរិសត្តំ ភាវរូបំ នាម

ហទយវត្ថុ ហទយរូបំ នាម

ជីវិតិន្ទ្រិយំ ជីវិតរូបំ នាម

កពឡីការោ អាហារោ អាហាររូបំ នាម

ឥតិ ច អដ្ឋារសវិធម្បេតំ រូបំ សភាវរូបំ សលក្ខណរូបំ និប្ផន្នរូបំ រូបរូបំ សមសនរូបន្តិ ច សង្គហំ គច្ឆតិ ៕

អាកាសធាតុ បរិច្ឆេទរូបំ នាម ៕

កាយវិញ្ញត្តិ វចីវិញ្ញត្តិ វិញ្ញត្តិរូបំ នាម

កាយស្ស លហុតា មុទុតា កម្មញ្ញតា វិញ្ញត្តិទ្វយំ វិការរូបំ នាម ៕

រូបស្ស ឧបចយោ សន្តតិ ជរតា អនិច្ចតា លក្ខណរូបំ នាម ៕

**ជាតិរូបភេទ បនេត្ត ឱបច្ចយ- សន្តតិនាមេន បចុច្ចតីតិ ឯកាទសវិធម្បេតិ រូបំ អដ្ឋវិសតិវិធំ ហោតិ សរូបវសេន ឥ ប្រែសេចក្តីថា**

មហាភូតរូប ៤ និង រូបដែលកើតអាស្រ័យមហាភូតរូប ៤ រួមរូបទាំងពីរយ៉ាងនេះ រមែងរាប់បាន ១១ចំណែក គឺ ១-បឋវីធាតុ ២-អាបោធាតុ ៣-តេជោធាតុ ៤-វាយោធាតុ ហៅថាភូតរូប ។

១-ចក្ខុបសាទរូប ២-សោតបសាទរូប ៣-ឃានបសាទរូប ៤-ជិវ្ហាបសាទរូប ៥-កាយបសាទរូប ហៅថា បសាទរូប ។

១-រូបារម្មណ៍ ២-សទ្ទារម្មណ៍ ៣-គន្ធារម្មណ៍ ៤-រសារម្មណ៍ ៥-ផោដ្ឋព្វារម្មណ៍ ដែលជាភូតរូបទាំង ៣ ( វៀរ អាបោធាតុ១ ) ។

១-សេចក្តីកើតពេញលេញរបស់ស្រី

២-សេចក្តីកើតពេញលេញរបស់ប្រុស ហៅថា ភាវរូប ។

ហទយវត្ថុ ហៅថា ហទយរូប

ជីវិតិន្ទ្រីយ៍ ហៅថា ជីវិតរូប

កពឡីការាហា ហៅថា អាហាររូប

រូម ១៨ រូប ដែលពោលមកហើយនេះ ហៅថា សភាវរូបសលក្ខណរូប និប្ផន្នរូប រូបរូប សមសនរូប

អាកាសធាតុ ហៅថា សមសនរូប ។

កាយវិញ្ញត្តិ វចីវិញ្ញត្តិ ហៅថា វិញ្ញត្តិរូប

សេចក្តីស្រាលរបស់រូប សេចក្តីទន់របស់រូប សេចក្តីគួររបស់រូប និង វិញ្ញត្តិទាំង ២ ហៅថា វិការរូប ។

សេចក្តីកើតរបស់រូប សេចក្តីចំរើនរបស់រូប សេចក្តីខ្សោយរបស់រូប និង សេចក្តីបែកធ្លាយរលត់របស់រូប ហៅថាលក្ខណរូប ។

## សេចក្តីផ្សេងៗ សំដៅហេតុ

ក្នុងលក្ខណរូប ៤ នេះ ជាតិរូប រូបតែ១ ហៅថា

ឧបច្ច័យ និង សន្តតិ ដូច្នេះរូបដែលបានពោលមកហើយ ដោយ ១២ ចំណែក ឬ ១១ ចំណែកនេះ រមែងប្រាកដជារូប ២៨ ដោយសរុប ។ សួរ

រូប ២៨ ប្រាកដហៅយ៉ាងណាខ្លះ ?

**ភូតប្បសាទវិសយា ភាវោ ហទយមិច្ចបិ**

**ជីវិតាហាររូបេហិ អដ្ឋារសេវិធំ តថា**

**បរិច្ឆេទោ ច វិញ្ញត្តិ . វិការោ**

**លក្ខណន្តិ ច**

**អនិប្ផន្នា ទសចេ្ចតិ អដ្ឋវីសតិវិធំ ភវេ**

**ប្រែសេចក្តីថា**

ភូតរូប ៤ បសាទរូប ៥ វិសយរូប ៤ ភាវរូប ២ ហទយរូប ១ ព្រមនិង ជីវិតរូប ១ អាហាររូប ១ រួមទាំងនិប្ផន្នរូប ១៨ ។ ក្រៅអំពី បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ លក្ខណរូប ៤ រួមអនិប្ផន្នរូប ១០រូប រួមអស់មានចំនួនរូប ២៨ ។

**អយមេត្ថ រូបសមុទ្ទេសោ ប្រែថា :**

ដូចដែលបានពោលមកហើយនេះ រូបសមុទ្ទេសន័យ សំដែងដោយសង្ខេប ។

## អធិប្បាយរូបសមុទ្ទេសសង្គហ

ពាក្យថា រូបសមុទ្ទេស ញែកបាន រូបៈ + សំ + ឧទ្ទេសៈ រួម ៣ បទ រូបៈ ប្រែថា រូប ធម្មជាតិ

សំ ប្រែថា សង្ខេប

ឧទ្ទេសៈ ប្រែថា សំដែង

មានន័យថា សំដែងរូប ២៨ ដោយសង្ខេប ។

ពាក្យថា រូបវិភាគ ញែកបាន រូបៈ + វិភាគ រួម ២ បទ ( រូបប្រែហើយ ) វិភាគៈ ប្រែថា ញែកចេញ ។ ប្រែរួមថា សំដែងរូប ២៨ ដោយមានន័យផ្សេងៗញែកចេញ ។

ពាក្យថា រូបសមុដ្ឋាន ញែកបាន រូបៈ+ សំ + ឧដ្ឋានៈ រួម ៣ បទ សំ ប្រែថា ល្អ ដោយល្អ ឧដ្ឋានៈ ប្រែថា កើត ។ ប្រែរួមថាកើតដោយរៀបរយល្អ ។

ពាក្យថា កលាបៈ ញែកបាន រូបៈ + កលាបៈ រួម ២ បទ

កលាបៈ ប្រែថា ក្រុម គណៈ ប្រែរួមថា សំដែងរូប ២៨ជា ក្រុម ១ ។

ពាក្យថា បវត្តិក្កមៈ ញែកបាន រូបៈ + បវត្តិ + កមៈ រួម ៣ បទ បវត្តិ ប្រែថា ការរស់ ឬ ការកើត កមៈ ប្រែថា លំដាប់ ប្រែរួមថា សំដែងរូប ២៨ ដែលកើតតាមលំដាប់ ។

ពាក្យថាមហាភូតរូប ញែកបាន មហា + ភូតៈ រួម ២ បទ មហាប្រែថាធំ ភូតៈប្រែថា ប្រាកដ ប្រែថារូប ប្រាកដ នៅ ដោយរូបជាធំ ទូទៅបានដល់ធាតុទាំង ៤ គឺទឹក ដី ភ្លើង ខ ដោយរូបជាធំ ទូទៅបានដល់ធាតុទាំង ៤ គឺទឹក ដី ភ្លើង ខ្យល់ ។

ពាក្យថាបសាទរូប ប្រែថារូបដែលថ្លាស្រស់ស្អាត ដូចសេចក្តីថ្លាស្អាតនៃកញ្ចក់ បានដល់ចក្ខុបសាទ គឺ សេចក្តីថ្លារបស់ភ្នែក

សោតបសាទ គឺ សេចក្តីថ្លាស្អាតរបស់ត្រចៀក

ឃានបសាត គឺ សេចក្តីថ្លាស្អាតរបស់ច្រមុះ

ជិវ្ហាបសាត គឺ សេចក្តីថ្លាស្អាតរបស់អណ្តាត

កាយបសាត គឺ សេចក្តីថ្លាស្អាតរបស់រាងកាយ ។

ពាក្យថា វិសយរូប ឬ គោចររូប ប្រែថាអារម្មណ៍ ឈ្មោះទាំងពីរនេះមានសេចក្តីដូចគ្នា គឺ

រូបដែលជាអារម្មណ៍ បានដល់ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ និង ផោដ្ឋព្វារម្មណ៍ ។ ប៉ុន្តែ ផោដ្ឋព្វារម្មណ៍នេះ ជាចំនួនមហាភូតរូបទាំង ៣ គឺ បឋវី តេជោ វាយោ នោះឯង ( ការរាប់រូប ២៨ នេះមិនចាំបាច់រាប់ផោដ្ឋព្វារម្មណ៍ ព្រោះធាតុទាំងបីនេះ មាននៅក្នុងមហាភូតរូប ៤ ហើយ ) ។

ពាក្យថា ភាវរូប ប្រែថា សេចក្តីកើតមកពីភាសាបាលីថា ភវតិ បានដល់ឥត្ថីភាវៈ សេចក្តីកើតពេញលេញជាស្រី និង បុរិសភាវៈ សេចក្តីកើតពេញលេញជាបុរស ។

ពាក្យថា ហទយរូប ប្រែថារូបគឺ ហទយៈ បានដល់រូបបេះដូងនោះឯង ។ ក្នុងទីនេះពាក្យ ហទយៈប្រែថាចិត្ត ឬ គំនិតក៏បាន ( មេត្តាមើលចិត្ត ៨៩ ដួងក្នុងចិត្តបរិច្ឆេទ )

ពាក្យថា ជីវិតរូប ប្រែថារូបជីវិត និង នាមជីវិត ក្នុងទីនេះបានដល់ រូបជាជីវិត គឺ រូបម្យ៉ាងដែលរក្សារូបទាំងអស់ក្នុងរាងកាយ ជួនកាលហៅថាអាយុក៏បាន ។ ប៉ុន្តែស័ព្ទថាអាយុ ប្រែបានច្រើនយ៉ាង មេត្តាមើលបរិច្ឆេទទី ៥ ក្នុងរឿង បវណ្ណបបត្តិ ៤ ។

ពាក្យថា អាហាររូប ប្រែថា រូបជាអាហារ តែអាហារមាន ២ យ៉ាង គឺ : រូបជាអាហារ និង នាមជាអាហារ ។ ក្នុងទីនេះបានដល់ រូបជាអាហារ ជាពិសេសគឺ អាហារដែលត្រឹមត្រូវហៅថា កវឡីការាហារ ។

រួមរូប ១៨ រូបនេះ រមែងមានឈ្មោះច្រើនយ៉ាងគឺ : សភាវរូប សលក្ខណរូប និប្ផន្នរូប រូបរូប សមសនរូប ជា ៥ ឈ្មោះមានន័យដូចគ្នា ។

ក្នុងទីនេះពាក្យថា សភាវរូប មានវគ្គហថា : ភាវិយតិ លក្ខិយតិ ឯតេនាតិ ភាវោ សស្ស ភាវោ សភាវោ ឬ សន្តោ ភាវោ សភាវោ ប្រែថា រូបមួយចំនួន ដែលមាន លក្ខណៈព្រម ហៅថា សភាវរូប ។

ពាក្យថា សលក្ខណរូប មានបទវិគ្គហៈ តាមគម្ពីរអភិធម្មត្ថវិភាវិនីថា ឧប្បាទាទីហិ វា អនិច្ចតាទីហិ វា លក្ខណេហិ សហិតន្តិ សលក្ខណំ ប្រែថា ព្រមគ្នាលក្ខណៈ កើត និង រលត់ ឬ ព្រមគ្នានិងត្រៃលក្ខណ៍ ដូច្នេះទើប ហៅថា សលក្ខណរូប ។

ពាក្យថា និប្ផន្នរូប តាមវិគ្គហៈថា និប្ផាទិយតេតិ និប្ផន្នំ ប្រែថា រូបជំពូកនេះរមែងកើតព្រោះសមុដ្ឋាន ដូច្នេះ ទើបហៅថា និប្ផន្នរូប ។

ពាក្យថា រូបរូប តាមវិគ្គហថា រូបំ អស្ស អត្ថីតិ រូបំ ប្រែថា រូបមួយជំពូកដែលមានលាយលក្ខណរូបហៅថា រូបរូប ។

ពាក្យថា សមសនរូប តាមអភិធម្មត្ថវិភាវិនីថា លក្ខណារោបនេន សម្មសិតុំ អរហត្តា សមសនរូបំ ប្រែថា ក្នុងការសំលឹងពិនិត្យវិបស្សនារបស់ព្រះយោគី សំឡឹងពិនិត្យរូបទាំងនេះ ដោយត្រៃលក្ខណ៍យ៉ាងងាយជាទីបំផុត ដូច្នេះ ហៅថា សមសនរូប ។ កាលរូប ១៨ ហៅថានិប្ផន្នរូបនោះ និង រូបដែលនៅសល់ ១០ រូបទៀតហៅថា អនិប្ផន្នរូប ។ អនិប្ផន្នរូប ១០នោះគឺ អាកាសរូប ដែលជាអាកាសគឺ ក្នុង រវាងរូបទាំងពីរ ហៅថាបរិច្ឆេទ ។ បរិច្ឆេទនេះហៅថាអាកាសរូប ។

ពាក្យថា វិញ្ញត្តិរូប តាមវិគ្គហថា

វិញ្ញាបេតីតិ វិញ្ញត្តិ ប្រែថា ធ្វើឱ្យអ្នកដទៃដឹង ហៅថា វិញ្ញត្តិ ។

វិញ្ញត្តិមានពីរយ៉ាងគឺ :

១-កាយវិញ្ញត្តិ

២-វចីវិញ្ញត្តិ

ក្នុងទីនេះ ការធ្វើឱ្យអ្នកដទៃដឹង ដោយអាការរាង កាយ ហៅថា កាយវិញ្ញត្តិ ។

ការធ្វើឱ្យអ្នកដទៃដឹងដោយវាចា ហៅថា វចីវិញ្ញត្តិ ។

ពាក្យថា វិការរូបញែកបាន វិ + ការៈ វិ ប្រែថា ពិសេស ការៈ ប្រែថា ការ មានសេចក្ដីថា អាការពិសេស របស់រូបបានដល់ លហុតា មុទុតា កម្មញ្ញតា និង វិញ្ញត្តិ ២ ផង ។ លហុតា សេចក្ដីថ្ពមរបស់រូប ក្នុងអាការរាងកាយ គ្រប់ៗចំណែក ចំណាកច្រើនជាងធម្មតា ហៅថា កម្មញ្ញតា របស់រូប ។ ចំណែកវិញ្ញត្តិរូបនោះ បានអធិប្បាយមកហើយ

ពាក្យថា លក្ខណរូប តាមអភិធម្មត្ថវិភាវិនី ថា លក្ខណរូបំ នាម ធម្មានំ តំ តំ អវត្ថាវសេន លក្ខណហេតុត្តា

**ប្រែថា** ៖ រូបធម៌ដែលមានលក្ខណ កើតរលត់ដោយកាល ហៅថា លក្ខណរូប បានដល់ឧបចួយ សន្តតិ ជរតា អនិច្ចតា រួម ៤ រូប ។

ក្នុងទីនេះ ឧបចយ្ច ប្រែថា រូបដែលកើតក្នុង ខណៈបដិសន្ធិ ។ សន្តតិ ប្រែថា សេចក្តីចំរើនរបស់រូប តាំងពីខណបដិសន្ធិតមក ។ ជរតា ប្រែថា ខណៈដែលតាំងនៅក្នុងរវាងកើត និង រលត់ ។ អនិច្ចតា ប្រែថា រូបដែលរលត់ក្នុងលក្ខណរូប ៤ ប្រការនេះ ឧបចយ្ច និងសន្តតិទាំង ២រូប ហៅថា ជាតិ ឬ បដិសន្ធិរូប ដូច្នោះរាប់ដោយសរុប បាន ២៨ ប៉ុណ្ណោះ ។

តាមគាថាសង្គហថា មហាភូតរូប ៤ បសាទរូប ៥ វិសយរូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ លក្ខណរូប ៤ រួមរូប ២៨ ។

## ពាក្យសួរ-ឆ្លើយរបស់ម្ចាស់ទេស

**សួរ** ពាក្យថាមហាភូតរូប និង ឧបាទាយរូប ទាំងពីរនេះផ្សេងគ្នាយ៉ាងណាខ្លះ ?

Page ണ്ടി missing

Page ៣០៨ missing

Page ൩൧൬ missing

Page ൩൧൭ missing

Page ៣១៨ missing

Page ៣១៩ missing

Page ៣២៩ missing

Page ៣២៣
missing

Page ៣២៩ missing

Page ៣២៥ missing

រូប សម្បត្តគាហៈ និង អសម្បត្តគាហៈទាំងពីរ ហៅថា គោចរគ្គាហិករូប សល់អំពី អគោចរគ្គាហិករូប ។

វណ្ណ គន្ធ រស ឱជា និង មហាភូតទាំង ៤ រូប ៨ រូប ហៅថា អវិនិព្ភោគរូប

## គាថាសង្គហៈ

**ឥច្ចេវមដ្ឋវីសតិ វិធំបិ ច វិចក្ខណា**
**អជ្ឈត្តិកាទិភេទេន វិភជន្តិ យថារហំ ។**

**ប្រែសេចក្តីថា**

ដូចនេះឯងរូប ២៨ បណ្ឌិត រមែងបែងចែកដោយ អជ្ឈត្តិកៈ ពាហិរៈជាដើមតាមតែ សមរម្យ ។

អយមេត្ថ រូបវិភាគោ ដូចដែលបានពោលមកហើយ ក្នុងបរិច្ឆេទទី ៦ ជារូបវិភាគន័យ ។

## អធិប្បាយក្នុងរូបវិភាគន័យ

ពាក្យថារូបវិភាគ ប្រែថារូប ២៨ ចែក ២ បទគឺ :



ខ: 307-320

រូបៈ + វិភាគ ។ រូបបានដល់រូប ២៨ ។ វិភាគៈ ប្រែថាបែងចែក ។ ពាក្យថា អហេតុកៈ ប្រែថា មិនមានហេតុគឺ ធម្មតារូបរមែងមិនប្រកបដោយ អលោភៈ អទោសៈ អមោហៈ ឬ លោភៈ ទោសៈ មោហៈ ។ ពាក្យថា សបច្ច័យ ប្រែថា មាន បច្ច័យតុបតែង គឺ រូបកើតព្រោះកម្ម ចិត្ត ឧតុ និង អាហារ ។ ពាក្យថា សាសវៈ ប្រែថា ព្រមជាមួយនិង អាសវៈ មានសេចក្តីថា ជាអារម្មណ៍របស់អាសវៈទាំង ៤ ។ ពាក្យថា សង្ខតៈ ប្រែថាបច្ច័យទាំង ៤ ធ្វើឱ្យកើតជារូប គឺ កម្ម ចិត្ត ឧតុ អាហារ ។ ពាក្យថាលោកិយ៍ ប្រែថា ធម្មជាតិដែលកើតក្នុង សង្ខារលោក គឺ សព្វេ សង្ខារា អនិច្ចា នោះឯង តែលោកិយ៍ មាន ៣ យ៉ាងគឺ សត្តលោក សង្ខារលោក ឱកាសលោក ។ ក្នុងទីនេះអធិប្បាយថា សត្វទាំងឡាយ ហៅថា សត្តលោក សង្ខារទាំងឡាយ ហៅថាសង្ខារលោក ទីនៅរបស់សត្វ ហៅថាឱកាសលោក ។ពាក្យថា កាមាវចរៈ ប្រែថាអារម្មណ៍របស់កាម គឺរូបទាំងអម្បាលនេះ រមែង

កើតក្នុងកាមភូមិដោយច្រើន ( មេត្តាមើល កាមាវចរចិត្ត ផង ) ។ ពាក្យថាអនារម្មណៈ ប្រែថាមិនអាចទទួលអារម្មណ៍ ដូចចិត្ត និង ចេតសិក ។ ពាក្យថា អប្បហាតព្វៈ ប្រែថា មិនជាធម្មជាតិដែលសម្លាប់បាន ដូចជាអកុសល ។

ដូចដែលបានពោលមកហើយ ជាឈ្មោះរបស់រូប ២៨មាន ន័យថា រូប ២៨នេះ មិនមានឈ្មោះចំពោះតែមួយ តែសេចក្តីពិតឈ្មោះមានច្រើនយ៉ាង ដូចជាអហេតុកៈ

អហេតុកៈ បានដល់រូប សប្បច្ចយ បានដល់ រូបសាសវ ដូច្នោះជាដើម ។ រួមឈ្មោះរបស់រូប ដែលសំដែងក្នុង អភិធម្មនេះមាន ៩ ឈ្មោះ រួមទាំងឈ្មោះរូបផង ។

ឈ្មោះទាំងអម្បាលនេះ អាស្រ័យខាងក្នុង និង ខាងក្រៅហើយបែងចែកតទៅ បសាទរូបទាំង ៥ គឺ ចក្ខុ សោត ឃាន ជីវ្ហា កាយ ហៅថា អជ្ឈត្តិករូប គឺ រូបខាងក្នុង សល់ពីនេះ ២៣ រូបហៅថា ពាហិររូប រូបខាងក្រៅ ។

បសាទរូបទាំង ៥ និង ហទយវត្ថុរូប រួម ៦ រូបនេះ មិនបានជាទីអាស្រ័យរបស់ចិត្ត ចេតសិក ហៅថា អវត្ថុរូប ។

បសាទរូបទាំង ៥ វិញ្ញត្តិរូប ២ រួម ៧ រូបនេះហៅថា ទ្វាររូប គឺ ជាទ្វាររបស់ចិត្ត និង ចេតសិក សល់ ២១រូបទៀត អទ្វាររូប មិនមែនជាទ្វាររបស់ចិត្ត និង ចេតសិក ។

បសាទរូប ៥ ភាវរូប ២ ជីវិតរូប ១ រួម ៨ រូបនេះ ហៅថា ឥន្ទ្រិយរូប គឺជារូបដែលគ្រប់គ្រងកិច្ចរបស់ខ្លួន សល់រូប ២០ ទៀត មិនបានគ្រប់គ្រងកិច្ចរបស់ខ្លួន ហៅថា អនិន្ទ្រីយរូប ។

បសាទរូប ៥ វិសយរូប ៧ រួម ១២ រូបនេះ ហៅថា ឱឡារិករូប គឺ រូបគ្រោតគ្រាត មានសេចក្តីថា ពួករូបដែលឃើញដោយបញ្ញា សល់ ១៦ រូប ហៅថា សុខុមរូប គឺ ពួករូបដែលមិនអាចមើលឃើញ ព្រោះសុខុម ល្អិតណាស់ ។

ឱឡារិករូប ១២នេះហៅថា សន្តិកេរូប គឺ ជារូបដែលជិតដល់បញ្ញា ឬ ដែលសម័យនិយមជិតខួរក្បាល

ឈ្មោះម្យ៉ាងទៀតថា សប្បដិឃរូប គឺ ជារូបត្រូវប៉ះទង្គិច សល់ពីនេះ ហៅថាទូររូប ។ ទូររូបគឺ រូបឆ្ងាយពី សេចក្តីដឹង ឈ្មោះម្យ៉ាងទៀតថា អប្បដិឃរូប គឺជារូបប៉ះទង្គិចមិនបាន ។

កម្មជរូប ១៨ ហៅថា ឧបាទិន្នករូប គឺ ជារូបដែលតណ្ហា មាន ៣ ទិដ្ឋ ទាំង ៣ ចាប់យកបាន សល់រូប ១០ ទៀតហៅថា អនុបាទិន្នករូប គឺ តណ្ហា មានៈ ទិដ្ឋិ មិនបានយឹតមក ។

ក្នុងរូប ២៨ នេះ រូបាយតនៈ ហៅថា សនិទស្សរូប គឺជារូបដែលឃើញនិងភ្នែកបាន សល់ ២៧ រូប ហៅថា អនិទស្សនរូប គឺជារូបដែលឃើញមិនបានដោយភ្នែក ចក្ខុ និង សោត ២ រូបនេះ ហៅថា អសម្បត្តគាហៈ គឺ អាចទទួលយកអារម្មណ៍ដែលមកដល់ខ្លួន រួម សម្បត្តគាហៈ និង អសម្បត្តគាហៈ ទាំង ២ ហៅថា គោចរគ្គាហិករូប គឺ រូបដែលទទួលយកអារម្មណ៍បាន សល់ ២៣រូបទៀត ហៅថា

អគោចរគ្គាហិករូប គឺរូបដែលមិនបានទទួលយកអារម្មណ៍។

វណ្ណ គន្ធ រស ឱជា និង បឋវី អាបោ តេជោ វាយោ រួមរូបទាំង ៨ ហៅថា អវិនិព្ភោគរូប គឺ រូបមួយជំពូកដែលញែកចេញពីគ្នាមិនបាន សល់ ២០ រូបទៀត ហៅថា វិនិព្ភោគរូប គឺ រូបមួយជំពូកដែលញែកចេញពីគ្នាបាន ។

## ពាក្យសួរឆ្លើយក្នុងរូបវិភាគន័យ

**សួរ** ក្នុងរូបវិភាគ ឈ្មោះរបស់រូប ២៨ រូបនេះ ឈ្មោះថា អហេតុកៈ និង កាមាវចរៈ រួម ២ ឈ្មោះនេះ ក្នុងចិត្តបរិច្ឆេទសំដែង រកហើយថា ជាឈ្មោះរបស់ចិត្តតែក្នុងទីនេះ ជាឈ្មោះរបស់រូប ទាំង ២នេះ អធិប្បាយមានផ្សេងគ្នាយ៉ាងណា ទើបឱ្យឈ្មោះផ្សេងគ្នាយ៉ាងនេះ ?

**ឆ្លើយ** ពាក្យថាអហេតុកៈ តាមវិគ្គហៈថា នត្ថិ ហេតុ ឯតេសន្តិ អហេតុកា ប្រែថា ធម៌ទាំងអស់នេះ ប្រាសចាកហេតុ គឺ **លោភៈ ទោសៈ មោហៈ** ជាដើម ដូច្នោះ ហៅថា អហេតុកៈបានដល់ អហេតុកៈ ២ យ៉ាងគឺ

អហេតុកចិត្ត ១៨ ដួង និង រូបទាំងអស់ ហៅថាអហេតុកៈ ព្រោះមិនមានហេតុ ប្រកប ។

ពាក្យថា កាមាវចរៈ វិគ្គហៈថា កាមេ អវចរតីតិ កាមាវចរំ ប្រែថា ធម៌ទាំងអស់នេះរមែងប្រាកដវិលវល់ក្នុងកាមលោក ដូច្នេះ ហៅថា កាមាវចរៈបានដល់ កាមាវចរ-ចិត្ត ៥៤ ដួង និង រូបទាំងអស់ ។ ប៉ុន្តែរូបធម្មតាមិនមានការវិលវល់ ក្នុងទីនេះត្រូវអធិប្បាយថា រមែងកើតច្រើនក្នុងកាមភូមិ ព្រោះហេតុដូច្នេះ ពាក្យថា អហេតុកៈ និងកាមាវចរៈមានន័យដូចគ្នា តែធម្មជាតិផ្សេងគ្នា គឺ ក្នុងនាមធម៌ហៅថាចិត្ត ក្នុងរូបធម៌ហៅថារូប ប៉ុណ្ណោះ ។

**សួរ** បសាទរូប ៥ ហៅថា អជ្ឈត្តិករូប ។ ពាក្យថា អជ្ឈត្តិកៈ ប្រែថាខាងក្នុង តែភ្នែក ត្រចៀកទាំងអស់នេះជាដើម ឃើញថានៅខាងក្រៅ ដូចម្តេចទើបហៅថា អជ្ឈត្តិករូបបាន ?

**ឆ្លើយ** កាលដែលភ្នែក ត្រចៀក ច្រមុះ ទាំងអស់នេះ ហៅថា អជ្ឈត្តិករូបនោះ មិនបានអាស្រ័យនៅក្នុង ឬ ក្រៅរាងកាយ សេចក្ដីពិត ការដែលហៅថាអជ្ឈត្តិករូប វិគ្គហថា អធិកោ អត្តាតិ អជ្ឈត្តា ប្រែថា អត្តៈ ដែលនៅខាងក្នុងហៅថា អជ្ឈត្ត. អជ្ឈត្តេ វិទិទោ បាកដោតិ អជ្ឈត្តិកោ ប្រែថា ធម៌ដែលប្រាកដក្នុងអជ្ឈត្តៈ ហៅថា អជ្ឈត្តិកៈ បានដល់ បសាទរូប ៥ គឺ ចក្ខុ សោត ឃាន ជីវ្ហា និង កាយ បសាទ រូប ៥ នេះ ជារូបដែលសំខាន់ជាទីបំផុតរបស់រាងកាយ ព្រោះសូម្បីរូបដទៃៗ ពេញទៅរហូតរាងកាយក្តី ប្រសិនបើ ខ្វះបសាទរូបទាំង ៥ រាងកាយក៏ប្រើមិនបានម្យ៉ាងវិញ ទៀតបសាទរូប ៥ នេះ ដោយត្រង់ទាក់ទងនិងមនោទ្វារ ព្រោះហេតុដូច្នោះ បសាទរូប ៥នេះ ទើបជារូបដែលសំខាន់ណាស់ និង ជារូបដែលទុកចិត្តបានច្រើនក្នុងរាងកាយ ឧបមាដូចយើងហៅថា មនុស្សក្នុងនិង មនុស្សក្រៅ។ មានសេចក្ដីថា មនុស្សដែលទុកចិត្តបានជាងមនុស្សទូទៅ ឬ

មិនដែលទាក់ទងដោយការងារ ហៅថា មនុស្សក្រៅ ឧបមានេះយ៉ាងណា អជ្ឈត្តិករូបទាំង ៥ ក៏ដូច្នោះដែរ ។ គឺ ដោយត្រង់រូបដែលទាក់ទងទ្វារ និង ជារូបដែលទុកចិត្ត ច្រើន ដូច្នេះទើបហៅថា អជ្ឈត្តិករូប ។

**សួរ** ក្នុងវិការរូប ៧រូបនេះ ចក្ខុ សោត ឃាន ជិវ្ហា កាយ ហៅថាទ្វារនោះ ត្រូវនឹងស័ព្ទថា ចក្ខុទ្វារ សោតទ្វារ ឃានទ្វារ ជិវ្ហាទ្វារ កាយទ្វារ ប៉ុន្តែវិញ្ញត្តិរូបទាំង ២ ហៅថា ទ្វារនោះ ព្រោះហេតុអ្វី ?

**ឆ្លើយ** វិញ្ញត្តិរូប ២ ដែលហៅថាទ្វាររូបនោះ ព្រោះវិញ្ញត្តិ-រូបទាំង ២ កើតមកដោយមនោទ្វារ ( មេត្តាមើលរូបសមុដ្ឋានន័យ ក្នុងបរិច្ឆេទនេះផង វគ្គដែលថា វិញ្ញត្តិទ្វយំ ចិត្ត-ជមេវ វិញ្ញត្តិទាំង ២ កើតដោយចិត្ត គឺមនោទ្វារនោះឯង) ព្រោះហេតុដូច្នោះ រូបទាំង ៥ ជារូបដែលចិត្ត ៤៦ ដួង ចេញចូលបាន គឺ ជាទ្វាររបស់ចិត្ត ចេតសិក និង វិញ្ញត្តិរូប ទាំង ២ ជារូបដែលទាក់ទងមកអំពីទ្វារខាងក្នុង គឺ មនោ

ទ្វារ ទើបព្រះអនុរុទ្ធាចារ្យ ហៅតាមអដ្ឋកថា ថា ទ្វាររូបទាំង ៧ ។

**សួរ** បសាទរូប ៥ ភាវរូប ២ ជីវិតរូប ១ រួម ៨ រូបនេះហៅថាឥន្ទ្រិយរូប ។ ពាក្យថាឥន្ទ្រីយ៍ ប្រែថារូបដែលជាអធិបតេយ្យ ឬ គ្រប់គ្រង រូបទាំង ៨ នេះជាធំយ៉ាងណាហើយគ្រប់គ្រងយ៉ាងណា ?

**ឆ្លើយ** ក្នុងឥន្ទ្រីយ៍ ២២ ដួង ( មើលមិស្សកសង្គហៈក្នុងបរិច្ឆេទទី ៧ ) គឺ រូបឥន្ទ្រីយ៍សុទ្ធៗ ៧ រូប រូបនិងនាមលាយ ១ រួម ៨ រូបនេះ ហៅថា រូបឥន្ទ្រីយ៍ សល់ ១៤ រូប ហៅថានាមឥន្ទ្រីយ៍ ដូច្នេះ ការដែលហៅរូប ៨ ដួងនេះជាឥន្ទ្រិយរូបតាមលំដាប់របស់ឥន្ទ្រីយ៍សំដែងថា **ពាវីសតិន្ទ្រិយានិ ចក្ខុន្ទ្រិយំ សោតន្ទ្រិយំ ឃានិន្ទ្រិយំ ជីវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ** ជាដើម ។ ការដែលហៅថា ឥន្ទ្រីយ៍ ព្រោះធម្មជាតិទាំងអម្បាលនេះអាចនឹងគ្រប់គ្រងកិច្ចការងារ ឬ តួនាទីរបស់

ខ្លួនបាន គឺ ចក្ខុន្ទ្រីយ៍អាចគ្រប់គ្រងការឃើញ រូបារម្មណ៍ បានរហូតដល់ ចក្ខុវិញ្ញាណចិត្ត ២ ដួងកើតឡើង ។ សោតិន្ទ្រីយ៍អាចគ្រប់គ្រងការបានឮសំឡេង សទ្ទារម្មណ៍ រហូតដល់សោតវិញ្ញាណចិត្ត ២ ដួងកើតឡើង ។ ឃានិន្ទ្រីយ៍អាចគ្រប់គ្រងការហិតក្លិន គន្ធារម្មណ៍ រហូតដល់ឃានវិញ្ញាណចិត្ត ២ ដួងកើតឡើង ។ ជិវ្ហិន្ទ្រីយ៍អាចគ្រប់គ្រងការលិតភ្លក់រសជាតិ រហូតដល់ជិវ្ហាវិញ្ញាណចិត្ត ២ ដួងកើតឡើង ។ កាយិន្ទ្រីយ៍អាចគ្រប់គ្រងការប៉ះពាល់ ផោដ្ឋព្វារម្មណ៍ រហូតដល់កាយ-វិញ្ញាណចិត្ត ២ ដួងកើតឡើង ។

ឥត្ថិន្ទ្រីយ៍ និង បុរិសិន្ទ្រីយ៍ អាចគ្រប់គ្រងអាការរបស់ស្រី និង ប្រុស គ្រប់ៗចំណែក និង រូបដែលកើតមកដោយចតុ-សមុដ្ឋាន គឺ អាការកិរិយាគ្រប់ៗយ៉ាង ដែលកើតមកព្រោះ កម្ម ចិត្ត ឧតុ អាហារ ។ រូបជីវិតិន្ទ្រីយ៍អាចគ្រប់គ្រងកម្មជ្ជ -

រូប ដើម្បីឱ្យតទៅមានរបៀបរៀបរយ ព្រោះហេតុដូច្នោះ រូប ៨ ដែលពោលមកហើយនេះ ព្រះអនុរុទ្ធាចារ្យ សំដែងថា ឥន្ទ្រិយរូប ។

**សួរ** ក្នុងឱឡារិករូប ១២ ពាក្យថា ឱឡារិកប្រែថា គ្រោតគ្រាតក្នុងទីនេះ គ្រោតគ្រាតមានសេចក្ដីថាយ៉ាងណា ពាក្យថាសន្តិកេ ប្រែថាជិត រូបទាំង ១២នេះ ឃើញកើតនៅរាងកាយនោះឯង មិនឃើញមានឆ្ងាយពីរាងកាយឡើយ ដូចម្ដេចហៅថាសន្តិកេ ?

**ឆ្លើយ** ការដែលហៅថា ឱឡារិក សន្តិកេរូប តាមដីកាចាស់ជនជាតិលង្កាទ្វីប សំដែងថា **ចក្ខាទិបញ្ចបសាទា ច រូបសទ្ទគន្ធរសផោដ្ឋព្វសង្ខាតំ វិសយរូបញ្ចាតិ ទ្វាទសវិធម្បិ ទ្វារាលម្ពណភាវេន ឃដ្ដនត្តា ឱឡារិកំ ថូលំ តតោ ឯវំ បរិគ្គហសុខត្តា សន្តិកេ រូបំ**

ប្រែសេចក្តីថា ·

បសាទរូប ៥ មានចក្ខុបសាទ ជាដើម និង រូប សំឡេង ក្លិន រស និង បឋវី តេជោ វាយោ រូមរូប ៣ ជារបស់ផោដ្ឋព្វ រួម ១២ រូបនេះដឹងបានងាយ ក្នុងទ្វារ និង អារម្មណ៍ ប៉ះទង្គិច ព្រោះវាជារូបគ្រោតគ្រាត ដូច្នេះទើបហៅថាឱឡារិករូប ។ ឱឡារិករូបនេះ កាលពិចារណាដោយបញ្ញាក្រឡេកឃើញងាយជាទីបំផុត ព្រោះហេតុដូច្នោះហៅថា សន្តិកេរូប ។ អធិប្បាយថា ខណៈដែលបសាទរូបប៉ះទង្គិចអារម្មណ៍ អារម្មណ៍ទាំង នេះគឺ ឃើញ ឮ ក្លិនជាដើម ដឹងងាយជាទីបំផុត ដូច្នេះទើបហៅថា ឱឡារិករូប ឧបមាវត្ថុណាមួយដែលបានងាយជាទីបំផុត ហៅថាវត្ថុនោះជិតចូលមកហើយ ហើយយើងយកបាន ហើយក៏មិនឆ្ងាយអំពីខ្លួនយើង ។

**សួរ** ពាក្យថាឧបាទិន្នករូប ប្រែថាយ៉ាងណា ? ហើយបានដល់អ្វី ?

**ឆ្លើយ** ពាក្យថាឧបាទិន្នករូបញែកបាន ២ស័ព្ទ ឧប+ អាទិន្នៈ វិគ្គហៈថា ឧបេតេន អាទិន្នំ ឧបាទិន្នំ ប្រែថា ជារូប១បែប ដែលតណ្ហា ទិដ្ឋិចាប់យក មានន័យថា ធម្មតាកម្មជរូបរមែង កើតមានជានិច្ច រហូតរាងកាយ តណ្ហារមែងកើតក្នុងរូប ហើយចាប់យកទុកថា យើងជាអ្នកសោយ ហើយជារបស់ យើង អត្តទិដ្ឋិរមែងចាប់យករូបនោះជារបស់យើង យើង នេះជា រូប រូមតណ្ហា និង ទិដ្ឋិទាំងពីរនេះ ប្រាកដព្រោះ កម្មជរូប នេះឯង ឬ អាស្រ័យកម្មជរូបនេះឯង ព្រោះដូច្នេះ ទើបហៅ ថា ឧបាទិន្នករូប ។

ជួនកាល ឧបាទិន្នកៈ ប្រែថា រហូតរាងកាយក៏មានគឺ ក្នុងធម្មសង្គណី អដ្ឋកថា ថា សរីរដ្ឋំ ហិ ឧបាទិន្នំ វា ហោតុ អនុបាទិន្នកំ វា អាទិន្នគហិតបរាមដ្ឋវសេន ធម្មំ ឧបាទិន្នមេវ = ប្រែថា រូបដែលប្រាកដនៅក្នុងរាងកាយនោះ ឧបាទិន្នកៈ ឬ អនុបាទិន្នកៈ ក៏ដោយ ព្រោះតណ្ហា និង ទិដ្ឋិ ប្រកាន់យក ដូច្នេះហៅថា ឧបាទិន្នកៈទាំងអស់ ។

**សួរ** ក្នុងគោចរគ្គាហិកៈទាំង ៥ ចក្ខុ និង សោតៈ ហៅថា អសម្បត្តៈ គឺ អាចទទួលអារម្មណ៍ដែលមិនបានមក ដល់ចំណែកឃានជីវ្ហា កាយនោះហៅថា សម្បត្តគាហៈ គឺ ទទួល អារម្មណ៍ដែលមកដល់ ។ ក្នុងទីនេះមនុស្សទូទៅដឹង ហើយថា អារម្មណ៍ដែលមិនបានមកដល់ភ្នែក ត្រចៀក ឃើញគ្នា បានឮយ៉ាងណា ព្រោះធម្មតាអារម្មណ៍ ប៉ះទង្គិច មុនមិនមែនឬ ?

**ឆ្លើយ** តាមមហាអដ្ឋកថាដើមអធិប្បាយថា បសាទរូប ៥ នេះ ជាសម្បត្តគាហៈ គឺ ទទួលយកអារម្មណ៍ដែលមកដល់ ប៉ុន្តែ ព្រះពុទ្ធឃោសាចារ្យ អធិប្បាយថា ចក្ខុ និង សោតៈ។ ពាក្យថា ចក្ខុ និង សោត ទាំង ២ សូម្បីអារម្មណ៍ដែលមិន មកដល់ក៏ទទួលបាន ដូច ព្រះអាទិត្យ ព្រះច័ន្ទ នៅឆ្ងាយពី មនុស្សលោក ៤២០០០យោជន៍ ចក្ខុក៏អាចទទួលអារម្មណ៍ នេះបាន ព្រោះហេតុដូច្នោះ ចក្ខុ និង សោតៈទាំង ២ ទើប ហៅថា អសម្បត្តគាហ គឺ រូបារម្មណ៍ដែលមិនមកដល់ក៏

ទទួលបាន សល់ឃានជិវ្ហាកាយនោះ ទទួលតែចំពោះអារម្មណ៍ដែលមកដល់ ។ ក្នុងវាទៈនេះព្រះអនុរុទ្ធាចារ្យ ឃើញថាត្រូវដែរ ដូច្នេះទើបលោករចនាទុកក្នុងបរិច្ឆេទទី៦ ថា :

**ចក្ខុាទិទ្វយំ អសម្បត្តវសេន ឃានទិត្តយំ សម្បត្តវសេនាតិ បញ្ចវិធម្បិ គោចរគ្គាហិករូបំ** ដូច្នេះ ។ ក្នុងទីនេះយើងលើកពាក្យឧបមារបស់ព្រះពុទ្ធ-ឃោសាចារ្យ ពិចារណាមើល ក៏ បានសេចក្តីថា ធម្មតារូបារម្មណ៍ មាន ២ ប្រភេទ គឺ រូបារម្មណ៍ ដែលមានពន្លឺ និងរូបារម្មណ៍ដែលមិនមានពន្លឺភ្លឺ ។ រូបារម្មណ៍គឺ ព្រះអាទិត្យព្រះច័ន្ទជាដើម រមែងមាន អលោកៈពន្លឺភ្លឺច្រើនជាទីបំផុត គឺ នៅឆ្ងាយពីមនុស្ស សូម្បីច្រើនយោជន៍ក្តី អាចនឹងមកដល់ចក្ខុបាន ដូច្នោះចក្ខុបសាទ ទើបអាចឃើញព្រះអាទិត្យបាន តែយ៉ាងណាក្តី អារម្មណ៍ដែលមកដល់នោះជាពន្លឺរបស់ព្រះអាទិត្យ គ្មានជាតួរូបនៃព្រះអាទិត្យទេ ។ តួព្រះអាទិត្យ

ដែលជារូបបារម្មណ៍ដើមនោះ រមែងប្រាកដនៅលើផ្ទៃមេឃ គ្មានបានមកដល់ចក្ខុ ។ ឧបមាម្យ៉ាងទៀតវេលាកណ្ដាលយប់យើងឃើញភ្លើងនៅលើភ្នំ ពន្លឺភ្លឺរបស់ភ្លើងមានកម្លាំងតិច ពន្លឺភ្លឺមិនដែលនឹងមកដល់ចក្ខុ តែចក្ខុអាចឃើញភ្លើងបានអំពីចម្ងាយ ទើបសំដែងថា ចក្ខុប់សាទអាចទទួលអារម្មណ៍ដែលមកមិនដល់បាន ព្រោះហេតុដូច្នោះ ព្រះពុទ្ធឃោសាចារ្យ ទើបជំទាស់វាទ របស់មហាអដ្ឋកថាដែលព្រះសង្ឃក្នុងលង្កាទ្វីប និយមពីបុរាណកាល រហូតដល់ឥឡូវនេះថា មិនត្រង់ និង ព្រះអធ្យាស្រ័យរបស់ព្រះបរមសាស្ដា ហើយកែឆ្នៃជាថ្មីថា ចក្ខុ និង សោតៈទាំងពីរជា អសម្បត្តគាហៈ អាចទទួលអារម្មណ៍ ដែលមកមិនបានដល់ក៏បាន ចំណែកអារម្មណ៍ដែលមកដល់ដូចព្រះអាទិត្យ ព្រះច័ន្ទនេះ ធានាថា ទទួលបានពេញទី ។

**សួរ** តាមបាលីរបស់ព្រះអនុរុទ្ធាចារ្យថា **វណ្ណោ គន្ធោ រសោ ឱជា ភូតចតុក្កញ្ចេតិ អដ្ឋវិធំបិ**

**អវិនិព្ភោគរូបំ** ប្រែថា វណ្ណៈ គន្ធៈ រសៈ ឱជា និងភូត-រូបទាំង ៤ រួម ៨ រូបនេះ ហៅថាអវិនិព្ភោគរូប ក្នុងទីនេះពាក្យថា វណ្ណរូបនេះមិនឃើញមាននៅក្នុងចំនួនរូប ២៨ និងពាក្យថា ឱជា ក៏ដូចគ្នា ព្រោះពាក្យថាវណ្ណរូប និង ឱជារូប ទាំង ២រូបនេះបានដល់អ្វី ? ហើយមានអធិប្បាយយ៉ាងណា ? ។

**ឆ្លើយ** ពាក្យថារូបារម្មណ៍ វណ្ណាយតន វណ្ណធាតុទាំងនេះប្រែថា ពណ៌ប៉ុណ្ណោះ តែគប្បីជ្រាបថា ពណ៌នោះមាន ២ យ៉ាង គឺពណ៌ដែលជារូបារម្មណ៍ ១ យ៉ាង ដែលជារូបារម្មណ៍មិនបាន ១ យ៉ាង ។ ពណ៌ ដែលប៉ះទង្គិច និង ភ្នែក ហៅថាពណ៌ជារូបារម្មណ៍ ។ ពណ៌ផ្សេងៗក្នុងទីកន្លែងដែលយើងមិនអាចសំឡឹងឃើញ គឺនៅដែលមិនបានមកប្រាកដចក្ខុបសាទរបស់យើងហៅថាពណ៌ ដែលនៅមិនជារូបារម្មណ៍ខាងក្រោយនេះឯង ហៅថាវណ្ណៈ ប្រែថាពណ៌ដូចគ្នា ។ ក្នុងទីនេះព្រះអនុរុទ្ធាចារ្យ សំដែងថា វណ្ណាយតនៈ វណ្ណរូបមាន

សេចក្តីថាពណ៌ ដែលជាអារម្មណ៍របស់ចក្ខុទ្វារឬទេ បើជាបែបហើយត្រូវហៅថាពាក្យសមញ្ញ វណ្ណប៉ណ្ណោះ ប៉ុន្តែកាលបើវណ្ណៈនេះមកប្រាកដនូវចក្ខុទ្វារ ទើបហៅពិសេសថារូបារម្មណ៍ ដូចដែលបានអធិប្បាយមកហើយចំណែកពាក្យថាឱជានោះ មានវិគ្គហៈថា ឧទតិ បសវត្តីតិ ឱជា ប្រែថាខ្លាញ់មួយបែបដែលធ្វើឱ្យលំអិតទៅ ទូទាំងសរសៃបសាទដូច្នោះ ហៅថាឱជា មានន័យថា ក្នុងវត្ថុគ្រប់បែបយ៉ាង ត្រូវមានខ្លាញ់ ឬ ទឹកសំរាប់រក្សាមួយបែបមកជ្រួតជ្រាបជានិច្ចជួនកាលមនុស្សយើងហៅថាជ័រ ដូចជាជ័រឈើជាប់នៅក្នុងស្លឹក ។ ជ័របែបនេះរមែងមាននៅក្នុងវត្ថុជានិច្ចទៅ ជ័រនេះឯងបើជាអាហារហើយធ្វើឱ្យលំអិត ចូលក្នុងសរសៃបសាទរបស់អ្នកទទួលទាន ។ ជ័របែបនេះផ្លូវសាសនា ហៅថាឱជារូប ។ សុំឱ្យអ្នកសិក្សា គប្បីចូលចិត្តថា ឱជារបស់អាហារ ក្នុងរូបបរិច្ឆេទ ចាត់ថា ជាអាហាររូបផង ព្រោះហេតុដូច្នេះ វិនិច្ឆ័យថា ពាក្យថាវណ្ណរូប ហៅថារូបារម្មណ៍

ឱជា ហៅថាអាហាររូប គប្បីជ្រាបដោយន័យផ្សេងៗដែលវិសជ្ជនា មកពីខាងដើម ។

**សួរ** ពាក្យថាអវិនិព្ភោគរូប ប្រែថាអ្វីបានដល់អ្វី ?

**ឆ្លើយ** ពាក្យថាអវិនិព្ភោគរូប មានវិគ្គហថា **វិសុំ វិសុំ និភុញ្ជតីតិ វិនិព្ភោគោ ន វិនិព្ភោគោ អវិនិព្ភោគោ** ប្រែថា រូបដែលអាចញែកពីគ្នាបាន ហៅថាវិនិព្ភោគរូបដែលផ្ទុយនិង វិនិព្ភោគរូប ហៅថា អវិនិ-ព្ភោគរូប បានដល់ មហាភូតរូប ៤ និង វណ្ណៈ គន្ធៈ រសៈ ឱជា រួម ៨ប្រការ ជួនកាលក៏ហៅថា អដ្ឋកលាបរូប ឬ ជួនកាលហៅ ថាសុទ្ធកលាបៈក៏បាន ។ ពាក្យថា វិនិព្ភោគ ញែកជា២បទ ( ២ ស័ព្ទ ) វិ + និព្ភោគៈ វិ ប្រែថា ចេញស័ព្ទជាវិសុំ វិសុំ និព្ភោគៈ សំរេចមកពីកិរិយាស័ព្ទថា និភុញ្ជតិ ប្រែថា ញែក ចេញ ផ្សំ និង វិ ហើយ ប្រែរួមគ្នាបានជាដុំៗផ្សំគ្នា អៈ បដិសេធនៅខាងមុខជា អវិនិព្ភោគ ប្រែថា ញែកចេញពីគ្នា ជាដុំៗមិនបាន ។

ក្នុងព្រះបាលីមហាវេទល្លសូត្រ ព្រះសារីបុត្តពោលថា **ន ច លព្ភា ឥមេសំ ធម្មានំ វិនិព្ភុញ្ជិត្វា វិនិព្ភុញ្ជិត្វា នានាករណំ បញ្ញាបេតុំ ប្រែថា :** ម្នាលអាវុសោ មហាកោដ្ឋិតៈ ធម៌ទាំងនេះ មិនបានញែកចេញជាដុំៗ ដើម្បីប្រាកដជានានាផ្សេងៗ ដូច្នេះ ក្នុងព្រះបាលីនេះ ព្រះសារីបុត្ត ប្រើស័ព្ទ វិនិព្ភុញ្ជិត្វា ។ វិនិព្ភុញ្ជិត្វា ប្រែថាចែក ឬ ញែក ព្រោះលោកអដ្ឋកថាអធិប្បាយថា **វិនិព្ភុញ្ជិត្វា វិនិព្ភុញ្ជិត្វា វិសុំ វិសុំ កត្វា វិនិវដ្ដេត្វា ប្រែថា :** បទថា វិនិព្ភុញ្ជិត្វានោះធ្វើឱ្យជាកំណាត់ៗ ដុំៗហើយ ញែកចេញពីគ្នាទៅដូច្នេះ ។ ពាក្យថា **វិនិព្ភោគ និង អវិនិព្ភោគ** សំគាល់ថារូបដែលញែកចេញពីគ្នាបានមួយជំពូក ញែកចេញពីគ្នាមិនបានមួយជំពូក គឺ រូប ២ នេះញែក ឬ នៅម្នាក់មួយកន្លែងហើយមិនមានការ ច្របូកច្របល់គ្នាឡើយ ។ រូប ៨រូបគឺមហាភូតរូប ៤ និង វណ្ណៈ គន្ធៈ រស ឱជា រួម ៨ រូបនោះនៅលាយឡំគ្នាជានិច្ច

មិនដែលបានញែកចេញពីគ្នាទេ ដូច្នេះ ហៅថា អវិនិព្ភោគរូប ។

**សួរ** តាមដែលព្រះអនុរុទ្ធាចារ្យ សំដែងមកហើយ រូបមានចំនួន ២៨ បរិបូណ៌ ក្រៅអំពីនេះនៅមានរូបអ្វីទៀតខ្លះឬទេ ?

**ឆ្លើយ** តាមមហាអដ្ឋកថា អធិប្បាយថា រូប ២៨ដែលពោលមកហើយនេះ ជាអាហច្ចភាសិត គឺជារូបដែលព្រះបរមសាស្តាទ្រង់សំដែងជាចំនួនទុក ប៉ុន្តែមហាអដ្ឋកថានេះអធិប្បាយតទៅថា នៅមានរូប ៤ យ៉ាងទៀតគឺ ១-ពលរូប ២-សម្ភវរូប ៣-សណ្ឋានរូប និង ៤-រោគរូប រួម ៤ ប្រការក្នុងទីនេះ ពាក្យថា ពលរូប គឺ រូបដែលមានកម្លាំង មានន័យថា កម្លាំងរបស់មនុស្ស ឬ សត្វ ហៅថា ពលរូប ។

សម្ភវរូប គឺ សុក្ករបស់ប្រុសស្រី បានដល់ អសុចិ ពាក្យថាសុក្ក ឬ អសុចិ នោះឯងហៅថា សម្ភវរូប ។

សណ្ឋានរូប បានដល់រូបរាងសណ្ឋានរបស់រូប ។

រោគរូប បានដល់រូបដែលធ្វើឱ្យកើតរោគ ឬ ខណៈដែលរោគកើត ហៅថារោគរូប ។ ទាំង ៤ រូបដែលពោលមកនេះជារូបដែលសំដែងក្រៅពីពុទ្ធភាសិត ។

រូបទាំង ៤ នេះសង្គ្រោះចូលគ្នា នឹងរូប ២៨ ដូចគ្នាគឺ:

| | | |
|---|---|---|
| ពលរូប | រួមចូលក្នុង | វាយោធាតុ |
| សម្ភវរូប | រួមចូលក្នុង | អាបោធាតុ |
| សណ្ឋានរូប | រួមចូលក្នុង | វណ្ណរូប |
| រោគរូប | រួមចូលក្នុង | ជរតារូប |

ដោយហេតុនេះ ព្រះអនុរុទ្ធាចារ្យ ដែលជាអ្នកប្រាជ្ញមួយអង្គ ក្នុងលង្កាទ្វីបសម័យនោះ ទើបបានសំដែងតែរូប ២៨ តាមពុទ្ធភាសិតដើម ។

**ចប់រូបវិភាគ**

# សំដែងរូបសមុដ្ឋានន័យតាមបាលី

កម្មំ ចិត្តំ ឧតុ អាហារោ ចេតិ ចត្តារិ រូបសមុដ្ឋានានិ នាម ។ តត្ថ កាមាវចរំ រូបាវចរញ្ចេតិ បញ្ចវីសតិវិធម្បិ កុសលាកុសលកម្មាភិសង្ខតំ អជ្ឈត្តិកសន្តានេ កម្មសមុដ្ឋានរូបំ បដិសន្ធិមុបាទាយខណេ ខណេ សមុដ្ឋាបេតិ

អរូបវិបាក ទ្វិបញ្ចវិញ្ញាណវជ្ជិតំ បញ្ចសត្ត-តិវិធម្បិ ចិត្តំ ចិត្តសមុដ្ឋានរូបំ បឋមភវង្គមុបា-ទាយ ជាយន្តមេវ សមុដ្ឋាបេតិ ។ តត្ថ អប្បនជវនំ ឥរិយាបថម្បិ សន្នាមេតិ វោដ្ឋព្វន-កាមាវចរជវនាភិញ្ញា បន វិញ្ញត្តិម្បិ សមុដ្ឋា-បេន្តិ ។ សោមនស្សជវនានិ បនេត្ថ តេរស ហសនម្បិ ជនេន្តិ ។

**ប្រែសេចក្ដីថា**

កម្ម ចិត្ត ឧតុ អាហារ រួម ៤ យ៉ាងនេះ ហៅ ថា រូបសមុដ្ឋានក្នុងទីនេះ កាមាវចរកុសលចិត្ត និង អកុសលចិត្ត ២០ដួង រូបាវចរកុសលចិត្ត ៥ រួម ២៥ដួងដែលបានធ្វើទុកហើយនោះ ធ្វើឱ្យកើតកម្មជរូប ក្នុងអជ្ឈត្តិកសន្តាន តាំងពីឧប្បាទខណៈរបស់បដិសន្ធិចិត្តដោយគ្រប់ៗខណៈទៅរហូតកាល។

ចិត្ត ៧៥ដួង ( វៀរលែង អរូបវិបាក ៤ ដួង ទ្វិបញ្ចវិញ្ញាណ ១០ ដួង រួម ១៤ ដួង ) ធ្វើឱ្យចិត្តជរូបកើត តាំងពីបឋមភវង្គដោយគ្រប់ៗ ឧប្បាទខណៈទៅរហូត។ ក្នុងចិត្ត ៧៥ដួងនេះ អប្បនាជវនចិត្ត ២៦ ដួង ជួយឧបត្ថម្ភឥរិយាបថទាំង ៤ ផង ប៉ុន្តែកាមាវចរជវនចិត្ត ២៩ ដួង និង វោដ្ឋវនចិត្ត ១ ដួង និង ចិត្តជាអភិញ្ញា ២ ដួង រួម ៣២ ដួងនេះ ធ្វើឱ្យកាយវិញ្ញត្តិ វចីវិញ្ញត្តិកើតបាន ។ ក្នុងចិត្ត ៣២ ដួង

ចិត្តដែលសំខាន់ គឺ សោមនស្សជវនចិត្ត ១២ ដួង ធ្វើឱ្យញញឹម និង សើចកើតបាន ។

## សំដែងព្រះបាលី " ត "

សីតុណ្ហោតុសមញ្ញាតា តេជោធាតុ ឋិតិប្បត្តាវ ឧតុសមុដ្ឋានរូបំ អជ្ឈត្តញ្ច ពហិទ្ធា ច យថារហំ សមុដ្ឋាបេតិ ឱជាសង្ខាតោ អាហារោ អាហារសមុដ្ឋានរូបំ អជ្ឈោហរណ-កាលេ ឋានប្បត្តោវ សមុដ្ឋាបេតិ ៕

តត្ថ ហទយឥន្ទ្រិយរូបានិ កម្មជានេវ ៕ វិញ្ញត្តិទ្វយំ ចិត្តជមេវ ៕ សទ្ទោ ចិត្តោតុជោ លហុតាទិត្តយំ ឧតុចិត្តាហារេហិ សម្ភោតិ អវិនិព្ភោគរូបានិ ចេវ អាកាសធាតុ ច ចតូហិ សម្ភូតានិ ៕

លក្ខណរូបានិ ន កុតោចិ ជាយន្តិ ៕

**ប្រែសេចក្ដីថា**

តេជោធាតុជាសីតឧតុ ឧណ្ហឧតុ ធ្វើឱ្យកើតឧតុជរូប ក្នុងអជ្ឈត្តៈ ឬ ពហិទ្ធៈក៏ដោយ តាំងពីឋិតិខណៈដោយរហូតកាល ។ អាហារដែលជាឱជារូប ធ្វើឱ្យអាហារជរូបកើត កាលខណៈលិឍភ្លក់អាហារ តាំងពីឋិតិខណៈរហូតទៅ

ក្នុងចំនួនរូបទាំងឡាយនេះ រូបហទយ ១ ឥន្ទ្រិយរូប ៨ រួម ៩ រូបនេះជាកម្មជរូបទាំងអស់ វិញ្ញត្តិរូបទាំង២ជាចិត្តជរូប សទ្ទរូបរមែងកើតព្រោះចិត្ត និង ឧតុរូបទាំង ៣ មានលហុតារូបជាដើម រមែងកើតព្រោះឧតុ និង អាហារ ។

អវិនិព្ភោគរូប ៨ និង អាកាសធាតុ ១ រួម ៩ រូបនេះរមែង កើតព្រោះសមុដ្ឋានទាំង ៤ប្រការ ។

លក្ខណរូបទាំង ៤ រមែងមិនកើតដោយសមុដ្ឋានណានីមួយឡើយ (ព្រោះតាមបាលីហៅថា ន កុតោចិសមុដ្ឋាន)

## សំដែងគាថាសង្គហ

**អដ្ឋារស បណ្ណរស តេរស ទ្វាទសាតិ ច កម្មចិត្តោតុកាហារជានិ ហោន្តិ យថាក្កមំ ។**

**ជាយមានាទិរូបានំ សភាវត្តា ហិ កេវលំ លក្ខណានិ ន ជាយន្តិ កេហិចីតិ បកាសិតំ ។**

**ប្រែសេចក្ដីថា**

រូប ១៨ រូប ១៥ រូប ១៣ រូប ១២ រូបទាំងអស់នេះរមែងកើតព្រោះ កម្ម ចិត្ត ឧតុ និង អាហារដោយលំដាប់ ។ ចំណែកលក្ខណរូបនោះលោកសំដែងទុកថារមែងកើតព្រោះសភាវរបស់ខ្លួន គឺ កម្លាំងកើតជាដើមរមែងកើតតាមសភាពរបស់ខ្លួន ព្រោះហេតុដូច្នេះ គ្មានបានកើតព្រោះ សមុដ្ឋានណាមួយទេ ។

**អយមេត្ថ រូបសមុដ្ឋាននយោ** ដូចដែលបានពោលមកហើយក្នុងបរិច្ឆេទទី ៦នោះ ជារូបសមុដ្ឋាននន័យ ។

## អធិប្បាយរូបសមុដ្ឋានន័យ

ពាក្យថា រូបសមុដ្ឋាន ប្រែថា ស្តែងធម្មជាតិដែលធ្វើឱ្យរូបផ្សេងៗកើត បានដល់សមុដ្ឋានរូប ៤ ប្រការគឺ កម្មចិត្ត ឧតុ អាហារ រួម ៤ ប្រការ ។

ក្នុងទីនេះ ពាក្យថា កម្ម បានដល់ចេតនា ២៥ គឺ ចេតនាអកុសល ១២ ចេតនាកុសល ៨ និង ចេតនារូបាវចរ ៥ រួមចេតនា ២៥ ដូចនេះ ធ្វើឱ្យកើតកម្មជរូប ១៨ ។ ក្នុងសន្តានរបស់បុគ្គល តាំងពីឧប្បាទខណៈរបស់បដិសន្ធិ រហូតដល់អស់ជីវិត ។

ពាក្យថា ចិត្ត បានដល់ចិត្តដែលធ្វើឱ្យកើតចិត្តជរូប ១៥ ចិត្តទាំងអស់នេះគឺ ក្នុងចិត្ត ៨៩ដួង ( វៀរលែងអរូបវិបាក ៤ និង ទ្វិបញ្ចវិញ្ញាណ ១០ រួម ១៤ ដួង ) កាលធ្វើឱ្យកើតរូប តាំងពីបដិសន្ធិកាល តាំងពីភវង្គចិត្ត កើតរហូតជីវិតទៅ ។ ពាក្យថា ឧតុនោះ បានដល់ឧតុជរូប ១៣ រូប កើតបានដល់សីតឧតុ និង ឧណ្ហឧតុទាំងពីរកើតមកអំពី ឋិតិខណៈ របស់ បដិសន្ធិកើតរហូតជីវិត ។ ប៉ុន្តែឧតុនោះ ឧតុ-

ក្រៅក៏មាន ដូចជាឧតុដី មេឃ អាកាស ភ្នំ ព្រៃឈើជាដើម ព្រោះហេតុដូច្នោះ ទើបលោកបែងចែកឧតុជា ២យ៉ាងគឺ : អជ្ឈត្តឧតុ និង ពហិទ្ធឧតុ ។ អជ្ឈត្តឧតុនោះ រមែងមាននៅក្នុងសន្ដានរបស់បុគ្គល ពហិទ្ធឧតុនោះ រមែងមានក្រៅបុគ្គល ដូចជាដី មេឃ ភ្នំ ព្រៃឈើជាដើម ។ មានសេចក្ដីថា ឧតុជរូបទាំងអស់នេះរមែងកើតរហូត ពេលវេលា គ្មានខ្វះទេ ។ ពាក្យថា អាហារ បានដល់ អាហារដែលធ្វើឱ្យអាហាររូប ១២ រូបកើត តែជាអាហាររូប គឺ អាហារផ្សេង-ៗដែល សត្វ និង មនុស្ស ទេវតា ទាំងឡាយបរិភោគជានិច្ច អាហារនេះឯង កាលលេបចូលទៅហើយ តាំងពីឋិតិខណៈធ្វើឱ្យអាហារជរូបកើតទៅរហូត ។

ក្នុងរូបសមុដ្ឋាន ៤ ប្រការដែលពោលមកហើយនេះ អប្បនាជវន ២៦ ដួង គឺ មហគ្គតកុសល ៩ ដួង មហគ្គតកិរិយា ៩ ដួង និង លោកុត្តរ ៨ ដួង រួម ២៦ដួងនេះ ជួយឧបត្ថម្ភឥរិយាបថទាំង ៤ គឺ ដេក ដើរ ឈរ អង្គុយ ។

វោដ្ឋវនចិត្ត ១ ដួង កាមជវន ២៩ ដួង អភិញ្ញា ចិត្ត ២ដួង រួម ៣២ដួងនេះ ធ្វើឱ្យកាយវិញ្ញត្តិ និង វចីវិញ្ញត្តិកើតបាន។ ក្នុងចំនួនចិត្ត ដែលធ្វើឱ្យវិញ្ញត្តិកើតនោះ នៅមាន សោមនស្សចិត្ត ១៣ ដួង គឺ ក្នុងលោភមូល ៤ ដួង អហេតុកកិរិយា ហសិតុប្បាទ ១ ដួង និង កាមាវចរកុសល ៤ ដួង និង កិរិយា ៤ ដួង រួម ១៣ ដួងនេះ ធ្វើឱ្យការសើច កើតបាន ។

ក្នុងរូបទាំងអស់ដែលពោលមកហើយនេះ ហទយរូប ១ ឥន្ទ្រិយរូប ៨ រួម ៩ រូប កើតព្រោះកម្ម ។ វិញ្ញត្តិរូបទាំងពីរកើតព្រោះចិត្ត និង ឧតុ ។ វិការរូបទាំង ៣ កើតព្រោះចិត្ត ឧតុ អាហារ ។ អវិនិព្ភោគរូប ៨ និង អាកាស-ធាតុរួម ៩រូបកើតព្រោះសមុដ្ឋានទាំង ៤ ។ ចំណែក លក្ខណរូប ៤ មិនបានកើតព្រោះសមុដ្ឋានណាមួយឡើយ ។

## អធិប្បាយគាថាសង្គហៈ

កម្មជរូប ១៨ គឺ ហទយរូប ១ ឥន្ទ្រិយរូប ៨ អនិទ្និ-ព្ភោគរូប ៨ អាកាសធាតុ ១ រួម ១៨រូបនេះ ហៅថា កម្ម-ជរូប ។

វិញ្ញត្តិរូប ២ សទ្ទរូប ១ វិការរូប ៣ អនិទ្និព្ភោគរូប ៨ អាកាសធាតុ ១ រួម ១៥ រូប ហៅថា ចិត្តជរូប ។

សទ្ទរូប ១ វិការរូប ៣ អនិទ្និព្ភោគរូប ៨ អាកាសធាតុ ១ រួម ១៣រូបនេះហៅថា ឧតុជរូប ។

វិការរូប ៣ អនិទ្និព្ភោគរូប ៨ អាកាសអាតុ ១ រួម ១២រូប ហៅថា អាហារជរូប ។

ចំណែកលក្ខណរូបកើតតាមសភាវៈគឺ កើត ចំរើន ទ្រុឌទ្រោម បែកធ្លាយរលត់ទៅតាមសភាពរបស់ខ្លួន ព្រោះហេតុដូច្នោះ ទើបលោកសំដែងថា មិនបានកើតជាមួយសមុដ្ឋានណាមួយឡើយ ។

# ពាក្យសួរឆ្លើយក្នុងរូបសមុដ្ឋានន័យ

**សួរ** ក្នុងរូបសមុដ្ឋានន័យ ៤ គឺ កម្ម ចិត្ត ឧតុ អាហារ ។ ក្នុងទីនេះពាក្យថាកម្ម កម្មនេះអ្នកណាក៏ដឹងថា ជាចេតនាចេតសិក ។ ចេតនាចេតសិកនេះ រមែងកើតពីចិត្ត កាលបើដូច្នោះ ពាក្យថា កម្មជរូប និង ចិត្តជរូបក៏ជាមួយគ្នាហើយ ដូចម្តេចទើបព្រះអនុរុទ្ធាចារ្យ ទ្រង់សំដែងចិត្តជរូបទៀត ?

**ឆ្លើយ** គ្មានដូច្នោះទេ ពាក្យថាកម្មជរូប កើតព្រោះ កម្មសមុដ្ឋាននោះ ប្រែថា កម្មដែលជាកុសល និង អកុសល ដែលធ្វើទុកមកពីជាតិមុនៗ ព្រោះហេតុដូច្នោះ សត្វមួយរូប កាលបដិសន្ធិនោះមាន ៣០ រូប គឺ កាយទសកៈ ភាវទសកៈ វត្ថុទសកៈ រួម ៣០ រូបនេះ ក៏ប្រាកដព្រមគ្នា និង បដិសន្ធិ ។ រូបទាំងអស់នេះ ហៅថាកម្មចាស់ ជូនឱ្យកើតកម្មជរូប អធិប្បាយដោយសង្ខេបថា កម្មជរូប គឺ រូបដែលកើតមក

ដោយកម្មនៃអតីតកាល ក្នុងខណៈដែលបដិសន្ធិ ឬ ហៅថា បដិសន្ធិរូបក៏បាន ។ ចំណែកចិត្តជរូប កាលបដិសន្ធិរលត់ចុះ បឋមភវង្គចិត្ត រមែងកើតតាំងពីនោះ មករហូតខណចិត្តរូប ទាំងអស់នេះកើត ហៅថា បវត្តិរូប ឬ ចិត្តធ្វើឱ្យកើតរូបក្នុង បវត្តិក៏បាន ដូច្នោះពាក្យថា កម្មនោះ បំណងយកអតីត-កម្ម។ ពាក្យថាចិត្តនេះ បំណងយកបវត្តិចិត្ត ។ កម្មជៈ និង ចិត្តជៈ ២ យ៉ាងនេះផ្សេងគ្នាច្រើន ដូចដែលបានអធិប្បាយ មកហើយ ។

**សួរ** រូបដែលកើតព្រោះកម្មចាស់ ដែលធ្វើទុកក្នុង ជាតិ មុននោះមានប៉ុន្មានប្រាកដ ?

**ឆ្លើយ** រូបដែលកើតដោយកម្មនោះ មានពីរជំពូក គឺ ចំពោះ កម្មពិតៗ ៩ រូបគឺ ហទយរូប ១ ភាវរូប ២ ជីវិតរូប ១ បសាទរូប ៥ រួម ៩ រូប និង រូបដែលលាយទឡំគ្នា និង សមុដ្ឋានដទៃៗ ៩ រូប គឺ មហាភូត ៤ វណ្ណៈ គន្ធៈ រសៈ ឱជា និង អាកាសធាតុរួម ៩ រូប រួមសារុប ១៨ រូបដែលពោល

មកហើយ ហៅថាកម្មជរូបតែ ៩ រូបក្រោយគ្មានជាកម្មជរូបសុទ្ធទេ ព្រោះកើតដោយសមុដ្ឋានទាំង ៤ និង ៩ រូបមុននោះ រមែងកើតព្រោះកម្មចាស់ពិតៗ ។ គប្បីឃើញឧទាហរណ៍ មនុស្សសត្វកាលខណៈ ដែលបដិសន្ធិ នៅមានរូប ១ ចំនួន គឺៈ កាយទសករូប ១០ ភាវទសករូប ១០ វត្ថុទសករូប ១០ រួមទាំង ៣ទសកៈ មានចំនួន ៣០ រូបនេះកើតដោយកម្មចាស់/ឧប្បត្តិកបដិសន្ធិ ដូចជាទេវតាជាដើម កាលបដិសន្ធិ នោះនៅមានរូប ១ ចំនួន គឺ ចក្ខុទសកៈ ១០ រូប សោតទសកៈ ១០ រូប ឃានទសកៈ ១០ រូប ជិវ្ហាទសកៈ ១០ រូប កាយទសកៈ ១០ រូប ភាវទសកៈ ១០ រូប វត្ថុទសកៈ ១០ រូប រួម ៧០ រូបនេះកើតព្រោះកម្មចាស់ រួម ២ យ៉ាងដូច អធិប្បាយមកហើយ ហៅថា កម្មជរូបទាំងអស់ ព្រោះហេតុដូច្នោះ ពាក្យថា កម្មជរូប ពោលដោយសង្ខេបមាន ៩ រូប ដោយពិស្តារមាន ១៨ រូប ថាដោយបដិសន្ធិក្នុងគភ៌បាន ៣០ រូប

សត្វដែលបដិសន្ធិ ដោយឧប្បត្តិកបាន រូប ៧០ ដូចដែលបាន បរិយាយមកហើយ ។

**សួរ** ក្នុងសមុដ្ឋាន ៤ ចិត្តជរូប គឺ ចិត្តដែលធ្វើឱ្យកើតរូប នោះមាន ៧៥ ដួង វៀរទ្វិបញ្ចវិញ្ញាណ ១០ ដួង និង អរូប-វិបាក ៤ ដួង ធម្មតាចិត្តមានលក្ខណៈជាមួយគ្នាហើយទាំង ៨៩ដួង ឬ ១២១ ដួង ហេតុណាទើបចិត្ត ១៤ ដួងនេះមិន អាចធ្វើឱ្យកើតរូបបាន ?

**ឆ្លើយ** ចិត្តដែលធ្វើឱ្យកើតចិត្តជរូប គឺ ចិត្តដែលមានកម្លាំង គ្រប់គ្រាន់ ។ ពាក្យថា កម្លាំងចិត្តនេះ គឺ បច្ច័យផ្សេងៗជួយ ឧបត្ថម្ភ ឬ មានហេតុដទៃៗ ធ្វើឱ្យកើតតាមចិត្តនិយាម សំរាប់ទ្វិបញ្ចវិញ្ញាណ ១០ នេះ កម្លាំងទន់ទាបជាទីបំផុត ហើយប្រាសចាកហេតុ ៣ប្រការ តាមសភាពរបស់អហេតុ-កចិត្ត ព្រោះហេតុដូច្នេះ ទើបមិនអាចនឹងឱ្យផលបាន ។ ចំណែកអរូបវិបាក ៤ នេះ សូម្បីអាចនឹងឱ្យផលក្តី ផលនោះ ជានាម គ្មានជារូបទេ ព្រោះហេតុដូច្នោះ ទ្វិបញ្ចវិញ្ញាណ ១០

ដួង និង អរូបវិបាក ៤ ដួង រួម ១៤ដួងនេះ មិនអាចធ្វើឱ្យកើតចិត្តជរូបបានឡើយ ក្រៅអំពី ១៤ ដួង ដូចពោលមកហើយ នៅមានចិត្ត ១ ដួងក៏មិនអាចធ្វើឱ្យកើតរូប រូបនោះគឺ ចុតិចិត្តរបស់ព្រះអរហន្តទាំងឡាយ ព្រោះព្រះអរហន្តទាំងឡាយ មិនបានកើតទៀតទេ ដូច្នេះ មិនឱ្យកើតរូប សេចក្តីនេះ ព្រះអនុរុទ្ធាចារ្យ មិនបានពោលទុកក្នុងអភិធម្មសង្គហៈផង ។

**ឆ្លើយ** ក្នុងចំនួនចិត្ត ៧៥ ដួង ដែលធ្វើឱ្យកើតរូបនោះ ព្រះអនុរុទ្ធាចារ្យ ដកចេញ ៣២ ដួង ដែលធ្វើឱ្យកើតកាយ-វិញ្ញត្តិ និង វចីវិញ្ញត្តិរូបតទៅ ដកចិត្ត ១៤ ចេញទៀត សំដែងថាជាចិត្ត ដែលធ្វើឱ្យសើច ដូច្នេះ អាការធ្វើឱ្យសើចនោះ បានទេ ?

**ឆ្លើយ** គ្មាន ដូច្នោះទេ ពាក្យថា វិញ្ញត្តិរូបនេះ ជារូបដែលធ្វើឱ្យអ្នកដទៃដឹងដែលសំដែងមកហើយ ក្នុងពាក្យសួរឆ្លើយក្នុងរូបវិភាគ ។ ពាក្យថា សើចនោះ ក្នុងបាលីថា ហសិត ឬ

និយាយតាមកិរិយាស័ព្ទថា ហសិ ប្រែថា ញញឹម ឬ សើច ប៉ុណ្ណោះ ។

ក្នុងទីនេះសើចមានច្រើនយ៉ាង គឺ សិត ហសិត វិហសីត ឧបហសិត អបហសិត អតិហសិត ។

រួម ៦ ស័ព្ទនេះ ជាស័ព្ទប្រែថា សើចទាំងអស់ ។ ក្នុងទីនេះព្រះអនុរុទ្ធាចារ្យ សំដែងថាចំណែក សោមនស្សចិត្តក្នុងកាមាវចរ ១៣ ដួងធ្វើឱ្យកើតសើចបាន តែការសើចនេះលោកមិនបានធានាថា ជាវិញ្ញត្តិរូបដោយពិតប្រាកដ ព្រោះលោកសំដែងបាលីទុកថា សោមនស្ស ជវនានិ បនេត្ថ តេរស ហសនំបិ មិនបានសំដៅសេចក្តីចំពោះតែវិញ្ញត្តិរូប ។ លោកអះអាងថា ក្រៅពីធ្វើឱ្យកើតវិញ្ញត្តិរូប ហើយចិត្ត ១៣ដួងនេះធ្វើឱ្យកើត សើចបានទៀតដោយពិសេស ព្រោះហេតុដូច្នេះ ហសនំបិ ស័ព្ទថា " បិ " ជាវុត្តសមុច្ច័យ ន័យតាមវេយ្យាករណ៍ ប្រែថា រួមដោយការសើច ឬ មិនចំពោះតែឱ្យកើតវិញ្ញត្តិរូបបានដូច្នេះ ។ ក្នុងអភិធម្មត្ថវិភាវិនីដីកា

អធិប្បាយថា វិញ្ញត្តិបិ សមុដ្ឋាបេន្តីតិ ន កេវលំ រូបិរិយាបថានេវ ។ល។ តថា ហាសជនកានិ ច សេចក្តីជាពាក្យថា វិញ្ញត្តិបិ សមុដ្ឋាបេន្តិ នោះមិនមែនចំពោះតែឱ្យកើតរូប ឥរិយាបថតែម្យ៉ាង សេចក្តីពិតធ្វើឱ្យកើតការសើចក៏បានដែរ ព្រោះហេតុដូច្នោះ ការសើចវិនិច្ឆ័យថា គ្មានជាវិញ្ញត្តិរូបទេ ព្រោះលោក អដ្ឋកថា អះអាងថា ការសើចនោះជាអាការរបស់រូបសាមញ្ញ កើតមកពីសេចក្តីត្រេកអរ ឬ សោមនស្ស ចំណែកវិញ្ញត្តិរូប សំដៅយកតែអាការកិរិយារបស់រាងកាយ ខណៈដែលរំជើបរំជួលប្រាកដឡើង ។

**សួរ** ការញញឹមនោះ កើតពីសោមនស្សទាំងអស់ឬ ? ព្រោះជួនកាលក៏បានឃើញថា ខណៈដែលសម្លាប់មនុស្ស ឬសត្វ អ្នកសម្លាប់មានអាការសើចផងដែរ ដូចជាពេជ្ឈឃាដខណៈដែលនឹងសម្លាប់មនុស្សនោះ មិនត្រឹមតែសើចទេ នៅមានអាការរាំផង ក្នុងទីនេះចង់ដឹងថា ទោស ធ្វើឱ្យកើតសើចបានឬទេ ?

**ឆ្លើយ** មិនបានទេ ព្រោះការសើចនេះ ជាអាការរបស់សោមនស្សដោយឡែក ក្នុងខណៈដែល ទោស ប្រាកដនៅនោះមិនមានការសើច តាមធម្មតាទោសៈ និង ទោមនស្សត្រូវមានសេចក្តីខូច ឬ ចិត្តខូចប៉ុណ្ណោះ ។ ការស្ងប់ហើយក៏ដឹងថា យើងនឹងបានធ្វើទុកធ្វើទោស ឬ យើងជាអ្នកឈ្នះវេលានោះសោមនស្សកើត ។ សោមនស្សនេះឯង ដោយត្រង់គឺលោភៈ ហើយធ្វើឱ្យសើច ឬ ញញឹមបាន ។ ក្នុងបញ្ចង្គុត្តរដីកាថា **ននុ ច កេចិ កោធវសេនាបិ ហសន្តីតិ ន តេ សម្បិ យន្តិ កោធវត្ថុំ តត្ថ មយំ យថាកាមការិតំ អាបជ្ជិស្សាមាតិ ឧប្បិល្លោ~ យស្សន្តរេន សោមនស្សចិត្តេនេវ ហសស្ស ឧប្បជ្ជនតោ ប្រែសេចក្តីថា** អ្នកខ្លះសើចដោយសេចក្តីខឹងមិនមែនឬ ? នេះជាពាក្យសួរ ។ កាលសើចមិនអាចតាំងនៅជាមួយនិង កោធវត្ថុនោះបានទេ តែអ្នកសម្លាប់ក៏ដឹងច្បាស់ថា យើងនឹងបានធ្វើតាមចិត្ត ឬ តាម

សេចក្ដីអង់អាចរបស់ខ្លួន ( យើង ) ហើយកើតសេចក្ដីត្រេកអរហើយ សើចក៏ប្រាកដឡើង ដោយសេចក្ដីដឹងជាថ្មីព្រោះហេតុដូច្នេះ ការសើចនេះមិនបានកើតមកអំពីទោស ឬ ទោមនស្ស មិន មានសភាពធ្វើឱ្យកើតសើចបានឡើយ ។

**សួរ** តាមបាលីរបស់ព្រះអនុរុទ្ធាចារ្យ សំដែងឧតុសមុដ្ឋាន-រូបថា **អជ្ឈត្តញ្ច ពហិទ្ធា ច យថារហំ សមុដ្ឋាបេន្តិ** ប្រែថា តេជោធាតុធ្វើឱ្យកើត ឧតុជរូបខាងក្នុង និង ខាងក្រៅ ។ ក្នុងទីនេះតេជោធាតុ រមែងឱ្យកើតរូបរាងខាងក្នុង ខាងក្រៅបានយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថាឧតុ និង ពាក្យថា តេជោធាតុ ពីរស័ព្ទនេះជាមួយគ្នាដោយសេចក្ដីបំណង ។ ពាក្យថា ឧតុ ប្រែត្រង់ៗថា បានសេចក្ដីកក់ក្ដៅរបស់ធាតុ ឬ ចំហាយក៏បានហើយ តេជោធាតុ បានដល់សេចក្ដីក្ដៅ ឬ ត្រជាក់ទាំង ២ ក្នុងបាលីហៅថា ឧណ្ហតេជោ និង សីតតេជោ ។

កាលសត្វបដិសន្ធិ តេជោធាតុ ឬ ឧតុដែលធ្វើឱ្យកើត

ឬ កក់ក្ដៅមាននៅជានិច្ច ។ ឧតុដែលកើតពីបដិសន្ធិរហូត ជីវិតរបស់សត្វនោះ ធ្វើឱ្យកក់ក្ដៅរក្សារូបមករហូត ឧតុនេះ ក្នុងព្រះបាលីហៅថា ឧស្មាតេជោធាតុ ។

ក្នុងព្រះបាលីវិភង្គ សំដែងតេជោធាតុ ៤ ប្រការគឺ សន្តាបតេជោ ទាហតេជោ បាចកតេជោ ជីរណតេជោ ។ ចំណែកឧស្មាតេជោនោះព្រះសាស្តា ទ្រង់ សំដែងថា **អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ** ជាដើម ប្រែថា កាលណាអាយុ ឧស្មា តេជោធាតុ និង វិញ្ញាណទាំង ៣ យ៉ាងនេះ ចោលរាងកាយ គប្បីជ្រាបថា៖ អាយុ ឧស្មា និង វិញ្ញាណ ទាំង ៣យ៉ាងនេះ ជាធម្មជាតិ រក្សារាងកាយជានិច្ច ។ ឧស្មាតេជោនេះធ្វើឱ្យរាងកាយកក់ ក្ដៅទើបហៅថា ឧតុ រហូតជីវិត ឧតុនេះឯង ហៅ ថាអជ្ឈត្តិកតេជោធាតុ ។ កាលអាកាសក្រៅ ឬ ដី ទឹក ភ្លើង ខ្យល់ ដែលមកអំពីខាងក្រៅ ប៉ះទង្គិចរាងកាយនោះ ហៅថា ឧតុខាងក្រៅគឺ ឧតុដែលមាន ក្នុងភ្នំ ទឹក ដី

ដើមឈើ ផ្សេងៗហៅថាពហិទ្ធឧតុតេជោ តេជោ ២យ៉ាង នេះ ជួយគ្នារក្សាជីវិត ។ កាលឧតុ ២យ៉ាងនេះប្រាសចាក រាងកាយហើយ ប្រែថា អ្នកស្លាប់តែម្តង ទោះបីមិនព្រម ដោយអង្គទាំង ៣ ក៏ដោយ ក៏មិនអាចតាំងខ្លួននៅបាន ដូច្នេះ អាយុប្រចាំ ហៅថា អជ្ឈត្តិកឧតុ ។ ឧតុខាងក្រៅ ដែលពោលមកហើយនេះ ហៅថា ពហិទ្ធឧតុ ។ ឧតុ២យ៉ាង នេះធ្វើឱ្យកើតរូបបានជានិច្ច ហើយសភាពរូបដែលទាក់ទង មកអំពីឧតុ ដែលពោលមកហើយហៅថា ឧតុជរូប ។

**ស្នូរ** តាមបាលីរបស់ព្រះអនុរុទ្ធាចារ្យថា សទ្ទោ ចិត្តោតុ-ជោ ប្រែថា សទ្ទះ ប្រែថា សំឡេង កើតមក ព្រោះចិត្ត និង ឧតុក្នុងទីនេះសំឡេងដែល កើតមកពីចិត្ត នោះ គឺ សំឡេង របស់មនុស្ស និង សត្វផ្សេងៗ ។ សំឡេង ដែលកើតមកពី ឧតុនោះ ដូចជាសំឡេង ផ្គរលាន់ ខ្យល់ជាដើម សំឡេង ដែលកើតពីឧតុនោះ អ្នកណាៗក៏ជ្រាបហើយ ចំណែក សំឡេងដែលកើតមកពីចិត្តនោះ ជាទីសង្ស័យព្រោះ

សំឡេងដែលកើតមកអំពីចិត្ត កាលចិត្តត្រូវសំឡេងពិរោះ ដូចម្តេចសំឡេងទើបមិនតាមចិត្ត ?

**ឆ្លើយ** កាលដែលព្រះអនុរុទ្ធាចារ្យអះអាងថា សទ្ទរូប រមែងកើតមកពីចិត្តនោះ គឺ កាលចិត្តត្រូវការនិយាយ អាស្រ័យដែលចិត្តត្រូវការនោះ ចិត្តជរូប វាយោធាតុ រមែងកើតមុន អាស្រ័យវាយោនេះហើយ សំឡេងស្រែក ក៏ប្រាកដមួយរំពេច ព្រោះហេតុដូច្នោះ លោកអធិប្បាយថា សទ្ទោ ចិត្តោតុជោ ។ កាលសំឡេងស្រែកចេញមកហើយ សំឡេងនោះល្អពិរោះឬទេ ? មិនមែនគតិរបស់ចិត្តដោយ ត្រង់សេចក្តីពិតសំឡេងល្អពីរោះនេះ ត្រូវអាស្រ័យកម្មទៀត ចំណែកកម្មជរូបក៏ដូចគ្នា ភ្នែកល្អ ត្រចៀកល្អ ច្រមុះល្អ មាត់ល្អ កាយល្អនោះ ព្រោះកុសលកម្មទៀតដោយឡែក ។ ឧទាហរណ៍ ដូចជាមាត់អ្នកខ្លះក្រអូបល្អនោះ ព្រោះ កុសលកម្មដូចព្រះបាលីក្នុង អង្គុត្តរៈថា

**សទ្ធម្មំ ទេសនាកាលេ សាធុ សាធូតិ ភាសតោ មុខតោ វាយតេ គន្ធោ ឧប្បលំវ យថោទកេ**

**សេចក្តីថា** ៖ អ្នកណាសាធុ អនុមោទនាក្នុងខណៈដែលស្តាប់ព្រះសទ្ធម្ម អ្នកនោះរមែងមានក្លិនក្រអូបចេញពីមាត់ដូចក្លិនផ្កាឈូកដុះក្នុងទឹក ។ ដូច្នេះ មនុស្សល្អ ស្អាតក្តី រមែងមានផលានិសង្ស ដោយឡែកដូចគ្នា ព្រោះហេតុដូច្នេះ សំឡេងដែលពិរោះ ក៏ត្រូវវិនិច្ឆ័យថា មិនចំពោះតែចិត្ត និង ឧតុ ។ តួនាទីរបស់ចិត្ត និង ឧតុនោះ ធ្វើឱ្យសំឡេងកើតប៉ុណ្ណោះ ។ ក្រៅពីនោះ និង ត្រូវរាប់យកកុសលជាប្រធានផង មានន័យថា អ្នកដែលមានបុណ្យវាសនា រមែងមានសំឡេងល្អពិរោះគួរចង់ស្តាប់ ដូច្នេះនៅក្នុង និធិកណ្ឌសូត្រ ទើបមានព្រះបាលីធានាថា **សុវណ្ណតា សុស្សរតា សុសណ្ឋានា សុរូបតា អាធិបច្ចំ បរិវារោ សព្វមេតេន លព្ភតិ** ដូច្នេះ ។ **ប្រែសេចក្តីថា**

កាលកើតជាមនុស្ស សម្បុរមាស សំឡេងពិរោះ រូបរាងសណ្ឋានល្អ រូបារម្មណ៍ល្អ និងមានអំណាច បរិវារទាំងអស់នេះ រមែងបានមកព្រោះកុសលកម្មទាំងអស់ ។

**សួរ** តាមបាលីរបស់ព្រះអនុរុទ្ធាចារ្យ សំដែងថា លក្ខណ-រូបានិ ន កុតោចិ ជាយន្តិ ប្រែថា លក្ខណរូបទាំង ៤ ជា ន កុតោចិ គឺ មិនបានកើតមកដោយកម្មសមុដ្ឋាន យ៉ាងណានិមួយ ក្នុងទីនេះ លក្ខណរូប ៤ គឺ ឧបចយ សន្តតិ ជរតា អនិច្ចតា ទាំង ៤ នេះមិនមានសមុដ្ឋាន ។

ការពិចារណាមើលតាមដែលព្រះអនុរុទ្ធាចារ្យ ពាក្យថា ឧបចយ និងសន្តតិ ជាឈ្មោះរបស់ជាតិរូប ដែលកើតមកដោយសមុដ្ឋានតែម្តង ព្រោះហេតុដូច្នេះ សុំពាក្យអធិប្បាយច្បាស់លាស់ថា ជាលក្ខណរូប ទាំង៤ជា ន កុតោចិ សមុដ្ឋានយ៉ាងណា ? ឬអាចជា កម្មសមុដ្ឋានបានយ៉ាងណាខ្លះ ?

**ឆ្លើយ** តាមព្រះអភិធម្មថា លក្ខណរូប ៤ ជា ន កុតោចិ សមុដ្ឋាន គឺមិនមានសមុដ្ឋាន យ៉ាងណានោះ ព្រះអនុរុទ្ធាចារ្យ មានសេចក្តីយល់ឃើញថា រូបទាំងអស់នេះកើតតាមធម្មតា គ្មានសមុដ្ឋានទេ គឺ ការកើត ការចំរើនរបស់រូបជាដើម រូបទាំងអស់នេះ ត្រូវកើត ត្រូវចំរើនវិយជាធម្មតា ។

លោកអធិប្បាយថា **លក្ខណានិ ន ជាយន្តិ កេហិចិតិបកាសិតំ** ប្រែថា លក្ខណរូបមិនមែនសមុដ្ឋាន ( មិនមានសមុដ្ឋាន ) តែកន្លែងខ្លះថា ឧបចយ និងសន្តតិរូបទាំង២ នេះ រាប់ចូលក្នុងកម្មជរូបក៏មាន ។ នៅមានព្រះបាលីគាថាមួយបទ ដែលអាចារ្យពីបុរាណប្រើមកហើយថា

**ឯកូនវីសតិត្តិយា នហានត្តាយ នតី គតា តាស្វេកំ កុម្ភិលោ គណ្ហិ តឆាវីសតិយរៈ មាគតា**

**ប្រែសេចក្តីថា**

មានស្រី ១៩នាក់ ទៅលេងកំពង់ទឹកដើម្បីសំអាតរាងកាយកាលនោះក្រពើស៊ី ១ នាក់ ត្រឡប់មកផ្ទះរាប់មើលក៏មាននមនុស្សស្រី ២០ នាក់ ។. ឆ្លើយ សំដៅយកសេចក្តីស្រី១៩នាក់ បានដល់ចិត្តបដិសន្ធិ ១៩ ដួង កាលជាតិរូបកើតហើយរលត់ទៅ កាលនោះឧបច្ច័យ និង សន្តតិរមែងកើតមានន័យថា ១៩ - ១ = ១៨ + ២ = ២០រូប

ក្នុងអភិធម្មត្ថសង្គហៈថា **ជាតិរូបមេវ បនេត្ថ ឧបចយសន្តតិនាមេន បវុច្ចតិ សេចក្តីថា** ក្នុងទីនេះជាតិរូបតែ ១ ហៅថា ឧបច្ចយរូប និង សន្តតិរូបរួម ២ រូប ដូចដែលពោលមកហើយនេះ សំដែងថា វាទៈរបស់អាចារ្យបុរាណរមែងមាន ២ ន័យ គឺ អាចារ្យខ្លះថាលក្ខណរូប ៤ ន កុតោចិ សមុដ្ឋាន ប្រែថាមិនមានសមុដ្ឋានសូម្បីណាមួយ ហើយអាចារ្យខ្លះក៏ថា កម្មជរូបដូច្នេះ តែយ៉ាងណាក្តីក្នុងព្រះបាលី សំដែងថា ឧបច្ចយ និង សន្តតិទាំងពីរជាសមុដ្ឋានិករូប គឺ កើតព្រោះកម្ម ចិត្ត ឧតុ អាហារ

ទាំង ៤យ៉ាង ចំណែកជរតា និង អនិច្ចតានោះជា ន កុតោចិ សមុដ្ឋាន គឺមិនមានសមុដ្ឋានឡើយ ព្រោះហេតុដូច្នេះ លក្ខណរូប ៤ ចាំបាច់ត្រូវអធិប្បាយជា ២ ន័យ គឺ តាមន័យនៃព្រះបាលីមួយ តាមន័យនៃអដ្ឋកថាមួយ ។ តាមន័យទី ១ ឧបចយ និង សន្តតិ រាប់ចូលក្នុងចតុសមុដ្ឋានិករូប ហើយត្រូវរាប់កម្មជរូប ២០ ចិត្តជរូប ១៩ ឧតុជរូប ១៥ អាហារ-ជរូប ១៤ ។ ន័យទី ២ តាមអដ្ឋកថា មានន័យថា កម្មជរូប ១៨ ចិត្តជរូប ១៥ ឧតុជរូប ១៣ និង អាហារជរូប ១២ ដូច្នេះ ។

**សួរ** កាលព្រះសាស្តាទ្រង់ទេសនាថា ឧបចយ និង សន្តតិ ជាចតុសមុដ្ឋានិករូប ហេតុដូចម្តេចបច្ចិមសាវក គឺ ព្រះអដ្ឋ-កថាចារ្យ និង ព្រះអនុរុទ្ធាចារ្យ សំដែងថា ន កុតោចិ សមុដ្ឋានទៀត ?

**ឆ្លើយ** ការដែលព្រះសាស្តាទ្រង់ទេសនា ឧបចយ និង សន្តតិ ជាចតុសមុដ្ឋាននិករូបនោះ មានន័យថា ភវបច្ចយា

ជាតិ ជាតិគឺ ឧបចយ និង សន្តតិរមែងកើតព្រោះកម្មភព គឺ កុសល និង អកុសល ។ ព្រោះហេតុដូច្នេះ រូប ក៏ ត្រូវថា កម្មជរូបដែលកើតដោយកម្មហើយត្រូវហៅថា ចិត្តជរូប ឧតុជរូប អាហារជរូប ផង លោកអធិប្បាយថា ចតុសមុ-ដ្ឋានរូប គឺ កើតព្រោះសមុដ្ឋានទាំង ៤ គឺ កម្ម ចិត្ត ឧតុ អាហារ តាមដែលព្រះអដ្ឋកថាចារ្យទាំងឡាយ ដូចជា ព្រះពុទ្ធឃោសាចារ្យ និង ព្រះអនុរុទ្ធាចារ្យជាដើម អធិប្បាយថា ន កុតោចិ សមុដ្ឋាន គឺ មិនមានសមុដ្ឋានណាមួយនោះប្រៀប សេចក្តីថា ធម្មតាអ្នកទិញនំដែលមានរសផ្អែម កាលទទួល ទានហើយ មិនចាំបាច់ត្រូវសងតម្លៃរស់ផ្អែម មានសេចក្តីថា ទិញនំ ក៏រួមទាំងរសផ្អែមផងដែរ ព្រោះហេតុដូច្នេះ ការដែល រាប់កម្មជរូប ១៨ ចិត្តជរូប ១៥ ឧតុជរូប ១៣ អាហារជរូប ១២ ហើយជាតួនាទីរបស់ជាតិ ឬ ន័យម្យ៉ាងទៀតថា ឧបចយ និង សន្តតិ ក៏ចូលរួមក្នុង

កម្មជ្ជ-ឧតុជ្ជ និង អាហារជ្ជរូបស្រេចហើយ តែឧបច្ឆ័យ និង សន្តតិមិនត្រូវចាំ បាច់ត្រូវមានសមុដ្ឋានទៀតទេ ព្រោះមិនមាន ឬ មានក៏ ដោយ ជាតិក៏ត្រូវកើតមកតាមធម្មជាតិរបស់គេប៉ុណ្ណោះ ទោះបីព្រះសាស្តាទ្រង់ទេសនាក្តី ទេសនារបស់ព្រះអង្គត្រឹម តែទេសនាសាមញ្ញ ដូច្នេះទើបសំដែងថា លក្ខណានិ ន ជាយន្តិ កេហិចិតិ បកាសិតំ សេចក្តីថា លក្ខណរូបទាំង ៤ រមែងមិនបានកើតដោយសមុដ្ឋានណាមួយឡើយ ។

**សួរ** ក្នុងធភិធម្មត្ថសង្គហៈ អដ្ឋកថានេះប្រើស័ព្ទ ជួនកាលថា " ហេតុ " ជួនកាលថា " បច្ច័យ " ជួនកាលថា "សមុដ្ឋាន " ។ ចង់ជ្រាបថា ពាក្យដែលពោលមកនេះ មានសេចក្តីផ្សេងគ្នា ឬ មានន័យដូចគ្នា ?

**ឆ្លើយ** ពាក្យថា " ហេតុ " និង " បច្ចយ " នោះបានអធិប្បាយក្នុងភាគ ១ហើយ ។ ចំណែកពាក្យថា "សមុដ្ឋាន" ក្នុងបញ្ហានេះមានអធិប្បាយដូច្នេះ ពាក្យថា សមុដ្ឋានមានវិគ្គហៈ

ថា **សមុដ្ឋហន្តិ ជាយន្តិ ឯតេនាតិ សមុដ្ឋានំ** ប្រែថា - ប្រាកដដោយបច្ច័យ ដូច្នេះពាក្យថា សមុដ្ឋាន បានសេចក្តីថា ធម្មតារូបដែលកើតដោយសារបច្ច័យ ឬ ដោយសង្ខេបៗ គឺ ការតាក់តែង តែពាក្យថាតុបតែង បានដល់សង្ខារទាំងអស់ក្នុងទីនេះ ជ្រើសតែចំពោះរូបដែល ជាសមុដ្ឋានរូបប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ព្រះសាស្តាទ្រង់ សំដែងបច្ច័យ ២៤ ថា ជា បច្ច័យដែលធ្វើឱ្យរូបកើត បច្ច័យដែលធ្វើឱ្យនាមកើត បច្ច័យ ធ្វើឱ្យនាមរូបកើតជា ដើម ។ ក្នុងទីនេះសភាវធម៌ដែលធ្វើ ឱ្យរូបកើតមាន ៤ យ៉ាងគឺ : កម្ម ចិត្ត ឧតុ អាហារ ហៅថារូបសមុដ្ឋាន ឬ បច្ច័យដែលធ្វើឱ្យកើតរូប តែរូបមិន កើតទេ ចូរពិចារណា មើលនាមស័ព្ទដែលជាឈ្មោះ របស់រូប ថាអហេតុកៈ ដែល ប្រែថា មិនមានហេតុ ។ ពាក្យថា ហេតុនេះ បានដល់ហេតុ ទាំង ៦ ដូច្នេះត្រូវពិចារណាថា កើតដោយបច្ច័យ ឬ សំខារ ក៏ហើយគ្នា យ៉ាងណាក្តីតាម វេយ្យាករណ៍របស់ស័ព្ទថា

**ឱចិត្រា កាលទេសតោ សន្ធត្ថា វិគជយន្តិ ន សន្ទោរយេវ គេវលា សេចក្តីថា** : ការប្រែសព្ទមិនអាស្រ័យតែចំពោះកេរ្វលាស័ព្ទទេ សេចក្តីពិតត្រូវប្រែតាមគួរ ឬ មិនគួរ ហើយទៅ តាមកាលៈទេសៈផងមានសេចក្តីថា ការប្រែស័ព្ទត្រូវ ពិចារណាតាមទីកន្លែងមិនប្រែស័ព្ទបានតែចំពោះប៉ុណ្ណោះ ទេ ។

ដោយហេតុដែលពោកមកហើយ ពាក្យថា "ហេតុ បច្ចយ ឬ សមុដ្ឋាន" នោះផ្សេងគ្នា : ហេតុបានដល់ហេតុ ៦ ប្រការ បច្ច័យ និង សមុដ្ឋាន បានដល់បច្ច័យ ២៤ ដូចដែលព្រះសាស្តាទេសនាទុកក្នុងមហាបដ្ឋាន គម្ពីរនោះហើយ

## សំដែងរូបកលាបន័យតាមបាលី

**ឯកុប្បទា ឯកនិរោធា ច ឯកនិស្សយា សហ វុត្តិនោ ឯកវីសតិ រូបកលាបា នាម ។ តត្ថ ជីវិតំ អវិនិព្ភោគរូបញ្ច ចក្ខុនា សហ**

ចក្ខុទសកន្តិ បវុច្ចតិ ។ តថា សោតាទីហិ សទ្ធឹ សោតទសកំ ឃានទសកំ ជិវ្ហាទសកំ

កាយទសកំ ឥត្ថីទសកំ បុមភាវទសកំ វត្ថុទសកញ្ចេតិ យថាក្កមំ យោជេតព្វំ ។

អវិនិព្ភោគរូបមេវ ជីវិតេន សហ ជីវិតនវកន្តិ បវុច្ចតិ ឥមេ នវ កម្មសមុដ្ឋាន-កលាបា ។

អវិនិព្ភោគរូបំ បន សុទ្ធកំ តទេវ កាយវិញ្ញត្តិយា សហ កាយវិញ្ញត្តិនវកំ វចីវិញ្ញត្តិសទ្ទលហុតាទីហិ តេរសកញ្ចេតិ ឥមេ ឆ ចិត្តសមុដ្ឋាន កលាបា ។

សទ្ទកំ សទ្ទនវកំ លហុតាទេកាទសកំ សទ្ទលហុតាទិទ្វាទសកញ្ចេតិ ឥមេ ចត្តារោ ឧតុសមុដ្ឋានកលាបា ។

**សុទ្ធដ្ឋកំ លហុតាទេកាទសកញ្ចេតិ ឥមេ ទ្វេ អាហារសមុដ្ឋានកលាបា ។ តត្ថ សុទ្ធដ្ឋកំ សទ្ទនវកញ្ចេតិ ទ្វេ ឧតុសមុដ្ឋានកលាបា ពហិទ្ធាបិ លព្ភន្តិ ។ អវសេសា បន សព្វេបិ អជ្ឈត្តិកាមេវាតិ ។**

**ប្រែសេចក្ដីថា**

រូបដែលព្រមដោយលក្ខណ ៣ យ៉ាងគឺ ឯកុប្បាទ កើតព្រមគ្នា ឯកនិរោធ រលត់ព្រមគ្នា ឯកនិស្សយដែលអាស្រ័យជាមួយគ្នា សហវុត្តិ កើតរួម ៣ យ៉ាងជាមួយគ្នា ហៅថារូបកលាប ២១ កលាប ។ ក្នុងរូបកលាប ២១ នេះ រួម ១០ រូប ហៅថាចក្ខុសកកលាប ។ ជីវិតរូប ១ អវិនិព្ភោគរូប ៨ ព្រមគ្នានិង សោតបសាទរូបជាដើមហៅតាមលំដាប់ថា **សោតទសកកលាបៈ ឃានទសកកលាបៈ ជិវ្ហាទសកកលាបៈ កាយទសកកលាបៈ ឥត្ថីភាវទសកកលាបៈ**

**បុរិសភាវទសកកលាបៈ និង វត្ថុទសកកលាបៈ**

ដូច្នេះ ។ អវិនិព្ភោគរូប ៨ និង ជីវិតរូបរួម ៩ នេះហៅថា ជីវិត នវកកលាបៈ រួម កលាបៈដែលកើតអំពីកម្មកលាបៈ ៩ កលាបៈ អវិនិព្ភោគរូប ៨ ហៅថា សុទ្ធកលាបៈ ។ សុទ្ធកលាបនេះ ព្រមគ្នានិងកាយវិញ្ញត្តិ ហៅថាកាយវិញ្ញត្តិ-នវកៈ ព្រមគ្នា និងវចីវិញ្ញត្តិរូប សទ្ទរូប ហៅថាវចីវិញ្ញត្តិទសកៈ ព្រមគ្នា និង លហុតាទី ៣ ហៅថាលហុតាទេកាទសកៈ ព្រមគ្នា និង កាយវិញ្ញត្តិលហុតាទិ ហៅថា កាយវិញ្ញត្តិលហុតាទិទ្វាទសកៈ ព្រមគ្នាវចីវិញ្ញត្តិមួយ សទ្ទមួយ លហុទិតា ហៅថា វចីវិញ្ញត្តិ សទ្ទតេរសកៈ រួមកលាបៈទាំង ៦ ដែលពោលមកហើយហៅថា ចិត្តជកលាបៈ សុទ្ធកលាបៈ សទ្ទនវកកលាប លហុតាទេ-កាទសកកលាបៈ សទ្ទលហុតាទិទ្វាទសកកលាបៈ រួម ៤ កលាបៈនេះហៅថា ឧតុជកលាប ។

សុទ្ធកលាបៈ លហុតាទេកាទសកកលាបៈ ទាំងពីរកលាបៈនេះ ហៅថា អាហារជកលាបៈ ។

ក្នុង ២១កលាបៈនេះ សុទ្ធកលាបៈ សទ្ទនវកលាបៈ ទាំងពីររមែងកើតខាងក្រៅក៏បាន ១៩ កលាបៈ នេះរមែងកើតបានខាងក្នុងទាំងអស់ ។

## សំដែងគាថាសង្គហៈ

**កម្មចិត្តោតុកាហារសមុដ្ឋានា យថាក្កមំ**
**នវ ឆ ចតុរោ ទ្វេតិ កលាបា ឯកវីសតិ ។**
**កលាបានំ បរិច្ឆេទលក្ខណត្តា វិចក្ខណា**
**ន កលាបង្គមិច្ចាហុ អាកាសំ លក្ខណានិ ច ។**

**ប្រែសេចក្តីថា**

កម្មសមុដ្ឋានរូប ចិត្តសមុដ្ឋានរូប ឧតុសមុដ្ឋានរូប និង អាហារសមុដ្ឋានរូប រួមរូបទាំង ៤នេះរមែងមាន៩ កលាបៈ ៦ កលាបៈ ៤កលាបៈ ២ កលាបៈ ដោយលំដាប់ ។ អាកាសធាតុ និង លក្ខណរូបទាំង ៤ បណ្ឌិតទាំងឡាយរមែងពោល

ថា មិនមែនក្នុងអង្គកលាបៈទេ ព្រោះរូបទាំង២ ត្រឹមតែចំណែកញែករូបកលាបៈ និង លក្ខណរូបប៉ុណ្ណោះ ។

អយមេត្ថ កលាប យោជនា ដូចដែលពោលមកហើយនេះ ជាការសំដែងរូបកលាបៈក្នុងបរិច្ឆេទប៉ុណ្ណោះ ។

អធិប្បាយកលាបយោជនាន័យ

ពាក្យថាកលាបៈ ប្រែថា ពួក ក្រុម សំណុំ ឬ គណៈក៏បាន ។ សំដែងថារូបដែលកើតព្រោះកម្មជាពួក ១ ព្រោះចិត្តជាពួក ១ ព្រោះឧតុ ជាពួក ១ ព្រោះអាហារជាពួក ១ រួម ៤ ពួកនេះហៅថាកម្មជកលាប ចិត្តជកលាបៈ ឧតុជកលាប អាហារជកលាប ដោយលំដាប់ ។

កលាបដែលពោលមកហើយពីខាងដើម រមែងមានលក្ខណៈ ៤ ប្រការ គឺ ឯកុប្បាទ ជាសភាពកើតព្រមគ្នា ឯកនិរោធរលត់ព្រមគ្នា ឯកនិស្សយ មានទីអាស្រ័យជាមួយគ្នា សហវុត្តិ ជាទីរួមគ្នានៃសភាពទាំង ៣ យ៉ាង ដែលពោលពីខាងដើមនោះ ។ ទាំង ៤ យ៉ាងដែលពោលមកហើយនេះ

ជាលក្ខណៈរបស់កលាបៈ បានដល់កម្មជកលាបៈ ៩ ចិត្តជកលាបៈ ៦ ឧតុជកលាបៈ ៤ និង អាហារជកលាបៈ ២ រួមជា ២១ កលាបៈ ។

### ✲ កម្មជកលាប ៩

១ - អវិនិព្ភោគរូប ៨ + ជីវិតរូប ១ + ចក្ខុបសាទរូប ១+ រួម ១០ ហៅថា ចក្ខុទសកៈ

២ - អវិនិព្ភោគរូប ៨ + ជីវិតរូប ១ + សោតបសាទរូប ១ រួម ១០ ហៅថា សោតទសកៈ

៣ - អវិនិព្ភោគរូប ៨ + ជីវិតរូប ១ + ឃានបសាទរូប ១ រួម ១០ ហៅថា ឃានទសកៈ

៤ - អវិនិព្ភោគរូប ៨ + ជីវិតរូប ១ + ជីវ្ហាបសាទរូប ១ រួម ១០ ហៅថា ជីវ្ហាទសកៈ

៥ - អវិនិព្ភោគរូប ៨ + ជីវិតរូប ១ + កាយបសាទរូប ១ រួម ១០ ហៅថា កាយទសកៈ

៦ - អវិនិព្ភោគរូប ៨ + ជីវិតរូប ១ + ឥត្ថីភាវរូប ១ រួម ១០ ហៅថា ឥត្ថីភាវទសកៈ

៧ - អវិនិព្ភោគរូប ៨ + ជីវិតរូប ១ + បុរិសភាវរូប ១ រួម ១០ ហៅថា បុរិសភាវទសកៈ

៨ - អវិនិព្ភោគរូប ៨ + ជីវិតរូប ១ + ហទយវត្ថុរូប ១ រួម ១០ ហៅថា វត្ថុទសកៈ

៩ - អវិនិព្ភោគរូប ៨ និង ជីវិតរូប ១ រួម ៩រូបនេះ ហៅថា ជីវិតនវកលាបៈ

រួមកម្មជកលាប ៩ កលាប

## ❋ ចិត្តជកលាប ៦

១ - អវិនិព្ភោគរូប ៨ ហៅថា សុទ្ធកលាបៈ

២ - អវិនិព្ភោគរូប ៨ + កាយវិញ្ញត្តិរូប ១ រួម ៩រូប ហៅថា កាយវិញ្ញត្តិ នវកៈ

៣ - អវិនិព្ភោគរូប ៨ + វចីវិញ្ញត្តិរូប ១ + សទ្ទរូប រួម ១០ រូប ហៅថា វចីវិញ្ញត្តទសកៈ

៤ - អវិនិព្ភោគរូប ៨ + លហុតាទិរូប ៣ + រួម ១១រូប ហៅថាលហុតាទេកាទសកៈ

៥ - អវិនិព្ភោគរូប ៨ + កាយវិញ្ញត្តិរូប ១ លហុតាទិរូប ៣រួម ១២ រូប ហៅថា កាយវិញ្ញត្តិលហុតាទិទ្វាទសកៈ

៦- អវិនិព្ភោគរូប ៨ + វចីវិញ្ញត្តិរូប ១ សទ្ទរូប ១ លហុតាទិរូប៣ រួម ១៣រូប ហៅថា វចីវិញ្ញត្តិសទ្ទលហុតាទិហិតេរសកៈ ។

រួមចិត្តជកលាប ៦ កលាបៈ

## ✲ ឧតុជកលាប ៤

១ - អវិនិព្ភោគរូប ៨ ហៅថា សុទ្ធកលាបៈ

២ - អវិនិព្ភោគរូប ៨ + សទ្ទរូប ១ រួម ៩ រូបហៅថា សទ្ទនវកកលាបៈ

៣ - អវិនិព្ភោគរូប ៨ + លហុតាទិរូប ៣ រួម ១១រូប ហៅថាលហុតាទេកាទសកៈ

៤ -  អវិនិព្ភោគរូប ៨ + សទ្ទរូប ១ + លហុតាទិរូប ៣ រួម ១២ រូប ហៅថា សទ្ទលហុតាទិទ្វាទសកៈ ។

រួមឧតុជកលាបៈ ៤

## ✵ អាហារជកលាបៈ ២

១ -  អវិនិព្ភោគរូប ៨ ហៅថា សុទ្ធកលាបៈ

២-  អវិនិព្ភោគរូប ៨ + លហុតាទិ ៣ ហៅថា លហុតាទេកាទសកៈ រួម អាហារជកលាបៈ ២

រួមចំនួន ២១ កលាបនេះ ឧតុជកលាបៈទី ១ និង កលាបៈទី ២ គឺ សុទ្ធកលាបៈ និង សទ្ទនវកលាបៈ រមែង កើតខាងក្នុងទាំងអស់ ។

# អធិប្បាយគាថាសង្ខេបៈ

កម្មជកលាបៈ គឺ រូបកលាបៈដែលកើតមកដោយចិត្ត ដោយកម្មមាន ៩ ពួក ។ ចិត្តជកលាប គឺ រូបកលាបៈដែល កើតមកដោយចិត្តមាន ៦ពួក។ ឧតុជកលាបៈគឺរូបកលាបៈ ដែលកើតមកដោយអាហារ មាន ២ ពួក រួម ២១ ពួក ជា

មួយគ្នាតាមលំដាប់ ។ ក្នុងការដែលរូប ២១ កលាបៈ រាប់ចូល ៤ ពួកនេះ អាកាសរូប និង លក្ខណរូប ៤ រួម ៥ រូប មិនបានរាប់ចូលជាមួយគ្នាទេ ព្រោះអាហាររូប ត្រឹមតែរូបដែលកើតមកអំពី ការរំញោករូប ២៨ ។ ចំណែកលក្ខណរូប ៤ ជារូបដែលបំណងយកអាហាររបស់រូបប៉ុណ្ណោះ ។

## ពាក្យសួរ-ឆ្លើយក្នុងរូបកលាបន័យ

**សួរ** ពាក្យថាកលាបៈប្រែថាយ៉ាងណា ? ប្រែថាអ្វី ? ហើយមានន័យយ៉ាងណា ? បានដល់អ្វីខ្លះ ?

**ឆ្លើយ** ពាក្យថាកលាប តាមពាក្យវិគ្គហៈថា កលាបិយន្តិ សមូហវសេន សង្ខយាបិ យន្តិ ។

ក្នុងសភាពនេះ រមែងរាប់ជាពួក ឬ ក្រុមជាគណៈក៏បាន ព្រោះហេតុដូច្នោះ ហៅថាកលាបៈ បានដល់រូប ៤ ពួកគឺ កម្មជកលាបៈ ៩ ចិត្តជកលាបៈ ៦ ឧតុជកលាបៈ ៤ អាហារជកលាបៈ ២ រួម ២១ កលាបៈ ឬ ២១ ពួក

**សួរ** ក្នុងចេតសិកបរិច្ឆេទ សំដែងសេចក្តីកើតរបស់ចិត្ត និង ចេតសិកថា មានលក្ខណ ៤ យ៉ាងគឺ ក្នុងរូបបរិច្ឆេទក៏សំដែងថាមាន ៤ យ៉ាង ។ ទាំង ២ បរិច្ឆេទនេះ ជិតជិតគ្នាណាស់ ចង់ជ្រាបថាលក្ខណៈនៃធម៌ទាំង ២ ផ្សេងគ្នាយ៉ាងណា ? សុំអធិប្បាយផង ។

**ឆ្លើយ** តាមលក្ខណៈរបស់ចេតសិក លោកសំដែងថា មាន៤ លក្ខណៈគឺ ឯកុប្បាទ ប្រែថា ចេតសិកមានឧប្បាទគឺ កើតព្រម១គ្នាជាមួយចិត្ត ។ ឯកនិរោធ ប្រែថា មានភង្គៈគឺរលត់ព្រមជាមួយនិង ចិត្ត ។ ឯកលម្ពន មានអារម្មណ៍ជាមួយគ្នានិង ចិត្ត មានន័យថា អារម្មណ៍របស់ចិត្ត ជាអារម្មណ៍របស់ចេតសិក ។ ឯកវត្ថុកៈ មានទីអាស្រ័យជាមួយនិងចិត្ត គឺចិត្តអាស្រ័យ ហទយវត្ថុ ចេតសិកក៏អាស្រ័យទីនោះដែរ ។ រូម ៤ ប្រការដែលអធិប្បាយមកហើយនោះ ជាលក្ខណៈរបស់ចិត្ត ។

ចំណែករូបកលាបៈនោះ ឯកុប្បាទៈប្រែថា កើតព្រមៗគ្នា គឺ មហាភូតរូប ៤ កើតហើយ ឧបាទាយរូប ២៤ ក៏កើតព្រមគ្នា ។ ឯកនិរោធ រលត់ក៏ព្រមគ្នា គឺមហាភូតរូបរលត់ រូបដទៃៗក៏រលត់ដែរ ។ ឯកនិស្សយៈ ជាទីអាស្រ័យជាមួយគ្នា គឺ អាស្រ័យមហាភូតរូប ៤ ប៉ុណ្ណោះ ។ សហវុត្តិរួម អាការទាំង ៣ យ៉ាងគឺ **ឯកុប្បាទ ឯកនិរោធ ឯកនិស្សយៈ** ចូលជាមួយគ្នារួម ៤ យ៉ាងនេះហៅថា លក្ខណរូបកលាប គប្បីជ្រាបដោយសង្ខេប ដូច្នេះលក្ខណៈរបស់ចេតសិក

១- ឯកុប្បាទ កើតព្រមគ្នា

២- ឯកនិរោធ រលត់ព្រមគ្នា

៣- ឯកាលម្ពន អារម្មណ៍ជាមួយគ្នា

៤- ឯកវត្ថុកៈ វត្ថុជាមួយគ្នា

រួមលក្ខណរបស់ចេតសិក

១- ឯកុប្បាទ កើតព្រមគ្នា

២- ឯកនិរោធ    រលត់ព្រមគ្នា

៣- ឯកនិស្សយៈ    ទីអាស្រ័យជាមួយគ្នា

៤- សហវុត្តិ

រួមលក្ខណៈរបស់រូបកលាបៈ

អធិប្បាយថា ចិត្ត និង ចេតសិក ជានាមធម៌ដូចគ្នា កាលវេលាកើត ក៏កើតជាមួយគ្នា ហើយរលត់ក៏រលត់ជាមួយគ្នា ជាអារម្មណ៍ជាមួយគ្នា និង វត្ថុជាមួយគ្នា ។ ចំណែករូបកលាបៈនោះ ការកើត ការរលត់ ជិតៗគ្នា និង ជាមួយចិត្ត -ចេតសិក តែយឺតច្រើនជាងចិត្ត ចិត្តរហ័សច្រើនដង ជាងអារម្មណ៍របស់រូប រមែងមិនមាន គឺ ពាក្យថា អារម្មណ៍នោះ រូបនោះឯង ជាអារម្មណ៍មាននៅ ហើយការប្រាកដ និង អាស្រ័យនោះ ផ្សេងគ្នានិងចិត្ត ព្រោះអាស្រ័យហទយវត្ថុរូប ។ ចំណែករូបនោះអាស្រ័យគ្នា និង គ្នា គឺ រូបតរូប ព្រោះហេតុដូច្នោះ សូម្បីចំនួនលក្ខណៈ ៤ យ៉ាង

ប្រហែលគ្នាក្តី និង សភាវៈគឺ អាការ ម្នាក់ម្យ៉ាង ដូចដែល បានអធិប្បាយមកហើយ ។

**សួរ** ក្នុងរូបកលាបៈ២១ ពាក្យថា កម្មជូលាបៈ ប្រែថារូប ១ ជំពូក ដែលកើតរូបកលាបៈបានដល់កម្មអ្វី ? ហើយចំនួន រូបដែលកើតមកព្រោះកម្មមានប៉ុន្មានប្រាកដ ?

**ឆ្លើយ** កម្មដែលធ្វើឱ្យកើតរូបកលាបៈ មាន ២៥ដួងគឺ : ចេតនាដែលកើតព្រមនិង កុសលចិត្ត ១៣ ដួង បានដល់ មហាកុសលចិត្ត ៨ដួង រូបាវចរកុសលចិត្ត៥ រួម ១៣ដួង និង ចេតនាដែលកើតព្រមជាមួយ និង អកុសលចិត្ត ១២ ដួង រួមចេតនារបស់កុសល និង អកុសល ២៥ ដួង ។ ២៥ដួងនេះ ហៅថាកម្ម ដែលធ្វើឱ្យកើតរូបកលាបៈ ( មេត្តា មើលរូបសមុដ្ឋានន័យក្នុងបរិច្ឆេទនេះ ) ។ ក្នុងមហាបដ្ឋាន កម្មប្បច្ច័យ ពោលទុកថា **កុសលាកុសលំ កម្មំ វិបាកានំ ខន្ធានំ កដត្តា ច រូបានំ កម្មបច្ចយេន បច្ចយោ ប្រែសេចក្តីថា** កុសល និង

អកុសលកម្មធ្វើឱ្យវិបាកបដិសន្ធិ (ខ័ន្ធ) និង រូបកើតដោយ អាស្រ័យកម្មប្បច្ច័យ ដូច្នេះ អធិប្បាយថាក្នុងរូប ២៨ នេះ រូបមួយជំពូកដែលកើតមកព្រោះកុសល និង អកុសលកម្ម នោះ ព្រះពុទ្ធអង្គចាត់ទុកថាមាន ១៨ រូប មេត្តាត្រួតមើល ក្នុងរូបសមុដ្ឋាននន័យ ក្នុងបរិច្ឆេទនេះ ។ បើនឹងថាជាពូក១ មាន ៩ ពូក ឬ ៩ កលាបៈ នេះរមែងកើតមកព្រោះកម្ម ឬ ចេតនា ដូចដែលបានពោលមកហើយ នៅសល់រូបដ៏ទៃ១ ទៀត រមែងកើតមកព្រោះចិត្តខ្លះ ឧតុខ្លះ អាហារខ្លះ ព្រោះ ហេតុដូច្នោះ កម្ម ចិត្ត ឧតុ អាហារ ៤ យ៉ាង នេះហៅថា សមុដ្ឋាន ឬ បច្ច័យក៏បាន តែថាបច្ច័យនោះរាប់យកបច្ច័យ ចាស់ប៉ុណ្ណោះ ។

**ស្លូវ** ក្នុងចតុសមុដ្ឋានិករូបកលាបៈទាំងអស់នោះ ធាតុ ទាំង ៤ គឺបឋវី អាបោ តេជោ វាយោប្រាកដនៅជានិច្ច ។

ពាក្យថាធាតុទាំង ៤ ពិចារណាមើលក៏ពេញទៅ ដោយទូទៅពិភពលោក ហេតុនេះ ទើបព្រះអនុរុទ្ធាចារ្យ

អធិប្បាយថា កើតមកដោយកម្ម និង ចិត្តទៀត ។ កើតមកដោយឧតុនិយាមមិនបានឬ ?

**ឆ្លើយ** បឋវី អាបោ តេជោ វាយោ រូបមហាទាំង ៤ ក៏ប្រាកដក្នុងសកលលោកនេះ អធិប្បាយថា រមែងកើតដោយសមុដ្ឋានគឺ ធាតុខ្លះ កើតព្រោះកម្មខ្លះ ធាតុខ្លះកើតព្រោះចិត្ត ធាតុខ្លះ កើតព្រោះឧតុ ធាតុខ្លះកើតព្រោះអាហារ ដូច្នេះ ទើបលោកហៅថា ចតុសមុដ្ឋានិករូប ។ អធិប្បាយតទៅទៀតថា ធម្មតាធាតុទាំង ៤ រមែងកើត ២ យ៉ាងគឺ អជ្ឈត្តិកធាតុខាងក្នុង និង ពហិទ្ធធាតុខាងក្រៅ ។ ធាតុខាងក្រៅរមែងកើតព្រោះ ឧតុនិយាម នេះជាពាក្យសំដីដែលសមរម្យ និង បញ្ជាក់តែម្តង ។ ចំណែកធាតុដែលកើតខាងក្នុងរបស់មនុស្សនោះ និង ថាកើតពីឧតុ ហាក់ដូចជាយ៉ាងណា ព្រោះធម្មតាមនុស្សកើតមកព្រោះកម្មជាធំ ដូចព្រះបាលីក្នុងអង្គុត្តរនិកាយថា **កម្មុនា វត្តតិ លោកោ កម្មុនា វត្តតិ បជា ប្រែថា** លោករមែង

កើតមកព្រោះកម្ម សត្វទាំងឡាយរមែងកើតព្រោះកម្ម ដូច្នេះ ។

លោកទាំងអស់មានជីវិតក្តី មិនមានជីវិតក្តី ក៏ព្រះសាស្តាទ្រង់ទេសនាថា កើតមកព្រោះកម្មទាំងអស់ ។ ពាក្យថាលោក ក្នុងទីនោះរួមធាតុទាំង ៤ ចូលផង ព្រោះហេតុដូច្នេះ ធាតុទាំង ៤ ទើបត្រូវជាកម្មសមុដ្ឋានផង ធាតុទាំង ៤ ដែលកើតមកដោយចិត្ត សមុដ្ឋាននោះ តាមបាលីសុត្តនិបាតថា

**ចិត្តេន នីយតិ លោកោ ចិត្តេន បរិកស្សតិ ចិត្តស្ស ឯកធម្មស្ស សព្វេវ វសមន្វគូ**

**ប្រែសេចក្តីថា**

លោកកើតព្រោះចិត្ត គិតការងារផ្សេងៗក៏ព្រោះចិត្ត សត្វលោកទាំងអស់រមែង ប្រព្រឹត្តទៅតាមអំណាចចិត្ត ដូច្នេះ។ ពាក្យថាលោក សំដែងក្នុងនេះ រួមធាតុទាំង ៤ ចូលផង ព្រោះហេតុដូច្នោះ ធាតុទាំង ៤ ខាងក្រៅ ឬ ខាងក្នុងក៏

រមែងកើតព្រោះកម្មក៏មាន ព្រោះចិត្តក៏មាន ។ ទើបព្រះអនុរុទ្ធាចារ្យអធិប្បាយថា **អនិប្ផន្នរូបានិ ចេវ អាកាសធាតុ ច ចត្តារិ សង្ខតានិ** ប្រែថា អវិនិព្ភោគរូប ៨ គឺ បឋវី អាបោ តេជោ វាយោ វណ្ណៈ គន្ធៈ រសៈ ឱជា និង អាហារធាតុ រមែងកើតព្រោះកម្ម ចិត្ត ឧតុ អាហារ រួម ៤ យ៉ាង ។ ហេតុផ្សេងៗដែលសំដែងមកនេះ បង្ហាញឱ្យឃើញថាខាងក្រៅ ឬ ខាងក្នុង ទូទាំងពិភពលោក រមែងកើតព្រោះកម្មក៏មាន ( ព្រោះ ) ចិត្តក៏មាន ។ តាមព្រះពុទ្ធភាសិតជាភស្តុតាង ដូចដែលសំដែងមកហើយ ។

**សួរ** រូបមានចំនួន ២៨ កាលព្រះអនុរុទ្ធាចារ្យ សំដែងកលាបៈនោះ មិនឃើញមានអាកាសរូប និង លក្ខណរូប ៤ គង់មានសេចក្តីថា រូបទាំង ៥នេះមិនមែនរូបកលាបៈ កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបលោកមិនចាត់ចូលក្នុងរូបកលាបៈ ?

**ឆ្លើយ** ការដែលព្រះអនុរុទ្ធាចារ្យ មិនចាត់អាកាសរូប និង លក្ខណរូប ៤ ចូលក្នុងកលាបៈនោះ ព្រោះអាកាសរូបមិនដូចរូបធម្មតា ឬ មានលក្ខណៈដោយឡែក គឺ ពាក្យថា អាកាស នេះបានដល់បរិច្ឆេទ ឬ អាកាសរូប ន័យម្យ៉ាងទៀតដែល យើងហៅថា ចន្លោះទំនេរនោះឯង ។ សំដៅយកចន្លោះទទេក្នុងរវាងរូបទាំង ២ ព្រោះហេតុដូច្នេះ អាការរបស់រូប ឬ លក្ខណៈរបស់រូប មិនប្រាកដច្បាស់លាស់ឡើយ ដូច្នេះ ទើបមិនរាប់កលាបៈ ។ ចំណែកលក្ខណរូបទាំង ៤ នោះ ឧបច្ច័យ និង សន្តតិ ជាឈ្មោះរបស់ជាតិ ប្រែថាសេចក្តីកើត របស់រូប ធម្មតារូបត្រូវកើតជានិច្ច ការកើតហើយក៏ត្រូវចំរើនវ័យឡើង ការកើតនិង ការចំរើនមិនមែនលក្ខណៈរបស់រូប ។ ព្រោះគ្រប់ៗរូបត្រូវកើតជាប្រាកដ ដូច្នេះ ជាតិរូប ជាឈ្មោះរបស់រូបទាំងអស់ គ្មានជារូបណាមួយទេ. ជរតា អនិច្ចតា ក៏ទំនងដូចគ្នា គឺកើតមកហើយត្រូវបែកធ្លាយ រលត់ជាធម្មតាទើបជាឈ្មោះ សាធារណៈដល់រូប

ទាំងអស់ ។ ព្រោះហេតុដូច្នេះ ទើបព្រះអនុរុទ្ធាចារ្យ អធិប្បាយទុកថា កលាបនំ បរិច្ឆេទលក្ខណត្តា វិចក្ខណា ន កលាបង្គមិច្ចាហុ អាកាសំ លក្ខណានិ ច ប្រែថា អាកាសរូប ១ និង លក្ខណរូប ៤ អ្នកប្រាជ្ញរមែងពោលថា មិនមែនអង្គ របស់រូបកលាប ព្រោះអាកាស ការវៀងរូប និង លក្ខណរូប ៤ ជាគ្រឿងសំគាល់នៃរូបទាំងអស់ប៉ុណ្ណោះ ។

**សួរ** ភ្នំ ព្រៃឈើ ដើមឈើជាដើម ហៅថា អវិញ្ញាណក-វត្ថុរូប ។ ក្នុងទីនេះបើនិយាយជាកលាបៈនោះ បានដល់រូប កលាបៈប៉ុន្មានប្រាកដ ?

**ឆ្លើយ** ភ្នំ ព្រៃឈើ ដើមឈើជាដើម វត្ថុដែលមិនមាន វិញ្ញាណ លោកពោលថាសុទ្ធកលាបៈ គឺ អវិនិព្ភោគរូប ៨នេះឯង រូបទាំងអស់នេះហៅថា ពហិទ្ធរូប មេត្តាត្រូវ ពិនិត្យមើលក្នុងកលាបយោជនាន័យថា តត្ថ សុទ្ធកំ សទ្ទនវកញ្ចេតិ ទ្វេ ឧតុ សមុដ្ឋានកលាបា ពហិទ្ធាបិ លព្ភន្តិ ។

**ប្រែថា** - សុទ្ធកលាបៈ និងសទ្ទខាងក្រៅ កលាបៈទាំងពីរ

រមែងកើតខាងក្នុង-ក្រៅផង ព្រោះហេតុដូច្នោះ ភ្នំ ព្រៃឈើ ដើមឈើ ជាដើមនេះរមែងកើតអំពីអវិនិព្ភោគរូប ៨ ដែលជាសុទ្ធកលាបៈតែមួយប៉ុណ្ណោះ ។

**សួរ** ពាក្យថាសុទ្ធនវកលាប ប្រែថា ជារូបមួយពួកដែល ព្រមដោយសទ្ទ គឺ សំឡេងនេះមានន័យថាយ៉ាងណា ? សុំ អធិប្បាយព្រមដោយលើកឧទាហរណ៍ដែលគួរជឿ ?

**ឆ្លើយ** ពាក្យថា សទ្ទនវកៈ ពួក ឬ ក្រុមទី ៩របស់រូប ព្រម និងសទ្ទៈនោះ អធិប្បាយថា វត្ថុណាមួយដែលមានសំឡេង ដូចជាដើមឈើមានសំឡេងចេញមក ព្រមជាមួយខ្យល់បក់ នោះ ។ ការសំដែងមកនេះហៅថា សទ្ទរូបៗនេះរមែងកើត មកអំពីវត្ថុ ដែលបរិបូណ៌ដោយអវិនិព្ភោគរូប ៨ ។ រួម អវិនិព្ភោគរូប ៨ និង សទ្ទរូប រួមជា៩ពួក ហៅថា សទ្ទនវ-កលាបៈ(មេត្តាមើលឧតុជរូបកលាបៈ ៤) ឧតុជរូបកលាបៈ ២ គឺ : សុទ្ធកលាបៈ និង សទ្ទនវកកលាបៈ រមែងកើតខាងក្រៅ ក៏បាន ព្រោះហេតុដូច្នេះ កាលដែល

ខ្យល់បក់ស្លឹកឈើ វិនិច្ឆ័យថា ខ្យល់ក៏កើតមកពីឧតុខាង - ក្រៅស្លឹកឈើក៏ជា សុទ្ធកលាបខាងក្រៅ សំឡេងជាសទ្ទរូប រួមទាំង ៣ មាន ចំនួនរូប ១០រូប ប៉ុណ្ណោះ តែរាប់ជាកលាបៈនោះហៅថា សទ្ទនវកកលាបៈ ។

**សួរ** វត្ថុណាមួយដែលត្រូវបុគ្គលកវាយដំ មានសំឡេងចេញមកនោះ ចាត់ជារូបបានប៉ុន្មាន ចូរឆ្លើយដោយហេតុផលដែលគួរឱ្យជឿបាន ?

**ឆ្លើយ** តាមដែលបុរាណាចារ្យពោលទុកថា វត្ថុណាមួយដែលវាយដំដោយឈើ ចាត់ជារូបកលាបៈបាន ១០០ រូប ។ តាមបរមត្ថន័យ វិធីតាមបរមត្ថន័យដែលរាប់បាន ១០០រូបនោះគឺ - វត្ថុដែលប្រើវាយ គឺ ឈើនោះ របស់រមែងមានសុទ្ធកលាបៈ ១ ឬចំនួនអវិនិព្ភោគ រូប ៨ ។ វត្ថុដែលវាយនោះ ក៏ចាត់ជារូប ៨ រូប តាមទំនងដូចគ្នារួម ២ យ៉ាងជា ១៦ រូប សំឡេងដែលឮចេញមកជាសទ្ទរូប ។ សទ្ទរូប១ទៀតរួមជា ១៧ ក្នុង ១៧ រូបនេះរមែងមានអាកាសរូប

កើត ១៥ ព្រោះក្នុងវាំងរូប ២ យ៉ាងរាប់អាកាសរូប ១ តាមដែលសំដែងមកហើយ ក្នុងរូបសមុទ្ទេសន័យដូច្នេះ ១៧ + ១៥ ទើបបាន ៣២រូប ៣២រូបនេះគុណ នឹង វិការ-រូប ៣បាន ៩៦រូប បូកនិងលក្ខណរូប ៤ បានចំនួន ១០០ រូប ។

ន័យម្យ៉ាងទៀត តាមវិធីរបស់អាចារ្យជនជាតិភូមាថា ចំនួនរូបក្នុងវត្ថុដែលត្រូវវាយ ឬ គោះ រាប់បាន ៨ រូប ឈើដែលវាយនោះក៏ ៨ រូប ។ សំឡេងដែលចេញមក ៩ រូប ។ រួមចូល ( ៨ + ៨ + ៩ = ២៥ ) ជារូប ២៥ គុណ នឹង លក្ខណរូប ៤ បានរូប ១០០ ដោយបរិបូណ៌ ។

**ស្នូវ** អាហារជ្ជកលាប គឺ សុទ្ធកលាប១ លហុតាទេកាទ-សកៈ១ រួម២ កលាប ។ ក្នុងទីនេះពាក្យថា អាហារផ្សេងៗ ដែលសត្វបរិភោគនៅរាល់ថ្ងៃនេះ និង អាហារទាំងអស់នេះ រមែងថាជាពហិទ្ធៈ គឺ ខាងក្រៅ ។ ការបរិភោគចូលទៅ ទះធ្វើឱ្យអាហារជ្ជរូបកលាបៈ២ យ៉ាងបាននិង រូបបែបណា

ចាត់ជាអាហាររដ្ឋរូបបាន ?

**ឆ្លើយ** ពាក្យថាអាហារ ប្រែត្រង់ៗ បានដល់ឱជារូបនោះឯង រមែងប្រាកដនៅក្នុងអវិញ្ញាណកៈថា គឺ របស់របរផ្សេងៗដែលមិនមានជីវិត និង សវិញ្ញាណកវត្ថុ គឺ សត្វផ្សេងៗដែលមានជីវិតទូទាំងសកលលោក មានន័យថាអវិនិព្ភោគរូប ៨ កើតត្រង់ ឱជារូប ឬ ឱជារូបរួមនៅក្នុងអវិនិព្ភោគរូប ៨ គ្រប់កន្លែង ។ កាលបើដូច្នេះអាហារក៏មានគ្រប់ៗកន្លែង ឬ រាល់ៗវត្ថុគ្រប់បែបយ៉ាងទូទាំងសកលលោក ព្រោះហេតុដូច្នោះ អាហារ ឬ ឱជារូបចាំបាច់ចែកជា ២ គឺ អជ្ឈត្តិកឱជា ឱជាខាងក្នុង និងពាហិទ្ធឱជា ឱជាខាងក្រៅ ។ ឱជា ខាងក្នុង បានដល់ឱជារូបក្នុងរាងកាយរបស់មនុស្ស និង សត្វ ។ ឱជាខាងក្រៅ បានដល់ឱជារូបរបស់វត្ថុផ្សេងៗដែល ប្រាកដនៅខាងក្រៅ ។ កាលបរិភោគអាហារ ឱជានៃអាហារដែលបរិភោគ រមែងហូរចូលទៅកាន់ឱជារបស់រាងកាយ រួមឱជាជាមួយគ្នាទៅ

ត្រង់នេះឯង ដែលឱជាធ្វើឱ្យ កើតកលាបៈទាំង ២ តែអ្នកបរិភោគដែលដឹង ជារូបស្ស លហុតា មុទុតា និង កម្មញ្ញតាដែលជាអាហារជរូប កលាបៈ ដែលទាក់ទងមកអំពីអាហារ ព្រោះហេតុដូច្នោះ ឱជាខាង ក្រៅធ្វើឱ្យ អាហារជរូប កើតបានដោយប្រការដូច្នេះ ។ ក្នុងអដ្ឋកថាមជ្ឈិមនិកាយថា **ភពឡិន្ខាវោ អាហារោ តាវ មុខេ ថបិតមត្តោ ឯវ អដ្ឋ រូបានិ សមុដ្ឋាបេតិ ប្រែថា** អាហារដែលបរិភោគព្រមគ្នាចូល ទៅក្នុងមាត់ រមែងញ៉ាំង អវិនិព្ភោគរូប ៨ ឱ្យកើតមួយ រំពេច ។

មហាដីកាថា ពហិទ្ធឱជាគ្មានធ្វើឱ្យកើតរូប ដោយត្រង់ទេ ពហិទ្ធឱជា ត្រឹមតែជួយឧបត្ថម្ភ អជ្ឈត្តិកឱជាប៉ុណ្ណោះ ។ សេចក្ដីពិតអជ្ឈត្តិកឱជាធ្វើឱ្យអាហារជកលាបៈកើតឡើង តែយ៉ាងណាក៏ដោយ តាមដែលមនុស្សលោកឃើញបានដោយភ្នែកនោះ ពហិទ្ធឱជា ធ្វើឱ្យមនុស្សឈឺចាប់ខុសអាហារ នឹងអ្នកដែលមិនមានកម្លាំង ។ កាលបាន

បរិភោគអាហារចូលហើយ រមែងមានកម្លាំងឡើង ព្រោះអាស្រ័យថ្នាំតែមួយមុខ រោគក៏បានជាមួយរំពេចនេះប្រាកដដល់ភ្នែកគ្រប់ៗគ្នាហើយ ព្រោះហេតុដូច្នោះ ពហិទ្ធឱជារូបធ្វើឱ្យអាហារជរូប កើតឡើងពិតប្រាកដ ។ ម្យ៉ាងវិញទៀតក្នុងគម្ពីរវិសុទ្ធិមគ្គ អដ្ឋកថា អធិប្បាយថា **សរីរេ មក្ខិតាហារោបិ រូបំ សមុដ្ឋាបេតិ** **ប្រែថា** អាហារដែលធ្វើទុក្ខ រាងកាយ ធ្វើឱ្យអាហារជរូបកើតបានដូច្នេះ ។ ព្រោះហេតុដូច្នោះ ការពិចារណាតាមមតិមហាដីកា ផ្ទុយគ្នានឹងអដ្ឋកថា និង សេចក្តីច្បាស់ដល់ភ្នែករបស់មនុស្សលោកទើបពោលថា ប្រាសចាកសេចក្តីពិតតែម្តង ។

ដោយន័យដែលពោលមកហើយ ត្រូវវិនិច្ឆ័យថា កាលដែលអាហារជរូបកើតនោះ មិនចំពោះតែឱជាខាងក្នុងទេ សេចក្តីពិត ឱជាខាងក្រៅ ក៏ធ្វើឱ្យអាហារជរូបកើតបានដែរ ដោយអាស្រ័យភស្តុតាង តាមមតិរបស់លោកអដ្ឋកថា ព្រមជាមួយ និងសេចក្តីជាក់ច្បាស់ដល់ភ្នែក របស់មនុស្ស

ទូទៅ ។

**ស្ទូវ** ក្នុងព្រះអភិធម្មត្ថសង្គហៈនេះ ព្រះអនុរុទ្ធាចារ្យ សំដែងថា លហុតាទិត្តយំ ឧតុចិត្តាហារេហិ សម្ភោតិ ប្រែថា អាហារស្រាលរបស់រូប សេចក្តីទន់របស់រូប សេចក្តីគួររបស់រូប ទាំង ៣ យ៉ាងនេះរមែងកើតព្រោះឧតុ ចិត្ត និង អាហារ មានន័យថា ការមានអនាម័យរមែងកើតដោយចិត្ត អាកាស អាហារ ឬ កាលចិត្តល្អ អាកាសល្អ និង អនាម័យល្អនេះ រមែងជាអនាម័យដល់រាងកាយ តែសុភសូត្រ ព្រះបាលីថា អប្បាពធសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ អវិហឹសា ប្រែថា សុភមាណព មិនបៀតបៀនអ្នកដទៃជាបដិបទាដែលល្អ ធ្វើឱ្យមានអនាម័យល្អដូច្នេះ កាលព្រះសាស្តាទ្រង់សំដែងដូច្នេះ សមគួរដល់ព្រះអនុរុទ្ធាចារ្យ ចែកថា ការមានអនាម័យល្អ ឬ តាមអភិធម្មថា វិការៈទាំង ៣ រមែងកើតព្រោះកម្ម ។ ហេតុអ្វី ទើបព្រះអនុរុទ្ធាចារ្យ សំដែងផ្ទុយគ្នានឹង ព្រះសាស្តា ?

**ឆ្លើយ** គ្មានដូច្នោះទេ ការដែលព្រះអនុរុទ្ធាចារ្យពោលថា ការមានអនាម័យ រមែងកើតមកដោយសមុដ្ឋាន ៣ ព្រោះលោកដឹងច្បាស់ថា ការមានអនាម័យគឺអ្វី ? ពាក្យថាអនា - ម័យ ឬ លហុតា មុទុតា កម្មញ្ញតា រួមទាំង ៣ នេះ កាលធាតុផ្សេងៗ ស្មើគ្នាល្អហើយ ការឈឺចាប់ក៏មិនសូវមាន ឬ មិនមានឡើយក៏បាន ។ កាលដែលឈឺចាប់ មិនមាននោះឯង ហៅថា អនាម័យ តែសមុដ្ឋានរបស់អនាម័យត្រូវមានទៀតដោយឡែកអាស្រ័យ សមុដ្ឋាននោះឯង ធាតុ ឬ មហាភូតរូបក្តី ដើរស្មើគ្នារហូតទៅ សមុដ្ឋាន គឺចិត្ត ឧតុ អាហារ រួម ៣ សមុដ្ឋាន ។ អ្នកដែលមានចិត្តល្អ អាកាសល្អ និង អាហារល្អនេះ អនាម័យក៏ល្អឡើង ការអនាម័យល្អដូច្នោះ នេះលោកថា កើតមកដោយសមុដ្ឋាន ៣ នោះឯង ។ ចំណែកការសំដែងរបស់ព្រះសាស្តា ក្នុងព្រះសុភសូត្រនោះ មានន័យថា អ្នកបរិបូណ៌ដោយកម្មដ៏ល្អហើយ កម្មជរូបដែលល្អក៏រមែងប្រាកដ ដូចភ្នែកល្អ ត្រចៀកល្អជាដើម និង

រាងកាយក៏សំបូណ៌គ្រប់បែបយ៉ាង មានន័យថា អនាម័យល្អមកពីបដិសន្ធិកាលហើយ ដូចជា **មហាពាក្កុលថេរ** ជាដើម ។ ព្រះថេរអង្គនេះ មានអាយុ ១៦០ឆ្នាំ ទើបរលត់ខន្ធទៅ ក្នុងរយៈ ១៦០ឆ្នាំនោះ លោកមិនមានឈឺចាប់អ្វីឡើយ ព្រោះហេតុដូច្នោះ មិនចាំបាច់អធិប្បាយ លហុតារូប មុទុតារូប និង កម្មញ្ញតារូបឱ្យដោយឡែកទេ មានន័យថា ចិត្តល្អ ឬ មិនល្អក៏ដោយ អានាម័យរបស់អ្នកមានបុណ្យរមែងកើតមកអំពីបុណ្យ ព្រោះព្រះសាស្តា ព្រះអង្គមិនមានបំណងដល់សមុដ្ឋានឡើយ ។

ការដែលព្រះអនុរុទ្ធាចារ្យ សំដែងសមុដ្ឋាននេះសំរាប់មនុស្សទូទៅ ឬ បំណងដល់មនុស្សដែលមានបុណ្យវាសនាអំពីអតីត ដូចព្រះពាកុលថេរ ។ ដូច្នោះពាក្យសំដីព្រះអនុរុទ្ធាចារ្យ គ្មានជំទាស់នឹង ព្រះសាស្តាទេ តែយ៉ាងណាក្តី អ្នកដែលមានបុណ្យវាសនា ដូចព្រះពាកុលថេរក៏មានតែមួយនាក់ ចំណែកមនុស្សទូទៅ ត្រូវអាស្រ័យអនាម័យ

តាមបែបផែន របស់ព្រះអនុរុទ្ធាចារ្យគ្រប់ៗគ្នា ទើបវិនិច្ឆ័យ ថា ការដែលមានអនាម័យល្អនោះ កើតមកពីចិត្ត - ឧតុ- អាហារ ។ តាមការអធិប្បាយរបស់ព្រះអនុរុទ្ធាចារ្យ ដែល ជាអ្នកប្រាជ្ញមួយអង្គ នៅលង្កាទ្វីប ដែលសមរម្យ និង តាម ហេតុផលផ្សេងៗដោយពិតប្រាកដ ។

## សំដែង បវត្តិក្កមន័យតាមបាលី

សព្វានិបិ បនេតានិ រូបានិ កាមលោកេ យថារហំ អនូនានិ បវត្តិយំ ឧបលព្ភន្តិ ។ បដិសន្ធិយំ បន សំសេទជានញ្ចេវ ឱប្បាតិកានញ្ច ចក្ខុសោតឃានជិវ្ហា កាយភាវវត្ថុទសកសង្ខាតានិ សត្តទសកានិ បាតុភវន្តិ ឧក្កដ្ឋវសេន ។ ឱមកវសេន បន ចក្ខុសោតឃាន-ភាវទសកានិ កទាចិបិ ន លព្ភន្តិ ។ តស្មា

តេសំ វសេន កលាបានិ វេទិតព្វ ។

គព្ភសេយ្យកសត្តានំ បន កាយភាវវត្ថុ ទសកសង្ខាតានិ តីណិ ទសកានិ បាតុភវន្តិ តត្ថាបិ ភាវទសកំ កទាចិ ន លព្ភតិ ។ តតោ បរំ បវត្តិកាលេ កមេន ចក្ខុទសកាទីនិ ច បាតុភវន្តិ ។

ឥច្ចេវំ បដិសន្ធិមុបាទាយ កម្មសមុដ្ឋានា ទុតិយចិត្តមុបាទាយ ចិត្តសមុដ្ឋាននា ឋិតិកាលមុបាទាយ ឧតុសមុដ្ឋានា ឱជាផរណមុបាទាយ អាហារសមុដ្ឋានា ចេតិ ចតុសមុដ្ឋានា រូបកលាបសន្តតិ កាមលោកេ ទីបជាលា វិយ នទីសោតោ វិយ ច យាវតាយុកមព្វោច្ឆិន្នា បវត្តតិ ។

មរណកាលេ បន ចុតិចិត្តោបរិ សត្តរសម ចិត្តស្ស ឋិតិកាលមុបាទាយ កម្មជរូបានិ ន

**ឧប្បជ្ជន្តិ ។ បុរេតរមុប្បន្នានិ ច កម្មជរូបានិ ចុតិចិត្តសមកាលមេវ បវត្តិត្វា និរុជ្ឈន្តិ ។ តតោ បរំ ចិត្តជាហាររូបញ្ច វោច្ឆិជ្ជតិ ។ តតោ បរំ ឧតុសមុដ្ឋានរូប្បរំ បរា យាវ មតកឡេវរសង្ខាតា បវត្តន្តិ ។**

**ឥច្ចេវំ មតសត្តានំ បុនទេវ ភវន្តរេ**
**បដិសន្ធិមុបាទាយ តថារូបំ បវត្តតិ ។**

ប្រែសេចក្តីថា

រូបទាំងអស់ដែលបានបរិយាយមកហើយនេះ រមែងកើតក្នុងកាមភូមិ ក្នុងបវត្តិកាលដោយមិនមានសល់ ។ ក្នុងបដិសន្ធិកាលនោះ សំរាប់សំសេទជបុគ្គល និង ឧប្បាតិកបុគ្គល រួមទាំង ២ នេះ ទសករូបទាំង ៧ ( ៧០រូប ) គឺ ចក្ខុ សោតៈ ឃានៈ និង ជិវ្ហា កាយ ភាវៈ និង វត្ថុទសកៈ រមែងកើត ដោយឧក្រិដ្ឋន័យ ដោយឱមកន័យ ជួនកាល ចក្ខុ សោតៈ ឃានៈ និង ភាវទសកៈទាំងអស់នេះ មិនបានកើត

ព្រោះហេតុដូច្នេះ រមែងដឹងចំនួនដោយចំណែករូបដែលខ្វះ ។

ចំណែកគព្ភសេយ្យកសត្វនេះ កាយ ភាវៈ វត្ថុទសកៈ រួម ៣ ទសកៈ ( ៣០រូប ) រមែងកើត តែជួនកាល ភាវទសកៈ ខ្វះទៅក៏មាន អំពីនោះតមក ក្នុងបវត្តិកាល ចក្ខុទសកៈជាដើម រមែងកើតដោយលំដាប់ ។

ដោយន័យដែលពោលមកហើយ កម្មសមុដ្ឋានិករូប កើតអំពីខណៈបដិសន្ធិចិត្ត ។ ចិត្តសមុដ្ឋានិករូបកើត អំពីខណៈ ទុតិយចិត្ត ( ភវង្គចិត្ត ) ។ ឧតុសមុដ្ឋានិករូប កើតអំពីឋិតិ ខណៈដែលឱជារបស់អាហារ ជ្រួតជ្រាប រហូតរាង កាយ ។ រួមសមុដ្ឋានិករូបទាំង ៤ នេះរមែងប្រាកដក្នុងកាមភូមិ រហូតជីវិត ដូចអណ្តាតភ្លើង ឬ ខ្សែទឹកដោយមិនខ្វះ ក្រសែឡើយ ។

ចំណែកសេចក្តីរលត់របស់រូបនោះ កាលជិតនឹងស្លាប់ តាំងពីឋិតិខណៈរបស់ចិត្ត ១៧ ដួង មុន ចុតិ កម្មជរូបរមែង រលត់ចុះ ។ កម្មជរូបដែលកើតមកអំពីមុនៗ រមែងរលត់

ព្រមនិង ចុតិចិត្ត អំពីនោះតមក ចិត្តជរូប និង អាហារជរូប ក៏រលត់ដែរ តពីនោះទៅឧតុសមុដ្ឋានិករូប ប្រាកដនៅរហូត គ្រប់ពេលវេលា ជាអសុភចនៈ ដល់រាងឆ្អឹង ដូច្នេះឯង ។

អ្នកដែលស្លាប់ពីលោកនេះ ក្នុងជាតិខាងមុខតាំងពី បដិសន្ធិរូបមាន ដូចដែលពោលមកហើយ រមែងកើតថ្មី ទៀត ។

## **សំដែងបាលីរូបបវត្តិកមន័យ " ត "**

**រូបលោកេ បន ឃានជីវ្ហាកាយភាវ ទសកានិ ច អាហារជកលាបានិ ច ន លព្ភន្តិ តស្មា តេសំ បដិសន្ធិកាលេ ចក្ខុសោត~ វត្ថុវសេន តីណិ ទសកានិ ជីវិតនវកញ្ចាតិ ចត្តារោ កម្មសមុដ្ឋានកលាបា បវត្តិយំ ចិត្តោ សមុដ្ឋានា ច លព្ភន្តិ ។**

**អសញ្ញសត្តានំ បន ចក្ខុសោតវត្ថុ សទ្ទានិបិ ន លព្ភន្តិ តថា សព្វានិបិ**

**ចិត្តជរូបានិ តស្មា តេសំ បដិសន្ធិកាលេ ជីវិតនវកមេវ លព្ភតិ បវត្តិយញ្ច សទ្ទនវកំ ឧតុសមុដ្ឋានរូបំ អតិរិច្ចតិ ៕**

**ឥច្ចេវំ កាមរូបាសញ្ញិសង្ខាតេសុ តីសុ ឋានេសុ បដិសន្ធិបវត្តិវសេន ទុវិធា រូបបវត្តិ វេទិតព្វា ៕**

ក្នុងរូបលោកនេះ ឃាន ជីវ្ហា កាយ ភាវទសក ទាំងអស់នេះ និងអាហារកលាបៈទាំងអស់រមែងមិនមាន ដូច្នេះក្នុងបដិសន្ធិកាលរបស់រូបព្រហ្ម រូបជាកម្មសមុដ្ឋាន រមែងកើត គឺ ចក្ខុ សោតៈ វត្ថុទសក និង ជីវិតនវកលាបៈ តែក្នុងបវត្តិកាលនោះ ចិត្តសមុដ្ឋានិករូប និង ឧតុសមុដ្ឋានិក រូបក៏បាន ។

ចំណែកព្រហ្មអសញ្ញីសត្តនោះ ចក្ខុ សោត វត្ថុទសកៈ និង សទ្ទនវកៈ រមែងមិនមានឡើយ ។ ចិត្តជរូបទាំងអស់ក៏ ទំនងជាមួយគ្នា រមែងមិនកើត ព្រោះហេតុដូច្នោះ ព្រហ្ម

អសញ្ញីសត្តកាលបដិសន្ធិនោះ មានតែជីវិតនវកលាបៈប៉ុណ្ណោះ។ ក្នុងបវត្តិកាលរមែងមានសល់តែឧតុសមុដ្ឋានិករូប វៀរលែងសទ្ទរូប ដូចន័យដែលពោលមកហើយ កាមភូមិ រូបភូមិ និង ព្រហ្មអសញ្ញីសត្ត រួម ៣ ភូមិ រូបបត្តិរមែងមាន ២ គឺ បដិសន្ធិ និង បវត្តិ ។

## សំដែងគាថាសង្គហៈ

**អដ្ឋវីសតិ កាមេសុ ហោន្តិ តេវីស រូបិសុ សត្តរសេវ សញ្ញីនំ អរូបេ នត្ថិ កិញ្ចិបិ សទ្ទោ វិការោ ជរតា មរណញ្ចោបបត្តិយំ ន លព្ភន្តិ បវត្តេតុ ន កិញ្ចិបិ ន លព្ភតិ ។**

**ប្រែសេចក្តីថា**

ក្នុងកាមភូមិរូប ២៨ រមែងកើតក្នុងរូបព្រហ្ម រូប ២៣ រមែងកើតក្នុងព្រហ្ម អសញ្ញីសត្តរូប ១៧ រមែងកើតតែក្នុងអរូបភូមិនោះ មិនមានរូបអ្វីឡើយ ។

ក្នុងឧប្បាទរបស់ឧបបាតិកសន្ធិ ចំនួនរូប ៨ រូប រមែងមិនបានកើត គឺ សទ្ទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ ជរតារូប ១ និង អនិច្ចតារូប ១ រួម ៨ រូប ក្នុងបវត្តិកាល នេះ រូបណាមួយក៏មិនមាន ។

**អយមេត្ថ រូបបវត្តិក្កមោ** ដែលបានសំដែងមក ហើយជារូបបវត្តិក្កមន័យ ។

## អធិប្បាយរូប បវត្តិក្កមន័យ

**រូបបវត្តិក្កមៈ** ប្រែថា ~ លំដាប់សេចក្តីកើត របស់រូប ២៨ បានដល់លំដាប់សេចក្តីនៃបដិសន្ធិកាល និង បវត្តិកាល ។ ក្នុងទីនេះ បដិសន្ធិមាន៤ យ៉ាងគឺ គព្ភសេយ្យ-កបដិសន្ធិ បានដល់សត្វដែលបដិសន្ធិ ក្នុងគភ៌មាតា ដូចជា សត្វតិរច្ឆាន ជំពូកខ្លះជាដើម ។ សំសេទជបដិសន្ធិ បានដល់ សត្វមានបដិសន្ធិអាស្រ័យញើស ក្អែល ដូចជា មនុស្ស សត្វ តិរច្ឆានមនុស្សខ្លះ ។ អណ្ឌេទជបដិសន្ធិ ( ពាក្យថា អណ្ឌេទជ កន្លែងខ្លះ អណ្ឌជៈក៏មាន) បដិសន្ធិក្នុងពង ដូចជា

សត្វមាន់ជាដើម ។ ឱបបាតិកបដិសន្ធិ បានដល់សត្វដែល បដិសន្ធិ ដោយការប្រាកដជាខ្លួនធំ តែម្តង ដូចជា ទេវតា ព្រះព្រហ្ម ប្រេត នរក អសុរកាយ ជាដើម ។

ការកើតរូប បដិសន្ធិ ផ្សេងគ្នាដូច្នេះ ក្នុងកាមភូមិ ១១ រមែងកើតពេញចំនួន ២៨ រូប ចំពោះ បវត្តិកាល ។ ចំណែកបដិសន្ធិកាល សំរាប់សំសេទជ

បុគ្គល និង ឱបបាតិកបុគ្គល ទាំង ២ រមែងមាន ទសក រូប ៧ទសក ឬ ៧០ រូបក៏ថាបាន គឺ

១- ជីវិត ១ អវិនិព្ភោគរូប ៨ ចក្ខុបសាទ ១ រួម ១០ ហៅថា ចក្ខុទសកៈ

២- ជីវិត ១ អវិនិព្ភោគរូប ៨ សោតបសាទ ១ រួម ១០ ហៅថា សោតទសកៈ

៣- ជីវិត ១ អវិនិព្ភោគរូប ៨ ឃានបសាទ ១ រួម ១០ ហៅថា ឃានទសកៈ

៤- ជីវិត ១ អវិនិព្ភោគរូប ៨ ជិវ្ហាបសាទ ១ រួម ១០ ហៅថា ជិវ្ហាទសកៈ

៥- ជីវិត ១ អវិនិព្ភោគរូប ៨ កាយបសាទ ១ រួម ១០ ហៅថា កាយទសកៈ

៦- ជីវិត ១ អវិនិព្ភោគរូប ៨ ភាវរូប ១ រួម ១០ ហៅថា ភាវទសកៈ

៧- ជីវិត ១ អវិនិព្ភោគរូប ៨ ហទយវត្ថុ ១ រួម ១០ ហៅថា វត្ថុទសកៈ

រួម ទសក ៧ ចំនួនរូប ៧០

ក្នុងទសកទាំង ៧នេះ ពួកដែលធ្លាប់មានអកុសលចិត្ត មិនបរិបូណ៌ដោយរូប មានន័យថា អ្នកខ្លះភ្នែកខ្វាក់ អ្នកខ្លះត្រចៀកថ្លង់ អ្នកខ្លះ ច្រមុះកង្កត អ្នកខ្លះភាវរូបខូច (ខ្ទើយ) ព្រោះរូប ៧០ រូបណាខូច រូបនោះ មិនត្រូវរាប់ចូលក្នុងចំនួនរូបដែលធ្លាប់បាន ។

សំរាប់គព្ភសេយ្យបុគ្គល និង អណ្ឌជបុគ្គល ២ នេះ បានទសកៈ ៣ ទសក ឬ ៣០ រូប ក្នុងខណបដិសន្ធិ គឺ :

១- ជីវិត ១ អវិនិព្ភោគរូប ៨ កាយបសាទ ១ រួម ១០ ហៅថា កាយទសកៈ

២- ជីវិត ១ អវិនិព្ភោគរូប ៨ ភាវរូប ១ រួម ១០ ហៅថា ភាវទសកៈ

៣- ជីវិត ១ អវិនិព្ភោគរូប ៨ ហទយវត្ថុ ១ រួម ១០ ហៅថា វត្ថុទសកៈ

រួមទសក ៣ ចំនួន ៣០រូប

ក្នុង ៣០រូបនេះ មនុស្សសត្វខ្លះ ជួនកាលមានភាវរូប មិនបរិបូណ៌ ព្រោះអកុសលចិត្ត ក្នុងជាតិមុន មានន័យថា រាប់បាន ២ ទសក អំពីនោះតមក ក្នុងបវត្តិកាល ចក្ខុ-សោត-ឃាន-ជិវ្ហា រមែងប្រាកដតាមលំដាប់ ។

ក្នុងទីនេះ ចិត្តដំបូងហៅថា បដិសន្ធចិត្ត ចិត្តទី ២ ហៅថា ភវង្គចិត្ត ឬ បវត្តិចិត្តក៏បាន ភវង្គចិត្តនេះឯង ស៊ី

សេចក្តីច្រើនជាងគ្នា គឺ ក្នុងរវាងបដិសន្ធិ និង ចុតិ ហៅថា ភវង្គចិត្តទាំងអស់ ដោយអាស្រ័យតាមលំដាប់ បដិសន្ធិ ភវង្គ ចុតិ ។

ក្នុងខណៈដែល ចិត្តដួងទាំង ៣ នេះ កម្មជរូបរមែង កើតអំពី ឧប្បាទខណៈរបស់បដិសន្ធិចិត្ត ។ ចិត្តជរូបរមែង កើតអំពី បឋមភវង្គចិត្ត ។ ឧតុជរូប រមែងកើតអំពីបឋម ភវង្គចិត្ត ។ ឧតុជរូបរមែងកើតអំពីឋិតិខណៈ របស់ បដិសន្ធិ។ ចំណែកអាហារជរូប រមែងកើតមកអំពីឱជាខាង ក្រៅ ជ្រាបចូលទៅខាងក្នុង រួម កម្មជរូប ចិត្តជរូប ឧតុជរូប និង អាហារជរូប ទាំង ៤នេះ ដូចអណ្តាតភ្លើង ឬ ក្រសែទឹក ដែលហូរទៅកាន់មហាសមុទ្ទ រមែងកើតរហូតដល់ចុតិចិត្ត។

# សត្វដែលជិតនឹងស្លាប់




ភាពវិថីចិត្តសំដែងមរណាសន្ន គឺ វិថីចិត្តរបស់អ្នកដែលជិតនឹងស្លាប់ ដែលសំដែងមកនេះ បង្ហាញឱ្យឃើញច្បាស់ថា កម្មជរូបរមែងរលត់ចុះ តាំងពីខណៈទី ១ របស់ភាវ មានន័យថា កម្មជរូបថ្មីមិនកើត អំពីដួងចិត្តនេះមករហូតចុតិចិត្ត រូបដែលកើតមកអំពីមុនៗ រមែងរលត់តាមវិថីចិត្តដួងនេះដែរ ពីនោះតមកចិត្តជរូប និង អាហារជរូបរលត់តាមៗគ្នាទៅ តែឧតុជរូបនោះ នៅកើតតមករហូតដល់អសុភ ទាល់ដល់រាងឆ្អឹង ។

តាមគាថាសង្គហៈអធិប្បាយថា សត្វដែលស្លាប់អំពីជាតិនេះ តាមទំនងដែលបានសំដែងមកហើយ អាស្រ័យបដិសន្ធិថ្មី ក្នុងជាតិថ្មីរមែងបានរូបដែលពោលមកហើយកើតតទៅទៀត ។ ក្នុងលោករបស់ព្រហ្មនេះ ឃានទសកៈ ជីវ្ហាទសកៈ កាយទសកៈ ភាវទសកៈនិង អាហារជកលាបៈទាំងអស់នេះ រមែងមិនមាន ព្រោះហេតុដូច្នោះ ក្នុងបដិសន្ធិកាលនោះ កម្មសមុដ្ឋានកលាបៈទាំង ៤ រមែងបានទទួលគឺ ចក្ខុទសកៈ សោតទសកៈ វត្ថុទសកៈ និង ជីវិតនវកកលាបៈ រួមកម្មសមុដ្ឋាន ៤ កលាបៈ ក្នុងបវត្តិកាលនោះ ចិត្តជៈ និង ឧតុជ្ជ រមែងបានទទួលដែរ

ចំណែកព្រហ្មអសញ្ញីសត្តនោះ ចក្ខុទសកៈ សោតទសកៈ និង វត្ថុទសកៈ មិនមានឡើយ ។ ចិត្តជរូបទាំងអស់មិនមានដូច្នេះ បដិសន្ធិរបស់ព្រហ្មអសញ្ញីសត្ត មានតែជីវិតនវកកលាបៈ គឺ ជីវិតរូប ១ និង អវិនិព្ភោគរូប ៨ រួម ៩ រូប ប៉ុណ្ណោះក្នុងបវត្តិកាលនោះ អវិនិព្ភោគរូប ៨ ជីវិតរូប ១

លហុតា មុទុតា កម្មញ្ញតា លក្ខណរូប ៤ នេះ និង អាកាសរូប ១ រួម ១៧ រូប ។

ដូច្នេះរូបបវត្តិរបស់ភូមិទាំង ៣ គឺ កាមភូមិ រូបភូមិ អរូបភូមិ និង អសញ្ញីសត្តភូមិ រួម ២ យ៉ាងគឺ បដិសន្ធិ និង បវត្តិកាល ។

## អធិប្បាយតាមគាថាសង្គហៈ

ក្នុងកាមភូមិ គឺ អបាយទាំង ៤ មនុស្ស និង ទេវតា ៦ ជាន់រមែងបានទទួល ចំនួនរូប ២៨ រូប ដោយបរិបូណ៌ ។ ក្នុងរូបព្រហ្មរមែងបានទទួលរូបចំនួន ២៣រូប ( វៀរលែង ឃានៈ ជីវ្ហា កាយ ឥត្ថីភាវៈ បុរិសភាវ) ។ក្នុងព្រហ្មអសញ្ញី-សត្វ បានត្រឹម ១៧ រូបគឺ អវិនិព្ភោគរូប ៨ ជីវិតរូប ១ វិការរូប ៣ លក្ខណរូប ៤ និង អាកាសរូប ១ រួម ១៧ ។ ក្នុងអរូបព្រហ្មនេះ មិនមានរូបឡើយ ។

ក្នុងខណបដិសន្ធិរបស់សត្វទាំងឡាយ ប្រាសចាករូប ទាំង ៨ ជានិច្ច គឺ សទ្ទៈ ១ វិញ្ញត្តិ ២ វិការរូប ៣ ជរតា ១

អនិច្ចតា ១ រូម ៨រូប តែក្នុងបវត្តិកាលនេះនឹងថា មិនកើតក៏មិនមាន មានន័យថា រូបអ្វីរមែងកើតបាន ។

## សំដែងនិព្វានតាមបាលី

និព្វានំ បន លោកុត្តរសង្ខាតំ ចតុមគ្គញ្ញាណេន សច្ឆិកាតព្វំ មគ្គផលានមារម្មណភូតា វានសង្ខាតាយ តណ្ហាយ និក្ខន្តត្តា និព្វានន្តិ បវុច្ចតិ ។ តទេតំ សភាវតោ ឯកវិធម្បិ សឧបាទិសេសនិព្វានធាតុ អនុបាទិសេសនិព្វានធាតុ ចេតិ ទុវិធំ ហោតិ ការណបរិយាយេន ។ តថា សុញ្ញតំ អនិមិត្តំ អប្បណិហិតញ្ចេតិ តិវិធំ ហោតិ អាការភេទេន ។

បទមច្ចុតមច្ចន្តំ អសង្ខតមនុត្តរំ
និព្វានមីតិ ភាសន្តិ វានមុត្តា

មហេសយោ ។

**ឥតិ ចិត្តំ ចេតសិកំ រូបំ និព្វានមិច្ចបិ**

**បរមត្ថំ បកាសេន្តិ ចតុធា វ តថាគតា ។**

**ឥតិ អភិធម្មត្ថសង្គហេ រូបសង្គហវិភាគោ នាម ឆដ្ឋមោ បរិច្ឆេទោ ។**

**ប្រែសេចក្តីថា**

ចំណែកព្រះនិព្វាន គឺ លោកុត្តរធម៌ គួរធ្វើឱ្យជាក់ច្បាស់ដោយមគ្គញ្ញាណទាំង ៤ ។ ធម៌ដែលជាអារម្មណ៍របស់មគ្គចិត្ត ៤ ផលចិត្ត ៤ ព្រះដ៏មានព្រះភាគ ត្រាស់ហៅថា "**ព្រះនិព្វាន**" ព្រោះរួចផុតពីតណ្ហា គ្រឿងវិតរុំ ។ ព្រះនិព្វាននោះឯង ថាដោយសភាវលក្ខណមាន ១ គឺ សេចក្តីស្ងប់ ថាដោយបរិយាយនៃហេតុមាន ២ គឺ **សឧបាទិសេសនិព្វាន ១ អនុបាទិសេសនិព្វាន ១ ថាដោយអាការមាន ៣ គឺ សុញ្ញតៈ ១ អនិមិត្តៈ ១ អប្បណិហិតៈ ១ ។**

ព្រះសម្មាសម្ពុទ្ធទាំងឡាយជាម្ចាស់ ដែលព្រះអង្គរួចផុតពីតណ្ហាជាគ្រឿង រួតរុំ រមែងត្រាស់ទុកថា អនុត្តរៈធម៌ដែលជាបច្ច័យទាំងឡាយ មិនប្រជុំតាក់តែង មិនមានសេចក្ដីស្លាប់ ឬ បែកធ្លាយជារបស់ទៀងហើយជាទីទៅក្នុងលោកនៃព្រះអរិយជាម្ចាស់ទាំងឡាយនោះ ហៅថាព្រះ**និញ្វន** ។

ព្រះតថាគតទាំងឡាយ ត្រាស់សំដែងបរមត្ថ ដោយសង្ខេបមាន ៤ ប្រការ គឺ ចិត្ត ចេតសិក រូប និញ្វន ដោយន័យដែលពោលមកពីខាងដើម ។

ក្នុងគម្ពីរអភិធម្មត្ថសង្គហ បរិច្ឆេទទី ៦ ដែលមាននាមថា រូបបរិច្ឆេទ ចប់ត្រឹមតែប៉ុណ្ណោះ ។

## សួរ_ឆ្លើយក្នុងរូបបវត្តិក្កមន័យ

**សួរ** ក្នុងរូបបវត្តិក្កមន័យ លោកសំដែងបដិសន្ធិ ៤ ប្រការ គឺ ឱបបាតិកៈ សំសេទជៈ អណ្ឌជៈ និង គព្ភសេយ្យកៈ ។ ក្នុងពាក្យថា ឱបបាតិកៈ ជាដើមនេះ ប្រែថាអ្វី ? ហើយព្រោះ

ហេតុអ្វី ? ទើបឈ្មោះផ្សេងគ្នាយ៉ាងនេះ សុំពាក្យឆ្លើយព្រមដោយភស្តុតាងផង ។

**ឆ្លើយ** ការដែលលោកបែងចែក បដិសន្ធិជា ៤ យ៉ាងនោះ ព្រោះក្នុងមហា សីហនាទសូត្រ មានព្រះបាលីថា

**ចតស្សោ ឥមា សារីបុត្ត យោនិយោ កតមា ចតស្សោ អណ្ឌជា យោនិ ជលាពុជា យោនិ សំសេទជា យោនិ ឱបបាតិកា យោនិតិ ប្រែសេចក្ដីថា**

ម្នាលសារីបុត្ត បដិសន្ធិ ឬ យោនិ ( កំណើត ) មាន ៤ ប្រការ គឺ អណ្ឌជយោនិ ជលាពុជយោនិ សំសេទជយោនិ និង ឧបបាតិកយោនិ រួម ៤ យ៉ាង ។

ពាក្យអណ្ឌជៈ មានវិគ្គហៈថា **អណ្ឌេ ជាយន្តីតិ អណ្ឌជា ប្រែថា** សត្វមួយជំពូកដែលកើតក្នុងពងដូច្នេះ ហៅថា អណ្ឌជៈ ដូចជាសត្វស្លាប ទា មាន់ ជាដើម ។

ពាក្យថា គព្ភសេយ្យកៈ មានវិគ្គហៈថា **គព្ភេ**

**សេទ្ធីតិ គព្ភសេយ្យ ប្រែថា** សត្វមួយជំពូករមែង អាស្រ័យផ្ទៃ ( គភ៌ ) មាតាទើបអាចកើតបាន ដូច្នេះហៅថា គព្ភសេយ្យៈ ស័ព្ទនេះជូនកាល ហៅថា ជលាពុជ ។ ក្នុងសាសនារបស់ព្រហ្ម ហៅថា ជលាយុជៈ ព្រោះវិគ្គហៈថា ជរំ ឯតីតិ ជរាយុ ជរាយុម្ហិ ជាតា ជរាយុជា ប្រែថា ផ្ទៃពោះមាតាហៅថា ជរាយុ អ្នកដែលកើតក្នុងជរាយុ ហៅថា ជរាយុជ ដូចជាមនុស្ស សត្វតិរច្ឆាន ពួកខ្លះ សុនខ គោ សេះ ជាដើម ។ ប៉ុន្តែ គព្ភសេយ្យកៈសត្វប្រសូតមកតែមួយដង ( មួយគ្រា ) អណ្ឌជសត្វ រមែងប្រសូត ២ ដង ដូច្នេះក្នុងព្រះបាលី ហៅថា ឯកជសត្វ ទ្វិជសត្វ ឯកសត្វ ប្រែថា ប្រសូត្រ ១ដង អណ្ឌជ ប្រែថា ប្រសូត ២ ដង ។

ពាក្យថា សំសេទជ តាមវិគ្គហៈថា សំសីទន្តិ ឯត្ថាតិ សំសីទោ . សំសេទេ ជាយន្តីតិ សំសេទជា ប្រែសេចក្តីថា ដែលមានទឹក មានជ័រ ហៅថា សំសីទ ។ សត្វដែលកើតអាស្រ័យសំសីទៈ ហៅថាសំសេទជៈ បានដល់អ្នកដែលកើត

ពីផ្កាឈូក ដើមឈើ ឬ សត្វដែលកើតពីញើសក្អែលជាដើម ។

ពាក្យថា ឧបបាតិកៈ តាមវិគ្គហថា តតោ តតោ ឧបបាតិត្វា វិយ ជាយន្តីតិ ឧបបាតិកា ប្រែថា សត្វមួយជំពូករមែងប្រាកដជារូបដូចដែលនឹងហើរមកពីភពចាស់ ដូច្នេះហៅថា ឧបបាតិក បានដល់ពូកសត្វ នរក អសុរកាយ និង ទេវតាជាដើម ។ ការដែលតាំងឈ្មោះបដិសន្ធិផ្សេងគ្នានោះព្រោះអាការបដិសន្ធិ និង ចំនួន រូបដែលមានផ្សេង១គ្នា ដូច្នេះ ។

**ស្នួរ** ក្នុងបដិសន្ធិទាំង ៤ ដែលបរិយាយមកហើយ គព្ភសេយ្យសត្វ និង អណ្ឌជសត្វ ទាំង ២ ជំពូកនេះកាលបដិសន្ធិរមែងបានទទួលរូបបានប៉ុន្មាន ? ហើយក្នុងបវត្តិបានប៉ុន្មាន ?

**ឆ្លើយ** អណ្ឌជសត្វ និង គព្ភសេយ្យសត្វ ទាំង ២ ជំពូកនេះពេលបដិសន្ធិកាល រមែងបានទទួលទសកៈទាំង ៣ គឺ

កាយទសកៈ ភាវទសកៈ និង វត្ថុទសកៈ រួម ៣ ទសក ឬ ៣០ រូប គឺ អវិនិព្ភោគរូប ៨ ជីវិតរូប ១ និង កាយបសាទ ១ រួម ១០ អវិនិព្ភោគរូប ៨ ជីវិតរូប ១ និង ភាវរូប ១ ( ប្រុស ឬ ស្រី ) រួម ១០ អវិនិព្ភោគ ៨ ជីវិតរូប ១ និង វត្ថុរូប ១ រួម ១០ រួមទាំងអស់ ៣០រូបដោយបរិបូណ៌ ។

ក្នុងបវត្តិកាលនេះបានរូប ២៨ ពេញបរិបូណ៌ គព្ភសេយ្យកៈនេះឯង ជូនកាលព្រះបាលីហៅថា ជលាពុជៈ ក្នុងសាសនាព្រហ្ម ហៅថា ជរាយុជ តែមានន័យដូចគ្នា ផ្សេងតែ ជលាពុជៈ ឬ គព្ភសេយ្យកៈ ជា ឯកជបដិសន្ធិ អណ្ឌជៈ ជាទ្វិជបដិសន្ធិ ព្រះបាលីក្នុងសុត្តនិបាតថា :

**ឯកជំវា ទិជំវា វាបិ យោធ បាណំ វិហឹសតិ ។ល។**

**ប្រែថា** អ្នកណាបៀតបៀន ឯកជសត្វ ឬ ទ្វិជសត្វ ដូចនេះ ឯកជសត្វ បានដល់សត្វប្រសូតតែ ១ ដង ចំណែកទ្វិសត្វ បានដល់សត្វ ប្រសូត ២ ដង មានន័យថា គ្រាដំបូងសំរាល

ចេញមកជាពងសិន ហើយអាស្រ័យការភ្ញាស់ពង រហូតកើត ១ដងទៀត ។ ឯក ឬ ទ្វីជ បរិបូណ៌ ដោយរូប ៣០រូប ដែលពោលមកហើយ ។

**សួរ** ឧបបាតិកបដិសន្ធិ និង សំសេទជបដិសន្ធិបានរូបប៉ុន្មាន ? និងក្នុងបវត្តិកាល បរិបូណ៌ដោយរូបប៉ុន្មាន ?

**ឆ្លើយ** ឧបបាតិកៈ ឬ សំសេទជៈ បុគ្គលទាំង ២ ក្នុងបដិសន្ធិកាលនោះ រមែងបានទទួលទសកៈ ទាំង ៧ ទសកៈ ឬ ៧០ រូប គឺ ចក្ខុទសកៈ សោតទសកៈ ឃានទសកៈ ជិវ្ហាទសកៈ កាយទសកៈ ភាវទសកៈ វត្ថុទសក រួម ៧ ទសកៈ ឬ ៧០រូប ដោយឧក្រិដ្ឋន័យ

ចំណែកឱមកន័យនោះ ចក្ខុ សោត ឃានៈ និង ភាវទសកៈ រមែងមិនកើតក៏មាន តែក្នុងបវត្តិកាលនោះ មានរូបពេញបរិបូណ៌ដូចគ្នា ដូចជាទេវតាជាដើម ។ ចំណែកមនុស្ស សំសេទជបដិសន្ធិ ដូជានាង អម្ពបាលិកា នាងចិញ្ចាមាណវិកា នាងបុទុមទេវី ជាដើម ។ ពូកនាងទាំងនេះ

កើតពីក្នុងផ្កាឈូក កើតពីដើមស្វាយ កើតពីដើមអំពិល ។

**សួរ** តាមអភិធម្មត្ថសង្គហៈថា ឧបបាតិកបដិសន្ធិ រមែងមិនបានទទួលចក្ខុ - សោតៈ - ឃានៈ ទាំងអស់នេះមានន័យថាយ៉ាងណា ? ពួកទេវតាខ្លះ មិនមានត្រចៀក - ភ្នែក និង ច្រមុះឬ ?

**ឆ្លើយ** ឧបបាតិកបុគ្គលខ្លះ ដូចជាប្រេត អសុរកាយ និងទេវតា ពួកចាតុម្មហារាជិកា នោះ ជាអ្នកភ្នែកខ្វាក់ ត្រចៀកថ្លង់ ច្រមុះកង្ហូត ត្រូវមានប្រាកដ ព្រោះសត្វអបាយទាំង ៤ ជាទុគ្គតិហេតុកបដិសន្ធិបុគ្គល ចំណែកចាតុម្មហា-រាជិកាទេវតា ជាសុគតិហេតុកបដិសន្ធិ ( មេត្តាមើលភាវរូបបុគ្គលចែកបុគ្គល ១២ជំពូក ) ។

អាចារ្យពួកខ្លះថា ឧបបាតិកបុគ្គលដែលមានភ្នែកខ្វាក់ ត្រចៀកថ្លង់ មាននៅ ។ ចំណែកឧបបាតិកបុគ្គលដែលមិនមានច្រមុះ ភ្នែក ត្រចៀក មិនមានភស្តុតាងថា អឃានកោ ឧបបាតិកោនត្ថិ ប្រែតាមអដ្ឋកថា ថា

ឧបបាតិកបុគ្គលដែលមាន ច្រមុះ ឬ ក៏គ្មានដូច្នេះ តែយ៉ាង ណាក៏ដោយក្នុងបាលី យមកៈ រ៉ាប់រងថា ឧបបាតិកបុគ្គល ដែលខ្វះ ឃានបសាទ ក៏ត្រូវមានដូចព្រះបាលីថា **អឃានកានំ ឥត្ថីនំ ឧបបជ្ជន្តីនំ តាសំ ឥត្ថិន្ទ្រិយំ ឧប្បជ្ជតិ នោ ច តាសំ ឃានិន្ទ្រិយំ ឧប្បជ្ជតិ** ដូច្នេះ ហើយថា **អឃានកានំ បុរិសានំ ឧបបជ្ជន្តានំ តេសំ បុរិសិន្ទ្រិយំ ឧប្បជ្ជតិ នោ ច តេសំ ឃានិន្ទ្រិយំ ឧប្បជ្ជតិ** ដូច្នេះ ប្រែថា រួមគ្នាទាំង ២ ព្រះបាលីថា ឧបបាតិក ស្រី និង ប្រុសដែលប្រាសចាក ឃានៈនេះ ឥត្ថិន្ទ្រីយ៍ និង បុរិសិន្ទ្រីយ៍កើត ឃានិន្ទ្រីយ៍មិន កើតឡើយ ព្រោះហេតុដូច្នេះ ឧបបាតិកបដិសន្ធិ ដែលមិន មានចក្ខុ ឬ បន្ថែមចក្ខុបសាទ សោតបសាទ ឃានបសាទ ក៏ត្រូវមានជា ប្រាកដ ព្រោះទាក់ទងនិង សុគតិហេតុក-បដិសន្ធិ ដែល អធិប្បាយមកហើយ ។

**សួរ** ក្នុងអភិធម្មត្ថសង្គហៈថា **តតោ បរំ បវត្តិកាលេ កមេន ចក្ខុទសកាទីនិ បាតុភវន្តិ ប្រែថា** ខាងក្រោយដែលបដិសន្ធិ គឺ បវត្តិកាលនោះ ចក្ខុសោតជាដើមរមែងកើតតាមលំដាប់ ។ ក្នុងទីនេះ ចក្ខុសោត ឃានៈ ជីវ្ហា កាយ ទាំងអស់នេះកើតតាមលំដាប់ ឬនិងកើតណាមុន ។ ពាក្យថា កមេនៈ ដោយលំដាប់ ឬជូនកាលថា កម្មេនៈ ប្រែថា ព្រោះកម្ម ។២ ស័ព្ទនេះ ស័ព្ទណាត្រង់នឹង ព្រះអធ្យាស្រ័យនៃព្រះសាស្តា ?

**ឆ្លើយ** ការសំដែងលំដាប់នៃបដិសន្ធិ ក្នុងសាសនារបស់យើង និង សាសនាដទៃ១មានច្រើន គឺ សាសនារបស់ពួកអារ៉ាប់ ចិន បារាំង ជាដើម ។ សំដែងទៅម្នាក់ម្យ៉ាង ម្នាក់១ គម្ពីរ តែនឹងសំដែងតទៅនេះ នឹងសំដែងតាមការទេសនារបស់ព្រះសាស្តា ដែលប្រាកដនៅក្នុងគម្ពីរ សំយុត្តនិកាយថា សម័យមួយព្រះសាស្តានៃយើងគង់នៅភ្នំ ឥន្ទកូដ ក្នុងមគធរដ្ឋ ។ សម័យនេះមានយក្ខ មួយនាក់ឈ្មោះ **ឥន្ទកៈ**

មកទូលសួរព្រះសាស្តាថា :

**រូបំ ន ជីវន្តិ វទន្តិ ពុទ្ធា កថំ នុយំ វិន្ទតិ សរីរំ កុតស្ស អដ្ឋិយមកបិណ្ឌមេតិ កថំ នុយំ សជ្ជតិ គព្ភស្មឹ ៗ**

**ប្រែសេចក្តីថា**

ព្រះពុទ្ធទាំងឡាយពោលថារូបមិនមែនជីវិត កាលបើដូច្នេះ សត្វដែលបដិសន្ធិក្នុងផ្ទៃមាតា បានរាងកាយមកពីណា គំនរឆ្អឹងបានមកពីណា និង ចូលបដិសន្ធិក្នុងផ្ទៃមាតាបានយ៉ាងណា ដូច្នេះតាមពាក្យបុច្ឆារបស់យក្ខបានសេចក្តីថាសង្ស័យរូប និង ជីវិត ថា ជីវិតជារូបនោះឯង ។ តាមដែលព្រះពុទ្ធជាម្ចាស់ទាំងឡាយពោលថា រូបមិនមែនជីវិត កាលបើដូច្នេះ អ្វីជាជីវិត សត្វបានរាងកាយមកពីណា ឆ្អឹងបានមកអំពីណា ហើយការប្រព្រឹត្តិក្នុងផ្ទៃមាតា កកើតមកបានយ៉ាងណា ។

កាលអ្នកសង្ស័យថា រូប និង ជីវិត ជាមួយគ្នា និង

ទាក់ទងមកអំពីបដិសន្ធិយ៉ាងណា ព្រះសាស្តាជាកំពូលអ្នកប្រាជ្ញក្នុងត្រៃលោក ទើបទ្រង់វិនិច្ឆ័យថា

**បឋមំ កលលំ ហោតិ កលលា ហោតិ អព្ពុទំ អព្ពុទា ជាយតេ បេសិ បេសិ និព្វត្តតោ ឃនោ បញ្ចសាខា ជាយន្តិ កេសា លោមា នខាបិច**

**ប្រែសេចក្តីថា**

សត្វដែលបដិសន្ធិក្នុងផ្ទៃមាតា កើតតាមលំដាប់សត្តាហៈ ( គឺ សប្តាហ៍ ៧ ថ្ងៃ ) គឺ **កលលសត្តាហ អព្ពុទសត្តាហ បេសិសត្តាហ ឃនសត្តាហ** និង **បញ្ចសាខសត្តាហ** តាមការសំដែងនេះ សត្តាហៈ ៥ រមែងកើតតាមលំដាប់ តែចក្ខុ សោតៈ ឃានៈជាដើមនៅមិនប្រាកដព្រោះ តាំងពីខណៈដែលបដិសន្ធិ ដល់បញ្ចមសត្តាហៈ ( សប្តាហ៍ទី ៥ ) បាន ៣៥ថ្ងៃ ភ្នែក ត្រចៀក ច្រមុះ នៅមិនទាន់មានឡើយ ។ កាលដែលភ្នែក ត្រចៀក

ច្រមុះកើត នោះព្រះអដ្ឋកថាចារ្យ អធិប្បាយថា តាំងពី ១១ សត្តាហៈ ឬ ៧៧ថ្ងៃ ពីនោះមកភ្នែក ត្រចៀក ច្រមុះ ទើបកើតតាមលំដាប់ តាមព្រះបាលី របស់ព្រះអនុរុទ្ធាចារ្យ ថា " កមេន ដោយលំដាប់ " នោះត្រង់នេះមានន័យថានៅ មានអាចារ្យខ្លះ ដែលមិនឃើញដោយស័ព្ទ " កមេន " អធិប្បាយថា កាលដល់ ១១ សប្តាហ៍ ឬ ៧៧ថ្ងៃ គ្រប់សព្វហើយ សត្វដែលបដិសន្ធិក្នុងផ្ទៃមាតាបាន អាយុ ២ ខែ និង ១៧ ថ្ងៃហើយ ចក្ខុ សោតៈ ឬ ឃានៈ រមែងកើត ណាមុនក៏បាន មិនចាំបាច់កើតតាមលំដាប់ព្រោះបាលីក្នុង សំយុត្តនិកាយថា

**បញ្ចិមេ ខោ ភិក្ខវេ សត្តាហេ បញ្ច បិឡកា ជាយន្តិ សណ្ឋហន្តិ កម្មតោ ។**

**ប្រែសេចក្តីថា**

ក្នុងសត្តាហទី ៥ នោះ ជាទីកើតស្លាម ឬ ទីកន្លែង របស់ចក្ខុ សោតៈ ឃាន ជីវ្ហា ប្រាកដឡើងតាមកម្ម ។ ព្រោះ

ហេតុដូច្នេះក្នុងព្រះអភិធម្មត្ថសង្គហៈថា " កមេន " នេះជូន កាលអាចជា "កម្មេន " ក៏បាន ។ ដោយអក្ខរាវិរុទ្ធ គឺ ខ្វះអក្សរ "ម" ឬផ្លាស់អក្សរទៅមួយតួក៏បាន ។

ការដែលអាចារ្យបុរាណ ប្រកែកជជែកតាមកនោះ ក៏ព្រោះក្នុងអភិធម្មត្ថសង្គហៈថា **បវត្តិកាលេ កមេន** ប្រែថា ក្នុងបវត្តិកាលតាមលំដាប់ ។ ពាក្យថា បវត្តិកាល ក្នុងដីកានៃអភិធម្មត្ថ វិភាវិនីកែថា **បវត្តិកាលេតិ សត្តមេ សត្តាហេ ប្រែថា** បវត្តិកាលនេះបានដល់ សត្តាហៈទី ៧ មានន័យថា លោកដីកាចារ្យអង្គនេះ ចូលចិត្ត សត្តាហៈទី ៧ ជាបវត្តិកាល និង ពាក្យថា កមេនៈសំដៅថា ចក្ខុ សោតៈ ឃានៈ ជីវ្ហា ទាំងអស់នេះរមែងប្រាកដតាំងពី ៧ សត្តាហៈមក ព្រោះហេតុដូច្នេះ តាមមតិលោកដីកាចារ្យ អង្គនេះ បង្ហាញឱ្យឃើញថា បវត្តិកាលនោះរាប់យកពី ៧ សប្តាហ៍ទៅ ។ ពាក្យថា កមេន នោះ ចក្ខុ សោតៈ ឃានៈ ជីវ្ហា រមែងកើតពី ៧ សប្តាហ៍ ដោយលំដាប់ដូច្នេះ ។

កាលលោកបុរាណាចារ្យ បានប្រកែកជជែករឿងបដិសន្ធិយ៉ាងនេះ ដោយមិនបានវិនិច្ឆ័យថា វាទៈរបស់អ្នកណាជាប្រាកដ ។ កាលបើដូច្នេះ ជាតួនាទីរបស់យើង ចាំបាច់ត្រូវស្រាវជ្រាវគម្ពីរផ្សេងៗ ដែលគួរស្តាប់ ជឿបាន ហើយត្រូវបង្ហាញដាច់ខាត ត្រង់ណាជាពុទ្ធបំណង ឬ វាទៈរបស់អ្នកណា ល្មមជាទីពឹងបានរបស់ពួកយើង អ្នកជាបច្ឆិមសាវ័កដែលមានសតិ ប្រាជ្ញាតិច ព្រោះហេតុដូច្នេះ ល្មមដែលនឹងពោលតទៅនេះ ជាពាក្យវិនិច្ឆ័យរបស់ព្រះអាចារ្យនៃយើង ព្រមជាមួយនឹងអត្តនោមត្យាធិប្បាយតាមសេចក្តី ចេះដឹងរបស់ខ្ញុំម្ចាស់ផង ។

ពាក្យវិនិច្ឆ័យស័ព្ទ កមេនៈ និង កម្មេនៈ តាមវាទៈរបស់ព្រះអនុរុទ្ធាចារ្យ នោះ ចក្ខុ សោតៈ ឃានៈ ជិវ្ហា រមែងប្រាកដតាមលំដាប់គឺ ១- ភ្នែកកើតមុន ២- ត្រចៀកកើត ៣- ច្រមុះកើត ៤- អណ្តាតកើតតាមលំដាប់ ។ ពីរពាក្យនេះ ខ្ញុំម្ចាស់បានស្រាវជ្រាវ មើលក្នុងនាមរូប បរិច្ឆេទ

អដ្ឋកថាដែលជាគម្ពីរ របស់ព្រះអនុរុទ្ធាចារ្យ មានព្រះបាលីថា **តតោ បរំ បវត្តិម្ហិ ទស្សមានស្ស ជន្តុនោ ចក្ខុទសកាទយោ ច ចត្តារោ ហោន្តិ សម្ភវា ប្រែថា** ខាងក្រោយដែលសត្វបដិសន្ធិ ក្នុងបវត្តិកាលនោះ សត្វដែលចំរើនវ័យនោះមក ទសកៈទី ៤ មានចក្ខុទសកៈ កើតជាដើម ប្រាកដតាមលំដាប់ដូច្នេះឯង។ ប្រការមួយវិញទៀត ពាក្យថាកម្មេនៈ ខ្ញុំម្ចាស់មិនឃើញថា ព្រះអនុរុទ្ធាចារ្យ ថែមទៀត ព្រោះក្នុងរូបសមុដ្ឋាន លោកបានអធិប្បាយមកហើយថា :

ហទយឥន្ទ្រិយរូបានិ កម្មជានេវ ប្រែថាហទយរូប និង ឥន្ទ្រិយរូប ៨ រួម ៩ រូបនេះ កើតមកព្រោះកម្ម ដូច្នេះ អ្នកណាក៏ដឹងថា ចក្ខុ សោតៈ ទាំងអស់នេះជាដើម បានមកព្រោះកម្ម ព្រោះហេតុដូច្នេះ ពាក្យថាកមេនៈនោះសំដូចរឿងបដិសន្ធិគព្ភសេយ្យកសត្វហើយ ។

ការដែលពោលដល់ ចក្ខុ សោតៈ ជាដើមកើតនោះ

សូម្បីក្នុងដីការបស់អភិធម្មត្ថវិភាវិនី សំដែងថា សប្តាហ៍ទី ៧ ចក្ខុ សោតៈ ឃានៈ ជីវ្ហា កើតតាមលំដាប់ ដូចនេះ ខ្ញុំម្ចាស់ក៏នៅ មិនយល់ព្រម សេចក្តីឃើញផងទេ ព្រោះសប្តាហ៍ទី ៧ អាយុនៅមិនទាន់បាន ២ ខែ បដិសន្ធិនៅទន់ ( ខ្ចី ) ច្រើនមានតែពក ( ចំណុច ) សំរាប់នឹងកើតជាជើង ២ ដៃ ២ និង ក្បាល ១ រួម ៥ ប៉ុណ្ណោះ ។ មានន័យថានៅជាដុំសាច់ក្រហម១ គ្មានភ្នែក ត្រចៀក ច្រមុះ អណ្តាតទេ ។ ដូច្នេះក្នុងកថាវត្ថុលោក អដ្ឋកថាចារ្យ បានអះអាងថា

**គព្ភសេយ្យកសត្តានំ អជ្ឈត្តិកាយតនេសុ មនាយតនកាយាយតនានេវ បដិសន្ធិក្ខណេ ឧប្បជ្ជន្តិ សេសានិ ចត្តារិ សត្ត សត្តតិ រត្តិម្ហិ ជាយន្តិ**

**ប្រែថា** សត្វដែលបដិសន្ធិក្នុងផ្ទៃមាតា ក្នុងអាយតនៈខាងក្នុង មនាយតនៈនិង កាយាយតនៈ ទាំង ២ នេះឯងកើតក្នុងខណបដិសន្ធិ នៅសល់ ចក្ខុ សោតៈ ឃានៈ ជីវ្ហា ទាំង ៤នេះ

រមែងកើតក្នុងយប់ ដែលបាន ៧៧ ថ្ងៃប៉ុណ្ណោះ ។ បាន សេចក្ដីថា ១១ សប្ដាហ៍ ឬ ៧៧ ថ្ងៃ ។ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត ទើបកើតតាមលំដាប់ ។

ព្រោះហេតុដូច្នេះ តាមអភិធម្មត្ថសង្គហៈថា បវត្តិកាលេ និង កមេនៈ ស័ព្ទនេះ សូមវិនិច្ឆ័យថា បវត្តិកាលដែល ចក្ខុ សោតៈ ដែលកើត ត្រូវរាប់ពី សប្ដាហ៍ និង ស័ព្ទថា កម្មេនៈ ឃើញសមគួរថា កមេនៈដោយមាន ភស្តុតាង ដែលបានអធិប្បាយមកហើយ ។

**សួរ** តាមព្រះពុទ្ធវចនដែលត្រាស់ថា : បឋមំ កលលំ ហោតិ ជាដើម ប្រែថា ទឹកកលលំ ដំបូងនៃសប្ដាហ៍នោះ ។ ពាក្យថាកលល អព្វុទ បេសិ ឃន បសាទ ទាំងអស់នេះ មានន័យថាដូចម្ដេចខ្លះ ?

**ឆ្លើយ** ពាក្យថា កលលៈ បានដល់ទឹកថ្លាស្អាតដែលបដិសន្ធិ ក្នុងផ្ទៃមាតា ។ សេចក្ដីថា ទឹកថ្លាស្អាតនេះ មិនអាចនឹង ឃើញបានដោយភ្នែកមនុស្ស ស្មានដូចដំណក់ប្រេងល្ង ដែល

លោកអដ្ឋកថាចារ្យថា

**តិលតេលស្ស យថា ពិន្ទុ សប្បិមណ្ឌោ អនាវិលោ ឯវំ វណ្ណប្បដិភាគំ កលលំ សម្បវុច្ចតិ**

**ប្រែថា** ដូចដំណក់ប្រេងល្ង ឬ មានន័យម្យ៉ាងទៀត មានវណ្ណៈ ឬ ពណ៌យ៉ាងនេះ ហៅថា កលលៈ ។ ទឹកកលលៈនេះមានវេលាតាំងនៅបានត្រឹម ៧ ថ្ងៃប៉ុណ្ណោះ ។ កាលគ្រប់ ៧ ថ្ងៃហើយក៏ប្រែសភាពជាអព្វុទៈ ប្រែថា ទឹកវាវច្នូលទៅបន្តិចរហូត ៧ ថ្ងៃ ។ កាលគ្រប់ ១៤ ថ្ងៃហើយ អព្វុទនេះប្រែសភាពជាបេសិមានពណ៌ ដូចសំណ រហូត៧ថ្ងៃ កាលគ្រប់២១ថ្ងៃហើយបេសិ ប្រែសភាពជាឃនៈ ជាដុំដូចក្រដាសពង រហូត ៧ ថ្ងៃ ។ ក្នុងអដ្ឋកថាអះអាងថា

**យថា កុក្កុដិយោ អណ្ឌំ សមន្តំ បរិមណ្ឌលំ ឯវំ ឃនស្ស សណ្ឋានំ និព្វត្តំ កម្មបច្ចយា**

**ប្រែថា** ដូចនឹងពងមាន់រាងមូលដោយប្រការទាំងពួង រូបរបស់យនបដិសន្ធិក៏ដូច្នេះ ព្រោះកម្ម ដូច្នេះនេះ ។ កាលគ្រប់ ២៨ ថ្ងៃប្រែសភាពជាពកសំរាប់សាខាទាំង ៥ គឺ ជើង ២ ដៃ ២ និង ក្បាល ១ រូម ៥ រហូត ៧ ថ្ងៃ ។ រូម៥សប្តាហ៍ជា (៣៥ ថ្ងៃ) ។ ព្រះបាលីក្នុងសំយុត្តនិកាយថា **បញ្ចមេ ខោ តិក្ខវេ សត្តាហេ បញ្ច បីឡកា ជាយន្តិ សណ្ឋហនតិ កម្មតោ ប្រែថា** ~ ក្នុងសប្តាហ៍ទី ៥ នៅបីឡកៈគឺ ពកសំរាប់កើតជាដៃ ជើង ក្បាល រមែងប្រាកដព្រោះកម្ម អំពីនេះតទៅទល់ដល់សប្តាហ៍ទី ១១ គឺ ៧៧ ថ្ងៃ ទើបបរិបូណ៌ដោយ ចក្ខុ សោតៈ ឃានៈ ជីវ្ហា រូម ៤ ប្រការ ប្រាកដតាមលំដាប់ ។ កាលដល់ ៤៣ សប្តាហ៍ កេសា លោមា នខា ជាដើមរមែងកើតតាមៗគ្នាមកដូច្នេះឯង ។

**ស្នូរ** តាមអភិធម្មត្ថសង្គហៈ ព្រះអនុរុទ្ធាចារ្យ ពោលទុកថា :

ក្នុងរូបលោករមែងបានរូប ២៣ គឺ ក្នុងរូប ២៨ វៀរលែង ឃានៈ ជិវ្ហា កាយ ឥត្ថីភាវៈ បុរិសភាវៈ និង អាហារជរូប ក្នុងទី នេះ អាហារជរូបមិនចាំបាច់ត្រូវមាន ដូចម្តេចទើបថារូប ២៣ ។ សំរាប់អាហារជរូបទាំង ២ ទើបនឹងត្រូវលើកលែង ចេញមិនមែនឬ ?

**ឆ្លើយ** កាលដែលព្រះអនុរុទ្ធាចារ្យ មិនបានដកអាហារជ-រូប ២នេះ ព្រោះ អាហារជរូបនោះ រមែងមាន ២ ប្រភេទ គឺ អជ្ឈត្តិកាហារ និង ពហិទ្ធាហារទាំង ២ យ៉ាងនេះ សូម្បីព្រហ្មមិនមានអាហារក៏ដោយ មហាភូតរូប ៤ គឺ បឋវី អាបោ តេជោ វាយោ រមែងប្រាកដនៅជានិច្ច ។ មហាភូត-រូបទាំង ៤នេះឯង រាប់ចូលក្នុងអាហារជរូបផង ។ មានន័យថា កាលដែលមិនបានលើកលែង អាហារជរូបនេះ អំពីរូប ២៣ ព្រោះពាក្យថា អាហារបានដល់ ឱជា ដូចដែលបាន អធិប្បាយមកហើយពីខាងដើម នៃបរិច្ឆេទនេះ។

កាលឱជាខាងក្នុងដកចេញ ឱជាខាងក្រៅក៏នៅមាន

ហើយ គន្ធារម្មណ៍ រសារម្មណ៍ និង ធាតុទាំង ៤ ក៏នៅមាន ប្រាកដ ។ ព្រោះហេតុដូច្នេះ ព្រះអនុរុទ្ធាចារ្យ មិនបានដក ចេញ តែយ៉ាងណាក្តីសូម្បីព្រះអនុរុទ្ធាចារ្យមិនបានដកចេញ ក្នុងវិភង្គនៅមានបាលីថា **រូបធាតុយា ឧប្បត្តិក្ខណេ បញ្ចាយតនានិ បាតុភវន្តិ ចក្ខាយតនំ រូបាយតនំ សោតាយតនំ មនាយតនំ ធម្មាយតនំ បញ្ចធាតុយោ បាតុភវន្តិ ចក្ខុធាតុ រូបធាតុ សោតធាតុ មនោវិញ្ញាណធាតុ**

**ប្រែថា** ក្នុងខណៈដែលបដិសន្ធិរូបព្រហ្ម អាយតនៈទាំង ៥ រមែងកើត គឺ **ចក្ខាយតនៈ រូបាយតនៈ សោតាយតនៈ មនាយតនៈ ធម្មាយតនៈ** រួម ៥ អាយតនៈ ។ ធាតុទាំង ៥ រមែងកើតគឺ ចក្ខុធាតុ រូបធាតុ សោតធាតុ មនោវិញ្ញាណធាតុ ធម្មធាតុ រួម ៥ ធាតុ ។

តាមព្រះបាលីដែលលើកមកហើយនេះ សំដែងឱ្យ ឃើញថា ក្នុងរូបព្រហ្ម ឃានបសាទ មិនមាន ក្លិន ក៏មិនចាំ

បាច់មាន ជីវ្ហាបសាទមិនមាន រស ក៏មិនចាំបាច់មាន ឱជាក៏មិនចាំបាច់ផង ដូច្នេះរូបព្រហ្ម ត្រូវមាន រូប ២០ ប៉ុណ្ណោះ គឺក្នុងចំនួនរូប ២៨ ដករូប ៨ គឺ : ឃានៈ ជីវ្ហា កាយ ឥត្ថីភាវៈ បុរិសភាវៈ គន្ធរស ឱជា រួម ៨រូបនេះ តែក្នុងអភិធម្មត្ថសង្គហៈថា រូប ២៣ដូចដែលបានអធិប្បាយមកហើយ ។

**សួរ៖** ក្នុងអសញ្ញិសត្តភូមិ កាលបដិសន្ធិបានរូប ៩ រូប ។ ក្នុងបវត្តិកាល បាន ១៧រូប ។ កាលបដិសន្ធិបាន ៩ រូប ហើយក្លាយជា ១៧រូបបានយ៉ាងណោ ?

**ឆ្លើយ** ព្រហ្មអសញ្ញីសត្វ ជារូបបដិសន្ធិនោះ កាលបដិសន្ធិបានចំពោះ ៩ រូប គឺ បឋវី អាបោ តេជោ វាយោ វណ្ណៈ គន្ធៈ រសៈ ឱជា និង ជីវិត រួម ៩ រូប ។ ក្នុងបវត្តិកាលបាន ១៧រូប គឺ អវិនិព្ភោគរូប ៨ ជីវិតរូប ១ វិការរូប ៣ លក្ខណរូប៤ និង អាកាសរូប ១ រួម ១៧រូប ។ ព្រោះកាលបដិសន្ធិត្រូវមាន ឧបចយ សេចក្តីកើត សន្តតិ សេចក្តីចំរើន ជរតាសេចក្តីទ្រុឌទ្រោម អនិច្ចតា សេចក្តីរលត់ និង អាកាសរូប

ក៏ចាំបាច់ត្រូវមានចំណែកវិការរូប ៣ បើរូបដទៃៗមាន ក៏ចាំបាច់មានដូចគ្នា សេចក្តីថា ៨ រូបដែលពោលមកហើយ ជារូបសាធារណៈទូទៅ បើរូបដទៃៗមានមកហើយ រូបនេះ ចាំបាច់ត្រូវមានផង ។ ព្រោះហេតុដូច្នោះ អាស្រ័យរូប ៩ រូប របស់បដិសន្ធិ រូប ៨ ទៀតដែលជាសាធារណៈដល់រូប ៩ រូបត្រូវមានជាធម្មតា ទើបរួមបាន ១៧រូប ដូចដែល អធិប្បាយមកហើយ ។

**សួរ** ពាក្យថានិព្វាន ប្រែត្រង់ៗបានដល់អ្វី និង និព្វានស័ព្ទ នោះគឺអ្វី ? រកភស្តុតាងអធិប្បាយផង ។

**ឆ្លើយ** ពាក្យថានិព្វាន ញែកបាន ២ ស័ព្ទគឺ និ + វានៈ ។ ស័ព្ទថា និ ប្រែថា ចេញស័ព្ទដើមជា និក្ខន្តៈ ប្រែថា រួចផុត ហើយ វានៈ ប្រែថា បានដល់តណ្ហា បានសេចក្តីថា តាមស័ព្ទ ថា **វានតោ និក្ខន្តត្តា និព្វានំ** ប្រែថា រួចផុតអំពី តណ្ហាទើប ហៅថា និព្វាន ។ វានៈក្នុងទីនេះ បានដល់តណ្ហា ដោយត្រង់ ន័យ ១ ទៀត និព្វានស័ព្ទនេះជាកិរិយាស័ព្ទ ប្រែ

ថារលត់ ។ ពាក្យថារលត់នេះ ប្រហែលគ្នានឹងរលត់ភ្លើង ភ្លើងក្នុងទីនេះបានដល់ រាគៈ ទោសៈ មោហៈ រួមជាភ្លើងរបស់ នាមធម៌ ៣ កង ។

ពាក្យប្រែនិព្វានស័ព្ទពីរន័យនេះ ន័យដំបូង ជាមតិរបស់ព្រះអនុរុទ្ធាចារ្យ ដូចបាលីរបស់លោកថា

**វានសង្ខាតាយ តណ្ហាយ និក្ខន្តត្តា និព្វានន្តិ បវុច្ចតិ** ប្រែថា ព្រោះបានចេញចាកតណ្ហា ដូច្នេះហៅថា " និព្វាន "។ មានន័យថា ផុតពីតណ្ហាហើយ ។ ន័យទី ២ ជាមតិរបស់លោកអដ្ឋកថាចារ្យ និងព្រះដីកាចារ្យ ដូចបាលីថា :

**និព្វាតិ វា ឯតេន រាគគ្គិអាទយោតិ និព្វានំ**

ប្រែថា ភ្លើងមានរាគៈជាដើម រមែងរលត់ដូច្នេះហៅថា និព្វាន មានន័យថា ជាគ្រឿងរំលត់ភ្លើង គឺ រាគៈ ទោសៈ មោហៈ ទាំង ៣ គំនរ យ៉ាងណាក្តីពាក្យប្រែ និង សេចក្តី

បំណង ២ ន័យដែលពោលមកហើយនេះ រកឲ្យក្តោបក្តាប់ រហូតដល់លោកុត្តរៈទាំង ៨ ឬ ទាំង ៩ ។ គោលបំណង របស់អ្នកយកចិត្តទុកដាក់នេះ គឺ និព្វានតែមួយដែលជា អសង្ខតធាតុ ដូច្នេះ ត្រូវអធិប្បាយថា និព្វានជាកិរិយា ប្រែថា រលត់ រលត់អ្វី ? ឆ្លើយថារលត់ទាំងអស់ ។ ដូចក្នុង ខុទ្ទកនិកាយ រតនសូត្រថា

**និព្វន្តិ ធីរា យថាយម្បទីបោ** ។ល។

**ប្រែថា** ព្រះអរហន្តទាំងឡាយ ដែលធីរៈបុគ្គលរមែងរលត់ (ចាកទុក្ខ) ដូចដួងប្រទីបរលត់ដូច្នោះដែរ ។

**សួរ** តាមមតិរបស់ព្រះអនុរុទ្ធាចារ្យ ប្រែនិព្វានថា ព្រោះ រួចផុតអំពីតណ្ហា ទើបហៅថា និព្វាន ។ កាលបើដូច្នោះ លោកុត្តរចិត្ត ក៏រួចផុតពីតណ្ហាបានដូចគ្នា និង ហៅថានិព្វាន បានឬទេ ?

**ឆ្លើយ** ការដែលព្រះអនុរុទ្ធាចារ្យពោលថា ព្រះនិព្វានជាធម៌ ដែលរួចផុតពីតណ្ហានោះ ក៏អាស្រ័យព្រះបាលីកន្លែងខ្លះ ក្នុង

ការអធិប្បាយ អរិយសច្ចៈ ៤ ប្រការថា ការដែលរួចផុតអំពីសមុទេយ្យ ជានិរោធសច្ច គឺ និព្វាននោះឯង ។ ព្រោះហេតុដូច្នោះលោកបំណងយកហេតុរបស់ទុក្ខ កាលរលត់ហេតុបាន ផលនោះមិនចាំបាច់ត្រូវអធិប្បាយរមែងមិនមានជាប្រាកដ ដូច្នេះលោកប្រកាន់ ហេតុជាតួរលត់ ហើយថាផុតអំពីតណ្ហាហៅថា និព្វាន ។

ការដែលលោកុត្តរ គឺ ព្រះអរហត្តផល ហៅថានិព្វាន ព្រោះអរហត្តមគ្គ-ផល បានផុតពីតណ្ហាហើយ ។ សូម្បីផុតពីតណ្ហាហើយក៏ពិតមែន តែអរហត្តផលនៅមិនទាន់ដល់អនុបាទិសេសនិព្វានធាតុ នៅទីដែលជាទុក្ខវេទនា បៀតបៀនបានជានិច្ច ។ ព្រោះហេតុដូច្នោះ ទើបគ្មានជាព្រះនិព្វាន ពិតតែ ជាព្រះនិព្វានដោយបរិយាយតែប៉ុណ្ណោះឯង។ ចំណែកពាក្យថា ព្រះនិព្វានពិតៗនោះ គឺការរំលត់ខន្ធទាំង៥នោះ គឺ អនុបាទិសេសនិព្វានធាតុនោះឯង ហៅថា ផុតអំពីទុក្ខទាំងពួងពិតមែន ។ ព្រះនិព្វាននេះសមដូចកិរិយា

ស័ព្ទថា និព្វុត្តិ ដែលប្រែថារលត់ មានន័យថា រលត់ភ្លើង ឬ រលត់ទុក្ខ អធិប្បាយថា កាលភ្លើងរលត់ហើយ អាការដែលភ្លើងឆេះហើយ សេចក្តីក្តៅក្រហាយរមែងបាត់ទៅ ព្រះនិព្វានក៏ដូចគ្នា កាលរលត់ភ្លើងទាំង ៣ បានហើយ អាការរបស់ភ្លើងទាំង ៣ ក៏ត្រូវរលត់ដែរ ហើយសេចក្តីក្តៅគឺទុក្ខទាំងពួង រមែងរលត់ជាពិតប្រាកដ ។ ព្រោះហេតុដូច្នោះ ពាក្យថានិព្វាន ប្រែថា រលត់ទុក្ខ ល្អៗជាងការប្រែដទៃៗ ព្រោះជាទីចូលចិត្តបានងាយ ហើយសមដូចដែលហៅថា អសង្ខតធាតុ ។

**រូបបរិច្ឆេទទី ៦ ចប់**